ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

# ឯកសារណែនាំសម្រាប់គ្រូបណ្តុះបណ្តាល
# កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ




Meta

សហការរៀបចំដោយនាយកដ្ឋានបរិវត្តកម្មឌីជីថលជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប)

គាំទ្រដោយក្រុមហ៊ុនមេតា

# គណៈកម្មការគ្រប់គ្រង

១. លោក **សុភ ថា**

២. លោក **អុំ ច័ន្ទតារា**

៣. កញ្ញា **សេង ស៊ីណែត**

៤. លោក **ផូ សុវណ្ណា**

៥. លោកស្រី **អ៊ិត ចណ្ណា**

៦. កញ្ញា **សឿង ចាន់ថូ**

៧. លោក **ហេង ឥន្ត្រី**

៨. Mr. **Kurt Bredenberg**

៩. លោក **អ៊ុល រួន**

១០. លោក **ស សុផាណាក់**

១១. លោក **នូ រដ្ឋា**

១២. លោក **ប៊ុត សុតារក្ស**

# គណៈកម្មការត្រួតពិនិត្យ និងរៀបចំកម្មវិធីសិក្សា

១. លោក **ស្រ៊ុន វណ្ណារ៉ា**

២. លោក **អ៊ីវ ប៉ូលី**

៣. កញ្ញា **ស៊ិន ឡៃហ៊ាង**

៤. លោក **អ៊ិច សុបញ្ញាឫទ្ធិ**

៥. លោក **គង់ សុប្ប៊ូល្លីន**

៦. លោកស្រី **គង់ សុជាតា**

៧. លោក **ថា ទុទ្ធី**

៨. លោក **ទ៉ោ ឆារ៉ា**

៩. លោក **មឿន ផល្លា**

១០. លោក **ប្រាក់ សន្តិភាព**

១១. លោកស្រី **ពោធ សុម៉ូលីណា**

១២. លោក **ឈិន សុវណ្ណនីកា**

១៣. លោក **សោ មុនីរតនៈ**

១៤. លោក **សូផាត ញូអ័រ**

១៥. លោក **ឈាប់ លីយុភ**

១៦. លោក **សម មុនីវឌ្ឍ**

១៧. លោក **សា សិលា**

១៨. លោកស្រី **គីម មិថុនា**

១៩. លោក **ឌិន លីហ្វុង**

២០. លោក **លាង បញ្ញារ៉ា**

២១. លោក **ឌឹម ចិន្តា**

២២. លោក **សូ ប៊ុនណេត**

២៣. លោក **យីម យន**

២៤. លោក **គឹម សុភាន់**

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មុខកថា

ប្រទេសនីមួយៗមានការរីកចម្រើនអភិវឌ្ឍជឿនលឿនទៅបាន អាស្រ័យទៅលើការធ្វើកំណែទម្រង់លើគ្រប់វិស័យទាំងអស់។ សម្រាប់វិស័យអប់រំជាផ្នែកមួយ ដែលដើរតួយ៉ាងសំខាន់ដើម្បីចូលរួមចំណែកទទួលបាននៅធនធានមនុស្សរួមមាន ចំណេះដឹង ជំនាញ និងការគិតបែបដោះស្រាយបញ្ហា ជាសក្តានុពលជំរុញការអភិវឌ្ឍសេដ្ឋកិច្ច វិស័យអប់រំបានផ្សារភ្ជាប់ជាមួយបច្ចេកវិទ្យាក្នុងកម្មវិធីឌីជីថល ដើម្បីបង្កើតក្លាយខ្លួនជាពលរដ្ឋឌីជីថលដែលមានទំនួលខុសត្រូវ ការគិតបែបស៊ីជម្រៅ ការយល់ចិត្តគ្នា និងការសន្ទនាបែបឌីជីថល។

បច្ចុប្បន្ន ហានិភ័យនៃការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល គឺជាកង្វល់របស់អ្នកអប់រំ និងអ្នកពាក់ព័ន្ធដែលកំពុងប្រើប្រាស់ ជាពិសេសកុមារដែលជាអ្នកងាយរងគ្រោះបំផុតស្ថិតនៅកម្រិតអនុវិទ្យាល័យ។ ការរៀបចំឯកសារណែនាំ សម្រាប់បណ្តុះបណ្តាលគ្រូ **កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ** ជួយដល់គ្រូបង្រៀនសិស្សានុសិស្ស មាតាបិតា និងអ្នកពាក់ព័ន្ធផ្សេងៗ បានយល់ដឹងកាន់តែច្បាស់អំពីការប្រើប្រាស់ឌីជីថលប្រកបដោយសុវត្ថិភាព ទទួលបានចំណេះដឹង និងឥរិយាបថប្រកបដោយសុវត្ថិភាព ព្រមទាំងសុខុមាលភាព បញ្ចៀសបាននូវគ្រោះថ្នាក់ ព្រមទាំងហានិភ័យផ្សេងៗ ដែលអាចកើតមានលើការប្រើប្រាស់កម្មវិធីឌីជីថល។

ឯកសារណែនាំគ្រូសម្រាប់បណ្តុះបណ្តាល **កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ** ត្រូវបានរៀបចំឡើង ដើម្បីជួយអភិវឌ្ឍជំនាញដែលយើងត្រូវការ ដើម្បីបង្កើតពលរដ្ឋឌីជីថលដែលពេញលេញ និងសម្រាប់អនុវត្តនៅកម្រិតមធ្យមសិក្សាបឋមភូមិទូទាំងប្រទេស ដែលនឹងក្លាយជាមូលធនមនុស្សប្រកបដោយសុខុមាលភាព។

ក្រសួងអប់រំ យុវជន និងកីឡា សូមថ្លែងអំណរគុណដ៏ស្មោះចំពោះបុគ្គលិកអប់រំ និងក្រុមហ៊ុនមេតា (Facebook) បានផ្តល់ជំនួយហិរញ្ញប្បទាន និងអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការ ខេប) ដែលបានផ្តល់ជាបច្ចេកទេស និងអង្គការដៃគូ ដែលបានចូលរួមចំណែកក្នុងការកសាងឯកសារណែនាំបង្រៀនដ៏មានសារៈសំខាន់នេះ ដើម្បីគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតមធ្យមសិក្សាបឋមភូមិ ក្នុងសាលារៀនជំនាន់ថ្មី (NGS) និងសាលាចំណេះដឹងទូទៅសាធារណៈនាពេលអនាគត ដែលជាផ្នែកមួយនៃការជំរុញការអប់រំបែបឌីជីថលនៅក្នុងប្រទេសកម្ពុជា។

ក្រសួងអប់រំ យុវជន និងកីឡា មានជំនឿជាក់ និងសង្ឃឹមថាសិស្សានុសិស្សគ្រប់ៗរូបបានរៀនសូត្រពីកម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ មានចំណេះដឹងដែលពួកគេទទួលបានពីគម្រោងមួយនេះ នឹងជួយតម្រង់ទិសក្នុងការប្រើប្រាស់ឌីជីថលប្រកបដោយការទទួលខុសត្រូវខ្ពស់។

ថ្ងៃ ពុធ ១៣រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ តុលា ឆ្នាំ២០២៤

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

# អារម្ភកថា

ក្នុងយុគសម័យឌីជីថលនេះ វិស័យបច្ចេកវិទ្យាព័ត៌មានលើសកលលោកពិតជាមានការវិវឌ្ឍជឿនលឿនយ៉ាងឆាប់រហ័ស។ ប្រទេសកម្ពុជាចាំបាច់ត្រូវមានកំណែទម្រង់លើគ្រប់វិស័យដើម្បីបង្កើតធនធានមនុស្សដែលមានចំណេះដឹងជំនាញ និងការគិតបែបដោះស្រាយបញ្ហា ដែលជាសក្តានុពលជំរុញ ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមជាតិ។ ការបញ្ជ្រាបបច្ចេកវិទ្យាព័ត៌មាន និងអក្ខរកម្មឌីជីថលក្នុងការរៀន និងបង្រៀន បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអប់រំឌីជីថល និងបរិវត្តកម្មឌីជីថលក្នុងវិស័យអប់រំ ដែលអាចផលិតបាននូវពលរដ្ឋឌីជីថល ហើយឈានដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល និងសង្គមឌីជីថលនាពេលអនាគត។ ក្រសួងអប់រំ យុវជន និងកីឡា និងដៃគូអភិវឌ្ឍនានា យល់ឃើញពីតម្រូវការចាំបាច់ក្នុងការអភិវឌ្ឍធនធានមនុស្សប្រកបដោយពុទ្ធិដែលអាចបម្រើឱ្យតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន។

ក្នុងឆ្នាំ២០២៤ នាយកដ្ឋានបរិវត្តកម្មឌីជីថល នៃក្រសួងអប់រំ យុវជន និងកីឡា (MoEYS) បានចូលរួមសហការយ៉ាងជិតស្និទ្ធ ជាមួយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (អង្គការខេប) ដោយទទួលបានជំនួយហិរញ្ញប្បទានពីក្រុមហ៊ុនមេតា (Facebook) ក្នុងការកែសម្រួលឯកសារណែនាំ កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ ដើម្បីគាំទ្រដល់ការអប់រំឌីជីថលនៅកម្រិតមធ្យមសិក្សាបឋមភូមិ។ កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរនេះបាន ដកស្រង់ចេញកម្មវិធីសិក្សា WeThinkDigital ដែលបង្កើតឡើងដោយក្រុមហ៊ុនមេតា (Facebook) នៅក្នុងឆ្នាំ២០១៩។ ក្នុងការជួយអភិវឌ្ឍជំនាញដែលយើងត្រូវការ ដើម្បីកសាងពលរដ្ឋឌីជីថល ដែលមានទំនួលខុសត្រូវ ការគិតបែបស៊ីជម្រៅ ការយល់ចិត្តគ្នា និងការសន្ទនាបែបឌីជីថល។

កម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ មានគោលបំណងក្នុងការផ្តល់សនិទានភាព និងការធ្វើឱ្យប្រសើរឡើងនូវកម្មវិធីសិក្សា ICT សម្រាប់កម្រិតមធ្យមសិក្សាបឋមភូមិ (ថ្នាក់ទី៧-៩) នៅក្នុងសាលារៀនជំនាន់ថ្មី (NGS) និងសាលារៀនចំណេះដឹងទូទៅសាធារណៈនាពេលអនាគត។ កម្មវិធីសិក្សានេះនឹងផ្តល់ឱ្យសិស្សនូវជំនាញមូលដ្ឋានគ្រឹះ អក្ខរកម្មឌីជីថល សុវត្ថិភាពអនឡាញ និងសុខមាលភាពឌីជីថល តាមរយៈការផ្តល់វគ្គបណ្តុះបណ្តាល និងសិក្ខាសាលា។ ឯកសារណែនាំកម្មវិធីសិក្សាអក្ខរកម្មឌីជីថលខ្មែរ នេះមានបួន (០៤) ម៉ូឌុល ដូចជា ១)ការណែនាំអំពីការរៀនបែបឌីជីថល ២)មូលដ្ឋានគ្រឹះឌីជីថល ៣)សុខុមាលភាពឌីជីថល និង ៤)ការចូលរួមបែបឌីជីថល ។

ក្រសួងអប់រំ យុវជន និងកីឡា ក្រុមហ៊ុនមេតា (Facebook) និងអង្គការខេប សង្ឃឹមថាកម្មវិធីសិក្សានេះនឹងធ្វើឱ្យប្រសើរឡើងនូវការសិក្សាបែបឌីជីថល ក្នុងចំណោមសិស្ស នៅក្នុងក្របខណ្ឌសាលារៀនជំនាន់ថ្មី ដែលជាការចូលរួមចំណែកដ៏សំខាន់មួយដល់ការអប់រំឌីជីថលនៅកម្ពុជា និងជំរុញការអភិវឌ្ឍជំនាញឌីជីថល នៅកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិនាពេលអនាគត។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# ម៉ូឌុល ១៖
# សេចក្តីផ្តើមអំពី*ការរៀនឌីជីថល*

[កម្មវិធីសិក្សាដែលមានភាពបត់បែន សិស្សដែលមានអាយុ ១៣-១៨ឆ្នាំ]

**គន្លឹះ៖**

| | |
|---|---|
| | ទទួលបានមាតិកាឌីជីថល |
| | ឱកាសក្នុងការផ្លាស់ប្តូរតាមអ្នកប្រើប្រាស់ឌីជីថល |
| | ឱកាសធ្វើមូលដ្ឋានីយកម្ម (Localization) |

# មាតិកា


មេរៀនទី១៖ តើអ្វីទៅជាអ៊ីនធឺណិត? តើយើងត្រូវតភ្ជាប់ដោយរបៀបណា? ..... 3

មេរៀនទី២៖ ព័ត៌មានឌីជីថល និងការចែករំលែក ..... 8

មេរៀនទី៣៖ ការចូលប្រើប្រាស់ព័ត៌មាន និងសហគមន៍អនឡាញ ..... 13

មេរៀនទី៤៖ អត្តសញ្ញាណកម្មឌីជីថល និងកេរ្តិ៍ឈ្មោះអនឡាញ ..... 17

មេរៀនទី៥៖ ភាពជាពលរដ្ឋឌីជីថល និងសារៈសំខាន់ ..... 22



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# មេរៀនទី១៖ តើអ្វីទៅជាអ៊ីនធឺណិត? តើយើងត្រូវតភ្ជាប់ដោយរបៀបណា?

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

តើអ៊ីនធឺណិតអាចប្រើប្រាស់បានក្នុងការរស់នៅប្រចាំថ្ងៃរបស់យើងបានដោយរបៀបណា?

**លទ្ធផលសិក្សា៖**

- សិស្សនឹងអភិវឌ្ឍការយល់ដឹងពីដំណើរការ និងការប្រើប្រាស់អ៊ីនធឺណិតប្រចាំថ្ងៃ។
- សិស្សនឹងស្វែងយល់ពីវិធីផ្សេងៗក្នុងការតភ្ជាប់កុំព្យូទ័រទៅនឹងអ៊ីនធឺណិត និងរបៀបចែករំលែកព័ត៌មាន។
- សិស្សនឹងស្វែងយល់ពីរបៀបដែលឧបករណ៍ដំណើការ និងការតភ្ជាប់អ៊ីនធឺណិត។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- ឱ្យសិស្សអង្គុយជាដៃគូ ឬក្រុមតូចដើម្បីពិភាក្សា។
- ចែកសន្លឹកក្រដាសទទេ (មួយសន្លឹកទៅដៃគូ ឬក្រុមតូច)
- ប៊ិក ឬខ្មៅដៃ
- ផ្តល់ឯកសារចែកអំពី រូបភាពរបស់ Statista (មួយសន្លឹកទៅដៃគូ ឬក្រុមតូច)
- រូបភាពពន្យល់អំពីការប្រើប្រាស់វ៉ាយហ្វាយ(Wi-Fi)
- ផ្តល់ឱ្យសិស្សនូវបញ្ជីសទ្ទានុក្រមសម្រាប់មេរៀននេះ។

**រំលឹកមេរៀន (១០នាទី)**

(ចំណាំ៖ សកម្មភាពនេះជួយគ្រូឱ្យយល់ដឹងពីកម្រិតចំណេះដឹងពីមុនរបស់សិស្ស។)

- **ផ្តល់ឯកសារចែក៖** មួយនាទីនៅលើអ៊ីនធឺណិតក្នុងឆ្នាំ ២០២០ https://www.statista.com/chart/17518/data-created-in-an-internet-minute/



**សួរសិស្ស៖** តើអ្នកស្គាល់ស្លាកសញ្ញា (Logo) ឬម៉ាក (Brand) អ្វីខ្លះ? តើក្រុមហ៊ុនទាំងនេះល្បីល្បាញដោយសារអ្វី? ផ្តល់សេវាកម្មអ្វីខ្លះ? ចម្លើយដែលសិស្សអាចឆ្លើយតប៖

- ការជជែក
- ការកម្សាន្ត - តន្ត្រី/វីដេអូ/ភាពយន្ត
- ការទំនាក់ទំនងជាមួយមនុស្ស
- ការទិញទំនិញ (ពាណិជ្ជកម្មឌីជីថល) និងការដឹកជញ្ជូន

**សួរសិស្ស៖** ផ្អែកលើបរិបទរបស់អ្នក (សូមមើលពាក្យវាក្យសព្ទ) និងការយល់ដឹងពីអ៊ីនធឺណិត តើអ្នកគិតថារូបភាពខាងលើ តំណាងឱ្យរយៈពេលប៉ុន្មាននាទី? អ្វីដែលពិសេសជាងនេះទៅទៀត ក្នុងបណ្តាញសង្គមយូធូប (YouTube) វីដេអូសរុបដែលមានរយៈពេល ៥០០ម៉ោង តើអ្នកប្រើប្រាស់ចំណាយពេលប៉ុន្មានដើម្បីដាក់នាំចូល (Upload)?

**ចម្លើយគឺមួយនាទី។**

និយាយ

**សង្ខេប៖**

- រូបភាពនេះបកស្រាយ ក្រុមហ៊ុន ដែលផ្តល់សេវាកម្មដល់អ្នកកំពុងប្រើប្រាស់អ៊ីនធឺណិតឆ្នាំ២០២០។
- យោងតាមទិន្នន័យ (ចងក្រងដោយ Visual Capitalist) ១នាទីអ៊ីនធឺណិតមាន៖
  - មានវីដេអូច្រើនជាង ៤០០ ០០០ម៉ោង បានចាក់ផ្សាយនៅលើ Netflix
  - វីដេអូសរុបចំនួន ៥០០ម៉ោង បានដាក់បញ្ចូលដោយអ្នកប្រើប្រាស់នៅលើ យូធូប (YouTube)
  - មានសារជិត ៤២លាន ត្រូវបានចែករំលែកតាមរយៈ WhatsApp
  - ក្នុងរយៈពេល ១នាទី មានទំនិញច្រើនជាង ៦៥០០ កញ្ចប់ត្រូវបានដឹកជញ្ជូនដោយ ក្រុមហ៊ុន Amazon។
  - ក្នុងរយៈពេល ១នាទី មានអ្នកចូលរួមប្រជុំតាម ZOOM ចំនួន ២០៨ ៣៣៣ នាក់។

**ការពិភាក្សាក្រុមធំ (១០នាទី)** សិស្សនឹងអភិវឌ្ឍការយល់ដឹងពីដំណើរការ និងការប្រើប្រាស់អ៊ីនធឺណិតប្រចាំថ្ងៃ។

- ទោះបីជាអ្នកបានដឹងពីអ៊ីនធឺណិតក៏ដោយ តើអ្នកធ្លាប់គិតទេថា 'តើអ្វីទៅជាអ៊ីនធឺណិត?'
- ធ្វើការជាដៃគូ ឬក្រុមតូចសូមចំណាយពេល ២នាទី ដើម្បីពិភាក្សា និងសរសេរគំនិតរបស់អ្នកជាមួយដៃគូ ឬក្រុមតូច។
- ឱ្យក្រុមទាំងអស់ចែករំលែកចម្លើយរបស់ពួកគេនៅលើក្តារខៀន (២នាទី)។
- បន្ទាប់ពីការចែករំលែក សូមសរសេរនិយមន័យទាំងនេះនៅលើក្តារខៀន៖
  - **អ៊ីនធឺណិត៖** គឺជាបណ្តាញដែលភ្ជាប់កុំព្យូទ័រជាមួយគ្នា និងអនុញ្ញាតឱ្យមានព័ត៌មាន ឬទិន្នន័យធ្វើដំណើរពីកុំព្យូទ័រមួយទៅកុំព្យូទ័រមួយទៀត។
  - **បណ្តាញ៖** តភ្ជាប់កុំព្យូទ័រជាមួយគ្នា ឧទាហរណ៍៖ ខ្សែបណ្តាញទូរសព្ទភ្ជាប់ទូរសព្ទពីផ្ទះរបស់អ្នកទៅទូរសព្ទផ្សេងទៀតហើយអនុញ្ញាតឱ្យអ្នកភ្ជាប់ជាមួយមនុស្សផ្សេងទៀត ដែលស្ថិតនៅក្នុងបណ្តាញទូរសព្ទជាមួយគ្នា។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- **ទិន្នន័យ៖** សមត្ថភាពក្នុងការយល់ដឹង បង្កើត ប្រមូល តំណាង វាយតម្លៃ បកស្រាយ និងវិភាគ ទិន្នន័យពីប្រភពឌីជីថល និងមិនមែនឌីជីថល។

- អនុញ្ញាតឱ្យសិស្សានុសិស្សបញ្ចេញគំនិតរបស់ពួកគេទៅនឹងនិយមន័យចំនួនពីរ។ តើមានភាពស្រដៀងគ្នា ឬខុសគ្នារវាងអ្វីដែលពួកគេគិត និងនិយមន័យនៃអ៊ីនធឺណិតដែលបានផ្តល់ឱ្យឬទេ?
- **សង្ខេប៖** តើនិយមន័យទាំងនេះដើរតួនាទីយ៉ាងដូចម្តេចនៅក្នុងវេបសាយ ដូចជា យូធូប (YouTube)?
  - **ឧទាហរណ៍៖** កម្មវិធី យូធូប (YouTube) គឺជាវេបសាយផ្សាយតាមអ៊ីនធឺណិត ដែលប្រើពាក្យសម្ងាត់ដើម្បី ចូលគណនីប្រើប្រាស់ទិន្នន័យ/មាតិកា។
  - **អ៊ីនធឺណិត៖** តភ្ជាប់អ្នកដោយផ្ទាល់ទៅ យូធូប (YouTube)។
  - **បណ្តាញ៖** អ្នកប្រើប្រាស់កុំព្យូទ័រ/ឧបករណ៍ដើម្បីតភ្ជាប់ទៅកាន់អ៊ីនធឺណិត តាមរយៈផ្លាយរណប ឬ បណ្តាញទូរសព្ទចល័ត។
  - **ទិន្នន័យ៖** ចូលប្រើប្រាស់បណ្ណាល័យវីដេអូ និងធនធាននៅលើ យូធូប (YouTube)។

### សកម្មភាពក្នុងថ្នាក់

**សួរសិស្ស (រយៈពេល ១០នាទី)**

សិស្សនឹងស្វែងយល់ពីវិធីផ្សេងៗក្នុងការតភ្ជាប់កុំព្យូទ័រទៅនឹងអ៊ីនធឺណិត និងរបៀបចែករំលែកព័ត៌មាន។

- ឥឡូវយើងបានយល់ដឹងពីមូលដ្ឋាននៃអ៊ីនធឺណិតរួចហើយ។
  - តើមនុស្សប្រើអ៊ីនធឺណិតបែបណាខ្លះ?
- សូមចំណាយពេល **២នាទី** ដើម្បីពិភាក្សាជាមួយដៃគូ។ យើងនឹងចែករំលែកនៅពេល ដែលអ្នកបានបញ្ចប់។
- បន្ទាប់ពីចំណាយពេល **២នាទី** ឱ្យសិស្សចែករំលែកចម្លើយរបស់ពួកគេ រួចសរសេរចម្លើយនៅលើក្តារខៀន។ ចម្លើយរំពឹងទុក៖
  - ការជជែក
  - ការដើរទិញឥវ៉ាន់
  - អ៊ីមែល
  - ការមើលវេបសាយកំប្លែង
  - ការផ្ញើ និងបង្កើតវីដេអូ
  - ការមើលភាពយន្ត
  - ការប្រមូលព័ត៌មាន
- សូមធ្វើចំណែកថ្នាក់ចម្លើយនៅលើក្តារខៀន។ ចម្លើយភាគច្រើនអាចចែកជាប្រភេទដូចខាងក្រោម៖ ការទំនាក់ទំនង ការកម្សាន្ត និងការងារ។

### សកម្មភាពក្នុងថ្នាក់

**សួរសិស្ស (២០នាទី)** សិស្សនឹងស្វែងយល់ពីរបៀបដែលឧបករណ៍ដំណើរការ និងការតភ្ជាប់អ៊ីនធឺណិត។

- អ៊ីនធឺណិតពិតជាបានផ្លាស់ប្តូរនូវសកម្មភាពរស់នៅប្រចាំថ្ងៃរបស់មនុស្ស។ តើមានឧទាហរណ៍ពីឧបករណ៍អ្វីខ្លះដែលប្រើអ៊ីនធឺណិតសព្វថ្ងៃនេះ ? សូមចំណាយពេល ២នាទី ដើម្បីពិភាក្សាជាមួយដៃគូរបស់អ្នក បន្ទាប់មក ចែករំលែកចម្លើយនៅពេល អ្នកបានបញ្ចប់។

និយាយ ២នាទីក្រោយមក ឱ្យសិស្សចែករំលែកចម្លើយរបស់ពួកគេ រួចសរសេរចម្លើយនៅលើក្តារខៀន។
ចម្លើយរំពឹងទុក៖

  - ទូរសព្ទ
  - ថេប្លេត (Tablet)
  - កុំព្យូទ័រ
  - ទូរទស្សន៍
  - ប្រព័ន្ធហ្គេម
  - រថយន្ត

- ឥឡូវនេះយើងបានកំណត់អត្តសញ្ញាណឧបករណ៍ហើយ។ តើឧបករណ៍ទាំងនេះតភ្ជាប់អ៊ីនធឺណិតដោយរបៀបណា ?
  - អ៊ីនធឺណិតឥតខ្សែ គឺជាមធ្យោបាយទូទៅក្នុងការតភ្ជាប់ឧបករណ៍ទៅអ៊ីនធឺណិត។ អ៊ីនធឺណិតឥតខ្សែ ប្រើរលកវិទ្យុ ដើម្បីតភ្ជាប់ឧបករណ៍ដោយមិនមានការតភ្ជាប់ជាលក្ខណៈរូបវន្ត ឬមានខ្សែ។
  - **បង្ហាញរូបភាពនេះ៖**
- ការប្រើរូបភាពដើម្បីពិពណ៌នាអំពីរបៀបតភ្ជាប់អ៊ីនធឺណិតដោយប្រើឧបករណ៍។
- ចូរស្រមៃថាអ្នកមានកុំព្យូទ័រយួរដៃនៅក្នុងផ្ទះដែលអ្នកចង់ភ្ជាប់អ៊ីនធឺណិត។ ដូច្នេះអ្នកត្រូវអនុវត្តដូចខាងក្រោម៖
  - **ចំណុចចូលដំណើរការ (Access Point)៖** គឺជាអ្វីៗដែលបញ្ជូន (ការផ្សាយ) សញ្ញា Wi-Fi និងផ្តល់សិទ្ធិចូលប្រើប្រាស់អ៊ីនធឺណិត។
  - **រ៉ោតទ័រ (Router)៖** គឺជាឧបករណ៍ដែលបង្កើតបណ្តាញរវាងឧបករណ៍តភ្ជាប់ទាំងអស់ (ឧទាហរណ៍៖ កុំព្យូទ័រ ថេប្លេត ទូរសព្ទចល័ត) នៅក្នុងទីតាំងដែលបានផ្តល់ឱ្យ (ដូចជាសាលារៀន បណ្ណាល័យ ឬផ្ទះរបស់អ្នក)។ ជាធម្មតារ៉ោតទ័រមានដែនកំណត់ (មានរយៈចម្ងាយខ្លី)
    ប្រសិនបើឧបករណ៍របស់អ្នក នៅឆ្ងាយពីរ៉ោតទ័រ អ្នកនឹងទទួលសេវាវ៉ាយហ្វាយ (Wi-Fi) ខ្សោយ ឬគ្មានសេវា។ ដូចគ្នានេះផងដែរ ប្រសិនបើមានអ្វីមួយបាំងអ្នក និងរ៉ោតទ័រ (ដូចជាអាគារ ឬជញ្ជាំងឥដ្ឋ) នោះនឹងកាត់បន្ថយសេវា។ ទោះបីជាការតភ្ជាប់ទៅរ៉ោតទ័រ ផ្តល់នូវការចូលប្រើបណ្តាញក៏ដោយ វាមិនអាចតភ្ជាប់អ្នកទៅកាន់ អ៊ីនធឺណិតទេ។ ដើម្បីតភ្ជាប់ទៅអ៊ីនធឺណិតបាន រ៉ោតទ័រត្រូវតែភ្ជាប់ជាមួយម៉ូដឹម (Modem)។
  - **ម៉ូដឹម (Modem)៖** គឺជាឧបករណ៍ដែលបង្កើត និងរក្សាការតភ្ជាប់ទៅកាន់អ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) របស់អ្នក ដើម្បីផ្តល់ឱ្យអ្នកនូវការចូលប្រើអ៊ីនធឺណិត។ វាបំប្លែងសញ្ញាពីខាងក្រៅទីតាំងដែលអ្នកបានផ្តល់ឱ្យ ទៅជាសញ្ញា អាចអានបានដោយកុំព្យូទ័ររបស់អ្នក និងឧបករណ៍ឌីជីថលផ្សេង ទៀត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- នៅក្នុងការដំឡើងធម្មតាចំណុចចូលដំណើរការ (Access Piont) និងរ៉ោតទ័រ គឺជាឧបករណ៍តែមួយដែលត្រូវបានតភ្ជាប់ទៅម៉ូដឹម ដោយប្រើខ្សែពិសេសហៅថាខ្សែអ៊ីសឺរណិត (Ethernet)។ នេះជាអ្វីដែលគេសំដៅចំពោះពេល ដែលមនុស្សនិយាយអំពីការតភ្ជាប់អ៊ីនធឺណិត "មានខ្សែ"។
- ឧបករណ៍ចល័តប្រើសេវាអ៊ីនធឺណិតចល័ត (Cellular) ដើម្បីតភ្ជាប់ទៅអ៊ីនធឺណិតផងដែរ ជាពិសេសប្រសិនបើគ្មានអ៊ីនធឺណិតនៅក្នុងសាលារៀន បណ្ណាល័យ ឬបណ្តាញផ្ទះ។ សេវាអ៊ីនធឺណិតចល័ត (Cellular) គឺជាប្រភេទ នៃសញ្ញាវិទ្យុឥតខ្សែ ដែលមានតំបន់គ្របដណ្តប់ធំជាងរ៉ោតទ័រ។ សេវាអ៊ីនធឺណិតចល័ត (Cellular) ប្រើឧបករណ៍បញ្ជូនជាក់លាក់ហៅថាបង្គោលអង់តែន (Cell Towers) ដើម្បីតភ្ជាប់ឧបករណ៍ចល័តរបស់អ្នកទៅអ៊ីនធឺណិត។

**ពង្រឹងពុទ្ធិ** (**១០នាទី**) សង្ខេបមេរៀនជាមួយនឹងចំណុចទាំងនេះ

- អ៊ីនធឺណិត គឺជាបណ្តាញកុំព្យូទ័រដ៏ធំដែលតភ្ជាប់គ្នាតាមរយៈបណ្តាញទូទាំងពិភពលោក។
- អ៊ីនធឺណិតបានផ្លាស់ប្តូរ ហើយនឹងបន្តផ្លាស់ប្តូរ របៀបដែលយើងរស់នៅក្នុងសង្គមទំនើប។
- មនុស្សប្រើប្រាស់អ៊ីនធឺណិតជារៀងរាល់ថ្ងៃក្នុងជីវិតរបស់ពួកគេដើម្បីទំនាក់ទំនង ធ្វើការស្រាវជ្រាវ និងសម្រាប់ការកម្សាន្ត។
- មនុស្សភ្ជាប់អ៊ីនធឺណិតដោយប្រើឧបករណ៍ជាច្រើនប្រភេទ ដូចជាកុំព្យូទ័រ ទូរសព្ទដៃ ទូរទស្សន៍ ឧបករណ៍លេងហ្គេម និងរថយន្តដើម្បីចែករំលែកព័ត៌មាន។
- មានវិធីជាច្រើនដើម្បីតភ្ជាប់ទៅអ៊ីនធឺណិតតាមខ្សែ ឬឥតខ្សែ។

# មេរៀនទី២៖ ព័ត៌មានឌីជីថល និងការចែករំលែក

**រយៈពេល៖** ៦០នាទី

**សំណួរគន្លឹះ៖** តើអ្វីជាព័ត៌មានឌីជីថល ហើយគេអាចចែករំលែកតាមអនឡាញដោយរបៀបណា?

**លទ្ធផលសិក្សា៖**

- សិស្សអាចកំណត់អត្តសញ្ញាណអ្វីដែលអាចចែករំលែកបានតាមអ៊ីនធឺណិត។
- សិស្សអាចកំណត់វិធីសាស្ត្រសុវត្ថិភាព និងសន្តិសុខចំពោះការចែករំលែកព័ត៌មាននៅលើអ៊ីនធឺណិត។
- សិស្សនឹងអាចថ្លឹងថ្លែងពីហានិភ័យ និងអត្ថប្រយោជន៍នៃការប្រើប្រាស់អ៊ីនធឺណិតនៅទីសាធារណៈ។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- សិស្សត្រូវអង្គុយជាដៃគូ ឬក្រុមតូចដើម្បីពិភាក្សា។
- ប្រមូល ៥-១០ រូបភាព បង្ហាញពីវិធីផ្សេងៗគ្នាពីការចែករំលែកព័ត៌មាន។ ឧទាហរណ៍៖ រូបភាពរបស់មនុស្សពីរនាក់កំពុងសន្ទនាគ្នា ការមើលវីដេអូ នរណាម្នាក់កំពុងអានសៀវភៅ នរណាម្នាក់កំពុងផ្ញើសារ ទៅមិត្តភ័ក្តិ។ល។ ប្រសិនបើអ្នកមិនមានសិទ្ធិចូលប្រើរូបភាពប្រភេទទាំងនេះទេ អ្នកអាចគូរវាដោយខ្លួនឯង ឬឱ្យសិស្សគូរពីវិធីដែលមនុស្សចែករំលែកព័ត៌មាន ដើម្បីបង្កើនសកម្មភាពក្នុងថ្នាក់។
- បោះពុម្ពរូបភាព ឬបង្ហាញក្នុងផ្ទាំងបង្ហាញ។
- ផ្តល់ឱ្យសិស្សនូវសន្ទានុក្រមសម្រាប់មេរៀននេះ។

**សំណួររំលឹកមេរៀន** (១០នាទី)

(ចំណាំ៖ សកម្មភាពនេះជួយគ្រូឱ្យយល់ដឹងពីកម្រិតចំណេះដឹងពីមុនរបស់សិស្ស។)

- **សួរសិស្ស៖** ចូរប្រាប់ដៃគូរបស់អ្នកនូវរឿងពីរយ៉ាង៖ ១)អាហារដែលអ្នកចូលចិត្ត ឬចំណង់ចំណូលចិត្ត និង ២)ថ្ងៃ ខែ ឆ្នាំកំណើតរបស់អ្នក បន្ទាប់មកសូមពិភាក្សា ថាតើការពិតមួយណាត្រូវបានចាត់ទុកថាជាព័ត៌មានទូទៅ ហើយមួយណាចាត់ទុកជាព័ត៌មានឌីជីថល។
- បន្ទាប់ពីរយៈពេល **២នាទី** សូមចែករំលែកជាមួយដៃគូ ឱ្យក្រុមនីមួយៗចែករំលែកនូវចម្លើយទាំងនេះ ដែលពួកគេគិតថាជាព័ត៌មានទូទៅ ហើយមួយណាដែលបានចាត់ទុកថាជាព័ត៌មានឌីជីថល។
- **ចម្លើយ៖** អាហារដែលចូលចិត្ត ឬចំណង់ចំណូលចិត្ត គឺជាព័ត៌មានទូទៅ ចំណែកឯ ថ្ងៃ ខែ ឆ្នាំកំណើត ជាព័ត៌មានឌីជីថល។
- **សរសេរនិយមន័យទាំងនេះនៅលើក្តារខៀន៖**
    - **ព័ត៌មាន** គឺជាការពិត ឬព័ត៌មានអំពីនរណាម្នាក់ ឬអ្វីមួយ។
    - **ព័ត៌មានឌីជីថល** គឺជាព័ត៌មានដែលកុំព្យូទ័រអាចដំណើរការបាន។ ព័ត៌មានទាំងនេះអាចជា៖ លេខ ពាក្យ រូបភាព វីដេអូ ឬសំឡេង។ ឧទាហរណ៍៖ អ៊ីមែលដែលអ្នកផ្ញើចេញ សារទៅមិត្តភ័ក្តិ រូបថតនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម ឬវីដេអូ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការពិភាក្សាក្រុម** ( **៥នាទី** ) សិស្សអភិវឌ្ឍការយល់ដឹងកាន់តែស៊ីជម្រៅពីទិន្នន័យជាច្រើន ដែលចែករំលែកនៅលើអ៊ីនធឺណិត។

- **សួរសិស្ស៖** តើអ្នកគិតថាមានមនុស្សប៉ុន្មាននាក់ប្រើប្រាស់អ៊ីនធឺណិត? អនុញ្ញាតឱ្យសិស្សចែករំលែក និងសរសេរ ការទស្សន៍ទាយរបស់ពួកគេនៅលើក្ដារខៀន។
- បន្ទាប់ពីការទស្សន៍ទាយ សូមប្រាប់សិស្សថាមនុស្សជិត **៤.៥៧ពាន់លាននាក់** ប្រើប្រាស់អ៊ីនធឺណិត ឬ ៥៩% នៃចំនួនប្រជាជនពិភពលោកហើយចំនួននោះនៅតែបន្តកើនឡើង។
- ចំនួនកើនឡើងនេះបង្កើតឱ្យមានទិន្នន័យកុំព្យូទ័រយ៉ាងច្រើន។ ទិន្នន័យកុំព្យូទ័រ គឺជាព័ត៌មានទាំងអស់ដែលបានផ្ញើឃើញ ចែករំលែករក្សាទុក និងដំណើរការនៅលើកុំព្យូទ័រ។
- បន្ទាប់មក យើងនឹងស្វែងយល់ពីរបៀបដែលទិន្នន័យទាំងនេះត្រូវបានចែករំលែក របៀបការពារ និងរក្សាទិន្នន័យរបស់អ្នកឱ្យមានសុវត្ថិភាព។

**សកម្មភាពក្នុងថ្នាក់** ( **២០នាទី** ) សិស្សអភិវឌ្ឍការយល់ដឹងកាន់តែស៊ីជម្រៅពីទិន្នន័យជាច្រើននៃការ ចែករំលែកនៅលើអ៊ីនធឺណិត។

- ចូរបែងចែកសិស្សក្នុងថ្នាក់ជាក្រុមតូចៗ ។
- បង្ហាញសិស្សរបស់អ្នកដោយប្រើរូបភាពមួយក្នុងចំណោមរូបភាព ៥-១០ ពីវិធីចែករំលែកព័ត៌មាន ដែលអ្នកបានប្រមូល។ ឧទាហរណ៍៖ រូបភាពមនុស្សពីរនាក់កំពុងសន្ទនា លេងវីដេអូ នរណាម្នាក់កំពុងអានសៀវភៅ នរណាម្នាក់ផ្ញើសារទៅមិត្តរបស់អ្នកមិត្តភ័ក្តិ។ល។ ***ការរំលឹក៖*** *ប្រសិនបើអ្នកមិនមានសិទ្ធិចូល ប្រើប្រភេទរូបភាព ទាំងនេះទេ អ្នកអាចគូរវាដោយខ្លួនឯង ឬឱ្យសិស្សគូរពីរបៀប ដែលមនុស្សចែករំលែក ព័ត៌មានដើម្បីបង្កើនសកម្មភាពនេះ។*
- បង្ហាញរូបភាពមួយក្នុងចំណោមរូបភាពទាំងនោះ ដូចជាការបោះពុម្ព ឬបង្ហាញនៅក្នុងផ្ទាំងបង្ហាញ។
- **សួរសិស្ស៖** ចូរពិភាក្សាក្នុងក្រុមតូចប្រហែល ១នាទី ក្នុងមួយរូបភាព តើរូបភាពទាំងនោះតំណាងឱ្យការចែករំលែកព័ត៌មានឌីជីថលដែរឬទេ? ទុកពេល សម្រាប់ការពិភាក្សាគ្នាប្រសិនបើក្រុមមានមតិខុសគ្នា។
- ពិនិត្យមើលរូបភាពនីមួយៗ ដោយប្រើវិធីដូចគ្នារហូតដល់អស់រូបភាព។

**សកម្មភាពក្នុងថ្នាក់** ( **២០នាទី** ) សិស្សនឹងយល់ពីរបៀបរក្សាព័ត៌មានឌីជីថលឱ្យមានសុវត្ថិភាព នៅលើអ៊ីនធឺណិត។

- សិស្សនៅតែស្ថិតក្នុងក្រុមតូចៗរបស់ពួកគេ។
- **សួរសិស្ស៖** តើព័ត៌មានរបស់អ្នកមានសុវត្ថិភាពនៅលើអ៊ីនធឺណិតដែរឬទេ? ហេតុអ្វីបានជាមានសុវត្ថិភាព ឬហេតុអ្វី បានជាមិនមាន?
- សូមផ្តល់ពេល ២នាទី ឱ្យសិស្សចែករំលែកគំនិតជាមួយក្រុមធំ។
- បន្ទាប់មកយើងពិភាក្សាអំពីវិធីបួនយ៉ាងដើម្បីរក្សាព័ត៌មានរបស់អ្នកឱ្យមានសុវត្ថិភាពនៅលើអ៊ីនធឺណិត៖
    - ពេល ខ្លះអ្នកត្រូវបានផ្តល់ជម្រើស តើបណ្តាញ (Network) មួយណាដែលអ្នកចង់ប្រើ អ្នកត្រូវចងចាំថាមានហានិភ័យធ្ងន់ធ្ងរ ប្រសិនបើអ្នកតភ្ជាប់ទៅបណ្តាញ (Network) ខុស។

- ចែករំលែក ឬបញ្ជាំងតារាងខាងក្រោម ដើម្បីបង្ហាញព័ត៌មានក្នុងតារាង៖

| **បណ្តាញ** | **សេចក្តីពន្យល់** | **ហានិភ័យ និងការពិចារណា** |
|---|---|---|
| ការតភ្ជាប់បណ្តាញសាធារណៈ(មិនមានសុវត្ថិភាព មិនគួរឱ្យទុកចិត្ត) | បណ្តាញដែលមិនទាមទារពាក្យសម្ងាត់ដើម្បីចូលប្រើប្រាស់។ | អ្នកផ្សេងទៀត ដែលនៅក្នុងបណ្តាញជាមួយអ្នកអាចឃើញព័ត៌មានរបស់អ្នក។ ពួកគេអាចលួចព័ត៌មានដែលអ្នកផ្ញើតាមបណ្តាញ ឬតាមដានអ្វីដែលអ្នកកំពុងធ្វើ។<br><br>**ឧទាហរណ៍៖** បើសិនអ្នកនៅរោងភាពយន្ត ហើយ អ្នកឃើញឈ្មោះបណ្តាញសាលានៅលើទូរសព្ទរបស់អ្នក ពេលកំពុងស្វែងរកការតភ្ជាប់ជាសាធារណៈ អ្នកត្រូវគិតថាបណ្តាញនោះអាចនឹងកំពុងព្យាយាមបំប្លែង ឬ"ក្លែងបន្លំ" ជាឈ្មោះបណ្តាញសាលារបស់អ្នក ដើម្បីប្រមូលពាក្យសម្ងាត់ពីសិស្ស។ |
| ការតភ្ជាប់បណ្តាញឯកជន (សុវត្ថិភាពទំនុកចិត្ត) | តម្រូវឱ្យបញ្ចូលពាក្យសម្ងាត់ និងបើកមុខងារបំប្លែងកូដ (Encryption៖ ការបំប្លែងអក្សរ និង លេខទៅកូដសម្ងាត់) ដើម្បីប្រាកដថា បណ្តាញដែលអ្នកកំពុងចូលគឺជាឈ្មោះបណ្តាញរបស់អ្នក។ | បណ្តាញដែលមានសុវត្ថិភាព និងទំនុកចិត្តនឹងផ្តល់នូវការការពារច្រើនបំផុត។ សូមពិចារណាពីបរិបទ ឬទីតាំងនៃបណ្តាញ។ |

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

| | | |
|---|---|---|
| បណ្តាញការពារដោយពាក្យសម្ងាត់ | នៅពេលបង្កើតបណ្តាញ ដែលការពារដោយពាក្យសម្ងាត់អ្នកប្រើប្រាស់ត្រូវបើកមុខងារអ៊ីនគ្រីបរបស់រ៉ោតទ័រ (router's encryption)។ | របៀបបើកមុខងារអ៊ីនគ្រីបទូទៅមាន៖Wired Equivalent Privacy (WEP), Wireless Internet Protected Access (WPA) or WPA2.។ ដំណើរការទាំងនេះដើម្បីធានាថាព័ត៌មានដែលបានផ្ញើតាមបណ្តាញឥតខ្សែត្រូវបាន អ៊ីនគ្រីប (ឬ "បំប្លែងកូដ")។ ការអ៊ីនគ្រីបត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យ Hacker កាន់តែពិបាកមើល និងតាមដានអ្វីដែលអ្នកកំពុងធ្វើ។ |
| វេបសាយ | HTTPS គឺជាស្តង់ដាដែលវេបសាយប្រើប្រាស់ដើម្បីអ៊ីនគ្រីបទិន្នន័យដែលបានឆ្លងកាត់តាមអ៊ីនធឺណិត។ | អ៊ីនគ្រីបអាចការពារកុំឱ្យជនទីបីចូលទៅមើល ទិន្នន័យដោយងាយស្រួលលើបណ្តាញតភ្ជាប់របស់អ្នក។ ដំណើរការនេះផ្តល់នូវស្រទាប់សុវត្ថិភាពបន្ថែម ហើយអាចប្រើនៅក្នុងកម្មវិធីរុករកណាមួយដោយបន្ថែម"https://" នៅពីមុខ URL ដែលអ្នកប្រើ (ឧទាហរណ៍៖ https://www.mysite.com)។ យ៉ាងណាក៏ដោយ មិនមែនគ្រប់វេបសាយទាំងអស់សុទ្ធតែគាំទ្រ HTTPS នោះទេ។ |

**សួរសិស្ស៖** តាមរយៈតារាងខាងលើ និងការសន្ទនាដែលយើងមាននៅថ្ងៃនេះពីព័ត៌មាននៅលើអ៊ីនធឺណិត និង របៀបចូលប្រើប្រាស់សូមចំណាយពេល ២ ឬ៣នាទី ដើម្បីឆ្លើយសំណួរទាំងបីខាងក្រោមជាក្រុមតូច ហើយចែករំលែក។

- តើការភ្ជាប់អ៊ីនធឺណិតមានគុណសម្បត្តិអ្វីខ្លះ?
- តើការភ្ជាប់អ៊ីនធឺណិតមានគុណវិបត្តិអ្វីខ្លះ?
- តើអ្នកព្រួយបារម្ភពីសុវត្ថិភាពអ្វីខ្លះ នៅពេល តភ្ជាប់អ៊ីនធឺណិតគ្មានខ្សែធៀបនឹងការតភ្ជាប់មានខ្សែ?

**ពង្រឹងពុទ្ធិ**(៥នាទី) សង្ខេបមេរៀនជាមួយនឹងចំណុចទាំងនេះ។

- អ៊ីនធឺណិតគឺជាបណ្តាញទិន្នន័យដ៏ធំ ហើយត្រូវបានប្រើប្រាស់ចំនួន ៥៩% នៃចំនួនប្រជាជនពិភពលោក (នឹងកំពុងកើនឡើង!)
- ព័ត៌មានឌីជីថលគឺជា ព័ត៌មានដែលបានចែករំលែកនៅលើអ៊ីនធឺណិតក្នុងទម្រង់ជាលេខ ពាក្យ រូបភាព វីដេអូ ឬសំឡេង។
- អ៊ីនធឺណិតអាចចូលប្រើបានតាមរយៈការតភ្ជាប់គ្មានខ្សែ ឬមានខ្សែ ហើយចាំបាច់ត្រូវមានតុល្យភាពរវាងគុណវិបត្តិ និងគុណសម្បត្តិនៃការតភ្ជាប់អ៊ីនធឺណិតសាធារណៈ។
- អ៊ីនធឺណិតគឺជា មធ្យោបាយដ៏សំខាន់មួយសម្រាប់មនុស្សក្នុងការចូលរួមក្នុងសង្គម នៅថ្នាក់មូលដ្ឋានជាតិ និងពិភពលោក។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៣៖ ការចូលប្រើប្រាស់ព័ត៌មាន និងសហគមន៍អនឡាញ

**រយៈពេល ៖** ៦០នាទី

***សំណួរ៖*** តើយើងចូលប្រើប្រាស់ព័ត៌មាន និងសហគមន៍អនឡាញ (Online) សម្រាប់ទទួលចំណេះដឹង និងធ្វើសង្គមនីយកម្ម (Socialization) ដោយរបៀបណា?

**លទ្ធផលសិក្សា៖**

- សិស្សអភិវឌ្ឍការយល់ដឹងពីដំណើរការចូលទៅប្រើប្រាស់ព័ត៌មាន និងសហគមន៍អនឡាញ។
- សិស្សអភិវឌ្ឍការយល់ដឹងពីការចូលប្រើព័ត៌មានដោយប្រើកម្មវិធីស្វែងរកផ្សេងៗ។
- សិស្សអភិវឌ្ឍការយល់ដឹងអំពីរបៀបចូលរួមប្រព័ន្ធអនឡាញសង្គម។
- សិស្សរកឃើញវិធីផ្សេងៗសម្រាប់ប្រាស្រ័យទាក់ទងតាមអនឡាញ។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- សិស្សពិភាក្សាជាដៃគូ ឬក្រុមតូច
- ក្រដាសទទេ
- ប៊ិក ឬខ្មៅដៃ
- ផ្តល់ឱ្យសិស្សនូវបញ្ជីសន្ទានុក្រមសម្រាប់មេរៀននេះ

**ដំណើរការបង្រៀន**

**រំលឹកមេរៀន៖ (១៥នាទី)**

(ចំណាំ៖ សកម្មភាពនេះជួយគ្រូឱ្យយល់ដឹងពីកម្រិតចំណេះដឹងពីមុនរបស់សិស្ស។)

**សួរសិស្ស៖** ធ្វើការជាមួយដៃគូ ឬក្រុមរបស់អ្នកសូមចំណាយពេល ពីរនាទីជ្រើសរើសល្បះផ្តើមដែលគេឱ្យខាងក្រោមហើយធ្វើការចែករំលែកបទពិសោធន៍ ឬរឿងរ៉ាវផ្ទាល់ខ្លួន។ សិស្សម្នាក់ៗចំណាយពេល មួយនាទីដើម្បីចែករំលែក៖

  - ខ្ញុំប្រើប្រាស់អ៊ីនធឺណិតសម្រាប់ស្វែងរក..........
  - ខ្ញុំដដែកតាមអនឡាញជាមួយនរណាម្នាក់អំពី.........
  - ខ្ញុំទទួល ឬផ្ញើសារតាមអនឡាញទៅកាន់..........
  - ខ្ញុំចែករំលែកអ្វីមួយតាមអនឡាញដែល..........
- សិស្សម្នាក់ៗគួរតែចែករំលែកអំពីបទពិសោធន៍គ្នាទៅវិញទៅមក។
- មានវិធីច្រើនយ៉ាងដែលយើងអាចផ្សារភ្ជាប់ជាមួយនឹងអ៊ីនធឺណិត ការស្វែងរកព័ត៌មាន ការទំនាក់ទំនងជាមួយមនុស្សដទៃ ឬទំនាក់ទំនងសង្គម។ បន្ទាប់មកយើងនឹងសិក្សាអំពីវិធីជាក់លាក់ក្នុងការអនុវត្តជាក់ស្តែង។

**ពិភាក្សាក្រុមធំ (១០នាទី)** សិស្សអភិវឌ្ឍការយល់ដឹងពីដំណើរការចូលទៅប្រើប្រាស់ព័ត៌មាន និងសហគមន៍អនឡាញ។

**សួរសិស្ស៖** អ៊ីនធឺណិតគឺជា បណ្ដាញដ៏ធំរបស់កុំព្យូទ័រ និងឧបករណ៍ជាច្រើន ប៉ុន្តែសព្វថ្ងៃនេះមានកុំព្យូទ័រច្រើនប្រភេទខុសៗគ្នា។

- ឱ្យសិស្សធ្វើការជាមួយដៃគូ ឬក្រុមតូចរយៈពេល **២នាទី** ដើម្បីពិភាក្សា តើកុំព្យូទ័រ ឬឧបករណ៍ខាងក្រោមគឺជាអ្វី? យើងនឹងចែករំលែកបន្ទាប់ពីការពិភាក្សា។ ចម្លើយរំពឹងទុក៖
    - កុំព្យូទ័រទំហំធំ (Big Computer) ដែលមិនផ្លាស់ទី
    - កុំព្យូទ័រយួរដៃ
    - ថេប្លេត (Tablet)
    - ទូរសព្ទឆ្លាតវៃ ឬ
    - នាឡិកាឆ្លាតវៃ។
- នៅពេល ដែលកុំព្យូទ័ររបស់អ្នកតភ្ជាប់ទៅអ៊ីនធឺណិត អ្នកតែងតែប្រើកម្មវិធីរុករក (Web Browser) ដើម្បីចូលទៅកាន់វេបសាយជុំវិញពិភពលោក (World Wide Web)។
- នៅលើវេប (Web) អ្នកនឹងឃើញវេបសាយ(Website) និងទំព័រវេប (Web Page) ។ ឧទាហរណ៍៖ វេទិកា ប្រព័ន្ធផ្សព្វផ្សាយសង្គម (Social Media Platform) កាសែតក្នុងស្រុក ឬហាងពេញនិយមផ្សេងៗមានទំព័រវេប។
- មូលហេតុចម្បងមួយដែលមនុស្សប្រើអ៊ីនធឺណិតគឺដើម្បីស្វែងរកព័ត៌មាន។ វិធីដ៏ពេញនិយមគឺប្រើឧបករណ៍ស្វែងរក។ បន្ទាប់មកយើងពិនិត្យមើលប្រភេទម៉ាស៊ីនស្វែងរក និងរបៀបប្រើប្រាស់ផ្សេងៗដើម្បីស្វែងរកព័ត៌មាន។

**សកម្មភាពសិស្ស (១០នាទី)** សិស្សអភិវឌ្ឍការយល់ដឹងពីការចូលប្រើព័ត៌មានដោយប្រើកម្មវិធីស្វែងរកផ្សេងៗ។

**សួរសិស្ស៖** យើងអាចជ្រើសរើសម៉ាស៊ីនស្វែងរកជាច្រើននៅក្នុងពិភពលោក សូមធ្វើការជាដៃគូ ឬក្រុមតូចរយៈពេល ពីរនាទី ដើម្បីពិភាក្សា។ តើអ្នកស្គាល់ម៉ាស៊ីនស្វែងរកអ្វីខ្លះ? យើងនឹងចែករំលែកបន្ទាប់ពីការពិភាក្សា។ ចម្លើយរំពឹងទុក៖

- Google
- Yahoo
- Bing
- Baidu
- YANDEX
- DuckDuckGo

- ម៉ាស៊ីនស្វែងរកស្វែងរកទំព័រវេប (Web Page) ផ្សេងៗគ្នាជាច្រើន និងអាចផ្តល់បញ្ជីទំព័រវេប (Web Page) ពាក់ព័ន្ធដែលអ្នកអាចស្វែងរកព័ត៌មានបន្ថែមលើប្រធានបទនោះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**សួរសិស្ស៖** សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន។ សូមចំណាយពេល ៥នាទី ដើម្បីពិភាក្សាសំណួរទាំងនេះជាមួយដៃគូ ឬក្នុងក្រុមតូច។ បន្ទាប់មកយើងនឹងចែករំលែកជាមួយក្រុមធំ។

- តើអ្នកណាខ្លះធ្លាប់ប្រើម៉ាស៊ីនស្វែងរក?
- តើអ្នកធ្លាប់ប្រើម៉ាស៊ីនស្វែងរកអ្វីខ្លះ?
- តើអ្នកស្វែងរកអ្វី?
- តើអ្នកបានរកឃើញអ្វីដែលអ្នកចង់ស្វែងរកឬទេ?

**សកម្មភាពសិស្ស** (១០នាទី) សិស្សអភិវឌ្ឍការយល់ដឹងអំពីរបៀបចូលរួមប្រព័ន្ធអនឡាញសង្គម។

**សួរសិស្ស៖** មនុស្សប្រើអ៊ីនធឺណិតដើម្បីធ្វើអន្តរកម្ម និងភ្ជាប់ទំនាក់ទំនងជាមួយមនុស្សដទៃទៀត។

- សូមធ្វើការជាមួយដៃគូ ឬក្រុមតូចរយៈពេល ២នាទី ដើម្បីពិភាក្សា។ តើអ្នកដឹងប្រព័ន្ធផ្សព្វផ្សាយសង្គមអ្វីខ្លះ ដែលមនុស្សប្រើប្រាស់ដើម្បីធ្វើអន្តរកម្ម និងទំនាក់ទំនងជាមួយគ្នាតាមអនឡាញ?
- យើងនឹងចែករំលែកបន្ទាប់ពីការពិភាក្សា។ ចម្លើយរំពឹងទុក៖
  - Facebook
  - Snapchat
  - Twitter
  - LinkedIn
  - Instagram
  - YouTube
  - TikTok
- អ្នកអាចចូលប្រើបណ្តាញសង្គមទាំងនេះនៅលើវេបសាយ តាមរយៈកុំព្យូទ័រយួរដៃ/ឧបករណ៍ ឬកម្មវិធីណាមួយនៅក្នុងទូរសព្ទដៃរបស់អ្នក។
- ប្រព័ន្ធផ្សព្វផ្សាយសង្គមបង្កើតបាននូវសហគមន៍អនឡាញ។ ប្រព័ន្ធផ្សព្វផ្សាយសង្គមជាច្រើនផ្តល់ឱ្យអ្នកប្រើប្រាស់នូវសមត្ថភាពបង្ហោះរូបភាព វីដេអូ ឬអត្ថបទដែលបង្ហាញពីព្រឹត្តិការណ៍ កើតឡើងនៅក្នុងជីវិតផ្ទាល់ខ្លួន ។
- ហេតុផលមួយទៀតនៃការប្រើប្រាស់អ៊ីនធឺណិតគឺសម្រាប់ផ្ញើសារភ្លាមៗ ដែលកម្មវិធីទាំងនោះមានដូចជា៖
  - Facebook Messenger
  - WhatsApp
  - Telegram
  - WeChat
  - LINE
  - Skype
- វេទិកាទាំងនេះអនុញ្ញាតឱ្យអ្នកនិយាយផ្ទាល់ជាមួយមនុស្សដទៃ ឬក្រុមមនុស្សជាលក្ខណៈឯកជន។

**សួរសិស្ស៖** សូមសរសេរសំណួរខាងក្រោមនៅលើក្តារខៀន រួចចំណាយពេល ប្រាំនាទី ដើម្បីពិភាក្សាសំណួរ ទាំងនេះជាមួយដៃគូ ឬក្រុមតូច។ បន្ទាប់មក យើងនឹងចែករំលែកជាមួយក្រុមធំ។

- តើអ្នកអាចធ្វើអន្តរកម្ម ឬភ្ជាប់ទំនាក់ទំនងជាមួយមនុស្សតាមអនឡាញដោយវិធីអ្វីខ្លះ?
- តើអ្នកធ្លាប់ប្រើប្រព័ន្ធផ្សព្វផ្សាយសង្គម ឬវេទិកាផ្ញើសារភ្លាមៗណាមួយពីមុនឬទេ?
- តើវេទិកាមួយណាដែលអ្នកចូលចិត្តជាងគេ?

**សកម្មភាពសិស្ស** (**១០នាទី**) សិស្សរកឃើញវិធីផ្សេងៗសម្រាប់ប្រាស្រ័យទាក់ទងតាមអនឡាញ។

**សួរសិស្ស៖** មនុស្សប្រើអ៊ីនធឺណិតដើម្បីទំនាក់ទំនង ឬផ្ញើសារអេឡិចត្រូនិក ឬ"អ៊ីមែល"។ សូមធ្វើការជាដៃគូ ឬក្រុមតូច រយៈពេល ២នាទី ដើម្បីពិភាក្សា។ តើវេទិកាអ៊ីមែលអ្វីខ្លះដែលពេញនិយម? បន្ទាប់មកយើងនឹងចែករំលែកជាមួយក្រុមធំ។ ចម្លើយដែលរំពឹងទុក៖

- Gmail
- Outlook
- Yahoo

- វេទិកាអ៊ីមែលទាំងនេះអនុញ្ញាតឱ្យបុគ្គលផ្ញើសារអេឡិចត្រូនិក និងសំបុត្រសម្រាប់ទំនាក់ទំនងជាមួយបុគ្គល ឬក្រុមតាមអនឡាញ។
- វេទិកាអ៊ីមែលជាច្រើនផ្តល់លទ្ធភាពឱ្យអ្នកប្រើប្រាស់បង្កើតសៀវភៅអាសយដ្ឋានអនឡាញ និងវិធីផ្ទុកទិន្នន័យ ដើម្បីតម្រៀប និងរៀបចំអ៊ីមែលរបស់ពួកគេ។

**ពង្រឹងពុទ្ធិ** (**៥នាទី**) សង្ខេបមេរៀនដែលផ្តោតលើចំណុចទាំងនេះ។

- នៅពេល អ្នកតភ្ជាប់ទៅអ៊ីនធឺណិត អ្នកនឹងឆ្លងកាត់ម៉ាស៊ីនរុករកតាមអ៊ីនធឺណិតជាញឹកញាប់ដើម្បីចូលប្រើវេបសាយជុំវិញពិភពលោក។ នៅលើវេប អ្នកនឹងរកឃើញវេបសាយ និងទំព័រវេប ដើម្បីចូលប្រើព័ត៌មាន និងសហគមន៍អនឡាញ។
- យើងមានម៉ាស៊ីនស្វែងរកច្រើនយ៉ាងដែលមានវេបសាយផ្សេងៗគ្នា និងផ្តល់បញ្ជីវេបសាយពាក់ព័ន្ធ ដែលអ្នកអាចស្វែងរកព័ត៌មានបន្ថែមលើប្រធានបទផ្សេងៗដែលអ្នកចង់រក។
- មនុស្សប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេបសាយដើម្បីចែករំលែកពីជីវិតផ្ទាល់ខ្លួនរបស់ពួកគេ ភ្ជាប់ទំនាក់ទំនងជាមួយគ្រួសារ និងមិត្តភ័ក្តិ ឬភ្ជាប់ជាមួយនឹងសកម្មភាពក្នុងសង្គមអនឡាញផ្សេងទៀតដូចជាការចែករំលែកតន្ត្រី ឬរឿងកំប្លែង។
- នៅពេល ដែលមានវេទិកាជាច្រើនដែលប្រើប្រាស់សម្រាប់ប្រាស្រ័យទាក់ទងគ្នាតាមអនឡាញ ទាំងផ្លូវការ និងក្រៅផ្លូវការ យើងកត់សម្គាល់ឃើញថា វេទិកាអនឡាញមួយចំនួនត្រូវគេប្រើប្រាស់សម្រាប់ការទំនាក់ទំនងផ្លូវការដូចជា ជាមួយនិយោជក ហើយកម្មវិធីផ្សេងទៀតសម្រាប់ទំនាក់ទំនងក្រៅផ្លូវការ ដូចជាជាមួយមិត្តភ័ក្តិនិងក្រុមគ្រួសារជាដើម។ យើងនឹងសិក្សាមេរៀនដាច់ដោយឡែកមួយទៀតស្តីពីសារៈសំខាន់នៃវេទិកា (Platform) អ្នកប្រើប្រាស់ និងសុវត្ថិភាព។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៤៖ អត្តសញ្ញាណកម្មឌីជីថល និងកេរ្តិ៍ឈ្មោះអនឡាញ

**រយៈពេល ៖** ៦០នាទី

សំណួរគន្លឹះ៖ ដោយផ្អែកលើព័ត៌មានរបស់អ្នកនៅលើអនឡាញ តើអ្នកគិតថាអ្នកដទៃនឹងយល់ឃើញពីអ្នកបែបណា?

## លទ្ធផលសិក្សា៖

- សិស្សចេះពិចារណាអំពីអ្វីដែលត្រូវឱ្យតម្លៃ និងអ្វីដែលសំខាន់។
- សិស្សយល់ដឹងអំពីរបៀបដែលព័ត៌មានសាធារណៈតាមអនឡាញ ជួយឱ្យអ្នកដទៃយល់ដឹងពីអ្នក។
- សិស្សចេះកំណត់ព័ត៌មានដែលពួកគេចង់បង្ហាញ នៅពេល នរណាម្នាក់ចង់ស្វែងរកឈ្មោះរបស់ពួកគេ។

## សម្ភារៈ ធនធាន និងការរៀបចំ៖

- សិស្សពិភាក្សាជាដៃគូ ឬក្រុមតូច
- ក្រដាសទទេ
- ប៊ិក ឬខ្មៅដៃ
- ផ្ដល់ឱ្យសិស្សនូវបញ្ជីសន្ទានុក្រមសម្រាប់មេរៀននេះ។
- **សកម្មភាពជម្រើស៖** តម្រូវឱ្យមានកុំព្យូទ័រ និងអ៊ីនធឺណិតសម្រាប់សិស្សប្រើប្រាស់។

## ដំណើរការបង្រៀន

**រំលឹកមេរៀន៖** (១០នាទី)

(ចំណាំ៖ សកម្មភាពនេះជួយគ្រូឱ្យយល់ដឹងពីកម្រិតចំណេះដឹងពីមុនរបស់សិស្ស។)

## សួរសិស្ស

- នៅពេល ដែលយើងនិយាយពីអត្តសញ្ញាណកម្មគឺសំដៅទៅលើ អ្នកជានរណា បុគ្គលិកលក្ខណៈជំនឿ និងគុណតម្លៃ ជំនាញ ចំណាប់អារម្មណ៍ និងចំណូលចិត្តរបស់អ្នក។ ប៉ុន្តែសូមចាំថាយើងក៏មានអត្តសញ្ញាណកម្មអនឡាញដែរ ដែលយើងហៅថាអត្តសញ្ញាណកម្មឌីជីថល។
- សូមចំណាយពេល ២នាទី និងសរសេរ ១០ចំណុចសំខាន់ៗ ដែលតំណាងឱ្យអត្តសញ្ញាណកម្មរបស់អ្នក។ សូមធ្វើកិច្ចការនេះជាបុគ្គល។ អ្នកមិនចាំបាច់ចែករំលែកចំណុចទាំងនេះក្នុងក្រុម។
- ឥឡូវនេះធ្វើការជាដៃគូ តើមានចំណុចចំនួនប៉ុន្មានដែលអ្នកអាចចែករំលែក៖
  - ជាមួយមិត្តរបស់អ្នក សូមសរសេរអក្សរ F នៅក្បែរនោះ

    - ជាមួយគ្រូបង្រៀន/និយោជក/ប្រធាន សូមសរសេរអក្សរ X នៅក្បែរនោះ
    - ហើយជាមួយមនុស្សចម្លែក សូមសរសេរអក្សរ S នៅក្បែរនោះ
- ព័ត៌មានទាំងអស់ដែលអ្នកបញ្ចូល បង្ហោះ និងចែករំលែក នៅពេល អ្នកកំពុងប្រើអ៊ីនធឺណិតជួយបង្កើតអត្តសញ្ញាណកម្មឌីជីថលរបស់អ្នក។ ប្រសិនបើអ្នកចែករំលែកចំណុចទាំង ១០ នេះនៅលើអនឡាញ អ្នកត្រូវដឹងថា ចំណុចអត្តសញ្ញាណកម្មទាំងនោះនឹងលេចឡើងនៅលើអនឡាញ។
- បន្ទាប់មក យើងនឹងពិភាក្សាពីអំពីរបៀបដែលព័ត៌មានសាធារណៈតាមអនឡាញ ជួយឱ្យអ្នកដទៃយល់ដឹងពីអ្នក។

**ការពិភាក្សាជាក្រុមធំ** (១០នាទី) សិស្សយល់ដឹងអំពីរបៀបដែលព័ត៌មានសាធារណៈតាមអនឡាញ ជួយឱ្យអ្នកដទៃយល់ដឹងពីអ្នក។

**សួរសិស្ស៖** សូមធ្វើការជាក្រុមតូច លើកឡើងបីចំណុច ដែលអាចបង្កើតអត្តសញ្ញាណកម្មឌីជីថលរួចហើយសរសេរនៅលើក្រដាសទទេដែលបានផ្តល់ជូន។

    - ចំណុចដែលលើកឡើងអាចរួមមាន អ្វីដែលពួកគេបង្ហោះ ឬចែករំលែកនៅលើអនឡាញ ដូចជា រឿងរ៉ាវថ្មី (New Stories) ទិដ្ឋភាពបែបកំប្លែង (Memes) ការបង្ហោះជាអត្ថបទ ព្រមទាំងព័ត៌មានដែលពួកគេ ជ្រើសរើសដើម្បីចែករំលែកតាមអនឡាញ (ឧទាហរណ៍៖ ប្រវត្តិរូបក្នុងប្រព័ន្ធផ្សព្វផ្សាយសង្គម លេខទូរសព្ទរបស់ពួកគេ ។ល។)
- ទុកពេល ៥នាទី ធ្វើការជាក្រុមដើម្បីពិភាក្សា បន្ទាប់មកចែករំលែកក្នុងក្រុមធំ។
    - រាល់ពេល ដែលអ្នកចូលប្រើអ៊ីនធឺណិត ហើយបង្ហោះ ឬបញ្ចូលព័ត៌មានអ្វីមួយ អ្នកបន្សល់ទុកដានសម្គាល់។
    - ឧទាហរណ៍៖ នៅពេល ដែលអ្នកដើរលើដី ឬភក់ អ្នកអាចឃើញដានជើងរបស់អ្នក ហើយអ្នកកំពុងទុកដាននោះនៅពីក្រោយអ្នក។ ពេល ខ្លះដានទាំងនោះមិនអាចលុបបានទេ។
    - ចំណុចនេះមានន័យថា សកម្មភាពណាមួយនៅលើអនឡាញបន្សល់ទុកនូវដានមួយ ដោយអាស្រ័យលើរបៀបដែលអ្នកគ្រប់គ្រងព័ត៌មានរបស់អ្នក។
    - បន្ទាប់មកយើងនឹងពិភាក្សាពីព័ត៌មានអ្វី ដែលអ្នកចង់បង្ហាញនៅពេល នរណាម្នាក់ស្វែងរកឈ្មោះរបស់អ្នក។

**សកម្មភាពក្នុងថ្នាក់** (១៥នាទី)សិស្សចេះកំណត់ព័ត៌មានដែលពួកគេចង់បង្ហាញនៅពេល នរណាម្នាក់ចង់ស្វែងរកឈ្មោះរបស់ពួកគេ។

- សូមណែនាំ កញ្ញាសោភា (មនុស្សតំណាង) សួស្តីសោភា! កញ្ញាសោភា ទើបតែបានចូលប្រឡូកក្នុងពិភពអនឡាញ។ គោលបំណងរបស់យើង គឺជួយនាងធ្វើដំណើរតាមពិភពអនឡាញរបស់នាង។ តស់មកស្គាល់កញ្ញាសោភា។

**សរសេរព័ត៌មាននេះនៅលើក្តារខៀន៖**

    - នាងមានអាយុ ១៩ឆ្នាំ ហើយនាងកំពុងសិក្សាជំនាញគិលានុបដ្ឋាក។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- នាងមកពីទីក្រុងសិរីសោភ័ណ ហើយនាងចូលចិត្តច្រៀងចម្រៀង។
- គ្រួសាររបស់នាងបានចិញ្ចឹមនាង និងប្អូនប្រុសរបស់នាងសុផា ពួកគេស្និទ្ធស្នាលគ្នាខ្លាំងណាស់ ព្រោះសុផា អាយុក្មេងជាងនាងតែ ២ឆ្នាំ ប៉ុណ្ណោះ។
- ពេលទំនេរនាងចូលចិត្តមើលភាពយន្ត។

**សួរសិស្ស៖**

- កញ្ញាសោភា ក៏មានអត្តសញ្ញាណកម្មអនឡាញ ដែលជាអត្តសញ្ញាណកម្មឌីជីថល។ តើអ្នកគិតថាអត្តសញ្ញាណកម្មឌីជីថលមានសណ្ឋានដូចម្ដេច? សូមចាំថា អ្វីដែលនាងជ្រើសរើសធ្វើតាមអនឡាញ (ឧទាហរណ៍៖ ចែករំលែក បង្ហោះ) ឬអ្វីដែលនាងធ្វើលើអ៊ីនធឺណិត នឹងបង្កើតបានជាអត្តសញ្ញាណកម្មឌីជីថលរបស់នាង។
- សូមធ្វើការជាក្រុមតូចរយៈពេល ៥នាទី សរសេរចំណុចទាំងអស់ដែល កញ្ញាសោភា ធ្វើនៅលើអនឡាញ ដោយផ្អែកលើព័ត៌មានដែលអ្នកបានដឹងកន្លងមក។
- សូមសរសេរចម្លើយរបស់អ្នកនៅលើក្រដាសទទេដែលបានផ្ដល់ឱ្យ។ យើងនឹងត្រឡប់មកជុំគ្នាវិញដើម្បីពិភាក្សានៅក្នុងថ្នាក់។ ចម្លើយរំពឹងទុក៖
  - ការស្រាវជ្រាវពីមុខរបរជាគិលានុបដ្ឋាយិកា
  - ទីកន្លែង (ភោជនីយដ្ឋាន) ច្រៀងចម្រៀង
  - អំណោយខួបកំណើត ឬថ្ងៃបុណ្យឈប់សម្រាកសម្រាប់ប្អូនប្រុសនាង
  - ការបញ្ចាំងភាពយន្តក្នុងស្រុក ឬម៉ោងបញ្ចាំងភាពយន្ត
  - ភាពយន្តកំពុងពេញនិយមនៅលើ Netflix
  - មហោស្រពភាពយន្ត

**សួរសិស្ស៖**

- ហេតុអ្វីអ្នកត្រូវរក្សាអត្តសញ្ញាណកម្មឌីជីថលរបស់អ្នកឱ្យមានសុវត្ថិភាព? ស្រមៃថាព័ត៌មានទាំងអស់ដែលអ្នកទើបតែបានសរសេរអំពី កញ្ញាសោភា ត្រូវបានរក្សាទុកជាឯកសារជាក់ស្ដែង ហើយស្រមៃពីអ្នកផ្សេងក៏អាចមើលឯកសារនោះដែរ។
- តើអ្នកនឹងជ្រើសរើសវិធីផ្សេងឬទេ ប្រសិនបើអ្នកដឹងថាសកម្មភាពរបស់អ្នកមិនមានឯកជនភាព? សូមផ្ដល់ពេលវេលាឱ្យសិស្សឆ្លើយតប។

**សកម្មភាពសិស្ស** (១៥នាទី ) សិស្សចេះកំណត់ព័ត៌មានដែលពួកគេចង់បង្ហាញ នៅពេល នរណាម្នាក់ចង់ស្វែងរកឈ្មោះរបស់ពួកគេ។

**សួរសិស្ស៖** អ្វីដែលអ្នកនឹងចែករំលែកអំពីខ្លួនអ្នកនៅលើអនឡាញ និងអ្វីដែលអ្នកនឹងរក្សាឯកជនភាព។ ជំហានដំបូងត្រូវកំណត់អត្តសញ្ញាណមនុស្សដែលអ្នកតែងតែមានទំនាក់ទំនងជាមួយ ឬអ្នកដែលអាចចូលប្រើព័ត៌មានរបស់អ្នក។ សូមធ្វើការជាក្រុមតូច រយៈពេល ២នាទី ហើយពិចារណាសំណួរខាងក្រោម៖

- ○ តើអ្នកនឹងប្រាប់ឈ្មោះអ្នកទៅកាន់មិត្តភ័ក្តិរបស់អ្នកឬទេ?
- ○ តើអ្នកនឹងប្រាប់អាសយដ្ឋានផ្ទះអ្នកទៅកាន់មិត្តភ័ក្តិរបស់អ្នកឬទេ?
- ○ តើអ្នកនឹងប្រាប់អាថ៌កំបាំងអ្នកទៅកាន់មិត្តភ័ក្តិរបស់អ្នកឬទេ?
- សូមចែករំលែកចម្លើយក្នុងក្រុមធំ។
- **សួរសិស្ស៖** ឥឡូវនេះ ចូរគិតពីអ្នកដទៃដែលអ្នកឃើញញឹកញាប់ ហើយសួរខ្លួនឯងនូវសំណួរខាងក្រោម។ សូមធ្វើការជាក្រុមតូចរយៈពេល ២នាទី ពិភាក្សាសំណួរខាងក្រោម៖
    - ▪ តើអ្នកនឹងឈរនៅមុខថ្នាក់រៀន ឬការិយាល័យមួយ ដែលអ្នកស្គាល់មនុស្សខ្លះៗ (ប៉ុន្តែមិនមែនគ្រប់គ្នា) តើអ្នកនឹងប្រាប់ឈ្មោះ ថ្ងៃខែឆ្នាំកំណើត និងអាសយដ្ឋានរបស់អ្នកទៅពួកគេឬទេ?
- ចែករំលែកចម្លើយនៅក្នុងក្រុមធំ។
- **ការឆ្លុះបញ្ចាំងចុងក្រោយ៖** ជាចុងក្រោយ សូមគិតពីវិធីប្រើប្រាស់អ៊ីនធឺណិតផ្ទាល់ខ្លួនរបស់អ្នក។ សូមធ្វើការជាក្រុមតូច គិតអំពីព័ត៌មានដែលអ្នកចែករំលែក ហើយពិចារណាថា តើការបង្ហោះរបស់អ្នកអាចប៉ះពាល់ដល់អ្នកដទៃយល់ច្រឡំ ឬប៉ះពាល់ដល់កេរ្តិ៍ឈ្មោះរបស់អ្នក ឬអ្នកផ្សេងឬទេ?
- ទុកពេល ឱ្យសិស្ស ៨នាទី ពិភាក្សាក្នុងក្រុមតូច បន្ទាប់មកពិភាក្សាជាក្រុមធំរយៈពេល ២នាទី។

**ពង្រឹងពុទ្ធិ** (១០នាទី)- សង្ខេបមេរៀនដែលផ្តោតលើចំណុចទាំងនេះ។

- នៅពេលដែលយើងចង់ចែករំលែកអ្វីមួយតាមអនឡាញ សូមពិចារណាពីគុណតម្លៃ និងអ្នកប្រើប្រាស់របស់អ្នកព្រោះវាជួយអ្នកឱ្យកំណត់ព័ត៌មាន ដែលអ្នកមានទំនុកចិត្តសម្រាប់ចែករំលែក និងអ្វីដែលមិនត្រូវចែករំលែកជាមួយអ្នកដទៃ។
- ក្នុងពេលដែលបច្ចេកវិទ្យាថ្មីៗកំពុងរីកចម្រើន ព័ត៌មានសាធារណៈតាមអនឡាញអាចរីកចម្រើនយ៉ាងឆាប់រហ័សសាយភាយដល់ទស្សនិកជនថ្មីៗ និងផ្តល់ជាការយល់ឃើញរបស់អ្នកដទៃចំពោះអ្នក។
- សូមគិតអំពីព័ត៌មានឯកជនណាមួយដែលអ្នកចង់បង្ហាញលើអនឡាញ នៅពេលនរណាម្នាក់ស្វែងរកឈ្មោះរបស់អ្នក ជាពិសេសព័ត៌មានទាក់ទងនឹងភាពអាម៉ាស់។ ព័ត៌មានប្រភេទនេះស្ថិតនៅលើអនឡាញវាអាចបង្កការពិបាកខ្លាំងលើការគ្រប់គ្រងទស្សនិកជនដែលឃើញខ្លឹមសារនេះ។
- នៅពេលដែលអ្នកចែករំលែកព័ត៌មានលើអនឡាញ (សូម្បីតែផ្ទាល់ជាមួយមនុស្សម្នាក់ ដូចជា ព័ត៌មាន ឬសារសម្ងាត់) អ្នកត្រូវតែគិតពីលទ្ធភាពដែលព័ត៌មាននេះអាចគេចែករំលែកលើសពីទស្សនិកជនដែលអ្នកចង់ឱ្យមើលឃើញ។
- ហេតុផលមួយទៀតដែលត្រូវគិតអំពីអត្តសញ្ញាណកម្មឌីជីថលរបស់អ្នក គឺ ព័ត៌មានមួយចំនួនដែលអ្នកបង្ហោះតាមអនឡាញអាចបង្ហាញជាសាធារណៈតាមការរុករកអនឡាញ។ ព័ត៌មានទាំងនោះរួមមាន៖ រូបភាព គណនីប្រព័ន្ធផ្សព្វផ្សាយសង្គម សាលារៀនរបស់អ្នក ការងារ និងនិយោជករបស់អ្នក រឿងថ្មីៗ និងសហគមន៍ ឬក្រុមបណ្តាញសង្គមរបស់អ្នក។
- មនុស្សដែលអ្នកជួបអាចប្រើម៉ាស៊ីនស្វែងរកដើម្បីទទួលបានព័ត៌មានបន្ថែមពីអ្នក។ អ្វីដែលគេរកឃើញ ល្អឬអាក្រក់ នឹងប៉ះពាល់ដល់អ្វីដែលគេគិតពីអ្នក។ ប្រសិនបើអ្នកចង់គ្រប់គ្រងការយល់ឃើញរបស់ពួកគេលើអ្នក អ្នកត្រូវដឹងពីព័ត៌មានដែលពួកគេអាចនឹងមើលឃើញ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- មនុស្សទាំងនោះរួមមាននិយោជកនាពេលអនាគត និងមន្ត្រីចុះឈ្មោះចូលរៀននៅតាមសាលារៀន មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ។ មន្ត្រីចុះឈ្មោះចូលរៀនអាចនឹងមិនជូនដំណឹងដល់អ្នកដាក់ពាក្យ ថាតើពួកគេពិនិត្យព័ត៌មានរបស់អ្នកដាក់ពាក្យតាមអនឡាញ ឬប្រើប្រាស់ព័ត៌មានដើម្បី សម្រេចចិត្ត។

**សកម្មភាពជម្រើស៖**

ប្រសិនបើសិស្សមានចាប់អារម្មណ៍ ឬនៅសល់ពេល សូមឱ្យពួកគេស្វែងរកឈ្មោះរបស់ពួកគេនៅក្នុង ម៉ាស៊ីនស្វែងរក ឬប្រសិនបើជាថ្នាក់ទាំងមូល អាចសម្រេចឱ្យពួកគេស្វែងរកបុគ្គលល្បី នៅក្នុងម៉ាស៊ីនស្វែងរក។

សួរសិស្សនូវសំណួរខាងក្រោម ហើយពិភាក្សាជាក្រុម៖

- តើពួកគេបានរកឃើញអ្វី?
- តើអ្នកភ្ញាក់ផ្អើលនឹងព័ត៌មានដែលបានរកឃើញឬទេ?
- តើមនុស្សច្រើននាក់ទៀតមានឈ្មោះដូចនឹងពួកគេឬទេ?
- តើអ្នកដែលមិនស្គាល់ពួកគេអាចមានចំណាប់អារម្មណ៍អ្វីខ្លះពេល ឃើញលទ្ធផលទាំងនេះ?

ទុកពេល ១០-១៥នាទី ពិភាក្សានៅក្នុងថ្នាក់។

# មេរៀនទី៥៖ ភាពជាពលរដ្ឋឌីជីថល និងសារៈសំខាន់

**រយៈពេល ៖** ៤៥នាទី

**សំណួរគន្លឹះ៖** តើពលរដ្ឋឌីជីថលមានន័យយ៉ាងដូចម្ដេច?

**លទ្ធផលសិក្សា៖**

- សិស្សកំណត់ និងបង្ហាញសារៈសំខាន់ អំពីភាពជាពលរដ្ឋឌីជីថល។
- សិស្សកំណត់អត្ថប្រយោជន៍ និងទំនួលខុសត្រូវ ក្នុងភាពជាសមាជិកសហគមន៍អនឡាញ។
- សិស្សអភិវឌ្ឍការយល់ដឹងអំពីអត្ថន័យនៃ ភាពជាពលរដ្ឋឌីជីថល និងសារៈសំខាន់នៅក្នុងពិភពអនឡាញ។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- ក្រដាសទទេ
- ប៊ិក ឬខ្មៅដៃ
- បែងចែកសិស្សពិភាក្សាជាដៃគូ ឬក្រុមតូច
- ផ្ដល់បញ្ជីសន្ទានុក្រមសម្រាប់មេរៀននេះដល់សិស្ស។

**ដំណើរការបង្រៀន**

**រំលឹកមេរៀន៖** (១០នាទី) **ចំណាំ៖** សកម្មភាពនេះជួយគ្រូឱ្យយល់ដឹងពីកម្រិតចំណេះដឹងពីមុនរបស់សិស្ស។

- **សួរសិស្ស៖** សូមសរសេរនិយមន័យនៃភាពជាពលរដ្ឋ និងសុខុមាលភាពឌីជីថលនៅលើក្ដារខៀន (សូមមើលបញ្ជីសន្ទានុក្រម)។ តើភាពជាពលរដ្ឋឌីជីថលមានន័យយ៉ាងណាចំពោះអ្នក?
    - សូមធ្វើការជាក្រុមតូច រយៈពេល ពីរនាទី ដោយអាននិយមន័យ និងជ្រើសរើសពាក្យពីនិយមន័យដែលបានផ្ដល់ឱ្យដែលពួកគេគិតថាពន្យល់បានល្អបំផុតអំពីអត្ថន័យនៃភាពជាពលរដ្ឋឌីជីថល និងពន្យល់បកស្រាយជម្រើសរបស់ពួកគេ។
        - **ឧទាហរណ៍៖** ការយល់ចិត្ត ពាក្យនេះពិពណ៌នាបានល្អបំផុតពីភាពជាពលរដ្ឋឌីជីថល ពីព្រោះអ្នកមានទំនាក់ទំនងជាមួយមនុស្សផ្សេងគ្នាជាច្រើនតាមអនឡាញ ហើយត្រូវយល់ថាពួកគេជានរណា និងយល់អារម្មណ៍របស់ពួកគេដើម្បីក្លាយជាពលរដ្ឋឌីជីថល។
    - ចែករំលែកចម្លើយក្នុងក្រុម។
    - ផ្អែកលើការពិភាក្សា និងនិយមន័យដែលបានផ្ដល់ឱ្យ តើសិស្សបង្កើតនិយមន័យផ្ទាល់ខ្លួនអំពីភាពជាពលរដ្ឋឌីជីថលមានន័យយ៉ាងណាចំពោះពួកគេ?
    - ចែករំលែកឧទាហរណ៍មួយ ឬពីរ។
    - បន្ទាប់មក យើងពិនិត្យមើលអត្ថប្រយោជន៍ និងទំនួលខុសត្រូវក្នុងភាពជាសមាជិកសហគមន៍អនឡាញ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**ការពិភាក្សាក្រុម (១៥នាទី)** សិស្សកំណត់អត្ថប្រយោជន៍ និងទំនួលខុសត្រូវ ក្នុងភាពជាសមាជិកសហគមន៍អនឡាញ។

- **សួរសិស្ស៖** ផ្អែកលើការពិភាក្សារបស់យើង និងនិយមន័យដែលបានផ្ដល់ជូនអំពី ភាពជាពលរដ្ឋឌីជីថល តើមានអត្ថប្រយោជន៍ និងទំនួលខុសត្រូវអ្វីខ្លះ ក្នុងភាពជាសមាជិកសហគមន៍អនឡាញ?
- **ឧទាហរណ៍៖** អត្ថប្រយោជន៍មួយ គឺអ្នកទទួលបានទំនាក់ទំនងជាមួយមនុស្សមកពីជុំវិញពិភពលោក ដូច្នេះអ្នកត្រូវមានទំនួលខុសត្រូវចំពោះការគោរពទស្សនៈរបស់អ្នកដទៃ។
- ទុកពេល ៥នាទីឱ្យក្រុមនីមួយៗគិត និងពិភាក្សា។ បន្ទាប់មក ឱ្យក្រុមនីមួយៗ ឡើងបកស្រាយនៅក្នុងថ្នាក់។ ចម្លើយរំពឹងទុក៖
  - ការអភិវឌ្ឍបំណិនជាប្រចាំ
  - មានសិទ្ធអំណាចប្រើប្រាស់បច្ចេកវិទ្យាសម្រាប់អំពើល្អ
  - ស្គាល់អ្វីជាអង្គហេតុ និងការប្រឌិត
  - កសាងទំនាក់ទំនងល្អ
  - រក្សាសុវត្ថិភាព
  - ចេះកំណត់តុល្យភាព និងសុខុមាលភាពពេលវេលាប្រើប្រាស់ឧបករណ៍អេឡិចត្រូនិក
  - ដឹកនាំដោយការយល់ចិត្ត និងចេះប្រាស្រ័យទាក់ទងគ្នា ដោយពហុវប្បធម៌
  - គោរពទស្សនៈអ្នកដទៃ
  - គិតឱ្យបានល្អិតល្អន់អំពីរបៀបដែលអ្នក និងអ្នកដទៃចូលរួមចំណែកក្នុងសង្គម និងធ្វើការរួមគ្នាដើម្បីឈានទៅមុខជាវិជ្ជមាន ទាំងក្នុង និងក្រៅបណ្ដាញអនឡាញ។
- បន្ទាប់មកយើងនឹងពិភាក្សាអំពីអត្ថប្រយោជន៍ និងទំនួលខុសត្រូវនៃភាពជាពលរដ្ឋឌីជីថល។

**សកម្មភាពក្នុងថ្នាក់** (១៥នាទី)

សិស្សអភិវឌ្ឍការយល់ដឹងអំពីអត្ថន័យនៃ ភាពជាពលរដ្ឋឌីជីថល និងសារៈសំខាន់នៅក្នុងពិភពអនឡាញ។

**សួរសិស្ស៖** សូមធ្វើការជាក្រុមតូចសរសេរហេតុផល ២-៣ចំណុច អំពីអត្ថប្រយោជន៍ និងទំនួលខុសត្រូវរបស់ភាពជាពលរដ្ឋឌីជីថល។

- **ឧទាហរណ៍៖** ភាពជាពលរដ្ឋឌីជីថលមានសារៈសំខាន់ ពីព្រោះសហគមន៍អនឡាញមិនខុសពីសហគមន៍ផ្ទាល់នោះទេ ដូច្នេះគេត្រូវចេះប្រព្រឹត្តដោយការគោរព និងសេចក្ដីថ្លៃថ្នូរ។
- ចម្លើយរំពឹង៖
  - សហគមន៍អនឡាញគឺជាកន្លែងសម្រាប់លើកកម្ពស់ភាពជាពលរដ្ឋសកម្ម
  - សហគមន៍អនឡាញគឺជាកន្លែងស្វែងរកគុណតម្លៃផ្ទាល់ខ្លួន
  - សហគមន៍អនឡាញគឺជាកន្លែងសម្រាប់បង្កើតបណ្ដាញ
  - សហគមន៍អនឡាញគឺជាកន្លែងស្វែងរកការគាំទ្រមតិ និងលើកកម្ពស់ការយល់ដឹង
  - សហគមន៍អនឡាញគឺជាកន្លែងស្រាវជ្រាវ និងស្វែងរកព័ត៌មានពិត

**ពង្រឹងពុទ្ធិ** ( **៥នាទី** ) សង្ខេបមេរៀនដែលផ្ដោតលើចំណុចទាំងនេះ។

- ភាពជាពលរដ្ឋឌីជីថលមានសារៈសំខាន់ក្នុងការរក្សាសហគមន៍អនឡាញឱ្យមានសុវត្ថិភាព និងការគោរព។
- អត្ថប្រយោជន៍ និងទំនួលខុសត្រូវក្នុងភាពជាពលរដ្ឋឌីជីថលល្អរួមមាន៖ ការអភិវឌ្ឍបំណិនជាប្រចាំលើការប្រើប្រាស់បច្ចេកវិទ្យាប្រកបដោយការទទួលខុសត្រូវ និងផ្ដល់សិទ្ធិអំណាច។ បំណិនទាំងនេះរួមមាន៖ ការជួយមនុស្សឱ្យស្គាល់អង្គហេតុ និងការប្រឌិត បង្កើតទំនាក់ទំនងល្អ រក្សាសុវត្ថិភាព ស្វែងរកសុខុមាលភាពកាន់តែប្រសើរឡើង បង្កើតភាពធន់ ដឹកនាំដោយការយល់ចិត្ត ការប្រាស្រ័យទាក់ទងបែប ពហុវប្បធម៌ គោរពទស្សនៈអ្នកដទៃ គិតពិចារណាស៊ីជម្រៅដើម្បីចូលរួមចំណែកដល់សង្គម និងធ្វើការរួមគ្នាដើម្បីបង្កើតវឌ្ឍនភាពជាវិជ្ជមាន ទាំងក្នុង និងក្រៅបណ្ដាញអនឡាញ។
- ពលរដ្ឋឌីជីថលបន្តរីកចម្រើន និងអភិវឌ្ឍការយល់ដឹងអំពីអត្ថន័យនៃភាពជាពលរដ្ឋឌីជីថល និងសារៈសំខាន់នៅក្នុងពិភពអនឡាញ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ម៉ូឌុល ២៖

# មូលដ្ឋានគ្រឹះឌីជីថល

[កម្មវិធីសិក្សាដែលមានភាពបត់បែន សិស្សដែលមានអាយុ ១៣-១៨ឆ្នាំ]

**គន្លឹះ៖**

| | |
|---|---|
| | ទទួលបានមាតិកាឌីជីថល |
| | ឱកាសក្នុងការផ្លាស់ប្តូរតាមអ្នកប្រើប្រាស់ឌីជីថល |
| | ឱកាសធ្វើមូលដ្ឋានីយកម្ម (Localization) |

## មាតិកា


មេរៀនទី១៖ ការណែនាំអំពីឯកជនភាព.................................................................................... 27

មេរៀនទី២៖ ឯកជនភាព និងអ្នក............................................................................................ 31

មេរៀនទី៣៖ ពាក្យសម្ងាត់ ..................................................................................................... 38

មេរៀនទី៤៖ វាយប្រហារសាធារណៈ ......................................................................................... 49

មេរៀនទី៥៖ សុវត្ថិភាពតាមអ៊ីនធឺណិត ការលួចបន្លំ និងសារឥតបានការ .................................. 57



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# មេរៀនទី១៖ ការណែនាំអំពីឯកជនភាព

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ ៖** នៅក្នុងបរិបទឌីជីថល តើ "ឯកជនភាព" មានន័យយ៉ាងណាចំពោះអ្នក?

**វត្ថុបំណងមេរៀន៖**

- សិស្សនឹងស្វែងយល់ពីឯកជនភាព និងផលប៉ះពាល់ដែលមានលើជីវិតផ្ទាល់ខ្លួនរបស់ពួកគេ។
- សិស្សនឹងពិចារណាអំពីប្រភេទព័ត៌មានជាក់លាក់ដែលពួកគេចង់រក្សាទុកផ្ទាល់ខ្លួន និងបរិបទបែបណាដែលពួកគេនឹងចែករំលែក ឬមិនចង់ចែករំលែក។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- សៀវភៅណែនាំ "ល្បែងសិក្សាឯកជនភាព"
- បោះពុម្ពសន្លឹកកិច្ចការសម្រាប់សិស្សម្នាក់ៗ

**តើ "ឯកជនភាព" មានន័យយ៉ាងណាចំពោះអ្នក?**

**ល្បែងសិក្សាឯកជនភាព**

**សកម្មភាពក្នុងថ្នាក់**

ចែកសន្លឹកកិច្ចការ "ល្បែងសិក្សាឯកជនភាព"។

**ប្រាប់សិស្សរបស់អ្នក**

អ្នកធ្វើការសម្រេចចិត្តអំពីឯកជនភាពរបស់អ្នកជារៀងរាល់ថ្ងៃ ជាពិសេសនៅពេល អ្នកអនឡាញ និងប្រើទូរសព្ទចល័ត ឬឧបករណ៍ឌីជីថលផ្សេងទៀត។ ជារឿយៗអ្នកប្រហែលជាមិនចំណាយពេលច្រើន ក្នុងការគិតអំពីការសម្រេចចិត្តទាំងនេះទេ។ ប៉ុន្តែការសម្រេចចិត្តទាំងនេះបង្កើនចំណេះដឹងអ្នកអំពីឯកជនភាព។ ឯកជនភាពគឺជា សមត្ថភាពក្នុងការគ្រប់គ្រងអ្វីដែលអ្នកដទៃដឹងអំពីអ្នក។ អ្នកអាចធ្វើវាបានដោយនិយាយរឿងខ្លះអំពីខ្លួនអ្នក (ដូចជាប្រាប់អ្នកដទៃអំពីអាសយដ្ឋានរបស់អ្នក ឬអ្វីដែលអ្នកចូលចិត្តធ្វើដើម្បីកំសាន្ត) ឬធ្វើរឿងជុំវិញអ្នកដទៃ (ដូចជាទៅហាងជាមួយមិត្តភ័ក្តិ និងជ្រើសរើសអ្វីដែលអ្នកចង់បានបំផុត)។

ឯកជនភាពមានសារៈសំខាន់ មិនថាអ្នកនៅក្នុងបន្ទប់ជាមួយមនុស្សផ្សេងទៀត ឬនិយាយជាមួយពួកគេតាមអ៊ីនធឺណិតទេ។ ឯកជនភាពគឺផ្អែកលើការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នក។ ការយល់ឃើញអំពីឯកជនភាពរបស់អ្នក និងគ្រួសារអ្នកអាចមានន័យខុសគ្នាពីការយល់ឃើញរបស់អ្នកដទៃ។ ប្រសិនបើយើងដឹងកាន់តែច្រើនអំពីអ្វីដែលយើងឱ្យតម្លៃជាឯកជន និងរបៀបដែលយើងប្រើប្រាស់អ៊ីនធឺណិត អាចកំណត់ឯកជនភាពរបស់យើង ហើយយើងនឹងអាចជ្រើសរើសបានប្រសើរជាងមុនអំពីប្រភេទឯកជនភាពដែលយើងចង់បាន។

ឥឡូវនេះយើងនឹងចូលរួមលេងល្បែងសិក្សាអំពីឯកជនភាព (សូមមើលសន្លឹកកិច្ចការ "ល្បែងសិក្សាឯកជនភាព") ដែលនឹងជួយអ្នកពិចារណាពីរបៀបដែលអ្នកគិត និងយល់អំពីឯកជនភាព។ អ្នកនឹងបំពេញ

សន្លឹកកិច្ចការរបស់អ្នក។ អ្នកកាន់សន្លឹកកិច្ចការដើរក្នុងបន្ទប់ ហើយណែនាំខ្លួនអ្នកទៅកាន់អ្នកផ្សេងទៀត បន្ទាប់មក សួរគ្នាទៅវិញទៅមកអំពីព័ត៌មានដែលមាននៅលើសន្លឹកកិច្ចការ។ កុំបង្ហាញសន្លឹកកិច្ចការរបស់អ្នកទៅអ្នកផ្សេងទៀត។ សន្លឹកកិច្ចការនឹងមិនត្រូវបានប្រមូលនៅចុងបញ្ចប់នៃសកម្មភាពទេ អ្នកអាចយកវាទៅផ្ទះ ឬបោះវាចោល។

នៅក្នុងការសន្ទនានីមួយៗសិស្សត្រូវតែចែករំលែកចម្លើយយ៉ាងហោចណាស់បី ចំពោះសំណួរដែលសិស្សផ្សេងសួរ សិស្សអាចជ្រើសរើសការចែករំលែកច្រើនជាងបី។ សិស្សក៏អាចជ្រើសរើសព័ត៌មានបី ឬច្រើនដែលពួកគេចង់ចែករំលែក។ តើព័ត៌មានប៉ុន្មានដែលសិស្សម្នាក់ៗនឹងចែករំលែក? តើព័ត៌មានអ្វីខ្លះដែលសិស្សម្នាក់ៗនឹងចែករំលែក? តស់ៗចាប់ផ្តើមដើរ និងជជែក!

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សបំពេញសន្លឹកកិច្ចការ បន្ទាប់មកទុកពេល ១៥នាទី ដើម្បីឱ្យសិស្សសួរសំណួរគ្នា ទៅវិញទៅមក។ បន្ទាប់មកសូមចូលរួមក្នុងការពិភាក្សាជាមួយក្រុមទាំងមូល ដោយប្រើសំណួរខាងក្រោម នៅចុងបញ្ចប់ត្រូវប្រាកដថាសិស្សទាំងអស់បានបោះចោលនូវសន្លឹកកិច្ចការរបស់ពួកគេ ឬយកវាទៅជាមួយ។ ក្នុងនាមជា អ្នកអប់រំ កុំប្រមូលសន្លឹកកិច្ចការទាំងនោះ។

## ការពិភាក្សា

### គ្រូសួរទៅសិស្ស

- តើមានព័ត៌មានពិតណាមួយដែលអ្នកមិនបានចែករំលែកជាមួយនរណាម្នាក់ទេ? ព័ត៌មានអ្វី? ហេតុអ្វី?
- តើព័ត៌មានពិតណាខ្លះដែលអ្នកបានចែករំលែក? ហេតុអ្វី?
- តើអ្នកទាំងអស់គ្នាបានគិតដូចគ្នាដែរឬទេ អំពីអ្វីដែលចង់ចែករំលែក? ហេតុអ្វី?
- អាស្រ័យលើមនុស្សដែលអ្នកចែករំលែកជាមួយ ហេតុអ្វីបានជាអ្នកអាចចែករំលែកព័ត៌មានប្រភេទនេះបានច្រើន ឬតិច? តើអ្នកនឹងចែករំលែកវានៅពេលណា?
- តើមានអ្វីខ្លះដែលអ្នកបានចែករំលែកក្នុងអំឡុងពេល សកម្មភាពនេះ ប៉ុន្តែមិនបានចែករំលែកជាមួយអ្នករាល់គ្នាដែលអ្នកស្គាល់? ហេតុអ្វី?
- តើព័ត៌មានប្រភេទនេះជាសាធារណៈ ឬឯកជន? ហេតុអ្វី? តើវាដូចគ្នាសម្រាប់មនុស្សគ្រប់គ្នាឬទេ?

និយាយ

### ប្រាប់សិស្សរបស់អ្នក

ដូចដែលអ្នកទើបតែបានឮ មនុស្សបានធ្វើការសម្រេចចិត្តខុសៗគ្នាអំពីអ្វីដែលត្រូវចែករំលែក និងអ្វីដែលមិនគួរចែករំលែក។ ពួកគេក៏មានហេតុផលផ្សេងៗសម្រាប់ជម្រើសរបស់ពួកគេផងដែរ។ អ្វីដែលយើងទើបតែធ្វើគឺជាល្បែងសិក្សាមួយ។ ប៉ុន្តែយើងធ្វើការសម្រេចចិត្ត ដូចគ្នានេះជារៀងរាល់ថ្ងៃក្នុងការរស់នៅ។ យើងសម្រេចចិត្ត ថាតើត្រូវបង្ហោះរូបថតជាក់លាក់នៅលើបណ្តាញសង្គមឬអត់។ យើងសម្រេចចិត្តថាតើយើងចង់បាន ឬមិនចង់បានព័ត៌មានទំនាក់ទំនងជាក់លាក់ ដូចជាអាសយដ្ឋានអ៊ីមែលរបស់យើងមានជាសាធារណៈ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

នៅលើគណនីបណ្ដាញសង្គមរបស់យើង។ អ្វីដែលយើងសម្រេចចិត្តអាចខុស ពីអ្វីដែលមិត្តល្អរបស់យើងសម្រេចចិត្ត ឬសូម្បីតែអ្វីដែលយើងបានសម្រេចចិត្តកាលពីខែមុន។ ទោះបីជាយើងធ្វើការសម្រេចចិត្តដូចគ្នានៅចំណុចពីរផ្សេងគ្នាក្នុងពេលវេលាណាក៏ដោយ ហេតុផលរបស់យើងអាចនឹងខុសគ្នា។ ការសម្រេចចិត្ត និងហេតុផលផ្សេងៗទាំងនេះ តំណាងឱ្យការយល់ដឹងផ្ទាល់ខ្លួនរបស់យើងអំពីឯកជនភាព។

និយាយឱ្យសាមញ្ញ ឯកជនភាពសំដៅលើរបៀបដែលយើងជ្រើសរើសដើម្បីគ្រប់គ្រងព័ត៌មានអំពីខ្លួនយើង។ ព័ត៌មាននេះអាចរួមបញ្ចូលផ្នែកនៃអត្តសញ្ញាណសកម្មភាព ចំណូលចិត្ត ទម្លាប់ និងទិដ្ឋភាពផ្សេងទៀតនៃជីវិតរបស់យើង។ នៅក្នុងពិភពឌីជីថលនាពេល បច្ចុប្បន្ននេះអ្នកមានឱកាសកាន់តែច្រើនជាងមុនក្នុងការចែករំលែកព័ត៌មានអំពីខ្លួនអ្នកជាមួយអ្នកដទៃ។ ដូច្នេះវាជារឿងសំខាន់ដែលយើងត្រូវដឹងអំពីឯកជនភាព ហើយយើងពេញចិត្តនឹងការយល់ដឹងនោះដែរឬទេ។

### ? សួរសិស្សរបស់អ្នក

- ដោយផ្អែកលើសកម្មភាពរបស់អ្នកនៅក្នុងល្បែងសិក្សាឯកជនភាព ក៏ដូចជាសកម្មភាពរបស់អ្នកនៅក្នុងជីវិតប្រចាំថ្ងៃ តើអ្នកនឹងកំណត់ឯកជនភាពដោយរបៀបណា? ហេតុអ្វី?
- តើព័ត៌មានឯកជនទាំងអស់ជាអាថ៌កំបាំងដែរឬទេ?

ឧទាហរណ៍៖ ថ្ងៃកំណើតរបស់អ្នក អាចមិនមែនជាអាថ៌កំបាំងដូចកំណត់ហេតុប្រចាំថ្ងៃរបស់អ្នកទេ។ មនុស្សជាច្រើននៅលើពិភពលោកដែលដឹងថ្ងៃខែឆ្នាំកំណើតរបស់អ្នក និងមនុស្សដែលត្រូវដឹងពីវា ដូចជាឪពុកម្ដាយ/អាណាព្យាបាល ឬគ្រូពេទ្យរបស់អ្នក។ ប៉ុន្តែដោយសារតែអ្វីមួយមិនមែនជាការសម្ងាត់អ្នកនៅតែអាចយល់ថា វាជាឯកជន។ យើងភាគច្រើនមិនចង់ឱ្យមនុស្សគ្រប់គ្នាដឹងពីថ្ងៃខែឆ្នាំកំណើតរបស់យើងទេ ព្រោះយើងយល់ថាវា ជាព័ត៌មានដែលមានតែមនុស្សជិតស្និទ្ធ ឬមនុស្សដែលមានហេតុផលជាក់លាក់ដើម្បីដឹងព័ត៌មាននេះ។ ប្រភេទ នៃការសម្រេចចិត្តអំពីអ្នកណាដែលគួរដឹងអ្វីមួយអំពីយើង ពេលណា និងហេតុអ្វី គឺជាគន្លឹះនៃឯកជនភាព។

### ? សួរសិស្សរបស់អ្នក៖

- តើមានរឿងអ្វីទៀតដែលមិនមែនជាអាថ៌កំបាំង តែអ្នកនៅតែចង់រក្សាឯកជនភាពពីមនុស្សដែលអ្នកមិនស្គាល់ច្បាស់/មនុស្សដែលអ្នកទើបតែបានជួប? ឧទាហរណ៍៖ លេខទូរសព្ទ អ៊ីមែល រូបថត វីដេអូ។ល។
- តើមានព័ត៌មានអ្វីខ្លះដែលអ្នកអាចលាក់បាំងពីឪពុកម្ដាយ/អាណាព្យាបាល ឬមិត្តភ័ក្តិ គ្រូបង្រៀន ឬអ្នកអប់រំផ្សេងទៀត? ឧទាហរណ៍៖ លទ្ធផលនៅសាលារៀន គណនី (Instagram) របស់អ្នក កំណត់ហេតុប្រចាំថ្ងៃ របស់អ្នក។
- តើអ្នកបានយល់ដឹងអ្វីខ្លះអំពីឯកជនភាពដែលធ្វើឱ្យអ្នកភ្ញាក់ផ្អើល?

**កិច្ចការ៖**

និយាយ

## ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះយើងនឹងស្វែងយល់ពីចំណេះដឹងរបស់អ្នកអំពីឯកជនភាពបន្ថែមទៀត។

1. ស្វែងរកឧទាហរណ៍បីនៅលើអនឡាញដែលមានគេចែករំលែក ឬបង្ហោះអ្វីមួយដែលអ្នកចង់រក្សាទុកវាជាឯកជន។ ទាំងនេះអាចមកពីតារាល្បីៗ ឥស្សរជននយោបាយ អ្នកដឹកនាំអាជីវកម្ម ឬអ្នកអាចស្វែងរកដោយ (hashtag) ឬតាមរយៈការស្វែងតាមអនឡាញដោយចៃដន្យ។ សូមព្យាយាមស្វែងរកធនធានឱ្យបានច្រើន (ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះដែលផ្តែកលើអត្ថបទដូចជា មតិយោបល់នរណាម្នាក់លើប្រព័ន្ធផ្សព្វផ្សាយសង្គម និងវេទិកាប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន) លើប្រធានបទផ្សេងៗ។
2. សម្រាប់ឧទាហរណ៍នីមួយៗ សូមសរសេរកថាខណ្ឌមួយ ដែលពិពណ៌នាអំពីមូលហេតុដែលអ្នកនឹងជ្រើសរើសរក្សាព័ត៌មាននេះជាឯកជន។

នៅក្នុងកថាខណ្ឌរបស់អ្នក សូមពន្យល់ពីគំនិតផ្ទាល់ខ្លួនរបស់អ្នក ក្នុងការចែករំលែកព័ត៌មាននេះដែលប្រែប្រួលតាមបរិបទឧទាហរណ៍ អ្នកប្រាស្រ័យទាក់ទងចំនួនមនុស្សដែលចូលរួមក្នុងទំនាក់ទំនង គោលបំណង និងគោលដៅ និងបរិយាកាស (ក្នុង និងក្រៅសាលា)។

**កិច្ចការ៖**

កិច្ចការនេះធ្វើនៅក្នុងថ្នាក់ ជាកិច្ចការផ្ទះ។ ខ្លឹមសារនេះរៀបចំឡើងដោយក្រុមហ៊ុនមេតា (Facebook) ហើយបច្ចុប្បន្ន រួមបញ្ចូលការរៀនសូត្រដែលទាញចេញពីយុវជន និងប្រព័ន្ធផ្សព្វផ្សាយ នៅមជ្ឈមណ្ឌល Berkman Klein For Internet and Society នៅសាកលវិទ្យាល័យ Harvard ក្រោមអាជ្ញាប័ណ្ណ Creative Commons Attribution-ShareAlike 4.0 International។ អ្នកអាចប្រើប្រាស់វារួមទាំងការចម្លង និងរៀបចំស្នាដៃចម្លង មិនថាជាពាណិជ្ជកម្ម ឬមិនមែនពាណិជ្ជកម្ម ដរាបណាអ្នកចាត់ទុកយុវជន និងប្រព័ន្ធផ្សព្វផ្សាយជា ប្រភពដើម ហើយធ្វើតាមលក្ខខណ្ឌផ្សេងទៀតនៃអាជ្ញាប័ណ្ណ ចែករំលែកការងារបន្ថែមទៀតក្រោមលក្ខខណ្ឌដូចគ្នា។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# មេរៀនទី២៖ ឯកជនភាព និងអ្នក

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើអ្នកសម្រេចចិត្តយ៉ាងណាថាព័ត៌មានណាខ្លះត្រូវចែករំលែក (ឬមិនចែករំលែក) តាមអនឡាញ ហើយអ្នកត្រូវចែករំលែកជាមួយអ្នកណា?
- តើបណ្ដាញសង្គមដើរតួនាទីអ្វីខ្លះ នៅក្នុងជម្រើសរបស់អ្នក?

**វត្ថុបំណងមេរៀន៖**

សិស្សនឹងស្វែងយល់ថាតើព័ត៌មានប្រភេទណាខ្លះដែលត្រូវរក្សាទុកជា "ឯកជនភាព" របៀបប្ដូរការកំណត់ឯកជនភាពតាមបណ្ដាញសង្គម និងពន្យល់ពីការសម្រេចចិត្ត ជ្រើសរើសការកំណត់របស់ពួកគេ ឧទាហរណ៍៖ ហេតុអ្វីបានជាព័ត៌មាននោះត្រូវកំណត់ទៅជា "មិត្តភ័ក្តិតែប៉ុណ្ណោះដែលអាចមើលឃើញ" នឹងការកំណត់ទៅជា "សាធារណៈ (អ្នកណាក៏អាចមើលឃើញ) "។

**សម្ភារៈ ធនធាន និងការរៀបចំ**

- "ល្បែងទស្សន៍ទាយ" សន្លឹកកិច្ចការ
- បោះពុម្ពសន្លឹកកិច្ចការសម្រាប់សិស្ស

## ល្បែងទស្សន៍ទាយ

**ផ្នែកទី ១**

**សកម្មភាពក្នុងថ្នាក់៖**

ចែកសន្លឹកកិច្ចការ "ល្បែងទស្សន៍ទាយ" ឱ្យសិស្សបំពេញ។ ឱ្យសិស្សជ្រើសរើសព័ត៌មានចំនួន៤ ដើម្បីចែករំលែកហើយអនុញ្ញាតឱ្យពួកគេចែករំលែកព័ត៌មាន ដែលពួកគេសរសេរក្នុងថ្នាក់។ ណែនាំឱ្យរក្សាសន្លឹកទីពីរ។

ផ្ដល់ឱ្យសិស្ស ១០នាទី ដើម្បីបំពេញឯកសារ។ បន្ទាប់មកប្រមូលសន្លឹកកិច្ចការ។

និយាយ

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះគ្រូនឹងអានព័ត៌មាននៅលើសន្លឹកកិច្ចការនីមួយៗ។ ដោយប្រើផ្នែកនៃការទស្សន៍ទាយ ដើម្បីសរសេរ ការទាយរបស់អ្នកអំពីសិស្សណាម្នាក់ដែលបានបំពេញក្នុងសន្លឹកកិច្ចការ។

**សកម្មភាពក្នុងថ្នាក់៖**

បន្ទាប់ពីឆ្លងកាត់ផ្ញើសន្លឹកកិច្ចការរួចរៀបចំក្រុមដើម្បីពិភាក្សា។

### សួរសិស្សរបស់អ្នក

- តើមានព័ត៌មានអ្វីខ្លះដែលអ្នកមិនបានចែករំលែកជាមួយនរណាម្នាក់? ព័ត៌មានណាមួយ? ហេតុអ្វី?
- តើអ្នកទាំងអស់គ្នាបានគិតដូចគ្នាដែរឬទេ អំពីអ្វីដែលចង់ចែករំលែក? ហេតុអ្វី?
- អាស្រ័យលើមនុស្សដែលអ្នកចែករំលែកជាមួយ ហេតុអ្វីបានជាអ្នកអាចចែករំលែកព័ត៌មានប្រភេទនេះបានច្រើន ឬតិច? តើអ្នកនឹងចែករំលែកវានៅពេលណា?
- តើវាងាយស្រួលប៉ុណ្ណាក្នុងការភ្ជាប់ព័ត៌មាននីមួយៗទៅកាន់អ្នកដែលសរសេរ ឬនិយាយវា?
- តើមានករណីណាខ្លះដែលការឆ្លើយតប ដែលបានផ្តល់ឱ្យអាចបង្ហាញដោយអចេតនានូវអ្វី ដែលលើសពីការ ឆ្លើយតបពិតប្រាកដ (ឧទាហរណ៍៖ នរណាម្នាក់បានបង្ហាញពីអាហារដែលពួកគេចូលចិត្ត ដែលអាចផ្តល់ ការចង្អុលបង្ហាញខ្លះថា មនុស្សនេះស្គាល់វប្បធម៌មួយណា)?
- តើអ្នកគិតថាអ្នកផ្សេងអាចនឹងធ្វើការសន្មតអ្វីខ្លះអំពីអ្នក ប្រសិនបើអ្នកបានចែករំលែកព័ត៌មាន ដែលជាផ្នែកមួយនៃល្បែងទស្សន៍ទាយជាមួយពិភពលោក?

## ផ្នែកទី ២៖

និយាយ

### ប្រាប់សិស្សរបស់អ្នក

ឯកជនភាពគឺជា សមត្ថភាពក្នុងការគ្រប់គ្រងអ្វីដែលអ្នកដទៃដឹងអំពីអ្នក។ អ្នកអាចធ្វើវាបានដោយនិយាយរឿងខ្លះអំពីខ្លួនអ្នក (ដូចជាប្រាប់អ្នកដទៃ អំពីអាសយដ្ឋានរបស់អ្នក ឬអ្វីដែលអ្នកចូលចិត្តធ្វើដើម្បីកម្សាន្ត) ឬធ្វើរឿងជុំវិញអ្នកដទៃ (ដូចជាទៅហាងជាមួយមិត្តភ័ក្តិ និងជ្រើសរើសអ្វីដែលអ្នកចង់បានបំផុត)។

ឯកជនភាពមានសារៈសំខាន់ មិនថាអ្នកនៅក្នុងបន្ទប់ជាមួយមនុស្សផ្សេងទៀត ឬនិយាយជាមួយពួកគេតាមអ៊ីនធឺណិតទេ។ ឯកជនភាពគឺផ្អែកលើការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នក។ ការយល់ឃើញអំពី ឯកជនភាពរបស់អ្នក និងគ្រួសារអ្នកអាចមានន័យខុសគ្នាពីការយល់ឃើញរបស់អ្នកដទៃ។ ប្រសិនបើយើង ដឹងកាន់តែច្រើនអំពីអ្វីដែលយើងឱ្យតម្លៃជាឯកជន និងរបៀបដែលយើងប្រើប្រាស់អ៊ីនធឺណិត អាចកំណត់ឯកជនភាពរបស់យើង ហើយយើងនឹងអាចជ្រើសរើសបានប្រសើរជាងមុន អំពីប្រភេទឯកជនភាពដែលយើងចង់បាន។ ឯកជនភាពក៏ផ្លាស់ប្តូរផងដែរ អាស្រ័យលើប្រភេទ ព័ត៌មានដែលកំពុងចែករំលែក នឹងជាមួយអ្នកណា ដែលវាត្រូវបានចែករំលែក។



youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### សួរសិស្សរបស់អ្នក៖

ឧទាហរណ៍ តើអ្នកនឹងចែករំលែកអាសយដ្ឋានផ្ទះរបស់អ្នកជាមួយ៖

- ឪពុកម្តាយ/អ្នកមើលថែ ឬមនុស្សពេញវ័យផ្សេងៗទៀតនៅក្នុងគ្រួសាររបស់អ្នក ?
- មិត្តភ័ក្តិ ?
- គ្រូបង្រៀន ?
- មនុស្សចម្លែក/អ្នកមិនស្គាល់ច្បាស់ ?
- មិត្តភ័ក្តិរបស់មិត្តភ័ក្តិអ្នក ?
- អង្គការ ឬក្រុមហ៊ុន ?

សង្ខេប

### ប្រាប់សិស្សរបស់អ្នក

នៅពេលអ្នកចែករំលែកព័ត៌មាន នៅលើអនឡាញរឿងសំខាន់អ្នកត្រូវពិចារណាថាតើអ្នកណាអាចឃើញព័ត៌មាននោះ ឬព័ត៌មានរបស់អ្នកណាម្នាក់ដែលត្រូវបានចែករំលែកថាពួកគេមានទំនុកចិត្តក្នុងការចែករំលែក ព័ត៌មាននោះជាមួយនឹងអ្នកដទៃ។ ព័ត៌មានខ្លះអាចមានផលអាក្រក់នៅពេលអនាគត ប្រសិនបើវាត្រូវបានចែករំលែកទៅមនុស្សមិនល្អ។ ប្រសិនបើជនចម្លែក ឬអ្នកមិនស្គាល់ច្បាស់ដឹងថាអ្នករស់នៅទីណានោះគាត់ អាចមកផ្ទះរបស់អ្នក ដែលអាចបង្កគ្រោះថ្នាក់។ ភាគតិច ឬច្រើននៅទីកន្លែងផ្សេងៗគ្នានៃពិភពលោក ហានិភ័យ (និងគ្រោះថ្នាក់ដែលអាចកើតមាន) អាចនឹងកើតឡើងពិតប្រាកដ។ ដើម្បីទទួលស្គាល់ជម្រើសឯកជនភាព ដែលនឹងរក្សាសុវត្ថិភាពអ្នក អ្នកត្រូវយល់ពី ឥទ្ធិពលនៃការចែករំលែកព័ត៌មាន។

## ការពិភាក្សា ការទំនាក់ទំនងខុស

### ប្រាប់សិស្សរបស់អ្នក

ពិភាក្សាគ្នាពីអ្វីដែលយើងនិយាយនៅក្នុងសារជាអក្សរ យើងនិយាយរបៀបណា និងភាពខុសគ្នាពីការប្រាស្រ័យទាក់ទងគ្នាដោយផ្ទាល់។

### សួរសិស្សរបស់អ្នក

- តើការនិយាយក្នុងសារជាអក្សរអាចខុសពីការនិយាយផ្ទាល់ដោយរបៀបណា ?
- ចម្លើយរំពឹងទុក៖ ប្រសិនបើអ្នកមិនឃើញប្រតិកម្មរបស់បុគ្គលនោះ អ្នកប្រហែលជាមិនដឹងថាពួក គេមានអារម្មណ៍យ៉ាងណាចំពោះអ្វីដែលអ្នកបាននិយាយនោះទេ។ អ្នកអាចនឹងប៉ះពាល់ដល់អារម្មណ៍ របស់នរណាម្នាក់ដោយមិនដឹងខ្លួន។

និយាយ

### ប្រាប់សិស្សរបស់អ្នក

នៅពេល និយាយជាមួយនរណាម្នាក់ទល់មុខគ្នា អ្នកអាចសង្កេតមើលប្រតិកម្មរបស់ពួកគេនៅពេលអ្នកនិយាយរួមទាំងភាសាសញ្ញា និងសំឡេង។ បរិបទមួយចំនួនត្រូវបានបាត់បង់នៅពេល ទំនាក់ទំនងតាម អនឡាញ។ យ៉ាងណាមិញការប្រាស្រ័យទាក់ទងគ្នាតាមអនឡាញ អ្នកអាចទទួលបានព័ត៌មានបរិបទប្រភេទផ្សេងទៀត ដែលអាចជួយក្នុងការទំនាក់ទំនង (ឧទាហរណ៍ វេទិកានីមួយៗអាចមានបទដ្ឋានជាក់លាក់ដែលផ្តល់ឱ្យអ្នកនូវការ យល់ដឹង កាន់តែប្រសើរឡើងទាក់ទងនឹងរបៀបដែលព័ត៌មានត្រូវបានបកស្រាយ)។

?

### សួរសិស្សរបស់អ្នក

- ប្រសិនបើអ្នកមិនមានការសង្កេត (ឧទាហរណ៍ ភាសាសញ្ញា សំឡេង) នេះអាចនាំឱ្យ សារជាអក្សររបស់អ្នក ឬសារអនឡាញផ្សេងទៀតត្រូវបានយល់ខុសដោយអ្នកទទួល (ឧទាហរណ៍ រឿងកំប្លែងអាចត្រូវបានគេយល់ខុស និងធ្វើឱ្យប៉ះពាល់ដល់អារម្មណ៍របស់នរណាម្នាក់)?
- ប្រសិនបើអ្នកត្រូវបានគេយល់ខុសនៅក្នុងការសន្ទនាដោយផ្ទាល់ តើអ្នកនឹងធ្វើអ្វីដើម្បីកែប្រែការយល់ខុសនោះ (ឧទាហរណ៍ អ្នកអាចសុំទោស ឬពន្យល់ពីអ្វីដែលអ្នកកំពុងតែព្យាយាមនិយាយ)? តើវាអាចខុសគ្នាយ៉ាងណា (ឧទាហរណ៍ ពិបាក ឬងាយជាង) តាមសារជាអក្សរ?

## តើអ្នកណាជាអ្នកគាំទ្ររបស់អ្នក?

### ផ្នែកទី១

និយាយ

### ប្រាប់សិស្សរបស់អ្នក

ខណៈពេល ដែលយើងមិនអាចបិទបាំង ពីការតាមដានទិន្នន័យពីសកម្មភាពអនឡាញរបស់យើងមានវិធីមួយចំនួនដែលយើងអាចគ្រប់គ្រងឯកជនភាព និងគ្រប់គ្រងកេរ្តិ៍ឈ្មោះអនឡាញរបស់យើង។ នៅលើបរិបទបណ្តាញសង្គមតែងតែមានការរួមបញ្ចូលការកំណត់ទៅក្នុងវេទិកា ដែលអនុញ្ញាតឱ្យយើងជ្រើសរើសអ្នកដែលអាចមើលឃើញអ្វីដែលយើងបានបង្ហោះ។ ទោះបីជាការកែតម្រូវការកំណត់ទាំងនោះក៏ដោយវាមិនរាំងស្ទះនូវការវិភាគរួមបញ្ចូលការវិភាគទិន្នន័យមេតា ឧទាហរណ៍៖ ភាគីទីបី (អ្នកផ្សាយពាណិជ្ជកម្ម អ្នកស្រាវជ្រាវ ឬក្រុមហ៊ុន) រួមទាំងវេទិកាខ្លួនឯងយើងអាចកំណត់អោយអ្នកប្រើប្រព័ន្ធផ្សព្វផ្សាយ សង្គមផ្សេងទៀតអាចឃើញ ឬព័ត៌មានដែលក្រុមហ៊ុន ឬអ្នកផ្សាយពាណិជ្ជកម្មអាចចូលប្រើបាន។

សម្រាប់អ្នកដែលចង់ដឹង ចង់ឃើញទិន្នន័យមេតា (Metadata) គឺជាទិន្នន័យមូលដ្ឋានពីទិន្នន័យ។ ទិន្នន័យមេតាអាចរួមបញ្ចូល ប៉ុន្តែមិនមានការកំណត់ចំពោះអ្វីៗដូចជា ពេលវេលា និងទីតាំងរបស់អ្នកពេល ចូលទៅប្រើបណ្តាញសង្គម និងព័ត៌មានអំពីការតភ្ជាប់អ៊ីនធឺណិតរបស់អ្នក។ ការកំណត់ឯកជនភាពមានភាពខុសគ្នានៅលើបណ្តាញសង្គមនីមួយៗ ប៉ុន្តែវាជួយយើងកំណត់បានចំពោះអ្នកដែលអាចមើលឃើញព័ត៌មានរបស់យើង។ ឧទាហរណ៍៖ ការកំណត់អាចអនុញ្ញាតឱ្យការបង្ហោះរបស់យើងជាសាធារណៈទាំងស្រុង អាចមើល

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ឃើញតែមិត្តភ័ក្តិរបស់មិត្តភ័ក្តិ និងកំណត់ចំពោះតែមិត្តភ័ក្តិរបស់នរណាម្នាក់ហើយជួនកាលអាចមើលឃើញតែចំពោះមិត្តដែលបានជ្រើសរើស មួយចំនួនប៉ុណ្ណោះ។ មុខងារផ្សេងទៀតដែលការកំណត់ទាំងនេះអាចប៉ះពាល់រួមមាន ទិន្នន័យទីតាំង និងការអនុញ្ញាតការចែករំលែក។ ខូគី (Cookie)ទាំងអស់ ដែលមានគោលដៅសម្រាប់ការការផ្សាយពាណិជ្ជកម្ម និងបញ្ចប់ការស្វែងរក អាចត្រូវបានបិទនៅលើសេវាកម្មភាគច្រើនតាមរយៈការផ្លាស់ប្តូរមួយចំនួន នៅក្នុង ជម្រើស/ការកំណត់នៅលើសេវាកម្មនីមួយៗ។ វាមានផ្នែកបន្ថែមនៃកម្មវិធីរុករក និងសេវាកម្មឌីជីថលផ្សេងទៀត ដែលអាចរកបានក្នុងការជួយ ពង្រឹងការការពារឯកជនភាពរបស់អ្នកនៅពេលអ្នកផ្លាស់ប្តូរពីវេបសាយមួយទៅមួយ (ឧទាហរណ៍ ផ្នែកបន្ថែមឯកជនភាព "កុំតាមដាន" ពី Electronic Frontier Foundation)។

## <u>ផ្នែកទី២</u>

### សកម្មភាពក្នុងថ្នាក់

ចែកសិស្សជាដៃគូ

### ?  សួរសិស្សរបស់អ្នក

សូមចំណាយពេល មួយនាទី ដើម្បីគិតពីបណ្តាញសង្គម ដែលម្នាក់ៗមានគណនី។ តើអ្នកដឹងថាការកំណត់ឯកជនភាពបច្ចុប្បន្នរបស់អ្នកមានអ្វីខ្លះនៅលើបណ្តាញសង្គមនីមួយៗ?

## <u>សកម្មភាពក្រុម</u>

### និយាយ  ប្រាប់សិស្សរបស់អ្នក

ចូរស្វែងយល់ពីមុខងារនៃការកំណត់ទាំងនេះដែលអាចធ្វើបាន និងស្វែងរកថាតើមុខងារមួយណាដែលសមស្របបំផុតក្នុងស្ថានភាព និងវេទិកាមួយណា។ សូមចូលទៅកាន់វេទិកាបណ្តាញសង្គមដែលអ្នកប្រើប្រាស់ និងពិនិត្យមើលការកំណត់ឯកជនភាពរបស់អ្នក។ ជាធម្មតា ការកំណត់ឯកជនភាពអាចត្រូវបានរកឃើញនៅក្នុងគណនីរបស់អ្នក ហើយវេទិកាមួយចំនួនមានបន្ថែមមុខងារពិសេសសម្រាប់ពិនិត្យមើលឯកជនភាពរបស់អ្នកផងដែរ។

បន្ទាប់ពីពិនិត្យមើលការកំណត់ឯកជនភាពរបស់អ្នករួចរាល់ សូមនិយាយជាមួយដៃគូពីការកំណត់ទាំងនេះ។ ហេតុអ្វីបានជាអ្នកត្រូវតែកំណត់ឯកជនភាពតាមវិធីបែបនោះ? តើការកំណត់ឯកជនភាពពេល ខ្លះទាក់ទងទៅនឹងបរិបទដែរឬទេ? (ឧទាហរណ៍៖ ការកំណត់ជាក់លាក់គឺត្រឹមត្រូវក្នុងករណីមួយ ប៉ុន្តែមិនចាំបាច់ក្នុងករណីផ្សេងទៀតទេ) តើអ្នកធ្លាប់ផ្លាស់ប្តូរការកំណត់របស់អ្នកទេ? តើអ្នកផ្លាស់ប្តូរពួកវាញឹកញាប់ប៉ុណ្ណា? ហេតុអ្វី? ត្រូវប្រាកដថា អ្នកកំពុងមើលទាំងការកំណត់ឯកជនភាព ដែលទាក់ទងនឹងការចែករំលែកព័ត៌មានជាមួយមនុស្ស ផ្សេងគ្នានៅលើវេទិកា ក៏ដូចជាព័ត៌មានដែលបង្ហាញពីចំនួនទិន្នន័យនៅលើវេទិកានោះ

និងភាគីទីបីដែលពាក់ព័ន្ធ (ដូចជាអ្នកផ្សាយពាណិជ្ជកម្ម) អាចទទួលបាន។ ទាំងអស់នេះជាកត្តាសំខាន់នៃការគ្រប់គ្រងឯកជនភាពឌីជីថលរបស់អ្នក សម្រាប់មនុស្សដែលអ្នកមិនស្គាល់ច្បាស់ មិត្តភ័ក្តិ គ្រួសារ និងក្រុមហ៊ុន។

## ការពិភាក្សា

### សួរសិស្សរបស់អ្នក

- តើគណនីទាំងអស់របស់អ្នក បានកំណត់ជាសាធារណៈ ឯកជន ឬអ្វីផ្សេងទេ? តើអ្នកសម្រេចចិត្តដោយរបៀបណាលើការកំណត់នេះ? តើការកំណត់ឯកជនភាពបច្ចុប្បន្នរបស់អ្នកដូចអ្វីដែលអ្នកចង់បានទេ?
- តើនៅពេលណាគួរតែចែករំលែកជាសាធារណៈ ហើយពេលណាដែលយើងគួររក្សាឯកជនភាព?
- តើអ្នកចង់ចែករំលែកព័ត៌មាន របស់អ្នកជាមួយនឹងបណ្តាញសង្គមដែលអ្នកប្រើ ឬក្រុមហ៊ុនផ្សាយពាណិជ្ជកម្មនៅលើវេទិកាទាំងនេះទេ? ហេតុអ្វី?
- តើការសន្ទនានេះធ្វើឱ្យអ្នកផ្លាស់ប្តូរការគិតអំពីការកំណត់ឯកជនភាពរបស់អ្នកទេ? ហេតុអ្វី?

## កិច្ចការ

### ប្រាប់សិស្សរបស់អ្នក

យើងបាននិយាយអំពីឯកជនភាពរួចហើយ អ្វីដែលមនុស្សអាចយល់បានដោយផ្អែកលើខ្លឹមសារដែលយើងចែករំលែក របៀបដែលមនុស្សយល់ពីសារអក្សរផ្សេងៗគ្នា ហើយហេតុអ្វីបានជាការកំណត់អាចជាឧបករណ៍មានប្រយោជន៍ដើម្បីសម្រេច ថាតើអ្វីដែលអ្នកចង់ចែករំលែកទៅកាន់នរណាម្នាក់ សូមអនុវត្តអ្វីដែលអ្នកទើបតែរៀន។ ក្នុងរយៈពេល ៣០នាទី បន្ទាប់ ចូរអ្នកឆ្លុះបញ្ចាំងលើសេណារីយ៉ូ ទាំងបីខាងក្រោម ព្រមទាំងសរសេរការឆ្លើយតបខ្លីសម្រាប់សេណារីយ៉ូនីមួយៗ៖

បុប្ផា មានអាយុ ១៣ឆ្នាំ នាងទើបតែចាប់ផ្តើមរៀនច្រៀង។ នាងមានអារម្មណ៍ថាមិនទាន់ពូកែទេប៉ុន្តែចង់ចែករំលែកចំណង់ចំណូលចិត្តថ្មីជាមួយមិត្តភ័ក្តិ និងទទួលបានយោបល់ពីពួកគេ។ នាងពិចារណាបង្ហោះវីដេអូខ្លះនៃការច្រៀងចម្រៀងដែលនាងចូលចិត្តលើបណ្តាញសង្គម។ តើវេទិកាប្រភេទណាដែលអ្នកនឹងណែនាំនាង? តើអ្នកគិតថាការកំណត់ឯកជនភាពបែបណាដែលល្អសម្រាប់វេទិកានោះ? សូមពន្យល់ពីមូលហេតុ។

ចិត្រា មានអាយុ ១៦ឆ្នាំ ហើយគាត់ចូលចិត្តធ្វើម្ហូប និងបង្កើតមុខម្ហូបថ្មីៗ។ គាត់បានធ្វើម្ហូបជាច្រើនមុខពីសាច់មាន់ ដែលធ្វើឱ្យគាត់សប្បាយចិត្តយ៉ាងខ្លាំង ហើយគាត់ចង់ចែករំលែករូបមន្តទាំងនេះជាមួយមិត្តភ័ក្តិ និងមនុស្សផ្សេងទៀត ដែលចាប់អារម្មណ៍ក្នុងការធ្វើម្ហូប។ តើវេទិកាប្រភេទណាដែលអ្នកនឹងណែនាំគាត់? តើអ្នកគិតថា ការកំណត់ឯកជនភាពបែបណាដែលល្អសម្រាប់វេទិកានោះ? សូមពន្យល់ពីមូលហេតុ។

រដ្ឋា មានអាយុ ១៨ឆ្នាំ ហើយនាងចង់ស្វែងរកការងារនៅខែក្រោយ។ នាងដឹងថានិយោជកត្រូវការប្រវត្តិរូប ប៉ុន្តែនាងមិនច្បាស់ពីរបៀបសរសេរឱ្យមានប្រសិទ្ធភាព។ នាងចាប់អារម្មណ៍ការងារក្នុងវិស័យ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ព័ត៌មានវិទ្យា ប៉ុន្តែនាងមិនដឹងថាមានការងារអ្វីសមស្របនឹងនាងទេ ហើយតើនាងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់មុខតំណែងនោះដែរឬទេ។ នាងចង់បានដំបូន្មាន ឬអនុសាសន៍ពីអ្នកដទៃ ដែលមានចាប់អារម្មណ៍ស្រដៀងគ្នា ប៉ុន្តែនាងមិនស្គាល់នរណាម្នាក់ធ្វើការក្នុងវិស័យព័ត៌មានវិទ្យាទេ។ តើវេទិកាប្រភេទណាដែលអ្នកនឹងណែនាំនាង? តើអ្នកគិតថាការកំណត់ឯកជនភាពបែបណាដែលល្អសម្រាប់វេទិកានោះ? សូមពន្យល់ពីមូលហេតុ។

### កិច្ចការ

ប្រសិនបើអាចធ្វើបាន នៅពេល ដែលអ្នកប្រជុំជាក្រុមម្តងទៀត សូមឱ្យសិស្សបែងចែកជាដៃគូដូចគ្នា ហើយអនុញ្ញាតឱ្យគូនីមួយៗចែករំលែកការឆ្លុះបញ្ចាំងពីកិច្ចការរបស់ពួកគេ។ ផ្តល់ពេលដល់សិស្ស ៣០នាទី ដើម្បីបញ្ចប់កិច្ចការនេះ។ កិច្ចការនេះអាចធ្វើនៅក្នុងថ្នាក់ ឬជាកិច្ចការផ្ទះ។

# មេរៀនទី៣៖ ពាក្យសម្ងាត់

**រយៈពេល** ៦០នាទី

**សំណួរគន្លឹះ**

- តើពាក្យសម្ងាត់អាចរក្សាព័ត៌មានរបស់អ្នកឱ្យមានសុវត្ថិភាពដល់កម្រិតណា ?

**វត្ថុបំណងមេរៀន**

សិស្ស នឹងរៀនពីរបៀបរក្សាព័ត៌មានអនឡាញរបស់ពួកគេឱ្យកាន់តែមានសុវត្ថិភាព ដោយប្រើ និងរក្សាពាក្យសម្ងាត់រឹងមាំ។ សិស្សនឹងសិក្សាអំពីគោលការណ៍នៃការបង្កើតពាក្យសម្ងាត់ដែលមានសុវត្ថិភាពខ្ពស់ និងបញ្ហាដែលអាចកើតមានក្នុងការចែករំលែកពាក្យសម្ងាត់។ ពួកគេនឹងរៀនពីរបៀបរក្សាពាក្យសម្ងាត់ឱ្យមានសុវត្ថិភាព និងរបៀបការពារពីការចូលប្រើគណនីរបស់ពួកគេដោយគ្មានការអនុញ្ញាត។

**សម្ភារៈ ធនធាន និងការរៀប**

- សន្លឹកកិច្ចការ "រៀនអំពីពាក្យសម្ងាត់"
- ចែកសន្លឹកកិច្ចការឱ្យសិស្ស

**មូលដ្ឋានគ្រឹះពាក្យសម្ងាត់**

**ផ្នែកទី១**

និយាយ

**ប្រាប់សិស្សរបស់អ្នក**

ជារឿយៗយើងមិនគិតច្រើនអំពីពាក្យសម្ងាត់ដែលយើងប្រើសម្រាប់វេបសាយ កម្មវិធី និងសេវាកម្មទេ។ ប៉ុន្តែពាក្យសម្ងាត់រឹងមាំរបស់អ្នក នឹងកំណត់ថាព័ត៌មានរបស់អ្នកមានសុវត្ថិភាពកម្រិតណា។

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សពិភាក្សាដោយប្រើសំណួរខាងក្រោម។ សូមរំលឹកសិស្សថាវាជារឿងសំខាន់ណាស់ ដែលមិនត្រូវចែករំលែកពាក្យសម្ងាត់ពិតប្រាកដរបស់ពួកគេក្នុងអំឡុងពេលនេះ ឬលំហាត់ផ្សេងទៀតណាមួយឡើយ។

**សួរសិស្សរបស់អ្នក**

- តើអ្នកមានពាក្យសម្ងាត់ចំនួនប៉ុន្មាន ?
- តើអ្នកមានពាក្យសម្ងាត់ខុសគ្នាសម្រាប់គណនីអ៊ីមែលនិងបណ្តាញសង្គមនីមួយៗរបស់អ្នកដែរឬទេ ?
- តើពួកវាខុសគ្នាខ្លាំង ឬជាភាពផ្សេងគ្នានៃពាក្យសម្ងាត់តែមួយ ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ប្រសិនបើអ្នកមានពាក្យសម្ងាត់ច្រើនជាងមួយ តើអ្នកចាំថាមួយណាជាគណនីមួយណា ?
- ជារឿយៗ តើអ្នកភ្លេចពាក្យសម្ងាត់សំខាន់ប៉ុន្មានដង ?
- តើអ្នកបានធ្វើដូចម្ដេច នៅពេលអ្នកភ្លេចពាក្យសម្ងាត់ ?
- តើអ្នកធ្វើឱ្យពាក្យសម្ងាត់របស់អ្នកងាយស្រួលចងចាំដោយរបៀបណា ?
- តើមានពាក្យសម្ងាត់មួយដែលអ្នកប្រើរាល់ថ្ងៃទេ ?
- តើនឹងមានអ្វីកើតឡើង ប្រសិនបើនរណាម្នាក់បានរកឃើញពាក្យសម្ងាត់របស់អ្នក (ប្រសិនបើអ្នកគ្មានចំណេះដឹងនេះ) ?
- តើត្រូវរកជំនួយពីនរណា ?
- តើព័ត៌មានប្រភេទណាខ្លះដែលគេអាចយកបាន ប្រសិនបើមាននរណាម្នាក់បានប្រើពាក្យសម្ងាត់របស់អ្នក ដើម្បីចូលទៅក្នុងគណនីរបស់អ្នក ?

<u>ផ្នែកទី២</u>

## សកម្មភាពក្នុងថ្នាក់

- ឱ្យសិស្សធ្វើការជាដៃគូ

### ប្រាប់សិស្សរបស់អ្នក

ជាមួយដៃគូរបស់អ្នកពិភាក្សាអំពីអ្វីដែលអាចកើតឡើង ប្រសិនបើនរណាម្នាក់ដែលចង់បង្កបញ្ហា បានដឹងពាក្យសម្ងាត់របស់អ្នកលើបណ្ដាញសង្គមដែលអ្នកចូលចិត្ត។

## សកម្មភាពក្នុងថ្នាក់

ទុកពេល ឱ្យសិស្ស ៥នាទី ដើម្បីពិភាក្សា ហើយឱ្យក្រុមនីមួយៗចែករំលែក។

### ប្រាប់សិស្សរបស់អ្នក

ពិភាក្សាជាមួយដៃគូរបស់អ្នក អំពីអ្វីដែលនឹងកើតឡើង ប្រសិនបើមានចោរលួចពាក្យសម្ងាត់ចូលទៅកាន់គណនីធនាគារអនឡាញរបស់ឪពុកម្ដាយ ឬអាណាព្យាបាលរបស់អ្នក។

## សកម្មភាពក្នុងថ្នាក់

ទុកពេល ឱ្យសិស្ស ៥នាទី ដើម្បីពិភាក្សា ហើយឱ្យក្រុមនីមួយៗចែករំលែក។

<u>ផ្នែកទី ៣</u>

### ប្រាប់សិស្សរបស់អ្នក

អ្នកប្រហែលជាឆ្ងល់ថាពួក Hacker អាចលួចពាក្យសម្ងាត់ឯកជនដោយរបៀបណា។ មានវិធីមួយចំនួន វិធីទីមួយគឺតាមរយៈការបន្លំលើបណ្ដាញសង្គម ឬបញ្ឆោតនរណាម្នាក់ឱ្យចែករំលែកពាក្យសម្ងាត់របស់ពួកគេ។ Hacker អាចធ្វើដូចនេះបានដោយការផ្ញើអ៊ីមែលដែលមើលទៅហាក់ដូចជាមកពីគណនីពិតប្រាកដរបស់វេទិកា ឬវេបសាយណាមួយ។ អ៊ីមែលអាចស្នើឱ្យបុគ្គលនោះចុចលើតំណភ្ជាប់ ហើយចូលប្រើប្រាស់ និងបំពេញពាក្យសម្ងាត់របស់ពួកគេ។ នៅពេលដែលបុគ្គលនោះចូល Hacker នឹងទទួលបានព័ត៌មាននេះ។

ពេលខ្លះពួក Hacker ព្យាយាមទាយពាក្យសម្ងាត់ដោយប្រើឃ្លាទូទៅដូចជា "password123" "test" ឬនាមខ្លួន ឬនាមត្រកូលរបស់អ្នក។ មធ្យោបាយមួយទៀតដែលពួក Hacker លួចពាក្យសម្ងាត់ឯកជនគឺតាមរយៈ **បញ្ចូលលេខសម្ងាត់ដោយចៃដន្យ** ( Brute Force Attack )។ ការបញ្ចូលពាក្យសម្ងាត់ដោយចៃដន្យកើតឡើងនៅពេល ដែលពួក Hacker ព្យាយាមចូលទៅក្នុងគណនីរបស់អ្នកដោយបញ្ចូលពាក្យសម្ងាត់ផ្សេងៗម្ដងហើយម្ដងទៀត។ ប្រសិនបើពួក Hacker មិនអាចធ្វើការបញ្ចូលលេខសម្ងាត់ដោយចៃដន្យ ដោយដៃបានពួកគេនឹងធ្វើវានៅលើកម្មវិធីកុំព្យូទ័រដែលធ្វើបានយ៉ាងឆាប់រហ័ស និងដោយស្វ័យប្រវត្តិនៅរាល់ការបញ្ចូលពាក្យសម្ងាត់ដែលអាចទៅរួចឧទាហរណ៍៖ បញ្ជីពាក្យសម្ងាត់ដែលប្រហាក់ប្រហែល ឬសំណុំនៃពាក្យសម្ងាត់ដែលមាន បន្សំនៃអក្សរ និងលេខផ្សេងៗគ្នា រហូតដល់វារកឃើញពាក្យសម្ងាត់ត្រឹមត្រូវ។

ជាការពិតណាស់ ការបញ្ចូលពាក្យសម្ងាត់ដោយចៃដន្យមួយចំនួនគឺ មានភាពស្មុគស្មាញណាស់។ ប្រសិនបើ ពាក្យសម្ងាត់របស់អ្នកស្ថិតនៅក្នុងបញ្ជីនៃពាក្យសម្ងាត់ដែលប្រហាក់ប្រហែលដូចជា "fido123" ឬ "password," បន្ទាប់មកកម្មវិធីមួយចំនួនអាចទាយ លឿនជាងមុនដោយសាកល្បងជម្រើសទាំងនោះមុនពេលដែលមិនសូវប្រហាក់ប្រហែល ឬលទ្ធភាពចៃដន្យ។ ការបញ្ចូលពាក្យសម្ងាត់ដោយចៃដន្យអាចត្រូវបានកែលម្អបន្ថែមទៀតផងដែរ ប្រសិនបើពួក Hacker ដឹងព័ត៌មានអំពីអ្នក។ ឧទាហរណ៍ ប្រសិនបើពួក Hacker ស្គាល់ឈ្មោះសត្វចិញ្ចឹមរបស់អ្នកគឺ Toby ពួកគេអាចសាកល្បង "Toby" ជាមួយនឹងការប្រែប្រួលផ្សេងគ្នានៃលេខនៅចុងបញ្ចប់ ( ឧទាហរណ៍ "Toby629" ឬ "Toby3020" )។

## គោលការណ៍បង្កើត

### សួរសិស្សរបស់អ្នក

តើអ្នកណាដឹងទេថាការមានពាក្យសម្ងាត់ "រឹងមាំ" ឬ"រឹងមាំជាង"មានន័យដូចម្ដេច? ហេតុអ្វីវាជាគំនិតល្អ?

### ប្រាប់សិស្សរបស់អ្នក

ពាក្យសម្ងាត់រឹងមាំជួយការពារព័ត៌មានរបស់អ្នក។ ការមានពាក្យសម្ងាត់រឹងមាំមិនធានាថាគណនីរបស់អ្នកនឹងមិនត្រូវបានគេលួចចូលនោះទេ ការមានពាក្យសម្ងាត់ខ្សោយធ្វើឱ្យមានភាពងាយស្រួលសម្រាប់នរណាម្នាក់ចូលលួចព័ត៌មានរបស់អ្នក។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## លំហាត់ពីពាក្យសម្ងាត់

### សួរសិស្សរបស់អ្នក

- តើពាក្យសម្ងាត់គ្មានសុវត្ថិភាពមានអ្វីខ្លះ? ឧទាហរណ៍៖ Password, 12345, Hello! ថ្ងៃខែឆ្នាំកំណើត ឈ្មោះហៅក្រៅ។
- ហេតុអ្វីបានជាអ្នកគិតថាឧទាហរណ៍ខាងលើគ្មានសុវត្ថិភាព? ចម្លើយ៖ ពួកវាអាចទាយយ៉ាងងាយស្រួលដោយមនុស្សម្នាក់ផ្សេងទៀត និងកុំព្យូទ័របញ្ចូលពាក្យសម្ងាត់ដោយចៃដន្យ។
- តើមានវិធីអ្វី ដែលអ្នកអាចធ្វើឱ្យពាក្យសម្ងាត់កាន់តែរឹងមាំ? ឧទាហរណ៍៖ ការបន្ថែមលេខ អក្សរធំ និងអក្សរតូច និមិត្តសញ្ញា ធ្វើឱ្យពាក្យសម្ងាត់វែង ជៀសវាងឃ្លា និងពាក្យសាមញ្ញរបស់ខ្លួនឯង។

### សកម្មភាពក្នុងថ្នាក់

បន្ទាប់ពីសិស្សផ្តល់ចម្លើយរបស់ពួកគេ សរសេរការណែនាំទាំងនេះនៅលើក្តារខៀន៖

- រួមបញ្ចូលយ៉ាងហោចណាស់លេខមួយតួ។
- រួមបញ្ចូលយ៉ាងហោចណាស់និមិត្តសញ្ញាមួយ។
- រួមបញ្ចូលយ៉ាងហោចណាស់អក្សរធំមួយ និងអក្សរតូចមួយ។
- ពាក្យសម្ងាត់គួរតែមានយ៉ាងហោចណាស់៧តួ។
- ពាក្យសម្ងាត់គួរតែងាយស្រួលចងចាំ (លុះត្រាតែប្រើកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់)។
- កម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ គឺជាវេបសាយ/កម្មវិធីដែលជួយអ្នកប្រើប្រាស់រក្សាទុក និងរៀបចំពាក្យសម្ងាត់របស់ពួកគេ។
- ពាក្យសម្ងាត់មិនគួរជាពាក្យធម្មតាមួយ ឬព័ត៌មានផ្ទាល់ខ្លួន (ថ្ងៃខែឆ្នាំកំណើត ឈ្មោះឪពុកម្តាយ ជាដើម)។
- ពាក្យសម្ងាត់មិនគួរត្រូវបានចែករំលែកនៅលើវេបសាយទេ។

### ប្រាប់សិស្សរបស់អ្នក

វិធីសាស្ត្រពីរដើម្បីបង្កើតពាក្យសម្ងាត់រឹងមាំ ទីមួយគឺធ្វើតាម "ក្បួនបង្កើតលេខសម្ងាត់" ដូចនៅលើក្តារខៀន។ ការប្រើក្បួនបែបនេះធ្វើឱ្យអ្នកបង្កើតបានពាក្យសម្ងាត់ដែលពិបាកទាយ គុណវិបត្តិនៃវិធីសាស្ត្រនេះគឺថាវាធ្វើឱ្យពាក្យសម្ងាត់ពិបាកចងចាំ។

## ពាក្យសម្ងាត់រឹងមាំ

### ប្រាប់សិស្សរបស់អ្នក

វិធីសាស្ត្រមួយទៀតក្នុងការបង្កើតពាក្យសម្ងាត់រឹងមាំគឺទាក់ទងនឹងប្រវែងពាក្យសម្ងាត់។ ដោយសារតែសុវត្ថិភាពខ្ពស់នៃពាក្យសម្ងាត់គឺទាក់ទងទៅនឹងប្រវែងពាក្យសម្ងាត់ ការប្រើចំនួនតួអក្សរចាប់ពី ៩តួឡើងទៅ

ធ្វើឱ្យពាក្យសម្ងាត់កាន់តែពិបាកទាយ និងបញ្ចូលលេខសម្ងាត់ដោយចៃដន្យដោយ Hacker។ វិធីសាស្ត្រនេះមានអត្ថប្រយោជន៍បន្ថែមជាងក្បួនបង្កើតលេខសម្ងាត់ដោយវាងាយស្រួលចង់ចាំជាង។

ចុងក្រោយ គេអាចប្រើការរួមបញ្ចូលគ្នានៃវិធីសាស្ត្រទាំងពីរនេះដោយភ្ជាប់មកជាមួយនូវពាក្យសម្ងាត់វែង ការប្រើចំនួននៃតួអក្សរចាប់ពី ៨តួឡើងទៅ រួមមាននិមិត្តសញ្ញា និងលេខផងដែរ។ គោលដៅនៃវិធីសាស្ត្រពីរផ្សេងគ្នាទាំងនេះមានគោលបំណងដូចគ្នាគឺ បង្កើតពាក្យសម្ងាត់ដែលមានលក្ខណៈពិសេស និងពិបាកទាយ។

### សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សធ្វើការជាដៃគូ

### ប្រាប់សិស្សរបស់អ្នក

ធ្វើការជាដៃគូ សូមព្យាយាមបង្កើតពាក្យសម្ងាត់ ដែលរឹងមាំមួយដោយប្រើក្បួនដែលបានណែនាំ។ សូមចាំថាពាក្យសម្ងាត់មួយ ដែលកុំព្យូទ័រពិបាកទាយដោយចៃដន្យ ប្រហែលជានៅតែងាយស្រួលសម្រាប់មនុស្ស ឬកុំព្យូទ័រដែលមានបញ្ជីពាក្យសម្ងាត់វែងក្នុងការទាយ។ ក្រដាសដែលមានពាក្យសម្ងាត់របស់អ្នកមិនត្រូវប្រមូលនៅចុងបញ្ចប់នៃសកម្មភាពនោះទេ។ យើងមិនលើកទឹកចិត្តឱ្យប្រើប្រាស់ពាក្យសម្ងាត់នេះ សម្រាប់គណនីផ្ទាល់ណាមួយរបស់អ្នកទេ ព្រោះអ្នកដែលនៅក្នុងក្រុមនឹងដឹងវា។

### សកម្មភាពក្នុងថ្នាក់

ទុកពេល ឱ្យសិស្ស ៥នាទី ដើម្បីធ្វើកិច្ចការនេះ។ បន្ទាប់មកសួរសិស្សផ្សេងទៀតក្នុងថ្នាក់នូវអ្វីដែលពួកគេ គិតថា ជាឧទាហរណ៍ពាក្យសម្ងាត់រឹងមាំបំផុតរបស់ពួកគេ។ សួរសិស្សថា ប្រសិនបើពួកគេអាចចងចាំ ពាក្យសម្ងាត់ដែលពួកគេបានបង្កើតដោយមិនមើលផ្ទាល់។

### ប្រាប់សិស្សរបស់អ្នក

វេបសាយមួយចំនួនតម្រូវឱ្យពាក្យសម្ងាត់របស់អ្នកបំពេញតាមលក្ខខណ្ឌរបស់វេបសាយនោះ ហើយវេបសាយផ្សេងទៀតមិនមានការរឹតបន្តឹងបែបនេះទេ។ អ្នកក៏អាចបង្កើតពាក្យសម្ងាត់ដោយប្រើតួអក្សរសាមញ្ញ។

### សកម្មភាពក្នុងថ្នាក់

នៅក្នុងដៃគូ ឱ្យសិស្សបង្កើតពាក្យសម្ងាត់ថ្មីដែលជាតួអក្សរ។ ឱ្យសិស្សបង្កើតពាក្យសម្ងាត់មួយដែលយ៉ាងហោចណាស់មាន ៤ពាក្យ ដើម្បីធ្វើឱ្យវារឹងមាំ និងងាយស្រួលក្នុងការចងចាំ។ ផ្តល់ពេលឱ្យសិស្ស **៥នាទី** ធ្វើកិច្ចការនេះ។ បន្ទាប់មកសួរសិស្សម្នាក់ៗ តើពាក្យសម្ងាត់របស់ពួកគេគឺជាអ្វី? ក្រដាសដែលមានពាក្យសម្ងាត់របស់អ្នកមិនត្រូវប្រមូលនៅចុងបញ្ចប់នៃសកម្មភាពនោះទេ។ ហើយក៏មិនគួរប្រើពាក្យសម្ងាត់នេះសម្រាប់គណនីណាមួយរបស់ពួកគេដែរ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ប្រាប់សិស្សរបស់អ្នក

គេហទំព័រខ្លះប្រើប្រព័ន្ធមួយហៅថា Multi-Factor (ឬ Two-Factor) Authentication ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់អ្នក។ គេហទំព័រទាំងនេះច្រើនតែប្រើការផ្ញើសារ កម្មវិធី ឬអ៊ីមែល ដើម្បីផ្ញើលេខកូដតែម្តង ដែលត្រូវតែបញ្ចូលជាមួយពាក្យសម្ងាត់។ វិធីសាស្ត្រនេះអាចធ្វើឱ្យគណនីរបស់អ្នកមានសុវត្ថិភាពជាងមុន ដោយបន្ថែមស្រទាប់សុវត្ថិភាពបន្ថែមទៀត ដែលពិបាកបំបែកឆ្ងាយ។ ឧទាហរណ៍៖ ដើម្បីចូលទៅក្នុងគណនី របស់អ្នក មនុស្សម្នាក់ត្រូវតែមានពាក្យសម្ងាត់របស់អ្នក និងចូលទៅកាន់កម្មវិធី ឧបករណ៍ ឬអាសយដ្ឋានអ៊ីមែល ដែលភ្ជាប់ជាមួយគណនី។

## <u>ការរក្សាពាក្យសម្ងាត់ឱ្យមានសុវត្ថិភាព</u>

### ប្រាប់សិស្សរបស់អ្នក

ទោះបីជាអ្នកបង្កើតពាក្យសម្ងាត់ដែលរឹងមាំសម្រាប់កុំព្យូទ័រ ឬមនុស្សក្នុងការបំបែកក៏ដោយមានវិធីផ្សេងទៀតដែលពាក្យសម្ងាត់អាចងាយស្រួលបំបែក។

### សួរសិស្សរបស់អ្នក

- តើការដាក់ពាក្យសម្ងាត់របៀបណាខ្លះធ្វើឱ្យងាយបំបែក? ឧទាហរណ៍៖ ការប្រើពាក្យសម្ងាត់តែមួយសម្រាប់គណនីច្រើន មានព័ត៌មានផ្ទាល់ខ្លួន ពាក្យសម្ងាត់ដដែលអស់រយៈពេល ជាច្រើនឆ្នាំ ខ្លាចភ្លេចពាក្យសម្ងាត់។
- តើអ្នកគិតថាអ្នកគួរតែផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នកញឹកញាប់ប៉ុណ្ណា?

### ប្រាប់សិស្សរបស់អ្នក

សូម្បីតែពាក្យសម្ងាត់រឹងមាំអាចត្រូវបានគេលួច ប៉ុន្តែនៅតែមានវិធីសាស្ត្រមួយចំនួនដែលអាចការពារខ្លួនអ្នកបាន។ ប្រសិនបើមានការបំពានទិន្នន័យនៅលើវេបសាយ ដែលអ្នកមានគណនីប្រើប្រាស់សូមផ្លាស់ប្តូរពាក្យសម្ងាត់របស់អ្នកនៅលើវេបសាយនោះ និងវេបសាយផ្សេងទៀតដដែលប្រើប្រាស់ពាក្យសម្ងាត់ស្រដៀងគ្នា ការចងចាំពាក្យសម្ងាត់វែង និងស្មុគស្មាញជាការលំបាក។

### សួរសិស្សរបស់អ្នក

- តើអ្នកគិតថាវាជាគំនិតល្អទេ ក្នុងការកត់ត្រាទុកពាក្យសម្ងាត់របស់អ្នកនៅលើក្រដាស ឬនៅក្នុងកុំព្យូទ័ររបស់អ្នក? ហេតុអ្វី?

### សកម្មភាពក្នុងថ្នាក់

សូមលើកឡើងលទ្ធភាពអាចធ្វើបានមួយចំនួនដូចជា នរណាម្នាក់ស្វែងរកក្រដាស ឬកត់ត្រាឯកសារនៅលើកុំព្យូទ័ររបស់អ្នក។ ណែនាំវិធីសាស្ត្រមួយគឺការប្រើកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ ដែលជាកម្មវិធីដែលជួយអ្នកប្រើប្រាស់រក្សាទុក និងរៀបចំពាក្យសម្ងាត់។

### ប្រាប់សិស្សរបស់អ្នក

ជារៀងរាល់ថ្ងៃ យើងប្រើប្រាស់គណនីផ្សេងៗគ្នាជាច្រើននៅលើវេបសាយផ្សេងៗគ្នា វាមានភាពស្មុគស្មាញក្នុងការចូល និងចេញពីវេបសាយរៀងរាល់ពេល។

### សួរសិស្សរបស់អ្នក

- តើអ្នកធ្លាប់ប្រើមុខងារ "រក្សាទុកពាក្យសម្ងាត់" នៅក្នុងកម្មវិធីរុករករបស់អ្នកទេ? ហេតុអ្វី?
- តើអ្នកយល់ពីរបៀបដែលវេបសាយចងចាំអ្នកជានរណា?
- សុំការពន្យល់។ បន្ទាប់មកពន្យល់ថាវេបសាយអាចចងចាំថាអ្នកបានចូលដោយរក្សាទុកខូឃី។ ខូឃីគឺជាឯកសារតូចៗដែលផ្ទុកនៅលើកុំព្យូទ័ររបស់អ្នក ដើម្បីជួយវេបសាយឱ្យដឹងថាអ្នក និងកុំព្យូទ័ររបស់អ្នកជានរណានៅ ពេល ចូលមើលនាពេល អនាគត ដោយមិនចាំបាច់ចូលម្តងទៀត។ ទោះយ៉ាងណាក៏ដោយ ខូឃី ប្រើដើម្បីតាមដានអ្នក នៅពេល អ្នកចេញពីវេបសាយមួយទៅវេបសាយមួយទៀត។ នោះគឺជាវិធីមួយដែលការផ្សាយពាណិជ្ជកម្មអាចកំណត់អ្នកជាគោលដៅ។
- តើវាល្អទេក្នុងការរក្សាទុកពាក្យសម្ងាត់នៅលើកុំព្យូទ័រផ្ទាល់ខ្លួនរបស់អ្នក?
- តើកុំព្យូទ័ររបស់អ្នកមានពាក្យសម្ងាត់ឬទេ? ចុះបើអ្នកចែករំលែកកុំព្យូទ័រជាមួយអ្នកដទៃ?

### ប្រាប់សិស្សរបស់អ្នក

ក្នុងករណីនេះ ទោះបីជាពាក្យសម្ងាត់របស់អ្នកនៅក្នុងប្រអប់ពាក្យសម្ងាត់អាចត្រូវបានលាក់ដោយប្រើចំណុចខ្មៅ ឬសញ្ញាផ្កាយជំនួសក៏ដោយ អ្នកផ្សេងទៀតដែលប្រើកុំព្យូទ័ររបស់អ្នកអាចដឹងថា តើពាក្យសម្ងាត់របស់អ្នកជាអ្វី។ អ្នកមិនអាចមើលឃើញពាក្យសម្ងាត់នៅលើអេក្រង់នោះមិនប្រាកដថា វាមិនរក្សាទុកនៅកន្លែងណាមួយទេ។

### សួរសិស្សរបស់អ្នក

- តើមានពេល ដែលអ្នកអាចចែករំលែកពាក្យសម្ងាត់បាន? ពេលណា? ហេតុអ្វី? ឧទាហរណ៍ខ្លះ ដូចជាឪពុកម្តាយចង់ចែករំលែកពាក្យសម្ងាត់ ឬពួកគេមានគណនីរួម ឬគ្រួសារនៅលើសេវាកម្មដូចជាក្រុមហ៊ុន Netflix ជាដើម។
- តើអ្នកចែករំលែកពាក្យសម្ងាត់ជាមួយនរណាម្នាក់ឬទេ? បើចែករំលែក តើជាមួយអ្នកណា? ហេតុអ្វី?
- ប្រសិនបើអ្នកស្និទ្ធស្នាលជាមួយនរណាម្នាក់ បើពួកគេនិយាយថា "ប្រសិនបើអ្នកខ្វល់ពីខ្ញុំ..." តើអ្នកចែករំលែកពាក្យសម្ងាត់ជាមួយពួកគេ? ហេតុអ្វី ឬហេតុអ្វីមិន?

### ប្រាប់សិស្សរបស់អ្នក

អ្នកអាចចែករំលែកពាក្យសម្ងាត់របស់អ្នកជាមួយនរណាម្នាក់ដែលអ្នកទុកចិត្ត ប៉ុន្តែការទុកចិត្តនេះមិនមានន័យថាពួកគេសមនឹងទទួលបានសិទ្ធិចូលប្រើគណនីអនឡាញរបស់អ្នកទេ។ គិតឱ្យបានច្បាស់ពី

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ទំនាក់ទំនងជាក់លាក់ជាមួយម្នាក់នោះ មុនពេលចែករំលែកពាក្យសម្ងាត់ការទំនាក់ទំនងនោះអាចនឹងផ្លាស់ប្តូរតាមពេលវេលា។ ឧទាហរណ៍៖ ការចែករំលែកជាមួយឪពុកម្តាយ ឬអាណាព្យាបាល ខុសគ្នាវាំងជាមួយមិត្តល្អបំផុតរបស់អ្នក។

### សួរសិស្សរបស់អ្នក

- តើមានអ្វីកើតឡើងចំពោះអ្នក ប្រសិនបើអ្នកចែករំលែកពាក្យសម្ងាត់? ឧទាហរណ៍មួយចំនួនរួមមាន៖ នរណាម្នាក់អាចលួចចូលគណនីធនាគាររបស់អ្នក ក្លែងបន្លំជាអ្នកតាមអនឡាញ ឬស្វែងយល់ពីអាថ៌កំបាំងមួយចំនួនរបស់អ្នក។
- ប្រសិនបើអ្នកចែករំលែកពាក្យសម្ងាត់របស់គណនីមួយ តើអ្នកនឹងប្តូរវិធីប្រើប្រាស់គណនីនោះដែរឬទេ?
- តើរឿងអ្វីដែលអ្នកមិនមើលនៅលើ Netflix ឬមិនសរសេរនៅក្នុងអ៊ីមែល ប្រសិនបើនរណាម្នាក់អាចមើលឃើញថាអ្នកកំពុងធ្វើអ្វី?

### សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សឆ្លុះបញ្ចាំងពីអាកប្បកិរិយារបស់ពួកគេនៅពេល ប្រើគណនីរួម។ ពួកគេគួរតែពិចារណាពីសកម្មភាព លើអនឡាញរបស់ពួកគេត្រូវបានបង្ហាញសម្រាប់អ្នកប្រើប្រាស់ផ្សេងទៀតនៅលើគណនីរួម។

### សួរសិស្សរបស់អ្នក

- ប្រសិនបើគណនីរបស់អ្នកជាតំណាងនិម្មិតរបស់អ្នក ដូចជាប្រូហ្វាលបណ្តាញសង្គម តើវាជាល្អទេក្នុងការអនុញ្ញាតឱ្យមនុស្សផ្សេងទៀតប្រើគណនីរបស់អ្នក?

### សកម្មភាពក្នុងថ្នាក់

ពិភាក្សាពីលទ្ធភាពដែលនរណាម្នាក់បន្លំជាអ្នក ហើយផ្ញើសារទៅមិត្តរបស់អ្នក។

### សួរសិស្សរបស់អ្នក

- តើអ្នកអនុញ្ញាតឱ្យឧបករណ៍ណាមួយដែលអ្នកប្រើរក្សាទុកពាក្យសម្ងាត់របស់អ្នកទេ? ហេតុអ្វី? តើវាមានសុវត្ថិភាពទេ ក្នុងការរក្សាទុកពាក្យសម្ងាត់របស់អ្នកនៅលើទូរសព្ទ ឬកុំព្យូទ័រផ្ទាល់ខ្លួនរបស់អ្នក? តើមានអ្វីកើតឡើង ប្រសិនបើអ្នកឱ្យមិត្តម្នាក់ខ្ចីទូរសព្ទ ឬកុំព្យូទ័ររបស់អ្នក?
- តើមានឧបករណ៍ណាមួយដែលអ្នកចែករំលែកជាមួយអ្នកដទៃ ដូចជាគ្រួសារ ឬមិត្តភក្តិដែរឬទេ? តើអ្នកចែករំលែកគណនីនៅលើឧបករណ៍នោះ ឬពួកគេមានគណនីផ្ទាល់ខ្លួន?
- តើអ្នកធ្លាប់ប្រើឧបករណ៍ "សាធារណៈ" ដូចជានៅបណ្ណាល័យ សាលារៀន ឬកន្លែងផ្សេងទៀតឬទេ? តើអ្នកកំណត់នៅលើឧបករណ៍នោះដូចដែលអ្នកកំណត់នៅលើឧបករណ៍ផ្សេងទៀតដែរឬទេ?

### សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សធ្វើការជាដៃគូ

និយាយ

**ប្រាប់សិស្សរបស់អ្នក**

ជាមួយដៃគូរបស់អ្នក ចូរពិភាក្សា ថាតើអ្នកធ្លាប់ចូលប្រើប្រាស់កុំព្យូទ័រនៅសាលារៀន បណ្ណាល័យ ឬនៅតាមសហគមន៍ផ្សេងទៀត ហើយបានឃើញគណនីបណ្តាញសង្គម ឬគណនីអ៊ីមែលរបស់អ្នកដទៃនៅដំណើរលើឧបករណ៍នោះ។ ឱ្យពួកគេពិចារណាថា តើពួកគេនឹងពិនិត្យមើលគណនី ឬធ្វើអ្វីផ្សេងទៀតឬទេ?

**សកម្មភាពក្នុងថ្នាក់**

ទុកពេល ឱ្យសិស្ស ៥នាទី ដើម្បីពិភាក្សាពីការប្រើប្រាស់ដែលគ្មានការអនុញ្ញាតបែបនេះ បន្ទាប់មក ឱ្យពួកគេចែករំលែក។

**ការចូលប្រើគណនីគ្មានការអនុញ្ញាត**

**ផ្នែកទី១**

***ចំណាំ៖*** *ផ្នែកមួយនៃខ្លឹមសារសកម្មភាពនេះគ្របដណ្តប់នៅក្នុង "សកម្មភាព ទី ១៖ មូលដ្ឋានគ្រឹះពាក្យសម្ងាត់។" យើងគោរពតាមការវិនិច្ឆ័យរបស់អ្នក ថាតើអ្នកចង់អនុវត្តម្តងទៀត ឬរំលងវា។*

និយាយ

**ប្រាប់សិស្សរបស់អ្នក**

អាចទៅរួចសម្រាប់អ្នកដទៃ ក្នុងការចូលប្រើគណនីរបស់អ្នកសូម្បីតែមិនបានដឹង ឬទាយដោយចៃដន្យពាក្យសម្ងាត់របស់អ្នក។ ប្រសិនបើនរណាម្នាក់ដឹងពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ពួកគេអាចទាយពាក្យសម្ងាត់របស់អ្នក ឬអាចបញ្ឆោះបញ្ចូលនរណាម្នាក់នៅក្នុងក្រុមហ៊ុនឱ្យប្រគល់ព័ត៌មានរបស់អ្នក។ ព្រោះពួកគេមិនប្រើបច្ចេកវិទ្យាដើម្បីលួចចូលទៅក្នុងគណនីអ្នក ការវាយប្រហារប្រភេទនេះ ត្រូវបានគេហៅថាការបន្លំលើបណ្តាញសង្គម។

**សួរសិស្សរបស់អ្នក**

- លើកដៃឡើង ប្រសិនបើអ្នកធ្លាប់ភ្លេចពាក្យសម្ងាត់ចូលទៅកាន់វេបសាយណាមួយ។ តើមានអ្វីកើតឡើងនៅពេលអ្នកចុចលើ "ខ្ញុំភ្លេចពាក្យសម្ងាត់របស់ខ្ញុំ?" ឧទាហរណ៍ វេបសាយនោះសួរសំណួរសុវត្ថិភាព ឬទាក់ទង អ្នកដោយប្រើលេខទូរសព្ទ ឬអ៊ីមែល។
- តើសំណួរសុវត្ថិភាពអ្វីខ្លះដែលវេបសាយសួររក? ពន្យល់ពីរបៀបខ្លះនៃសំណួរទាំងនេះ ដែលមិត្តភ័ក្តិ ឬអ្នកស្គាល់អាចឆ្លើយ ឬទាយបានដូចជាឈ្មោះសត្វចិញ្ចឹម ទីកន្លែងកំណើត ឈ្មោះឪពុកម្តាយ ឈ្មោះគ្រូសំណព្វចិត្ត ឈ្មោះមិត្តល្អ និងក្រុមកីឡាដែលគាំទ្ររបស់ពួកគេ។
- តើអ្នកណាទៀតអាចដឹងពីព័ត៌មានទាំងនេះពីអ្នក?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើវេបសាយទាក់ទងអ្នកដោយរបៀបណា នៅពេលអ្នកភ្លេចពាក្យសម្ងាត់? តើអ្នកណាទៀតដែលមានព័ត៌មានគណនីរបស់អ្នក?
- តើមនុស្សយើងមិនស្គាល់អាចដឹងពីព័ត៌មានផ្ទាល់ខ្លួន ដែលទាក់ទងនឹងចម្លើយសុវត្ថិភាពរបស់អ្នកដោយរបៀបណា? ឧទាហរណ៍៖ ការបង្ហោះតាមបណ្តាញសង្គម ការស្វែងរកព័ត៌មានសាធារណៈរបស់អ្នក ការទស្សន៍ទាយច្រើនដង ទាក់ទងទៅមិត្តភក្តិរបស់អ្នក។ល។
- តើអ្វីខ្លះជាឧទាហរណ៍នៃការបង្ហោះព័ត៌មានផ្ទាល់ខ្លួននៅតាមបណ្តាញសង្គម? ឧទាហរណ៍៖ ការបង្ហោះរូបថ្នា និងឈ្មោះនៅលើ Instagram រូបថតដែលមានស្លាកទីតាំង ឬថ្ងៃខួបកំណើតជាសាធារណៈ។
- តើអ្នកអាចប្រើ Google ដើម្បីស្វែងយល់បន្ថែមពីនរណាម្នាក់ និងHack ពាក្យសម្ងាត់របស់ពួកគេដោយរបៀបណា? ឧទាហរណ៍៖ ប្រសិនបើម៉ាស៊ីនស្វែងរកបង្ហាញអ្នកនូវរូបថត**ថ្នាក់ទី៩** របស់នរណាម្នាក់នៅក្នុងកាសែតសាលាតាមអនឡាញ អ្នកអាចស្វែងយល់ពីឈ្មោះគ្រូបង្រៀន**ថ្នាក់ទី៩** របស់គាត់។

## ផ្នែកទី២

### ប្រាប់សិស្សរបស់អ្នក

ការបង្ហោះព័ត៌មានដែលមានចម្លើយសុវត្ថិភាពអាចគ្មានសុវត្ថិភាព។ សូមជ្រើសរើសសំណួរសុវត្ថិភាពដែលមានតែអ្នកប៉ុណ្ណោះដឹង។ អ្នកអាចប្រឌិតឡើងចម្លើយសម្រាប់សំណួរសុវត្ថិភាព ដរាបណាអ្នករក្សាទុកនៅក្នុងកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ ឬងាយស្រួលចងចាំ។ វេបសាយអាចទាក់ទងអ្នកប្រើប្រាស់ដោយប្រើលេខទូរសព្ទ ឬអ៊ីមែលដែលភ្ជាប់ជា មួយគណនីរបស់អ្នកប្រើប្រាស់។ ប្រសិនបើអ្នកប្រើភ្លេចពាក្យសម្ងាត់ វេបសាយតែងតែផ្តល់ពាក្យសម្ងាត់ បណ្តោះអាសន្ន ឬតំណភ្ជាប់ដែលអ្នកប្រើប្រាស់អាចប្រើដើម្បីកំណត់ពាក្យសម្ងាត់របស់ពួកគេឡើងវិញ។

### សួរសិស្សរបស់អ្នក

- តើនេះជាវិធីសុវត្ថិភាពក្នុងការធានាថាអ្នកដែលស្នើសុំពាក្យសម្ងាត់ថ្មីគឺជាអ្នកប្រើប្រាស់ដែរឬទេ?
- តើអ្នកបានចែករំលែកអាសយដ្ឋានអ៊ីមែលដែលភ្ជាប់ជាមួយគណនីដែរឬទេ? ឧទាហរណ៍៖ វិធីសាស្រ្តកំណត់ពាក្យសម្ងាត់ឡើងវិញគឺមានសុវត្ថិភាពបំផុត ប៉ុន្តែប្រសិនបើអ្នកចែករំលែកគណនី ឬពាក្យសម្ងាត់ជាមួយនរណាម្នាក់ផ្សេងទៀត វាធ្វើឱ្យអ្នកប្រឈមនឹងហានិភ័យ។

### ប្រាប់សិស្សរបស់អ្នក

ការលួចចូលគណនីបណ្តាញសង្គមអាចធ្វើបានដោយមនុស្ស ដែលទាក់ទងមកអ្នកដោយផ្ទាល់ ហើយព្យាយាមបញ្ឆោតឱ្យផ្តល់ព័ត៌មានរបស់អ្នក។ ពេលខ្លះមនុស្សនឹងផ្ញើអ៊ីមែលមកដោយក្លែងធ្វើជាមិត្តភក្តិ សមាជិកគ្រួសារ ឬនរណាម្នាក់មកពីធនាគារ ហើយសុំឱ្យអ្នកចែករំលែកព័ត៌មានសំខាន់ៗជាមួយពួកគេដូចជា ថ្ងៃខែ

ឆ្នាំកំណើតរបស់អ្នក ដើម្បីផ្ទៀងផ្ទាត់អត្តសញ្ញាណ។ វិធីនេះអាចធ្វើឱ្យអ្នកធាប់ទុកចិត្តជាងមុន ប្រសិនបើនរណាម្នាក់បានលួចចូលគណនីបណ្ដាញសង្គមរបស់មិត្តភ័ក្តិអ្នកហើយផ្ញើសារមកអ្នក និងអាចផ្ញើទៅមិត្តផ្សេងទៀត ដោយសួរពីថ្ងៃខែឆ្នាំកំណើត ឬកន្លែងរស់នៅរបស់អ្នក។ ប្រសិនបើអ្នកទទួលបានសារណាមួយពី មិត្តភ័ក្តិរបស់អ្នក ដែលមើលទៅចម្លែក អ្នកប្រហែលជាចង់ទាក់ទងទៅវិញ (នៅខាងក្រៅទម្រង់បណ្ដាញសង្គម) ដើម្បីកំណត់ថា តើពួកគេ ពិតជាកំពុងផ្ញើខ្លឹមសារឬអត់។

ការវាយប្រហារដែលប្រើអ៊ីមែល ឬវេបសាយដែលមើលទៅពិតប្រាកដ ត្រូវបានគេហៅថាការបន្លំ ហើយអាចនាំ ទៅដល់ការលួចអត្តសញ្ញាណ។ ឧទាហរណ៍៖ ការលួចអត្តសញ្ញាណ ចោរអាចបើកកាតឥណទានក្រោមឈ្មោះរបស់អ្នកហើយប្រើប្រាស់វា ដែលអាចធ្វើឱ្យអ្នកពិបាកក្នុងការទទួលបានប័ណ្ណឥណទាននៅពេលក្រោយ។ ការបន្លំឱ្យចោរក្លែងបន្លំជាអ្នក និងទទួលបានព័ត៌មានបន្ថែម ដោយអនុញ្ញាតឱ្យពួកគេលួចមើលអ៊ីមែល និងផ្ញើសារទៅកាន់មិត្តភ័ក្តិខណៈពេល ដែលក្លែងខ្លួនជាអ្នក ឬលួចលុយរបស់អ្នក ចោរអាចរារាំង អ្នកមិនឱ្យចូលគណនីរបស់អ្នកដោយបង្កើតពាក្យសម្ងាត់ថ្មី។

**កិច្ចការ**

ឱ្យសិស្សឆ្លើយសំណួរខាងក្រោម ហើយសរសេរចម្លើយជាទម្រង់អត្ថបទ រូបភាពទៅក្នុងសន្លឹកកិច្ចការ "ការរៀនអំពីពាក្យសម្ងាត់"។

- តើការយល់ដឹងចំនួនបី អ្វីខ្លះពីវគ្គនេះ អ្នកនឹងយកទៅអនុវត្តពេល បង្កើតពាក្យសម្ងាត់នៅពេលក្រោយ?
- តើអ្វីជាឧទាហរណ៍មួយ ដែលអ្នកមានអារម្មណ៍ថាសុវត្ថិភាពក្នុងការចែករំលែកពាក្យសម្ងាត់របស់អ្នកជាមួយ អ្នកផ្សេង?
- តើវិធីសាស្ត្របី យ៉ាងណាខ្លះ ដែលអ្នកប្រើដើម្បីចែករំលែកពាក្យសម្ងាត់ជាមួយអ្នកផ្សេងដោយសុវត្ថិភាព?
- តើមានឧទាហរណ៍បី យ៉ាងណាខ្លះ ដែលអាចនឹងមានបញ្ហាប្រសិនបើពាក្យសម្ងាត់ទៅដល់ដៃជនខិលខូច?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៤៖ វ៉ាយហ្វាយសាធារណៈ

**រយៈពេល៖ ៦០នាទី**

**សំណួរគន្លឹះ**

- តើព័ត៌មានរបស់អ្នកមានសុវត្ថិភាពកម្រិតណា នៅពេល អ្នកភ្ជាប់ទៅ Wi-Fi សាធារណៈ?
- តើអ្នកអាចកំណត់ពីតុល្យភាពរវាងហានិភ័យ និងអត្ថប្រយោជន៍នៃការប្រើ Wi-Fi សាធារណៈដោយរបៀបណា?

## វត្ថុបំណងមេរៀន

សិស្សនឹងសិក្សាពីបណ្ដាញ Wi-Fi សាធារណៈ អត្ថប្រយោជន៍ និងហានិភ័យ។ ពួកគេនឹងរៀនស្គាល់ Wi-Fi ដែលគ្មានសុវត្ថិភាព ដែលអាចភ្ជាប់បាន ស្វែងយល់ពីការជ្រើសរើសផ្លូវដែលមានស្រាប់ក្នុងការប្រើប្រាស់ Wi-Fi ដែលគ្មានសុវត្ថិភាព និងធ្វើការសម្រេចចិត្តបានល្អពេលណាត្រូវភ្ជាប់ និងប្រើប្រាស់ Wi-Fi ដែលគ្មានសុវត្ថិភាព។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- សន្លឹកកិច្ចការ "សុវត្ថិភាពនៃការតភ្ជាប់"
- សន្លឹកកិច្ចការ "សុវត្ថិភាពនៃការតភ្ជាប់" ច្បាប់ចម្លងសម្រាប់គ្រូ
- រូបភាពម៉ូដឹម

**តើ Wi-Fi ជាអ្វី?**

**<u>ផ្នែកទី១</u>**

## សួរសិស្សរបស់អ្នក

- តើអ្នកប្រើឧបករណ៍ណាខ្លះដើម្បីចូលប្រើអ៊ីនធឺណិត?
- តើឧបករណ៍ទាំងនោះភ្ជាប់អ៊ីនធឺណិតដោយរបៀបណា?

និយាយ

## ប្រាប់សិស្សរបស់អ្នក

Wi-Fi គឺជាវិធីសាមញ្ញមួយដើម្បីភ្ជាប់ឧបករណ៍ទៅអ៊ីនធឺណិត។ Wi-Fi ប្រើរលកសញ្ញាដើម្បីភ្ជាប់ឧបករណ៍ ដោយមិនចាំបាច់មានការតភ្ជាប់ជារូបវន្ត ឬមានខ្សែ។ ស្រមៃថាអ្នកមានកុំព្យូទ័រយួរដៃចំនួន ៣គ្រឿង នៅក្នុងផ្ទះ ដែលអ្នកចង់ភ្ជាប់អ៊ីនធឺណិត។ ដើម្បីភ្ជាប់បានអ្នកត្រូវអនុវត្តដូចខាងក្រោម៖

1. **ចំណុចចូលដំណើរការ** (AP)៖ គឺជាការបញ្ជូនរលកសញ្ញា Wi-Fi និងផ្តល់ច្រកចូលទៅកាន់អ៊ីនធឺណិត។ ឧបករណ៍របស់អ្នកត្រូវចាប់យកសញ្ញាទាំងនេះដើម្បីភ្ជាប់ទៅអ៊ីនធឺណិត។ ពេលខ្លះអ្នកត្រូវការការអនុញ្ញាតពិសេស (ឧទាហរណ៍៖ ឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់) ដើម្បីចូល និងប្រើអ៊ីនធឺណិតដែលចំណុចចូលដំណើរការបញ្ជូនរលកសញ្ញាមក។
2. **រ៉ោតទ័រ៖** គឺជាឧបករណ៍ដែលបង្កើតបណ្តាញរវាងឧបករណ៍ប្រើប្រាស់ទាំងអស់ (ឧទាហរណ៍៖ កុំព្យូទ័របន្ទះ Tablet ទូរសព្ទចល័ត) នៅក្នុងទីតាំងដែលបានផ្តល់ឱ្យ (ដូចជាសាលារៀន បណ្ណាល័យ ឬផ្ទះរបស់អ្នក)។ ជាធម្មតា រ៉ោតទ័រ មានចំណុចចូលដំណើរការដែលបានភ្ជាប់មករួចជាស្រេច។ រ៉ោតទ័រមានកម្រិតដែនកំណត់ (ជាធម្មតាខ្លី)។ ហេតុនេះហើយ ប្រសិនបើឧបករណ៍របស់អ្នកនៅឆ្ងាយពីរ៉ោតទ័រ អ្នកនឹងទទួលបានរលកសញ្ញា Wi-Fi ខ្សោយ ឬគ្មានសញ្ញាអ្វីសោះ។ ប្រសិនបើមានអ្វីមួយបាំងរវាងអ្នកនិង រ៉ោតទ័រ (ដូចជាអាគារ ឬជញ្ជាំងឥដ្ឋ) ដែលធ្វើឱ្យកាត់បន្ថយរលកសញ្ញារបស់អ្នក។ ទោះបីជាបានភ្ជាប់ទៅរ៉ោតទ័រហើយក៏ដោយ ប៉ុន្តែវាមិនទាន់អាចភ្ជាប់ទៅកាន់អ៊ីនធឺណិតទេ។ សម្រាប់ឧបករណ៍ជាច្រើននៅលើបណ្តាញដើម្បីអាចភ្ជាប់ទៅអ៊ីនធឺណិតបាន រ៉ោតទ័រត្រូវតែភ្ជាប់ទៅម៉ូដឹម។
3. **ម៉ូដឹម៖** គឺជាឧបករណ៍ដែលបង្កើត និងរក្សាការតភ្ជាប់ទៅកាន់អ្នកផ្តល់សេវាអ៊ីនធឺណិត (ISP) របស់អ្នកដើម្បីផ្តល់ឱ្យអ្នកចូលប្រើអ៊ីនធឺណិត។ វាបំប្លែងរលកសញ្ញាពីមជ្ឈដ្ឋានខាងក្រៅទៅឱ្យកុំព្យូទ័រ និងឧបករណ៍ឌីជីថលផ្សេងទៀតប្រើប្រាស់បាន។

នៅក្នុងការដំឡើងធម្មតា ចំណុចចូលដំណើរការ រ៉ោតទ័រ ជាឧបករណ៍តែមួយគត់ដែលភ្ជាប់ទៅម៉ូដឹមដោយប្រើខ្សែពិសេសហៅថាខ្សែអ៊ីសឺរណិត។ ដែលសំដៅការតភ្ជាប់អ៊ីនធឺណិត "មានខ្សែ"។ ឧបករណ៍ចល័តប្រើប្រាស់ជាប្រព័ន្ធទំនាក់ទំនងឥតខ្សែ (Cellular) ដើម្បីភ្ជាប់ទៅអ៊ីនធឺណិត ជាពិសេស បើមិនមានបណ្តាញអ៊ីនធឺណិតនៅក្នុងសាលារៀន បណ្ណាល័យ ឬនៅផ្ទះ។ ការតភ្ជាប់ប្រព័ន្ធទំនាក់ទំនងឥតខ្សែ គឺជាប្រភេទនៃសញ្ញាវិទ្យុឥត ខ្សែដែលមានតំបន់គ្របដណ្តប់ធំជាងរ៉ោតទ័រ។ ការភ្ជាប់ប្រព័ន្ធទំនាក់ទំនងឥតខ្សែប្រើឧបករណ៍បញ្ជូនជាក់លាក់ ហៅថាអង់តែន (Cell Towers)ដើម្បីភ្ជាប់ឧបករណ៍ចល័តទៅអ៊ីនធឺណិត។

## ផ្នែកទី២

### សួរសិស្សរបស់អ្នក

- តើ Wi-Fi មានអត្ថប្រយោជន៍អ្វីខ្លះ?
- តើ Wi-Fi មានគុណវិបត្តិអ្វីខ្លះ?
- តើអ្វីអាចជាកង្វល់សុវត្ថិភាព ពេលប្រើ Wi-Fi ធៀបនឹងការតភ្ជាប់អ៊ីនធឺណិតតាមខ្សែ?
- ហេតុអ្វីបានជាអ្នកមិនអាចប្រើ Wi-Fi នៅលើទូរសព្ទនៅពេល អ្នកចាកចេញពីអាគារ?

### ការជ្រើសរើសបណ្តាញ Wi-Fi

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

សួរសិស្សរបស់អ្នក

- តើបណ្តាញ Wi-Fi ទាំងអស់មានសុវត្ថិភាពដែរឬទេ ? ហេតុអ្វី ?

និយាយ

### ប្រាប់សិស្សរបស់អ្នក

អ្នកត្រូវជ្រើសរើសប្រព័ន្ធ Wi-Fi ដែលអ្នកចង់ប្រើ។ ជារឿងសំខាន់អ្នកត្រូវចងចាំថាមានហានិភ័យធ្ងន់ធ្ងរ ប្រសិនបើអ្នកភ្ជាប់ទៅបណ្តាញគ្មានសុវត្ថិភាព។ ឧទាហរណ៍៖ Wi-Fi គ្មានសុវត្ថិភាពគឺជា បណ្តាញដែលមិនទាមទារពាក្យសម្ងាត់ដើម្បីចូល។ បើអ្នកនៅលើបណ្តាញដែលមិនមានសុវត្ថិភាព អ្នកផ្សេងទៀតនៅលើបណ្តាញតែមួយ អាចមើលឃើញព័ត៌មានរបស់អ្នក។ ពួកគេអាចលួចព័ត៌មានដែលអ្នកផ្ញើតាមបណ្តាញ ឬតាមដានអ្វីដែលអ្នកកំពុងធ្វើ។

ប្រព័ន្ធ Wi-Fi មានសុវត្ថិភាព និងទំនុកចិត្ត គឺជាបណ្តាញដែលទាមទារពាក្យសម្ងាត់ បើកការអ៊ិនគ្រីប ហើយប្រាកដថាបណ្តាញដែលអ្នកកំពុងចូលគឺជាឈ្មោះបណ្តាញជាក់លាក់។ ឧទាហរណ៍៖ ការចូលទៅក្នុងបណ្តាញដែលក្លែងបន្លំឈ្មោះនៃបណ្តាញរបស់សាលារបស់អ្នកអាចនាំអោយមានការលួចយកព័ត៌មានគណនី។ ដូច្នេះហើយបណ្តាញដែលមានសុវត្ថិភាព និងជឿជាក់ គឺជាបណ្តាញដែលផ្តល់ការការពារច្រើនបំផុត។

រឿងមួយត្រូវពិចារណាគឺបរិបទ ឬទីតាំងប្រព័ន្ធ Wi-Fi។ ឧទាហរណ៍៖ ប្រសិនបើអ្នកនៅក្នុងពេងភាពយន្ត ហើយឃើញឈ្មោះបណ្តាញរបស់សាលាអ្នកនៅលើទូរសព្ទរបស់អ្នក ពេលកំពុងស្វែងរកប្រព័ន្ធ Wi-Fi ដើម្បីតភ្ជាប់ អ្នកពិចារណាថាបណ្តាញកំពុងព្យាយាម "ក្លែងបន្លំ" បណ្តាញសាលាអ្នក ដើម្បីប្រមូលពាក្យសម្ងាត់ពីសិស្សដែលមិនបានចាប់អារម្មណ៍។

ពេលរៀបចំពាក្យសម្ងាត់ការពារប្រព័ន្ធ Wi-Fi ម្ចាស់ត្រូវជ្រើសរើសបើកអ៊ីនគ្រីបរបស់រ៉ោតទ័រ។ អ៊ីនគ្រីបទូទៅគឺ Wired Equivalent Privacy (WEP) ប្រព័ន្ធ Wi-Fi ការចូលប្រើប្រព័ន្ធការពារ (WPA) ឬ WPA2។ គោលការណ៍ទាំងនេះបញ្ជាក់ថាព័ត៌មានដែលបានផ្ញើលើបណ្តាញត្រូវបាន អ៊ីនគ្រីប។ ការអ៊ីនគ្រីបត្រូវបានបង្កើតឡើងដើម្បីធ្វើឱ្យវាកាន់តែលំបាកសម្រាប់ពួក Hacker មើលអ្វីដែលអ្នកកំពុងធ្វើ។ គោលការណ៍ទាំងអស់នេះ (WEP, WPA, និង WPA2) បង្ហាញថា Hacker មានការលំបាកដូច្នេះវា មានសារៈសំខាន់ក្នុងការប្រើប្រាស់ បណ្តាញដែលមានសុវត្ថិភាពនៅពេល បញ្ជូនព័ត៌មានតាមអ៊ីនធឺណិត។

HTTPS គឺជាស្តង់ដាដែលប្រើដោយវេបសាយដើម្បីអ៊ីនគ្រីបទិន្នន័យដែលឆ្លងកាត់អ៊ីនធឺណិត។ ការអ៊ីនគ្រីប អាចការពារភាគីទីបី ពីការមើលទិន្នន័យយ៉ាងងាយស្រួលពីការតភ្ជាប់របស់អ្នក។ វាផ្តល់នូវស្រទាប់សុវត្ថិភាពបន្ថែម ហើយអាចប្រើនៅក្នុងកម្មវិធីរុករកណាមួយដោយបន្ថែម "https://" នៅពីមុខ URL ដែលអ្នកប្រើ (ឧទាហរណ៍ https://www.mysite.com)។ ទោះយ៉ាងណាក៏ដោយ មិនមែនគ្រប់វេបសាយទាំងអស់គាំទ្រ HTTPS ទេ។ អ្នកគួរតែបញ្ចូលតែព័ត៌មានសំខាន់ៗ (ឧទាហរណ៍៖ ពាក្យសម្ងាត់ ព័ត៌មានកាតឥណទាន)

នៅលើទំព័របណ្តាញដែលមានបុព្វបទHTTPS://។ កម្មវិធីរុករកសំខាន់ៗមានសញ្ញាបញ្ជាក់សុវត្ថិភាពដែលមើលទៅដូចជាមេសោ នៅជិតរបារអាសយដ្ឋានដើម្បីបង្ហាញពីការតភ្ជាប់ HTTPS។ HTTPS មិនធានាថាអ្នកមានសុវត្ថិភាពទេ ដោយហេតុថាវេបសាយដែលមានភ្ជាប់ជាមួយមេរោគមួយចំនួនក៏អាចគាំទ្រ HTTPS ផងដែរ។ HTTPS ធានាការតភ្ជាប់ ប៉ុន្តែមិនប្រាកដថាវេបសាយនោះមានសុវត្ថិភាពទេ។

និយាយ

## ប្រាប់សិស្សរបស់អ្នក

Secure Sockets Layer ( SSL )/Transport Layer Security ( TLS ) គឺជាឈ្មោះសម្រាប់បច្ចេកវិទ្យាដែលរក្សា HTTPS ឱ្យមានសុវត្ថិភាព។ SSL/TLS ប្រើសោអ៊ីនគ្រីបឌីជីថល ដែលដំណើរការច្រើនដូចជាកូនសោពិត។ ប្រសិនបើអ្នកបង្កើតឯកសារសម្ងាត់មួយសម្រាប់មិត្ត អ្នកដែលរកឃើញក្រដាសនោះអាចមើលឃើញអាថ៌កំបាំងរបស់អ្នក។ ផ្ទុយទៅវិញ ស្រមៃថាអ្នកបានផ្តល់ឱ្យពាក្យសម្ងាត់មួយដោយផ្ទាល់ ហើយបន្ទាប់មកផ្ញើឯកសារអាថ៌កំបាំងរបស់អ្នក។ ប្រសិនបើនរណាម្នាក់រកឃើញឯកសារអាថ៌កំបាំងនោះ ពួកគេនឹងពិបាកបើកមើលឯកសារអាថ៌កំបាំងរបស់អ្នកដោយគ្មានកូនសោ។ ប្រសិនបើនរណាម្នាក់ព្យាយាមជំនួសឯកសារអាថ៌កំបាំងដែលមានរូបរាងស្រដៀងគ្នា អ្នកនឹងសម្គាល់ឃើញថាសោរបស់អ្នកនឹងមិនដំណើរការទេ។ SSL/TLS ដំណើរការដូចគ្នា ប៉ុន្តែជាមួយវេបសាយ។

សញ្ញាបញ្ជាក់សុវត្ថិភាពនៅលើកម្មវិធីរុករក ទាក់ទងព័ត៌មានវិញ្ញាបនបត្រ ទទួលស្គាល់សុវត្ថិភាព ( EV ) ផងដែរ។ វិញ្ញាបនបត្រទទួលស្គាល់សុវត្ថិភាព ផ្តល់ទៅឱ្យវេបសាយដែល ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ពួកគេទៅស្ថាប័នទទួលស្គាល់វិញ្ញាបនបត្រ។ នៅក្នុងកម្មវិធីរុករកតាមអ៊ីនធឺណិតពេលខ្លះវិញ្ញាបត្រទទួលស្គាល់សុវត្ថិភាព យកទម្រង់នៃឈ្មោះវេបសាយ ឬអង្គភាពចុះឈ្មោះនៅជាប់ របារអាសយដ្ឋាន។ ប្រសិនបើអ្នកសង្ស័យលើខ្លឹមសារនៅលើវេបសាយណាមួយ អ្នកអាចពិនិត្យមើលថាតើ URL ក្នុងវិញ្ញាបនបត្រត្រូវគ្នានឹង URL នៅក្នុងកម្មវិធីរុករកតាមអ៊ីនធឺណិតដោយចុចលើ "មើលវិញ្ញាបនបត្រ"។ (វាអាចមានប្រយោជន៍ដើម្បីបង្ហាញដល់សិស្សពីរបៀបស្វែងរក "មើលវិញ្ញាបនបត្រ"។ របៀបដែលអ្នករុករក ប្រែប្រួលតាមកម្មវិធីរុករកផ្សេងៗគ្នា។ ឧទាហរណ៍ នៅលើ Chrome ក្រោម "View" ចុច "Developer" ហើយបន្ទាប់មក "Developer Tool" ចុចផ្ទាំង "Security" បន្ទាប់មក "View Certificate"។ )

## សួរសិស្សរបស់អ្នក

- តើអ្នកគួរគិតលើអ្វីខ្លះ មុនពេលភ្ជាប់ទៅបណ្តាញថ្មីណាមួយ ?
  - ចម្លើយរំពឹងទុក៖ ទីតាំង ឬឈ្មោះបណ្តាញ ការចូលប្រើ ឬអ្នកណាផ្សេងទៀតត្រូវ បានភ្ជាប់ទៅបណ្តាញ និងសកម្មភាពដែលអ្នកកំពុងធ្វើនៅលើបណ្តាញ។
- តើអ្នកណាជាម្ចាស់បណ្តាញ Wi-Fi របស់អ្នកនៅផ្ទះ ? នៅសាលា ? នៅហាងកាហ្វេ ?
  - ឪពុកម្តាយ ឬអាណាព្យាបាលជាម្ចាស់បណ្តាញ Wi-Fi នៅផ្ទះរបស់អ្នក អ្នកគ្រប់គ្រង ឬអាជ្ញាធរជាម្ចាស់បណ្តាញនៅសាលារៀន ហើយម្ចាស់ហាងកាហ្វេជាម្ចាស់បណ្តាញ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើអ្នកស្គាល់មនុស្សទាំងនេះដោយផ្ទាល់ទេ?
- តើអ្នកទុកចិត្តមនុស្សទាំងនេះទេ?

ឱ្យសិស្សពិភាក្សាពីរបៀបដែលពួកគេទុកចិត្តមនុស្សទាំងនេះតាមរបៀបផ្សេងៗគ្នា។

និយាយ **ប្រាប់សិស្សរបស់អ្នក**

អ្នកគួរតែដឹង និងជឿជាក់លើបុគ្គលដែលធ្វើជាម្ចាស់បណ្តាញ Wi-Fi។ អ្នកអាចកំណត់ថាអ្នកណាជាម្ចាស់កំពុងប្រើ SSID របស់បណ្តាញ។ The Service Set Identifier (SSID) គឺជាឈ្មោះដែលបានផ្តល់ឱ្យបណ្តាញ Wi-Fi ដែលអ្នកអាចមើលឃើញនៅពេល ដែលអ្នកព្យាយាមតភ្ជាប់។ SSID ត្រូវបានប្រើជាញឹកញាប់ដើម្បីទំនាក់ទំនងអ្នកដែលជាម្ចាស់បណ្តាញ និងព័ត៌មានលម្អិតផ្សេងទៀតអំពីបណ្តាញ។ សូមប្រយ័ត្ន ព្រោះស្ទើរតែគ្រប់គ្នាដែលដឹងពីរបៀបអាចបង្កើត SSID បាន។ ឧទាហរណ៍៖ នរណាម្នាក់អាចបង្កើត SSID ដែលដូច គ្នាទាំងស្រុងទៅនឹងអ្វីដែលអ្នកប្រើនៅសាលា។ នេះគឺជាឧទាហរណ៍ នៃការបន្លំបណ្តាញដែលគេស្គាល់ និងជឿទុកចិត្តដើម្បីប្រមូលឈ្មោះអ្នកប្រើប្រាស់ និងពាក្យសម្ងាត់។

ការដឹងថាអ្នកណាជាអ្នកបង្កើតបណ្តាញអាចជួយអ្នកកំណត់ថា តើបណ្តាញមានសុវត្ថិភាពឬអត់? ប្រសិនបើវាជាកម្មសិទ្ធិរបស់មនុស្ស ឬស្ថាប័នដែលអ្នកទុកចិត្ត អ្នកមានទំនុកចិត្តក្នុងការតភ្ជាប់។ ទោះយ៉ាងណាក៏ដោយប្រសិនបើវាជាបណ្តាញដែលមិនស្គាល់អ្នកមិនគួរភ្ជាប់ទេ ព្រោះអ្នកមិនដឹងថាអ្នកណាជាម្ចាស់រ៉ោតទ័រដែលអ្នកកំពុងភ្ជាប់។ ដោយសារតែការភ្ជាប់ទាំងអស់នៅលើបណ្តាញឆ្លងកាត់រ៉ោតទ័រ ម្ចាស់រ៉ោតទ័រអាចតាមដានឬកត់ត្រាសកម្មភាពនៅលើវេបសាយរបស់អ្នក។

នៅពេលអ្នកភ្ជាប់ទៅ Wi-Fi ឧបករណ៍របស់អ្នកភ្ជាប់ទៅឧបករណ៍បណ្តាញមូលដ្ឋានហើយបណ្តាញនោះភ្ជាប់ទៅអ៊ីនធឺណិតកាន់តែទូលំទូលាយ។ ដោយសារតែឧបករណ៍របស់អ្នកកំពុងផ្លាស់ប្តូរព័ត៌មានជាមួយបណ្តាញនេះវាជាការសំខាន់ក្នុងការជឿជាក់លើឧបករណ៍ផ្សេងទៀតដែលអ្នកបានភ្ជាប់។ ដូចជាការងារជាក្រុមដែលអ្នកធ្វើនៅសាលា អ្នកចង់អាចទុកចិត្តមនុស្សផ្សេងទៀតដែលអ្នកកំពុងធ្វើការជាមួយ។ ការប្រើពាក្យសម្ងាត់នៅលើបណ្តាញអាចកំណត់ ថាអ្នកណាអាចភ្ជាប់ទៅវាបាន។ នេះមានន័យថាអ្នកនឹងមានគំនិតកាន់តែប្រសើរឡើងពីអ្នកដែលចូលទៅបណ្តាញ តើជាគ្រួសារ មិត្តភ័ក្តិ ឬអតិថិជននៅក្នុងហាងកាហ្វេ ជាជាង បណ្តាញបើកចំហ។

តើអ្នកសម្រេចចិត្តភ្ជាប់បណ្តាញដែលគួរឱ្យសង្ស័យ ឬទេ ប្រសិនបើអ្នក ត្រូវប្រឈមសុវត្ថិភាពអនឡាញ? អ្នកគួរពិចារណាថា "តើអ្នកគួរថ្លឹងថ្លែងពីសក្តានុពលនៃគណនីរបស់អ្នកដែលអាចនឹងរំលោភបំពានធៀបនឹងភាពងាយស្រួលនៃការភ្ជាប់បណ្តាញដែលមាន?"

### សួរសិស្សរបស់អ្នក

- តើអ្នកគួរអានព័ត៌មានអនឡាញ ឬប្លក់ (Blog) ដោយប្រើ Wi-Fi នៅផ្ទះ? សាលា? ហាងកាហ្វេឬទេ?
- ពន្យល់ថា ខ្លឹមសារនៃទំព័រវេបជាទូទៅមិនមែនជាព័ត៌មានសំខាន់។ អ្នកអាចធ្វើវាបាននៅលើបណ្តាញណាមួយក៏បានដែរ។
- តើអ្នកគួរផ្ញើលេខកាតឥណទានដោយប្រើ Wi-Fi នៅផ្ទះ? សាលា? ហាងកាហ្វេដែរឬទេ? ហេតុអ្វី?
- សូមចូលរួមពិភាក្សា ហេតុអ្វីជាការផ្ញើលេខកាតឥណទានដោយប្រើ Wi-Fi នៅផ្ទះមានសុវត្ថិភាពជាង Wi-Fi ហាងកាហ្វេ។ សូមពិភាក្សា ខណៈ Wi-Fi របស់សាលារៀនគួរឱ្យទុកចិត្ត វាអាចមិនសមនឹងប្រថុយ ដោយសារព័ត៌មានលេខកាតឥណទានសំខាន់ខ្លាំង។
- តើអ្នកគួរពិនិត្យមើលអ៊ីមែលផ្ទាល់ខ្លួនរបស់អ្នកដោយប្រើ Wi-Fi នៅផ្ទះ? សាលា? ហាងកាហ្វេដែរឬទេ?
- សូមពិភាក្សាពីរបៀបដែលវាមានសុវត្ថិភាពបំផុតក្នុងការធ្វើដូច្នេះជាមួយ Wi-Fi នៅផ្ទះរបស់ពួកគេ អាស្រ័យលើខ្លឹមសារនៃគណនីអ៊ីមែល។ ឧទាហរណ៍៖ បុគ្គលមួយចំនួនមានគណនីអ៊ីមែលច្រើន ដែលពួកគេប្រើសម្រាប់គោលបំណងផ្សេងៗគ្នា (ឧទាហរណ៍៖ អ៊ីមែលទីផ្សារ ឬផ្សព្វផ្សាយសម្រាប់គណនីមួយ ហើយអ៊ីមែលទៅមិត្តភ័ក្តិ និងគ្រួសារនៅលើគណនីផ្សេងទៀត)។

### ប្រាប់សិស្សរបស់អ្នក

ព័ត៌មានសំខាន់រួមមានពាក្យសម្ងាត់ និងព័ត៌មានពីធនាគារត្រូវបានផ្ញើ ឬមើលនៅលើបណ្តាញលក្ខណៈឯកជន និងសុវត្ថិភាព នៅលើវេបសាយដោយប្រើ SSL/TLS ជាជាងនៅលើបណ្តាញសាធារណៈ។ ព័ត៌មាន ឯកជននេះមានហានិភ័យ ប្រសិនបើអ្នកដាក់បញ្ជូន ឬចូលប្រើវា ខណៈពេល ដែលនៅលើបណ្តាញសាធារណៈ ដែលមានអ្នកមិនស្គាល់កំពុងប្រើប្រាស់។ វាមានភាពមិនច្បាស់ ថាតើព័ត៌មានសំខាន់ ឬមិនសំខាន់ ដែលអាស្រ័យលើការសម្រេចចិត្តបុគ្គលម្នាក់ៗ អ្នកត្រូវតែធ្វើសម្រាប់ខ្លួនអ្នក។ វាមានសារៈសំខាន់ណាស់ក្នុងការពិចារណា ស្ថានភាពនីមួយៗដោយខ្លួនឯង ដើម្បីកំណត់ថា តើអ្នកគួរតែភ្ជាប់ទៅបណ្តាញណាមួយ។ សួរថាតើអ្នកទុកចិត្តម្ចាស់បណ្តាញអ្នកផ្សេងទៀតបានភ្ជាប់វា តើសកម្មភាពអ្វីនៅលើអនឡាញ និងព័ត៌មានអ្វី ដែលអ្នកចែករំលែក មុនពេលសម្រេចចិត្តភ្ជាប់ ឬទេ៕

## បណ្តាញសុវត្ថិភាព និងគ្មានសុវត្ថិភាព

**ផ្នែកទី១**

*សូមចំណាំ៖ ផ្នែកមួយនៃខ្លឹមសារសកម្មភាពនេះគ្របដណ្តប់នៅក្នុង" សកម្មភាពទី២៖ ការជ្រើសរើស Wi-Fi។ យើងគោរពតាមការវិនិច្ឆ័យរបស់អ្នក ថាតើអ្នកចង់អនុវត្តម្តងទៀត ឬរំលងវា។*

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ប្រាប់សិស្សរបស់អ្នក

ដូចបានរៀបរាប់ខាងលើ Wi-Fi មិនមានសុវត្ថិភាពគឺជាបណ្តាញដែលមិនទាមទារពាក្យសម្ងាត់ដើម្បីចូល។ ការប្រើប្រាស់បណ្តាញដែលមិនមានសុវត្ថិភាពបង្កហានិភ័យដល់ទិន្នន័យដែលអ្នកបញ្ជូន និងទទួលតាមបណ្តាញ។ Wi-Fi មានសុវត្ថិភាព គឺជាបណ្តាញដែលទាមទារពាក្យសម្ងាត់ និងបានបើកការអ៊ីនគ្រីប។ អ្នកគ្រប់គ្រងបណ្តាញគឺជាអ្នកមានសិទ្ធិបិទ ឬបើកការអ៊ីនគ្រីប។ ការអ៊ីនគ្រីបច្របូកច្របល់ព័ត៌មានដែលអ្នកផ្ញើ ឬទទួលហេតុដូចនេះធ្វើឱ្យពួក Hacker ពិបាកមើលឃើញទិន្នន័យដែលអ្នកផ្ញើ។ បណ្តាញមួយមានសុវត្ថិភាពមិនប្រាកដថាទិន្នន័យរបស់អ្នកមានសុវត្ថិភាពនោះទេ ប៉ុន្តែវាជាល្អជាងការប្រើប្រាស់បណ្តាញគ្មានសុវត្ថិភាព ដោយហេតុថាពួក Hacker អាចរកផ្លូវទៅយកព័ត៌មានយើងបានដែរ។ គោលការណ៍អ៊ីនគ្រីបចំនួនបីសម្រាប់ Wi-Fi គឺ Wired Equivalent Privacy ( WEP ), Wi-Fi Protected Access ( WPA ) ឬ WPA2។ WEP និង WPA គឺហួសសម័យ ហើយបណ្តាញដែលពឹងផ្អែក លើគោលការណ៍ទាំងនេះគេគិតថាគ្មានសុវត្ថិភាព។ លើសពីនេះ WPA2 ក៏ត្រូវបានបង្ហាញថាងាយស្រួលលួចចូលផងដែរ។ ដើម្បីប្រាកដថាព័ត៌មានអ្នកត្រូវបានការពារក្នុងកម្រិតខ្ពស់បំផុត សូមពិនិត្យមើលថាវេបសាយដែលអ្នកកំពុងប្រើត្រូវបានអ៊ីនគ្រីបដោយប្រើ SSL/TLS។

### សួរសិស្សរបស់អ្នក

- តើមាននរណាម្នាក់អាចឱ្យឧទាហរណ៍នៃបណ្តាញដែលការពារដោយពាក្យសម្ងាត់ពួកគេធ្លាប់ប្រើដែរឬទេ ?
  - ឧទាហរណ៍៖ Wi-Fi នៅផ្ទះរបស់ពួកគេ សាលារៀន និងនៅទីតាំងសាធារណៈមួយចំនួន ដូចជាហាងកាហ្វេជាដើម។
- តើមាននរណាម្នាក់អាចឱ្យឧទាហរណ៍នៃបណ្តាញគ្មានសុវត្ថិភាព ដែលពួកគេធ្លាប់ប្រើដែរឬទេ ? និង ឧទាហរណ៍បណ្តាញមានសុវត្ថិភាព ?

### ប្រាប់សិស្សរបស់អ្នក

អ្នកអាចពិនិត្យមើលថាតើ Wi-Fi បានអ៊ីនគ្រីបដោយពិនិត្យមើលការកំណត់បណ្តាញ ឬឥតខ្សែនៅលើឧបករណ៍របស់អ្នក។

## <u>ផ្នែកទី២</u> សកម្មភាពក្នុងថ្នាក់

មុនសិក្សាមេរៀននេះ សូមធ្វើការស្វែងរកតាមអ៊ីនធឺណិត ដើម្បីពិនិត្យមើលរបៀបត្រួតពិនិត្យមើលប្រភេទ ការអ៊ីនគ្រីបបណ្តាញ Wi-Fi សម្រាប់ប្រព័ន្ធប្រតិបត្តិការផ្សេងៗ។ បន្ទាប់មកបង្ហាញពីរបៀបស្វែងរកប្រភេទនៃការអ៊ីនគ្រីបដែលបណ្តាញកំពុងប្រើប្រាស់។ ឧទាហរណ៍៖ នៅលើ MacOS ចុចលើ System Preferences -> Network -> Select Wi-Fi -> ជ្រើសរើសឈ្មោះ Network ដែលសមស្រប។ នៅក្រោមផ្ទាំង Wi-Fi នឹងមាន បញ្ជីបណ្តាញដែលបង្ហាញថាប្រភេទការអ៊ីនគ្រីបណាមួយកំពុងប្រើប្រាស់។

និយាយ

## ប្រាប់សិស្សរបស់អ្នក

ការតភ្ជាប់ទាំងអស់មិនស្មើគ្នាទេ នៅពេលដែលបណ្ដាញគ្មានសុវត្ថិភាពអ្នកណាម្នាក់ក៏អាចភ្ជាប់ទៅបណ្ដាញ ហើយវាមិនច្បាស់ថាអ្នកណាជាអ្នកគ្រប់គ្រងបណ្ដាញទេ។ ការតភ្ជាប់បណ្ដាញដែលគ្មានសុវត្ថិភាពធ្វើឱ្យអ្នកងាយរងគ្រោះ ព្រោះព័ត៌មានដែលអ្នកផ្ញើ និងទទួលដូចជា គេហទំព័រ ពាក្យសម្ងាត់។ល។ អាចនឹងត្រូវបាន មើលដោយអ្នកណាម្នាក់នៅលើបណ្ដាញ ប្រសិនបើអ្នកមិនប្រើការតភ្ជាប់ SSL/TLS។

## សកម្មភាពក្នុងថ្នាក់

អាស្រ័យលើចំណេះដឹងបច្ចេកវិទ្យាសិស្សរបស់អ្នក អ្នកគួរតែឱ្យពួកគេពិភាក្សាពីការប្រើប្រាស់បណ្ដាញឯកជននិម្មិត (VPN) ជាស្រទាប់សុវត្ថិភាពបន្ថែមនៅពេល ប្រើប្រាស់ប្រព័ន្ធ Wi-Fi។

## ការទទួលស្គាល់សុវត្ថិភាពនៃការតភ្ជាប់

## សកម្មភាពក្នុងថ្នាក់

បែងចែកសិស្សជា ២ ឬ៣ក្រុម។ ចែកសន្លឹកកិច្ចការ "សុវត្ថិភាពនៃការតភ្ជាប់" ហើយផ្ដល់សេណារីយ៉ូដល់ក្រុមនីមួយៗ។ ផ្ដល់ពេល ឱ្យសិស្ស ៥នាទី ពិភាក្សាពីសេណារីយ៉ូពីរបស់ពួកគេ។ បន្ទាប់មកឱ្យក្រុមនីមួយចែករំលែកចម្លើយរបស់ពួកគេ។

## កិច្ចការ

កំណត់ពេលវេលាប្រចាំថ្ងៃសម្រាប់ការភ្ជាប់ Wi-Fi ដែលអ្នកភ្ជាប់។ បណ្ដាញដែលបានជ្រើសរើសបង្ហាញនៅលើការកំណត់ពេលវេលា សូមជ្រើសរើសពីរ ហើយសរសេរអត្ថបទខ្លីសម្រាប់នីមួយៗពិពណ៌នាពីបណ្ដាញ។ តើអ្នកណាទៀតដែលភ្ជាប់វា? តើវាមានសុវត្ថិភាពកម្រិតណា? លើសពីនេះទៀតសម្រាប់បណ្ដាញទាំងពីរដែលបានជ្រើសរើស ពិពណ៌នាពីឱកាសដែលភ្ជាប់មកជាមួយការភ្ជាប់ទៅបណ្ដាញទាំងនេះ និងអ្វីដែលហានិភ័យដែលពាក់ព័ន្ធអាចមាន។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៥៖ សុវត្ថិភាពតាមអ៊ីនធឺណិត ការលួចបន្លំ និងសារផេតបានការ

រយៈពេល ៦០នាទី

**សំណួរគន្លឹះ៖**

- តើអ្នកដឹងដោយរបៀបណាថាព័ត៌មាន ឧបករណ៍ និងសម្ភារប្រើប្រាស់របស់អ្នក (ឧទាហរណ៍៖ ពាក្យសម្ងាត់) មានសុវត្ថិភាពនៅពេល អ្នកប្រើបច្ចេកវិទ្យាឌីជីថល?

**វត្ថុបំណងមេរៀន៖**

- សិស្សនឹងសិក្សាពីអ្នកប្រើប្រាស់អនឡាញដែលមានគំនិតមិនល្អ ដែលព្យាយាមប្រើភាពទន់ខ្សោយផ្នែកសុវត្ថិភាពដើម្បីប្រមូលព័ត៌មានពីពួកគេ។
- សិស្សនឹងមានលទ្ធភាពពិពណ៌នាពីហានិភ័យការប្រើអ៊ីនធឺណិត បង្កើតវិធីប្រើប្រាស់ប្រកបដោយសុវត្ថិភាពជាងមុន កំណត់អត្តសញ្ញាណសារផេតបានការ និងពន្យល់នរណាដែលគួរសុំពាក្យសម្ងាត់របស់ពួកគេ។

**សម្ភារៈ ធនធាន និងការរៀបចំ៖**

- សន្លឹកកិច្ចការ "សារផេតបានការ"
- សន្លឹកកិច្ចការ "សារផេតបានការ" - ច្បាប់ចម្លង
- បោះពុម្ពសន្លឹកកិច្ចការសម្រាប់សិស្សម្នាក់ៗ។

## ហានិភ័យលើប្រព័ន្ធអនឡាញ

និយាយ

**ប្រាប់សិស្សរបស់អ្នក**

នៅពេលអ្នកកំពុងប្រើប្រាស់អ៊ីនធឺណិតអ្នកអាចប្រឈមនឹងហានិភ័យ តាមរយៈសកម្មភាពនៃការចូលប្រើទំព័រវេប ទំនាក់ទំនងតាមអនឡាញ ឬការទាញយកទិន្នន័យ។ ពេលខ្លះវាអាចកើតឡើងចំពោះវេបសាយដែលអ្នកចូលទៅប្រើមនុស្សនៅលើបណ្តាញតែមួយ ឬសូម្បីតែភាគីទីបី ក៏អាចស្វែងរកទីតាំងរបស់អ្នក ឬព័ត៌មានផ្សេងទៀតពីអ្នកនៅពេល ដែលអ្នករុករក។

**សួរសិស្សរបស់អ្នក**

- តើនរណាអាចទាញយកអត្ថប្រយោជន៍ពីភាពងាយរងគ្រោះផ្នែកសុវត្ថិភាពអនឡាញ ដើម្បីមើលព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក?
    - ចម្លើយរំពឹងទុក៖ ពួក Hacker, ការឃ្លាំមើលរបស់រដ្ឋាភិបាល។ល។

### ប្រាប់សិស្សរបស់អ្នក

នៅពេលអ្នកចូលប្រើវេបសាយ វាអាចទៅរួចសម្រាប់ពួក Hacker ដែលមានគំនិតអាក្រក់ក្នុងការប្រមូលទិន្នន័យរបស់អ្នកតាមរបៀបដូចគ្នាដែលអ្នកផ្តល់សេវាអ៊ីនធឺណិត។ ដើម្បីកាត់បន្ថយហានិភ័យនេះ អ្នកត្រូវតែប្រើការតភ្ជាប់ដែលមានសុវត្ថិភាពរវាងអ្នក និងវេបសាយដែលអ្នកកំពុងព្យាយាមចូលប្រើ។ ដោយមិនគិតពីការតភ្ជាប់របស់អ្នក វេបសាយជាច្រើនព្យាយាមតាមដាន លំនាំនៃការប្រើប្រាស់របស់អ្នកនៅលើវេទិកាចម្រុះ។ ពួកគេអាចមើលរុករកទីតាំង និងលំនាំប្រើប្រាស់ផ្សេងទៀតរបស់អ្នកដើម្បីព្យាយាមស្វែងយល់ថាអ្នកជានរណា។

### សួរសិស្សរបស់អ្នក៖

- ហេតុអ្វីបានជាពួក Hacker ព្យាយាមចូលប្រើព័ត៌មានរបស់អ្នកតាមអនឡាញ ?
- តើពួកគេកំពុងស្វែងរកព័ត៌មានអ្វីខ្លះ ?
- តើមានអ្នកណាមួយដឹងថា Malware ជាអ្វី ? តើវាអាចធ្វើអ្វីបាន ?

### ប្រាប់សិស្សរបស់អ្នក៖

Malware គឺជាកូដគ្រោះថ្នាក់ដែលដំណើរការដោយសម្ងាត់នៅលើកុំព្យូទ័ររបស់អ្នក។ Malware មួយចំនួនអាច ប្រមូលទិន្នន័យពីផ្នែកណាមួយនៃកុំព្យូទ័ររបស់អ្នក ចាប់ពីអង្គផ្ទុកទិន្នន័យ (Hard Disk) រហូតដល់ទិន្នន័យរុករក (Browser Data)។ វាក៏អាចអនុញ្ញាតឱ្យពួក Hacker គ្រប់គ្រងកុំព្យូទ័ររបស់អ្នកហើយប្រើវាតាមអ្វីដែលពួកគេចង់។ Malware ភាគច្រើនមានលក្ខណៈសាមញ្ញ ដូចជាវេបសាយដែលចម្លងប្រកសុវត្ថិភាពដូចជាធនាគារ ឬផ្នែកបន្ថែម ដែលដាក់ការផ្សាយពាណិជ្ជកម្មនៅក្នុងកម្មវិធីរុករករបស់អ្នកដើម្បី រកប្រាក់។

### សួរសិស្សរបស់អ្នក៖

តើអ្នកអាចធ្វើអ្វីដើម្បីការពារខ្លួនអ្នកពី Malware ចារកម្ម ឬតាមដាន ?

### ប្រាប់សិស្សរបស់អ្នក៖

សូមប្រយ័ត្នពេលចុចលើតំណ ការផ្សាយពាណិជ្ជកម្ម ឬការបង្ហោះតាមបណ្តាញសង្គម។ តើ URL ត្រូវគ្នានឹងអ្វីដែលអ្នករំពឹងទុកទេ ? តើអ្នកចូលទៅដល់ទំព័រដូចគ្នាដែរឬទេ ? នៅពេលអ្នកវាយវាម្តងទៀតដោយខ្លួនឯង ឬស្វែងរកវេបសាយ ? វិធីល្អមួយគឺថា SSL/TLS គួរតែការពារពេលចូលទំព័រណាមួយសម្រាប់គណនីសំខាន់ៗ (ដូចជា Google, Facebook, Twitter(X) ឬគណនីធនាគារ)។ SSL/TLS ធ្វើឱ្យ Hacker ដែលនៅលើ បណ្តាញតែមួយជាមួយអ្នក ពិបាកធ្វើវេបសាយក្លែងក្លាយមកអ្នក ប្រសិនបើអ្នកវាយបញ្ចូល URL ដែលត្រឹមត្រូវ។ វេបសាយមួយចំនួនអាចដំណើរការកូដដើម្បីចូលប្រើព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ឬគណនីអនឡាញ ប្រសិនបើវេទិកាទាំងនោះមានកំហុសផ្នែកកូដ។ បន្ទាប់មកពួកគេអាចប្រើគណនីរបស់អ្នក ដើម្បីផ្ញើសារឥតបានការទៅអ្នកដទៃ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

គួរទាញយក ឬដំឡើងកម្មវិធីពីប្រភពដែលគួរឱ្យទុកចិត្ត ហើយត្រូវគិតឱ្យបានច្បាស់នៅពេល ដែលអ្នកទាញយកកម្មវិធីដែលអាចដំឡើងបាន (.exe, .pkg, .sh, .dll ឬ .dmg extensions)។ កម្មវិធីដែលអាដំឡើងបាន គឺជាអ្វីដែលអនុញ្ញាតសកម្មភាពមួយមានដំណើរការ (ការដំឡើងកម្មវិធីក្នុងកុំព្យូទ័រ)។ ពេលខ្លះការដំឡើងកម្មវិធីទាំងអស់នេះមិនប្រាកដថាល្អទេ។ ឧទាហរណ៍៖ នរណាម្នាក់អាចសរសេរកម្មវិធីដែលអាចលុបអង្គទិន្នន័យរបស់នរណាម្នាក់ ឬដំឡើងកម្មវិធីរុករកក្លែងក្លាយ។ នេះជាមូលហេតុដែលអ្នកគួរដំឡើង   កម្មវិធីពីប្រភពជឿទុកចិត្តប៉ុណ្ណោះ។ អ្នកអាចប្រើកម្មវិធីកំចាត់មេរោគដើម្បីការពារអ្នកពី Malware ។ កម្មវិធីកំចាត់មេរោគមួយចំនួនភ្ជាប់មកជាមួយ កុំព្យូទ័ររបស់អ្នក (ឧទាហរណ៍៖ Microsoft Security Essentials for Windows ឬ Windows Defender) ប្រព័ន្ធប្រតិបត្តិការមួយចំនួន ដូចជា កុំព្យូទ័រ Apple មានការកំណត់ សុវត្ថិភាពដែលរារាំងកម្មវិធីពីប្រភព ដែលមិនគួរឱ្យទុកចិត្ត។ ចូរគិតដោយប្រុងប្រយ័ត្នមុននឹងកែប្រែការកំណត់ ទាំងនេះ។

អ្នកក៏អាចពិចារណាផ្នែកបន្ថែមរបស់កម្មវិធីរុករកតាមអ៊ីនធឺណិត ដែលអាចទប់ស្កាត់កម្មវិធីជំនួយដែលធ្វើឱ្យវាកាន់តែពិបាកសម្រាប់វេបសាយក្នុងការតាមដាន និងស្វែងយល់ថាអ្នកជានរណា។ ទោះយ៉ាងណាក៏ដោយ កម្មវិធីជំនួយក៏ដូចគ្នានឹងកម្មវិធីបន្ថែមដែលអាចទប់ស្កាត់មុខងារនៃវេបសាយ ដូចជាការមើលវីដេអូជាដើម។ តើអ្នកសម្រេចចិត្តដំឡើង ឬមិនដំឡើងផ្នែកបន្ថែមកម្មវិធីរុករកអាស្រ័យលើ ចំណូលចិត្តរបស់អ្នក និងការដោះដូរដែលអ្នកចង់ធ្វើទាក់ទងនឹងសុវត្ថិភាពអនឡាញ។ អ្នកគួរសួរខ្លួនឯងថា! តើវាពិបាកប៉ុណ្ណាសម្រាប់អ្នកដែលត្រូវបានគេតាមដាន? តើឯកជនភាពរបស់អ្នកមានសារៈសំខាន់កម្រិតណា? តើអ្នកចង់មើលមាតិកានេះកម្រិតណា (ប្រសិនបើផ្នែកបន្ថែមរបស់កម្មវិធីរុករកតាមអ៊ីនធឺណិតរារាំងកម្មវិធីជំនួយដែលបង្ហាញវីដេអូ)?

## ឧបករណ៍សុវត្ថិភាព

*ចំណាំ៖ ផ្នែកមួយនៃខ្លឹមសារនៃសកម្មភាពនេះត្រូវបានគ្របដណ្តប់នៅក្នុង" សកម្មភាពទី១៖ ហានិភ័យលើអ៊ីនធឺណិត"។   យើងពន្យាពេល   ការវិនិច្ឆ័យរបស់អ្នកទាក់ទងនឹងថាតើអ្នក   ចង់ឆ្លងកាត់ម្តងទៀតឬទេ ប្រសិនបើអ្នកបានចូលរួមក្នុងសកម្មភាព ទី១ រួចហើយ ឬរំលងវា។*

### សួរសិស្សរបស់អ្នក៖

អ្នកដឹងទេថា តើមានសុវត្ថិភាព ឬទេ ពេលអ្នកប្រើអ៊ីនធឺណិត?

និយាយ

### ប្រាប់សិស្សរបស់អ្នក៖

វាជាការលំបាក ប្រសិនបើយើងមិនប្រុងប្រយ័ត្ន ហើយមិនចេះការពារខ្លួនពីហានិភ័យអនឡាញទាំងនេះ (អ្វីដែលបានពិពណ៌នានៅក្នុងផ្នែកមុន)។ ហានិភ័យអនឡាញថ្មីលេចឡើងគ្រប់ពេល  ដូច្នេះអ្នកត្រូវប្រុងប្រយ័ត្ន។

## សួរសិស្សរបស់អ្នក៖

- តើពួកគេធ្វើអ្វី ប្រសិនបើពួកគេចង់បញ្ឆោះបញ្ឆួលអ្នក ថាវេបសាយរបស់ពួកគេពិតជាសំខាន់ ?
- ឧបករណ៍ដែលអ្នកអាចប្រើដើម្បីជៀសវាង ឬកាត់បន្ថយហានិភ័យទាំងនេះ។ តើមាននរណាដឹងខ្លះទេ ?

និយាយ

## ប្រាប់សិស្សរបស់អ្នក៖

HTTPS គឺជាស្តង់ដាដែលប្រើដោយវេបសាយ ដើម្បីអ៊ីនគ្រីបទិន្នន័យដែលឆ្លងកាត់អ៊ីនធឺណិត។ ការអ៊ីនគ្រីប អាចការពារភាគីទីបីពីការមើលទិន្នន័យយ៉ាងងាយស្រួលពីការតភ្ជាប់របស់អ្នក។វាផ្តល់នូវស្រទាប់សុវត្ថិភាពបន្ថែម ហើយអាចប្រើនៅក្នុងកម្មវិធីរុករកណាមួយដោយបន្ថែម "https://" នៅពីមុខURL ដែលអ្នកប្រើ (ឧទាហរណ៍ https://www.mysite.com)។ ទោះយ៉ាងណាក៏ដោយ មិនមែនគ្រប់វេបសា ទាំងអស់គាំទ្រ HTTPS ទេ។អ្នកគួរតែបញ្ចូលតែព័ត៌មានសំខាន់ៗ (ឧទាហរណ៍៖ ពាក្យសម្ងាត់ ព័ត៌មានកាតឥណទាន) នៅលើទំព័របណ្តាញដែលមានបុព្វបទ HTTPS://។ អ្នកអាចប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីធានាថាអ្នកតែងតែប្រើ HTTPS គ្រប់ពេល។ កម្មវិធីរុករកសំខាន់ៗ មានសញ្ញាបញ្ជាក់សុវត្ថិភាពដែលមើលទៅដូចជា មេសោនៅជិតរបារអាសយដ្ឋានដើម្បីបង្ហាញពីការតភ្ជាប់ HTTPS។ HTTPS មិនធានាថាអ្នកមានសុវត្ថិភាពទេ ដោយហេតុថាវេបសាយដែលមានភ្ជាប់ជាមួយមេរោគមួយចំនួនក៏អាចគាំទ្រ HTTPS ផងដែរ។ HTTPS ធានា ការតភ្ជាប់ប៉ុន្តែមិនប្រាកដថាវេបសាយនោះមានសុវត្ថិភាពទេ។

Secure Sockets Layer (SSL)/Transport Layer Security (TLS) គឺជាឈ្មោះសម្រាប់បច្ចេកវិទ្យាដែលរក្សា HTTPS ឱ្យមានសុវត្ថិភាព។ SSL/TLS ប្រើសោអ៊ីនគ្រីបឌីជីថល ដែលដំណើរការច្រើនដូចជាកូនសោពិត។ ប្រសិនបើអ្នកបង្កើតឯកសារសម្ងាត់មួយសម្រាប់មិត្ត អ្នកដែលរកឃើញក្រដាសនោះ អាចមើលឃើញអាថ៌កំបាំងរបស់អ្នក។ ផ្ទុយទៅវិញ ស្រមៃថាអ្នកបានផ្តល់ឱ្យពាក្យសម្ងាត់មួយដោយផ្ទាល់ ហើយបន្ទាប់មកផ្ញើឯកសារអាថ៌កំបាំងរបស់អ្នក។ ប្រសិនបើនរណាម្នាក់រកឃើញឯកសារអាថ៌កំបាំងនោះពួកគេនឹងពិបាកបើកមើលឯកសារអាថ៌កំបាំងរបស់អ្នកដោយគ្មានកូនសោ។ ប្រសិនបើនរណាម្នាក់ព្យាយាមជំនួសឯកសារអាថ៌កំបាំងដែលមាន រូបរាងស្រដៀងគ្នាអ្នកនឹងសម្គាល់ឃើញថាសោរបស់អ្នកនឹងមិនដំណើរការទេ។ SSL/TLS ដំណើរការដូចគ្នាប៉ុន្តែជាមួយវេបសាយ សញ្ញាបញ្ជាក់សុវត្ថិភាពនៅលើកម្មវិធីរុករកនឹងទាក់ទងព័ត៌មាន វិញ្ញាបនបត្រទទួលស្គាល់សុវត្ថិភាព (EV) ផងដែរ។ វិញ្ញាបនបត្រទទួលស្គាល់សុវត្ថិភាព ផ្តល់ទៅឱ្យវេបសាយដែលផ្ទៀងផ្ទាត់អត្តសញ្ញាណ របស់ពួកគេទៅស្ថាប័នទទួលស្គាល់វិញ្ញាបនបត្រ។ នៅក្នុងកម្មវិធីរុករកតាម អ៊ីនធឺណិតពេលខ្លះវិញ្ញាបត្រទទួលស្គាល់សុវត្ថិភាព យកទម្រង់នៃឈ្មោះវេបសាយ ឬអង្គភាពចុះឈ្មោះនៅជាប់ របារអាសយដ្ឋាន។ ប្រសិនបើអ្នកសង្ស័យលើខ្លឹមសារនៅលើវេបសាយណាមួយអ្នកអាចពិនិត្យមើលថាតើ URL ក្នុងវិញ្ញាបនបត្រត្រូវគ្នានឹង URL នៅក្នុងកម្មវិធីរុករកតាមអ៊ីនធឺណិតដោយ ចុចលើ "មើលវិញ្ញាបនបត្រ"។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ក្រៅពីការមិនដំឡើងកម្មវិធីពីប្រភពដែលមិនគួរឱ្យទុកចិត្ត កម្មវិធីកំចាត់មេរោគអាចការពារអ្នកពីការចូលទៅទំព័រដែលមិនគួរឱ្យទុកចិត្ត និងទាញយក Malware។ សកម្មភាពនៃ "ការលួចបន្លំ" កើតឡើងជាចម្បងលើអ៊ីមែលពីអ្នកផ្ញើសារផេតបានការដែលដើរតួជាភាគីត្រឹមត្រូវ។ បន្ទាប់មក ពួកគេសួររកពាក្យសម្ងាត់របស់អ្នកដែលពួកគេសង្ឃឹមថាអ្នកនឹងផ្ញើតាមអ៊ីមែល ឬចូលទៅក្នុងវេបសាយក្លែងក្លាយ។ តម្រងសារផេតបានការអាចការពារអ៊ីមែលទាំងនេះមួយចំនួនពីការបង្ហាញនៅក្នុងប្រអប់ទទួលរបស់អ្នក។ ដើម្បីធ្វើឱ្យតម្រងសារផេតបានការប្រសើរជាងមុន ត្រូវប្រាកដថាកំណត់អ៊ីមែលដែលគួរឱ្យសង្ស័យដែលមាននៅក្នុងប្រអប់សាររបស់អ្នកជាសារផេតបានការ។

### សួរសិស្សរបស់អ្នកៈ

តើអ្នកអាចចាត់វិធានការអ្វីខ្លះ ដើម្បីការពារពីការទាញយកឯកសារដែលបង្កគ្រោះថ្នាក់ ដល់កុំព្យូទ័ររបស់អ្នកដោយចៃដន្យ?

និយាយ

### ប្រាប់សិស្សរបស់អ្នកៈ

ពិនិត្យឡើងវិញថា អ្នកកំពុងទាញយកពីវេបសាយដែលគួរឱ្យទុកចិត្តបំផុត។ ***សូមប្រយ័ត្នឱ្យបានខ្ពស់ពីការបើក ឯកសារភ្ជាប់អ៊ីមែលដែលអ្នកមិនស្គាល់ ហើយចុចលើផ្ទាំងព័ត៌មានលេចឡើង និងសារដែលមិនដំណើរការ។*** អ្នកក៏អាចពិចារណា ដំឡើងកម្មវិធីកំចាត់មេរោគល្បីឈ្មោះនៅលើកុំព្យូទ័ររបស់អ្នក។

## ការចែករំលែកពាក្យសម្ងាត់

### សួរសិស្សរបស់អ្នក

- តើនៅពេលណាដែលអ្នកគិតថាអាចចែករំលែកពាក្យសម្ងាត់របស់អ្នកបាទ?
  - ចម្លើយរំពឹងទុកៈ គណនីរួម(ឧទាហរណ៍ៈ Netflix)។
- តើហានិភ័យអ្វីខ្លះ ដែលអាចផ្សារភ្ជាប់នឹងការចែករំលែកពាក្យសម្ងាត់របស់អ្នក?
  - ប្រសិនបើមនុស្សមិនស្គាល់ទទួលបានពាក្យសម្ងាត់របស់អ្នក នោះគណនីរបស់អ្នកអាចត្រូវបានគេលួចចូល។ ការចែករំលែកពាក្យសម្ងាត់របស់អ្នក អាចអនុញ្ញាតនរណាម្នាក់ចូលប្រើបានដោយងាយស្រួល។ ប្រសិនបើពាក្យសម្ងាត់ដូចគ្នានេះប្រើនៅលើវេបសាយផ្សេងទៀត ពួកគេអាចចូលប្រើផងដែរ។

និយាយ

### ប្រាប់សិស្សរបស់អ្នក

ជាស្តង់ដា អនុវត្តដែលអ្នកមិនគួរចែករំលែកពាក្យសម្ងាត់ មួយនរណាម្នាក់ក្រៅពី កម្មវិធីដែលទាមទារពាក្យសម្ងាត់សម្រាប់ចូល។ ដូចដែលបានពិពណ៌នាពីមុន ការលួចបន្លំគឺជាការបោកបញ្ឆោតនរណាម្នាក់ ឱ្យចែករំលែកពាក្យសម្ងាត់របស់ពួកគេ។ ទោះជាយ៉ាងណាក៏ដោយ មនុស្សមួយចំនួនសួររកពាក្យសម្ងាត់ដោយផ្ទាល់ ដើម្បីចូលប្រើគណនីរបស់ អ្នក ដោយអះអាងថាគណនីរបស់អ្នកអាចស្ថិតក្នុងគ្រោះថ្នាក់។ ខណៈពេល

ដែលមនុស្សមួយចំនួនមានចេតនា ល្អ ដូចជាមិត្តភ័ក្តិចង់ជួយមើលអ្វីមួយនៅក្នុងគណនីអ្នក ដែលធ្វើឱ្យអ្នកឆ្ងល់ វាមិនសមហេតុផលទេក្នុងការចែករំលែកពាក្យសម្ងាត់របស់អ្នក ជាពិសេសប្រសិនបើអ្នកប្រើពាក្យសម្ងាត់នោះសម្រាប់គណនីច្រើន។ ប្រសិន បើអ្នកមានគម្រោងចែករំលែកពាក្យសម្ងាត់ សូមប្រាកដថាវាមិនត្រូវបានប្រើនៅគណនីណាផ្សេង ហើយប្រើកម្មវិធីគ្រប់គ្រងពាក្យសម្ងាត់ដើម្បីចែករំលែកការចូលប្រើប្រាស់។ ពេលខ្លះមនុស្សដែលសួររកពាក្យសម្ងាត់ របស់អ្នក អាចជាមនុស្សដែលអ្នកស្គាល់ និងទុកចិត្តដូចជា ឪពុកម្តាយ គ្រូបង្រៀន ឬនិយោជករបស់អ្នក។ ទោះបីជាអ្នកស្គាល់ និងជឿជាក់លើមនុស្សទាំងនេះក៏ដោយជាធម្មតាវាជាបទពិសោធន៍ដ៏ផ្អែមសម្រាប់មនុស្សគ្រប់គ្នាពីមូលហេតុ ដែលពួកគេស្នើសុំ និងរបៀបដែលពួកគេគ្រប់គ្រងពាក្យសម្ងាត់របស់អ្នក។ ជាពិសេសជាមួយមនុស្សនៅក្រៅគ្រួសាររបស់អ្នក វាជាការល្អក្នុងការសួរពួកគេដោយផ្ទាល់ថាតើមានច្បាប់ ឬបទបញ្ញត្តិផ្សេងទៀត ដែលតម្រូវឱ្យអ្នកផ្តល់ពាក្យសម្ងាត់របស់អ្នកដល់ពួកគេដែរឬទេ។

ការសួរសំណួរប្រកបដោយសុជីវធម៌ និងច្បាស់លាស់អំពីច្បាប់ និងបទបញ្ញត្តិខាងលើមានសារៈសំខាន់ណាស់នៅពេលដែល ការសំណើសុំពាក្យសម្ងាត់មកពីមនុស្សដទៃដែលអ្នកមិនស្គាល់ ដូចជាមន្ត្រីអនុវត្តច្បាប់ជាដើម។ ប្រសិនបើអ្នកត្រូវបានសួរដោយមន្ត្រីប៉ូលីស ឬមន្ត្រីរដ្ឋាភិបាលផ្សេងទៀត រកពាក្យសម្ងាត់បណ្តាញសង្គមរបស់អ្នកសូមរក្សាជំហរដោយក្តីគោរព។ ហេតុអ្វីបានជាពួកគេត្រូវការហើយតើច្បាប់ ឬបទបញ្ញត្តិណាមួយដែលតម្រូវឱ្យពួកគេមកទាមទារព័ត៌មាននេះពីអ្នក។ អាស្រ័យលើកាលៈទេសៈនៃសំណើដោយ មាតាបិតា ឬអាណាព្យាបាល គ្រូបង្រៀន និយោជក មន្ត្រីអនុវត្តច្បាប់ មន្ត្រីរដ្ឋាភិបាល ឬមនុស្សផ្សេងទៀតអ្នកប្រហែលជាត្រូវ ផ្តល់ឱ្យពួកគេនូវពាក្យសម្ងាត់របស់អ្នក។ កាលៈទេសៈដែលតម្រូវឱ្យអ្នកផ្តល់ពាក្យសម្ងាត់ រួមមានច្បាប់ ឬបទបញ្ញត្តិដែលតម្រូវឱ្យអ្នកធ្វើដូច្នេះ ឬការវិនិច្ឆ័យរបស់អ្នកថាអត្ថប្រយោជន៍ដែលអ្នកនឹងទទួល បានពីជំនួយរបស់ពួកគេមានលើសពីហានិភ័យ។

ប្រសិនបើនរណាម្នាក់ស្នើសុំពាក្យសម្ងាត់របស់អ្នក ហើយសំណើនោះធ្វើឱ្យអ្នកមិនពេញចិត្ត ស្វែងរកជំនួយពីឪពុកម្តាយ ឬអាណាព្យាបាល និងមនុស្សដែលគួរឱ្យទុកចិត្តផ្សេងទៀត ភ្លាមៗមុនពេលដែលអ្នកត្រូវការឆ្លើយតបទៅនឹងសំណើនោះ។

### ? សួរសិស្សរបស់អ្នក

- តើអ្នកគួរចែករំលែកពាក្យសម្ងាត់របស់អ្នកតាមអ៊ីនធឺណិតនៅពេលណា?
  - ឧទាហរណ៍រំពឹងទុក៖ នៅពេលដែលអ្នកត្រូវបានសួររកពាក្យសម្ងាត់របស់អ្នកនៅលើវេបសាយ ដែលអ្នកកំពុងព្យាយាមចូលប្រើ។
  - កុំចែករំលែកពាក្យសម្ងាត់របស់អ្នកនៅកន្លែងណាផ្សេង រួមទាំងតាមរយៈអ៊ីមែល ដែលជាធម្មតាមិនត្រូវបានអ៊ីនគ្រីប ឬមានសុវត្ថិភាពនោះទេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## កិច្ចការ

### <u>ផ្នែកទី១</u>

### សន្លឹកកិច្ចការ

បែងចែកសិស្សជាពីរ ឬបីក្រុមចែកសន្លឹកកិច្ចការ "Spam" បន្ទាប់មកសូមឱ្យសិស្សបង្កើតតារាងលំហូរដើម្បីបង្ហាញអ្នកដទៃ ពីរបៀបដែលពួកគេអាចកំណត់អត្តសញ្ញាណ សារផេតបានការ និង តើពួកគេគួរចែករំលែក ព័ត៌មាននោះជាមួយបុគ្គល ឬក្រុមមនុស្សជាក់លាក់ដែរឬទេ។

**ប្រាប់សិស្សរបស់អ្នក**

អានសេណារីយ៉ូនីមួយៗ ហើយពិភាក្សា តើសារនីមួយៗជាសារផេតបានការ និង តើអ្នកគួរតែចែករំលែកព័ត៌មានជាមួយមនុស្ស ឬក្រុមមនុស្សនៅក្នុងសេណារីយ៉ូ។

### សកម្មភាពក្នុងថ្នាក់

ទុកពេល ឱ្យសិស្ស ១០នាទី ដើម្បីពិភាក្សា បន្ទាប់មក ឱ្យក្រុមនីមួយៗចែករំលែកចម្លើយរបស់ពួកគេ។

**សួរសិស្សរបស់អ្នក**

តើអ្នកគួរចែករំលែកពាក្យសម្ងាត់របស់អ្នកតាមអ៊ីមែលនៅពេលណា?

**ប្រាប់សិស្សរបស់អ្នក**

ជាការអនុវត្តស្តង់ដាសម្រាប់វេបសាយ និងក្រុមហ៊ុននានាមិនតម្រូវឱ្យសួររក ពាក្យសម្ងាត់របស់អ្នកតាមរយៈអ៊ីមែលឡើយ។ អ្នកមិនគួរផ្ញើពាក្យសម្ងាត់របស់អ្នកទៅនរណាម្នាក់តាមរបៀបនេះទេ ទោះបីជាវាហាក់ដូចជា ប្រភពច្បាស់លាស់ក៏ដោយ អ៊ីមែលស្ទើរតែមិនដែលមានសុវត្ថិភាព។

### <u>ផ្នែកទី ២</u>

ឱ្យសិស្សត្រឡប់ទៅកាន់កន្លែងអង្គុយវិញហើយធ្វើការជាបុគ្គល ទុកពេលឱ្យសិស្ស ១៥នាទី ដើម្បីបង្កើតតារាងលំហូររបស់ពួកគេ។

**ប្រាប់សិស្សរបស់អ្នក**

ឥឡូវនេះ នៅលើសន្លឹកក្រដាសមួយ សូមបង្កើតតារាងលំហូរដើម្បីបង្ហាញបុគ្គលម្នាក់ៗ ពីរបៀបដែលពួកគេអាច កំណត់អត្តសញ្ញាណសារផេតបានការ និងគួរចែករំលែកព័ត៌មាននោះនៅលើអនឡាញជាមួយអ្នកដទៃដែរឬទេ។ វាមានប្រយោជន៍ក្នុងការប្រើសេណារីយ៉ូជាក់លាក់មួយ ដើម្បីផ្អែកលើតារាងលំហូររបស់អ្នក ទាំងសេណារីយ៉ូណាមួយដែលបានបង្ហាញនៅលើសន្លឹកកិច្ចការ (ប្រសិនបើអ្នកជ្រើសរើសធ្វើដូច្នេះសូមសរសេរ

លេខសេណារីយ៉ូខាងលើតារាងលំហូររបស់អ្នក) ឬក៏បង្កើតថ្មីទាំងស្រុង! ប្រសិនបើអ្នកបង្កើតរចនាសេណារីយ៉ូផ្ទាល់ខ្លួនរបស់អ្នក សូមពណ៌នា នៅក្នុងកថាខណ្ឌមួយខាងលើតារាងលំហូររបស់អ្នក។

ទុកពេល ឱ្យសិស្ស ១៥នាទី ដើម្បីបង្កើតតារាងលំហូររបស់ពួកគេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ម៉ូឌុល ៣៖

# *សុខុមាលភាពឌីជីថល*

[កម្មវិធីសិក្សាដែលមានភាពបត់បែន សិស្សដែលមានអាយុ ១៣–១៨ឆ្នាំ]

គន្លឹះ៖

| | |
|---|---|
| (green) | ទទួលបានមាតិកាឌីជីថល |
| (lavender) | ឱកាសក្នុងការផ្លាស់ប្តូរតាមអ្នកប្រើប្រាស់ឌីជីថល |
| (orange) | ឱកាសធ្វើមូលដ្ឋានីយកម្ម (Localization) |

# មាតិកា

មេរៀនទី១៖ កេរ្តិ៍ឈ្មោះនៅលើអនឡាញ .................... 67

មេរៀនទី២៖ បណ្តាញសង្គម និងការចែករំលែក .................... 74

មេរៀនទី៣៖ វត្តមានលើអនឡាញ .................... 82

មេរៀនទី៤៖ ទស្សនៈផ្សេងគ្នា .................... 85

មេរៀនទី៥៖ តើអ្នកចង់ក្លាយជាអ្វី? .................... 90

មេរៀនទី៦៖ ពេលវេលាផ្ទាល់ខ្លួនសម្រាប់មនុស្សវ័យជំទង់ .................... 93

មេរៀនទី៧៖ ពេលវេលាដែលខ្ញុំមានអារម្មណ៍ដឹងគុណ .................... 96

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី១៖ កេរ្តិ៍ឈ្មោះនៅលើអនឡាញ

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ៖** ផ្អែកលើព័ត៌មានរបស់អ្នកលើអនឡាញ តើអ្នកអាចកំណត់ពីវិធីដែលអ្នកដទៃដឹងពីអ្នកដោយវិធីណា?

## វត្ថុបំណងមេរៀន

- សិស្សអាចពិចារណាពីរបៀបដែលព័ត៌មានតាមប្រព័ន្ធអនឡាញសាធារណៈ អាចជួយបង្កើតការយល់ឃើញរបស់អ្នកដទៃមកលើពួកគាត់។
- សិស្សអាចកំណត់អ្នកប្រើប្រាស់ តាមប្រភេទផ្សេងៗនៃការទំនាក់ទំនងតាមអនឡាញ ពិចារណាតើព័ត៌មានអ្វីដែលពួកគេចង់ឱ្យឃើញនៅពេលនរណាម្នាក់ ចង់ស្វែងរកឈ្មោះពួកគេ និងស្វែងយល់ពីវិធីផ្សេងៗឆ្លើយតបនឹងមាតិកាដែលពួកគេមិនពេញចិត្តលើអ៊ីនធឺណិត។

## សម្ភារៈ ធនធាន និងការរៀបចំ

- សន្លឹកកិច្ចការ "តើអ្នកគួរធ្វើអ្វី?"
- សន្លឹកកិច្ចការ - ច្បាប់ចម្លងសម្រាប់គ្រូ "តើអ្នកគួរធ្វើអ្វី?"
- ចែកសន្លឹកកិច្ចការដល់សិស្សម្នាក់ច្បាប់។
- សិស្សត្រូវការចូលប្រើអ៊ីនធឺណិតសម្រាប់មេរៀននេះ។

**តើនរណាដឹងពីអាថ៌កំបាំងរបស់អ្នក?**

**<u>ផ្នែកទី១</u>**

និយាយ

**ប្រាប់សិស្សរបស់អ្នក**

តើអ្នកមានអាថ៌កំបាំងអ្វីខ្លះ? រក្សាអាថ៌កំបាំងនេះនៅក្នុងចិត្តរបស់អ្នក។ អ្នកមិនត្រូវចែករំលែកអាថ៌កំបាំងនេះជាមួយនរណាម្នាក់ ឬសរសេរវានោះទេឡើយ។ ឥលូវឆ្លើយសំណួរទាំងនេះក្នុងចិត្តរបស់អ្នក សូមកុំប្រាប់ចម្លើយរបស់អ្នក ឬសរសេរវា៖

- តើមានមនុស្សប៉ុន្មាននាក់នៅក្នុងថ្នាក់រៀននេះដឹងពីអាថ៌កំបាំងរបស់អ្នក?
- តើមានអ្នកជិតខាងប៉ុន្មាននាក់ដឹងពីអាថ៌កំបាំងរបស់អ្នក?
- តើមានមនុស្សប៉ុន្មាននាក់ដែលអ្នកមិនធ្លាប់ស្គាល់ ដឹងពីអាថ៌កំបាំងរបស់អ្នក?

សូមស្រមៃថា អ្នកបានសរសេរអាថ៌កំបាំងនៅលើក្រដាសមួយច្បាប់ ហើយសមាជិកក្រុមម្នាក់នៅក្នុងក្រុមនេះបានអានវា។ ខាងក្រោមនេះគឺជាសំណួរមួយចំនួន ដែលអ្នកត្រូវឆ្លើយវានៅក្នុងចិត្ត ឬមិនចាំបាច់សរសេរនៅលើក្រដាស។

**មួយសប្តាហ៍ក្រោយមក៖**

- តើមានមនុស្សប៉ុន្មាននាក់នៅក្នុងថ្នាក់រៀននេះអាចដឹងពីអាថ៌កំបាំងរបស់អ្នក?

- តើមានអ្នកជិតខាងប៉ុន្មាននាក់អាចដឹងពីអាថ៌កំបាំងនោះ ?
- តើមានមនុស្សប៉ុន្មាននាក់ដែលអ្នកមិនធ្លាប់ស្គាល់ អាចដឹងពីអាថ៌កំបាំងនោះ ?

## ផ្នែកទី ២

### ប្រាប់សិស្សរបស់អ្នក

ចូរអ្នកគិតពីមនុស្សដែលមើលឃើញអាថ៌កំបាំង ឬព័ត៌មានរបស់អ្នកគឺជា "ទស្សនិកជន"។ ការស្គាល់ច្បាស់ពីទស្សនិកជនរបស់អ្នក អាចជួយឱ្យអ្នកកំណត់បានពីព័ត៌មានដែលអ្នកចង់ ឬមិនចង់ចែករំលែក។

ទស្សនិកជនបង្កើតឡើងដោយមនុស្សម្នាក់ ឬមនុស្សមួយក្រុម ដែលអាចចូលមើលព័ត៌មានជាក់លាក់។ ជាមួយបច្ចេកវិទ្យាថ្មីៗនាពេលបច្ចុប្បន្ននេះ ទស្សនិកជនអាចកើនឡើងយ៉ាងឆាប់រហ័ស។ ដោយសារតែកំណើនទស្សនិកជននេះហើយ វាបានបង្កភាពលំបាកដល់អ្នកក្នុងការកំណត់ទស្សនិកជនចំពោះព័ត៌មាន និងសកម្មភាពតាមអនឡាញរបស់អ្នក។ វាល្អដែលមានទស្សនិកជនកើនឡើងឆាប់រហ័ស ពេលអ្នកចង់ចែករំលែកការងាររបស់អ្នកទៅកាន់មនុស្សច្រើន ប៉ុន្តែវាមិនល្អទេនៅពេលដែលអ្នកចង់រក្សាទុកព័ត៌មានជាលក្ខណៈឯកជន។

ព័ត៌មានឯកជន ជាពិសេសព័ត៌មានគួរឱ្យអាម៉ាស់ គឺតែងតែធ្វើឱ្យមនុស្សរំជួលចិត្តនៅពេល ដែលពួកគេបានឃើញវា ដូច្នេះនៅពេលដែលព័ត៌មានប្រភេទនេះមានវត្តមានលើអនឡាញ វាមានភាពលំបាកណាស់ក្នុងការគ្រប់គ្រងអ្នកឃើញមាតិកាទាំងអស់នោះ។ រាល់ពេល ដែលអ្នកចែករំលែកព័ត៌មាននៅលើអនឡាញ (សូម្បីតែធ្វើដោយផ្ទាល់ជាមួយមនុស្សម្នាក់ដូចជាក្នុងសារ ឬសារឯកជន) អ្នកគួរតែត្រៀមខ្លួនពីលទ្ធផល ដែលព័ត៌មាននោះអាចបែកធ្លាយដល់ទស្សនិកជនដែលអ្នកមិនមានបំណងឱ្យឃើញ។

## ផ្នែកទី ៣

### សួរសិស្សរបស់អ្នក

- នៅពេលអ្នកបង្ហោះ ធ្វើបច្ចុប្បន្នភាពស្ថានភាព រូបថត ឬព័ត៌មានផ្សេងៗនៅលើបណ្តាញសង្គម តើនរណាខ្លះជាទស្សនិកជន ដែលអ្នកចង់ឱ្យឃើញ ?
- តើវាអាស្រ័យលើបណ្តាញសង្គមដែរឬទេ ? ឬទៅតាមបរិបទ ?

### ប្រាប់សិស្សរបស់អ្នក

ផ្អែកលើការកំណត់ឯកជនភាពរបស់អ្នក ក៏ដូចជាវេទិកា (Platform) បណ្តាញសង្គមដែលអ្នកជ្រើសរើស ប៉ុន្តែទស្សនិកជនរបស់អ្នកអាចមានតែមិត្តជិតស្និទ្ធ ឬអ្នកតាមដាន (Followers) ឬការភ្ជាប់ទំនាក់ទំនងរបស់អ្នក ឬទូលំទូលាយជាងនេះដើម្បីឱ្យមនុស្សគ្រប់គ្នាដែលប្រើបណ្តាញសង្គមនោះ ឬនរណាផ្សេងទៀតដែលស្វែងរកអ្នកតាមអនឡាញ។ ប៉ុន្តែមិនថាទស្សនិកជនជានរណាទេ ព័ត៌មានអាចចម្លង និងបង្ហោះនៅកន្លែងផ្សេងៗទៅកាន់អ្នកផ្សេង អាចមាននរណាម្នាក់ថតរូប ឬថតអេក្រង់មាតិកា ឬចែករំលែកតាមរយៈការសន្ទនាផ្ទាល់ និងតាមអនឡាញ។

### សួរសិស្សរបស់អ្នក

- តើនរណាគឺជាទស្សនិកជន ដែលអ្នកចង់ឱ្យឃើញពេល អ្នកបន្ថែមមាតិកានៅលើបណ្តាញសង្គម ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- អ្នកបង្ហោះសារនៅលើ Facebook Timeline របស់នរណាម្នាក់ផ្សេងទៀត ឬនៅពេលដែលអ្នកបន្ថែមមាតិកាបណ្តាញសង្គមរបស់នរណាម្នាក់ (ឧទាហរណ៍៖ បញ្ចេញមតិលើរូបភាពណាមួយរបស់ពួកគេ ភ្ជាប់ពួកគេក្នុងការបង្ហោះ ឬរូបភាព)។

### ប្រាប់សិស្សរបស់អ្នក

អាស្រ័យលើការកំណត់ឯកជនភាពរបស់អ្នក និងរបស់ពួកគេ ប៉ុន្តែជាញឹកញាប់ខ្លឹមសារទាំងនេះនឹងអាចមើលឃើញដោយមិត្តភ័ក្តិ ឬទស្សនិកជន ឬអ្នកភ្ជាប់ ដែលរួមបញ្ចូលមនុស្សដែលអ្នកមិនស្គាល់ វាអាចមានសមាជិកគ្រួសាររបស់ពួកគេ អ្នករដ្ឋបាល ឬគ្រូបង្រៀននៅសាលារៀនរបស់ពួកគេ។

### សួរសិស្សរបស់អ្នក

នៅពេលអ្នកផ្ញើសារ (ឧទាហរណ៍៖ អត្ថបទ អ៊ីមែល សារឯកជន ឬផ្ទាល់នៅលើបណ្តាញសង្គម) តើនរណាជាទស្សនិកជន ដែលអ្នកចង់ឱ្យឃើញ?

### ប្រាប់សិស្សរបស់អ្នក

ទស្សនិកជនរបស់អ្នកគឺជាមនុស្សដែលអ្នកផ្ញើទៅ ប៉ុន្តែត្រូវប្រយ័ត្ន អ្នកផ្សេងទៀតអាចឃើញផងដែរ ។

### សួរសិស្សរបស់អ្នក

- តើសាររបស់អ្នកអាចទៅដល់មនុស្សផ្សេងពីអ្នកដែលអ្នកផ្ញើវាទៅដោយរបៀបណា? មធ្យោបាយដែលអាចធ្វើបានរួមមានតាមរយៈរូបថត ឬរូបថតអេក្រង់ ការបញ្ជូនបន្ត និងការចែករំលែកតាមទូរសព្ទដោយផ្ទាល់។
- តើករណីណាខ្លះ ដែលសាររបស់អ្នកអាចទៅដល់អ្នកអានច្រើន ហើយមានប្រយោជន៍? ឧទាហរណ៍៖ មានគោលដៅផ្សព្វផ្សាយសារទៅកាន់អ្នកអានច្រើន កៀរគរមនុស្ស ឬបង្កើនការយល់ដឹង។
- តើករណីណាខ្លះ ដែលអាចបង្កជាបញ្ហា នៅពេលដែលអ្នកអានកើនឡើងច្រើនលើសការគ្រោង? ការចែករំលែកលើសពីអ្នកអាន ដែលអ្នកមានបំណងចង់ឱ្យឃើញអាចធ្វើឱ្យអ្នកមានបញ្ហា បង្កភាពអាម៉ាស់ ប៉ះពាល់ដល់កេរ្តិ៍ឈ្មោះ។
- តើស្ថានភាពណាខ្លះដែលការរក្សាកេរ្តិ៍ឈ្មោះល្អតាមអនឡាញមានសារសំខាន់? ឧទាហរណ៍៖ ការដាក់ពាក្យទៅសាលា មហាវិទ្យាល័យ ឬសាកលវិទ្យាល័យ ការសុំការងារធ្វើ និងបង្កើតមិត្តថ្មីៗ។

## ការស្រាវជ្រាវកេរ្តិ៍ឈ្មោះរបស់អ្នក

### <u>ផ្នែកទី ១</u>

### សកម្មភាពក្នុងថ្នាក់

គ្រូជ្រើសរើសបុគ្គលល្បីល្បាញម្នាក់ (Public Figure) (ឧទាហរណ៍៖ ជនល្បីល្បាញនៅក្នុងវិស័យសិល្បៈ ឥស្សរជននយោបាយ ឬប្រធានអាជីវកម្ម) ដែលសិស្សស្គាល់។ រកមើលឈ្មោះរបស់បុគ្គលល្បីល្បាញលើម៉ាស៊ីនស្វែងរកតាមអនឡាញជាមួយសិស្ស សូមពិនិត្យមើលលក្ខណៈមួយចំនួនដែលបង្ហាញឡើង (សូមបង្ហាញលទ្ធផលស្រាវជ្រាវនៅលើក្តារខៀន)។ ស្វែងរកពីវត្តមានបណ្តាញសង្គមរបស់បុគ្គលនោះ។ បន្ទាប់ពីបានចំណាយពេលស្វែងរករយៈពេល ពីរ ឬបីនាទី ឱ្យសិស្សពីរនាក់ឡើងបង្ហាញពីបុគ្គលសាធារណៈ និងអ្នកគាំទ្រ។

### សួរសិស្សរបស់អ្នក

- តើមានអារម្មណ៍យ៉ាងណាពេល អ្នកជួបនរណាម្នាក់ដោយចៃដន្យ ដែលដឹងព័ត៌មានជាច្រើនពីខ្លួនអ្នក?
- តើអ្នកមានអារម្មណ៍យ៉ាងណា ប្រសិនបើព័ត៌មាននោះមិនត្រឹមត្រូវ?
- តើមានមនុស្សប៉ុន្មាននាក់ដែលអាចចូលប្រើព័ត៌មាននេះបាន?
- តើអ្នកអាចគ្រប់គ្រងព័ត៌មានអ្វីខ្លះអំពីខ្លួនឯង ដែលមាននៅលើអនឡាញដោយរបៀបណា?

## ផ្នែកទី ២

### ប្រាប់សិស្សរបស់អ្នក

មនុស្សដែលអ្នកជួបនឹងប្រើម៉ាស៊ីនស្វែងរកដើម្បីទទួលបានព័ត៌មានបន្ថែមពីអ្នក។ អ្វីដែលគេរកឃើញល្អ ឬអាក្រក់នឹងប៉ះពាល់ដល់ការគិតរបស់គេមកលើអ្នក។ ប្រសិនបើអ្នកចង់ពិនិត្យមើលលើរបៀបដែលពួកគេយល់ឃើញពីអ្នកវាជារឿងសំខាន់សម្រាប់អ្នកដឹងព័ត៌មានដែលពួកគេចង់ឃើញ។

មនុស្សទាំងនេះរួមមាននិយោជកនាពេលអនាគត និងមន្ត្រីនៅសាលា ឬសាកលវិទ្យាល័យ។ មន្ត្រីទទួលបន្ទុកចុះឈ្មោះចូលរៀនអាចមិនប្រាប់ ថាតើពួកគេរកមើលឃើញព័ត៌មានអ្នកតាមប្រព័ន្ធអនឡាញទេ ប៉ុន្តែពួកគេនឹងប្រើប្រាស់ព័ត៌មានទាំងនោះក្នុងការសម្រេចចិត្ត។

## ផ្នែកទី ៣

### សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សធ្វើការជាដៃគូ។

### ប្រាប់សិស្សរបស់អ្នក

ចូរបំផុសគំនិតបីយ៉ាង ដែលអ្នកចង់បង្ហាញ នៅពេលនរណាម្នាក់ ស្វែងរកឈ្មោះរបស់អ្នកតាមអនឡាញ។ តើអ្នកគិតថារឿងទាំងនេះនឹងបង្ហាញឡើងក្នុងលទ្ធផលស្រាវជ្រាវបែបណា? ចែករំលែកជាមួយដៃគូរបស់អ្នក។

### សួរសិស្សរបស់អ្នក

- តើអ្នក និងដៃគូរបស់អ្នកមានគំនិតអ្វីខ្លះ?
- សូមលើកដៃ ប្រសិនបើអ្នកបានស្វែងរកឈ្មោះខ្លួនឯង តាមអនឡាញ។ តើអ្នកបានឃើញអ្វីឬទេ? តើមានរូបថតអ្វីខ្លះបង្ហាញឡើងឬទេ? តើអ្នកអាចស្វែងរកព័ត៌មានផ្ទាល់ខ្លួនរបស់អ្នក ឬមានមនុស្សផ្សេងទៀតក្នុងពិភពលោកបានចែករំលែកឈ្មោះរបស់អ្នកឬទេ?
- បើគេមានឈ្មោះរួមមួយ ឱ្យសិស្សបន្ថែមព័ត៌មានក្នុងការស្វែងរករបស់ពួកគេ ដូចជាស្រុកកំណើត ឬឈ្មោះសាលារបស់ពួកគេ។
- អ្នកក៏អាចឱ្យសិស្សទៅចូលកម្មវិធី Google ដោយខ្លួនឯង ឬស្វែងរកឈ្មោះរបស់ពួកគេតាមអនឡាញកំឡុងពេល សកម្មភាពនេះសិស្សអាចប្រើកុំព្យូទ័រ ឬទូរសព្ទឆ្លាតដែលមានភ្ជាប់អ៊ីនធឺណិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### សួរសិស្សរបស់អ្នក

នៅពេល អ្នកស្វែងរកឈ្មោះរបស់អ្នកតាមអនឡាញ សូមសួរសំណួរខាងក្រោមនេះ៖

- តើលទ្ធផលដំបូងជាអ្វីខ្លះ?
- តើអ្នករីករាយជាមួយព័ត៌មាននេះដែរឬទេ?
- តើលទ្ធផលផ្សេងទៀតបង្ហាញអ្វីខ្លះ ដែលបញ្ជាក់ថាអ្នកជាមនុស្សម្នាក់ ឬជាសិស្សម្នាក់ ឬជាបុគ្គលិកម្នាក់?
- តើអ្នកដែលមិនស្គាល់អ្នកមានចំណាប់អារម្មណ៍ដូចម្ដេច នៅពេលដែលឃើញលទ្ធផលទាំងអស់នោះ? តើពួកគេមានចំណាប់អារម្មណ៍ដូចម្ដេច នៅពេល ដែលពួកគេបានចុច និងអានព័ត៌មានដែលមានក្នុងលទ្ធផលនោះ?

## ឆ្លើយតបទៅនឹងព័ត៌មានស្មុគស្មាញ

### សកម្មភាពក្នុងថ្នាក់

ចែកសន្លឹកកិច្ចការ "តើអ្នកគួរធ្វើអ្វី?"។ ឱ្យសិស្សធ្វើការជាដៃគូ រួចពិភាក្សាពីសេណារីយ៉ូនៅលើសន្លឹកកិច្ចការហើយបង្កើតយុទ្ធសាស្ត្រ ឬដំណោះស្រាយចំនួនពីរ សម្រាប់សេណារីយ៉ូនីមួយៗ និងគិតពីផលវិបាកដែលអាចកើតមានសម្រាប់សកម្មភាពរបស់ពួកគេ។ ទុកពេល ១៥នាទី ធ្វើកិច្ចការនេះ។

### សួរសិស្សរបស់អ្នក

- តើអ្នកគួរធ្វើយ៉ាងណានៅពេល នរណាម្នាក់បង្ហោះខ្លឹមសារអំពីអ្នកដែលអ្នកមិនចូលចិត្ត ឬរកឃើញថាមិនសមរម្យក្នុងបរិបទនោះ?
- តើអ្នកគួរគិតពីអ្វីខ្លះ មុននឹងបង្ហោះព័ត៌មានរបស់អ្នកផ្សេង?

## ឆ្លើយតបទៅនឹងព័ត៌មានអវិជ្ជមាន

<u>ផ្នែកទី១</u>

### សួរសិស្សរបស់អ្នក

- ប្រសិនបើអ្នករកឃើញព័ត៌មានអវិជ្ជមានពីខ្លួនអ្នក ពេលអ្នកស្វែងរកឈ្មោះរបស់អ្នកតាមអនឡាញ (ឧទាហរណ៍៖ តាមរយៈម៉ាស៊ីនស្វែងរក ឬនៅលើបណ្ដាញសង្គម) តើអ្នកនឹងធ្វើអ្វីខ្លះ?
- ចូរលើកឧទាហរណ៍ តើខ្លឹមសារអ្វីខ្លះដែលអ្នកមិនចង់ឱ្យអ្នកដទៃមើលឃើញ?

<u>ផ្នែកទី ២</u>

### ប្រាប់សិស្សរបស់អ្នក

មានវិធីសាស្ត្រផ្សេងៗគ្នាជាច្រើនទៀតដែលអ្នកអាចធ្វើបាន ប្រសិនបើអ្នកជួបប្រទះមាតិកាអនឡាញពីខ្លួនអ្នក ដែលអ្នកមិនពេញចិត្ត (អាស្រ័យតាមបរិបទ និងប្រភេទនៃព័ត៌មាន) ក្នុងចំណោមកត្តាផ្សេងៗទៀត។

វិធីសាស្ត្រមួយគឺ "ការនិយាយបកស្រាយ" ដែលមានន័យថាទាក់ទាញចំណាប់អារម្មណ៍ ឬបង្វាញពីរឿងវិជ្ជមានពីខ្លួនអ្នកដោយបង្កើត និងគ្រប់គ្រងខ្លឹមសារដែលឆ្លុះបញ្ចាំងអ្នកនៅក្នុងជីវិតពិត។ ឧទាហរណ៍៖

អ្នកអាចធ្វើដូចនេះបាន ដោយបង្ហាញវត្តមានលើបណ្ដាញសង្គមនៅពេលសមស្រប ចាប់ផ្ដើមបង្កើតប្លុក (Blog) ឬបង្កើតវេបសាយដោយប្រើឈ្មោះរបស់អ្នក។

វិធីសាស្ត្រទីពីរ រួមមានការវាស់វែងផ្សេងគ្នាដើម្បីលុបមាតិកាអវិជ្ជមានចេញ។ ឧទាហរណ៍៖ ប្រសិនបើអ្នកឃើញមាតិកាដែលអ្នកមិនចូលចិត្ត (រូបថតរបស់អ្នក) អ្នកអាចព្យាយាមទាក់ទងដោយផ្ទាល់ទៅបុគ្គលដែលបានបង្ហោះវា (ជាពិសេសនៅលើបណ្ដាញសង្គម ឬកម្មវិធីផ្ញើសារ) ដើម្បីស្នើគាត់ឱ្យលុបមាតិកានោះចេញ។

វេទិកាជាច្រើនផ្ដល់ផ្ទាំងព័ត៌មានដែលអ្នកមានអារម្មណ៍ រំខាន ឬមាតិកាដែលមិនចាប់អារម្មណ៍ (ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះជាអត្ថបទ) ដែលបង្ហាញអ្នកក្នុងន័យអវិជ្ជមាន ឬមិនមានទំនុកចិត្ត មាតិកាដែលមិនគួរមាននៅលើវេទិកា (ឧទាហរណ៍៖ ការប្រមាថ ហិង្សា ឬត្រូវហាមឃាត់) ហើយមាតិកាដែលបង្ហាញឡើង ជាការបោកប្រាស់។ បន្ទាប់មក វេទិកាត្រួតពិនិត្យ និងផ្ទៀងផ្ទាត់លក្ខខណ្ឌនៃសេវាកម្ម និងបទដ្ឋានសហគមន៍ (Terms of Service and Community Norms)។

ក្នុងករណីខ្លះ អ្នកមានដំណោះស្រាយផ្លូវច្បាប់ ដែលអាចធ្វើបាន ឧទាហរណ៍ការដាក់ពាក្យបណ្ដឹងនៅតុលាការ ពឹងលើយុត្តាធិការ (Jurisdiction) និងច្បាប់ដែលអាចអនុវត្តបាន (ឧទាហរណ៍៖ ករណីខ្លះពីការជ្រៀតជ្រែកឯកជនភាព ឬសេចក្ដីថ្លែងការណ៍មិនពិតដែលធ្វើឱ្យខូចកេរ្តិ៍ឈ្មោះរបស់នរណាម្នាក់)។ ប្រទេសមួយចំនួនមានច្បាប់ជាក់លាក់ ដែលតម្រូវឱ្យវេទិកាខ្លះត្រូវដកចេញនូវមាតិកាមួយចំនួន ដែលមិនស្របច្បាប់ដោយមានការជូនដំណឹង (ឧទាហរណ៍៖ Network Enforcement Act ក្នុងប្រទេសអាល្លឺម៉ង់) ឬនាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា (Anti Cyber Crime Department) នៅប្រទេសកម្ពុជា។

**សូមចំណាំ៖** ពេលខ្លះការព្យាយាមទប់ស្កាត់ ដកចេញ ឬកែតម្រូវមាតិកាអាចទាក់ទាញការយកចិត្តទុកដាក់កាន់តែខ្លាំង ចំពោះព័ត៌មាន។

**<u>ផ្នែកទី ៣</u>**

## ប្រាប់សិស្សរបស់អ្នក

លើសពីនេះទៅទៀត ប្រជាជនដែលរស់នៅសហភាពអឺរ៉ុប (EU) មានច្បាប់មួយគឺ "សិទ្ធិក្នុងការលុប" ដែលស្គាល់ជាទូទៅថាជា "សិទ្ធិក្នុងការបំភ្លេចចោល" (សិទ្ធិនេះនៅតែអនុវត្តទោះបីជាពួកគេកំពុងធ្វើដំណើរ ឬរស់នៅក្រៅសហភាពអឺរ៉ុបក៏ដោយ)។ ចំពោះសិទ្ធិនេះស្ថិតក្នុងបទប្បញ្ញត្តិការពារទិន្នន័យទូទៅ (General Data Protection Regulation) ប្រជាជននៅសហភាពអឺរ៉ុបអាចស្នើសុំឱ្យ "អ្នកត្រួតពិនិត្យទិន្នន័យ" លុបព័ត៌មានមួយចំនួនពីពួកគេ។ ("អ្នកត្រួតពិនិត្យទិន្នន័យ" គឺជាអ្នកធ្វើជំនួញ ប្រជាជន ភ្នាក់ងាររដ្ឋាភិបាល និងអ្នកផ្សេងទៀត ដែលធ្វើការសម្រេចចិត្តពីរបៀបប្រើប្រាស់ព័ត៌មានរបស់បុគ្គល។)

ហេតុផល ៦យ៉ាង ដែលប្រជាជនក្នុងសហភាពអឺរ៉ុបអាចស្នើសុំឱ្យលុបព័ត៌មានពួកគេបាន។ ហេតុផលទាំងនេះស្របតាមកាលៈទេសៈជាច្រើន។ ឧទាហរណ៍៖ ហេតុផលមួយក្នុងចំណោមនោះគឺព័ត៌មានអំពី "កុមារ" ដែលការសម្រេចចិត្តថាវាមានហានិភ័យខ្លាំងចំពោះការចែករំលែកព័ត៌មានប្រភេទនេះ។ ប្រហែលជាគ្មានហេតុផល ដែលយុវជនអាយុ ២៥ឆ្នាំ សម្រេចចិត្តថាពួកគេចង់លុបព័ត៌មានដែលគេចែករំលែកនៅពេល អាយុ ១៦ឆ្នាំទេ។ វាក៏មានដែនកំណត់ផងដែរអំពីសិទ្ធិក្នុងការលុបបំបាត់។ មានហេតុផល៥យ៉ាង ដែលការស្នើសុំលុបនឹងត្រូវបដិសេធ។ មូលហេតុនៃការប្រានចោលមានលក្ខណៈទូលំទូលាយ ដែលគ្របដណ្ដប់លើស្ថានភាពជា

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

ច្រើនប្រភេទ។ យើងនិយាយពីហេតុផលសំខាន់ចំពោះការបដិសេធ (គឺដើម្បីការពារសិទ្ធិនិយាយដោយសេរី) ក្នុងរយៈពេល ពីរ ឬបីនាទី។

GDPR (The General Data Protection Regulation) បានចូលជាធរមាននៅថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៨។ ការចំណាយពេលវេលាច្រើនជាមួយ GDPR ឱ្យចូលជាធរមាន យើងរៀនច្រើនពីរបៀបដែលប្រជាជនសហភាពអឺរ៉ុបប្រើប្រាស់សិទ្ធិរបស់ពួកគេលុបព័ត៌មាន និងរបៀបដែលក្រុមហ៊ុន ភ្នាក់ងាររដ្ឋាភិបាល និងក្រុមផ្សេងទៀតឆ្លើយតប។

## <u>កិច្ចការ</u>

និយាយ

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ យើងនិយាយពីរបៀបព័ត៌មានអនឡាញជាសាធារណៈ ជួយបង្កើតមតិពីមនុស្សផ្សេងទៀត យើងយកអ្វីដែលអ្នកទើបតែបានរៀនមកអនុវត្ត។ ក្នុងរយៈពេល ៣០នាទី សិស្សធ្វើការជាបុគ្គលចូលរួមសកម្មភាពខាងក្រោម។

ជ្រើសរើសបុគ្គលល្បីល្បាញម្នាក់ (ឧទាហរណ៍៖ នរណាម្នាក់នៅក្នុងវិស័យសិល្បៈ ឥស្សរជននយោបាយ អ្នកដឹកនាំអាជីវកម្ម)។ រកព័ត៌មានដែលមានជាសាធារណៈពីបុគ្គលនោះលើបណ្តាញអនឡាញ ហើយពន្យល់ ក្នុងកថាខណ្ឌខ្លីមួយពីរបៀបដែលព័ត៌មាននេះបានជួយអ្នកបង្កើតជាគំនិតពីបុគ្គលនេះ។ ប្រសិនបើអ្នកផ្តល់អនុសាសន៍ចំនួន៤ ដល់បុគ្គលនេះ ពីរបៀបដែលព័ត៌មានរបស់ពួកគេមាននៅលើអនឡាញខុសៗគ្នា (ឧទាហរណ៍៖ ការផ្លាស់ប្តូរការកំណត់ឯកជនភាព ទស្សនិកជន ខ្លឹមសារនៃមាតិកា) និងមិនអាចផ្លាស់ប្តូរបាន (ឧទាហរណ៍៖ បានលុបចេញ) ជាវិធីដើម្បីលើកកម្ពស់កេរ្តិ៍ឈ្មោះបុគ្គលនោះនៅលើអនឡាញ។ តើគេនឹងយល់យ៉ាងម៉េចពីគាត់?

# មេរៀនទី២៖ បណ្តាញសង្គម និងការចែករំលែក

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ៖** តើអ្នកគួរបង្ហោះព័ត៌មានអ្វីខ្លះនៅលើបណ្តាញសង្គម?

## វត្ថុបំណងមេរៀន

- សិស្សអាចពិចារណាពីឯកជនភាពទាក់ទងនឹងរបៀបដែល ពួកគេចែករំលែកព័ត៌មាន និងទំនាក់ទំនងជាមួយអ្នកដទៃតាមអនឡាញ ជាពិសេសទាក់ទងនឹងការប្រើប្រាស់បណ្តាញសង្គម។
- សិស្សមានលទ្ធភាពពន្យល់ពីតម្លាភាពនៃឯកជនភាពក្នុងបរិបទបណ្តាញសង្គម និងរៀនពីរបៀបប្រើប្រាស់ការកំណត់ឯកជនភាពលើអនឡាញប្រកបដោយប្រសិទ្ធភាព។

## ការរៀបចំ ធនធាន និងសម្ភារៈ

- បិទស្លាកសញ្ញា**យល់ព្រម** និង**មិនយល់ព្រម** ទៅជ្រុងម្ខាងនៃបន្ទប់។
- វីដេអូផ្ទុះការចាប់អារម្មណ៍ពាក់ព័ន្ធនឹងសហគមន៍របស់អ្នក។

## ការប្រើប្រាស់បណ្តាញសង្គម

មុននឹងធ្វើសកម្មភាពនេះ សូមបិទស្លាកសញ្ញា **"យល់ព្រម"** និង **"មិនយល់ព្រម"** នៅជ្រុងម្ខាងនៃបន្ទប់។

### ប្រាប់សិស្ស

ឱ្យសិស្សដឹងថានៅពេល អ្នកអានកថាខណ្ឌនីមួយៗ ពួកគេឈរនៅជ្រុងនៃស្លាកខាងលើ អាស្រ័យលើការសម្រេចចិត្តរបស់ពួកគេ សិស្សអាចឈរនៅចំណុចកណ្តាលសញ្ញាទាំងពីរ ប្រសិនបើពួកគេមិនទាន់បានសម្រេចចិត្ត។

## សកម្មភាពក្នុងថ្នាក់

នៅរវាងស្ថានភាពនោះ ឱ្យសិស្សចូលរួមក្រុមពិភាក្សាពីមូលហេតុដែលពួកគេជ្រើសរើសសញ្ញាទាំងពីរខាងលើ។

### ប្រាប់សិស្សរបស់អ្នក

ខ្ញុំនឹងអានល្បះកថាខណ្ឌមួយ ប្រសិនបើអ្នកយល់ព្រម ១០០ភាគរយ សូមដើរទៅសញ្ញា "យល់ព្រម" ប្រសិនបើអ្នកមិនយល់ព្រម សូមដើរទៅសញ្ញា "មិនយល់ព្រម"។ បើអ្នកមិនប្រាកដសូមដើរទៅទីតាំងកណ្តាលដែលបង្ហាញពីទស្សនរបស់អ្នក។

- ខ្ញុំមានគណនីលើវេទិកាបណ្តាញសង្គមដូចជា Facebook, WhatsApp, TikTok, Telegram, Discord, Twitter (X), Instagram, Line, ។
- ខ្ញុំប្រើប្រាស់បណ្តាញសង្គមជារៀងរាល់ថ្ងៃ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- ព័ត៌មានផ្ទាល់ខ្លួនរបស់ខ្ញុំលើបណ្តាញសង្គម ភាគច្រើនដាក់បង្ហាញជាសាធារណៈ។
- ខ្ញុំមានមិត្តភ័ក្តិ អ្នកតាមដាន ឬភ្ជាប់ទំនាក់ទំនងផ្សេងៗគ្នា នៅលើវេទិកាបណ្តាញសង្គមផ្សេងៗ ដែលខ្ញុំប្រើប្រាស់ (និយាយឱ្យខ្លី មានទស្សនិកជនផ្សេងគ្នា) ។
- ជំនាន់របស់ខ្ញុំ មានវិធីគិតផ្សេងគ្នាពីព័ត៌មានដែលបានចែករំលែកនៅលើបណ្តាញសង្គម បើប្រៀបធៀបជាមួយជំនាន់ផ្សេង។
- ខ្ញុំប្រើប្រាស់វេទិកាបណ្តាញសង្គមផ្សេងៗគ្នាចំពោះការបង្ហោះទៅតាមប្រភេទមាតិកា។

**វិសាលគមសំណើមិត្តភ័ក្តិ(Friend Request Spectrum)**

**<u>ផ្នែកទី១</u>**

**ប្រាប់សិស្សរបស់អ្នក**

វេទិកាបណ្តាញសង្គម គឺជាវេទិកាអនឡាញដែលអ្នកអាចប្រើប្រាស់ភ្ជាប់ទំនាក់ទំនងជាមួយមនុស្ស និងអន្តរកម្មជាមួយពួកគេ។

**សួរសិស្ស**

តើវេទិកាបណ្តាញសង្គមណាខ្លះដែលអ្នកធ្លាប់លឺ ឬស្គាល់?

**<u>ផ្នែកទី២</u>**

មុននឹងធ្វើសកម្មភាពខាងក្រោម សូមបិទស្លាកសញ្ញា "យល់ព្រម" និង "មិនយល់ព្រម" នៅលើជ្រុងម្ខាងនៃបន្ទប់។

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សដឹងថានៅពេល អ្នកអានកថាខណ្ឌនីមួយៗ ពួកគេឈរនៅជ្រុងម្ខាង អាស្រ័យលើការសម្រេចចិត្តរបស់ពួកគេ សិស្សអាចឈរនៅចំណុចកណ្តាលសញ្ញាទាំងពីរ ប្រសិនបើពួកគេមិនទាន់សម្រេចចិត្ត។ នៅស្ថានភាពនោះ ឱ្យសិស្សចូលរួមក្រុមពន្យល់តួនាទីរបស់ពួកគេ និងពិភាក្សាដោយប្រើសំណួរខាងក្រោម។

**ប្រាប់សិស្សរបស់អ្នក**

ខ្ញុំនឹងអានល្បះកថាខណ្ឌមួយ។ ប្រសិនបើអ្នកយល់ព្រម១០០ភាគរយ សូមដើរទៅសញ្ញា "យល់ព្រម" ប្រសិនបើអ្នកមិនយល់ព្រម សូមដើរទៅសញ្ញា "មិនយល់ព្រម"។ បើអ្នកមិនប្រាកដសូមដើរទៅទីតាំងកណ្តាលដែលបង្ហាញពីទស្សនៈរបស់អ្នក។ សម្រាប់សកម្មភាពនេះ សូមគិតពីគណនីបណ្តាញសង្គមដែលអ្នកប្រើច្រើនជាងគេ។

**សួរសិស្សរបស់អ្នក**

**គណនីបណ្តាញសង្គមរបស់ខ្ញុំបានកំណត់ជាសាធារណៈ។**

- តើវាផ្លាស់ប្តូររបៀបដែលអ្នកបង្ហោះលើអនឡាញឬទេ? តើផ្លាស់ប្តូរយ៉ាងដូចម្តេច? ប្រសិនបើមិនផ្លាស់ប្តូរ ហេតុអ្វី?

**គណនីបណ្តាញសង្គមរបស់ខ្ញុំគឺសម្រាប់តែមិត្តភ័ក្តិ ឬមនុស្សដែលខ្ញុំស្គាល់ច្បាស់តែប៉ុណ្ណោះ។**

- ហេតុអ្វីបានជាអ្នកធ្វើការសម្រេចចិត្តបែបនេះ?
- តើអ្នកនឹងបង្ហោះរឿងរ៉ាវផ្សេងទៀតទេ ប្រសិនបើអ្នករាល់គ្នាអាចមើលឃើញវាបាន? តើរឿងរ៉ាវទាំងនោះមាន អ្វីខ្លះ?

**ខ្ញុំមានមិត្តភ័ក្តិ អ្នកតាមដាន ឬទំនាក់ទំនងនៅលើបណ្តាញសង្គម ដែលខ្ញុំមិនធ្លាប់បានជួបផ្ទាល់។**

- ហេតុអ្វីបានជាអ្នកភ្ជាប់ទំនាក់ទំនងជាមួយពួកគេ? តើអ្នកធ្លាប់ជួបពួកគេដែរឬទេ?
- តើអ្នកនឹងពណ៌នាទំនាក់ទំនងយ៉ាងដូចម្តេច?
- ដោយសារតែអ្នកធ្វើការទំនាក់ទំនងគ្នាតាមអនឡាញ តើវាមានឥទ្ធិពលយ៉ាងណាចំពោះទំនាក់ទំនងរបស់អ្នក? តើមានអត្ថប្រយោជន៍អ្វីខ្លះចំពោះទំនាក់ទំនងប្រភេទនេះ? បញ្ហាប្រឈមអ្វីខ្លះដែលអាចកើតមាន?

**ខ្ញុំទទួលយករាល់សំណើសុំជាមិត្ត អ្នកតាមដាន ឬការភ្ជាប់ទំនាក់ទំនងដែលខ្ញុំទទួលបាន។**

- តើការទទួលយកសំណើនេះមានអត្ថប្រយោជន៍អ្វីខ្លះ? តើបញ្ហាប្រឈមអ្វីខ្លះដែលអាចកើតមាន?
- តើសំណើសុំជាមិត្តភ័ក្តិអ្នកតាមដាន ឬការភ្ជាប់ទំនាក់ទំនងមានសារៈសំខាន់នៅពេលនិយាយពីឯកជនភាពរបស់អ្នកដែរឬទេ? ហេតុអ្វី?

**រាល់ពេលដែលខ្ញុំជួបមនុស្សថ្មីៗ ខ្ញុំផ្ញើសំណើសុំជាមិត្តភ័ក្តិ អ្នកតាមដាន ឬភ្ជាប់ទំនាក់ទំនងលើបណ្តាញសង្គម។**

- តើវាជាគំនិតល្អ ឬអាក្រក់? ហេតុអ្វី?

**ខ្ញុំបានលុបចេញពីបញ្ជីមិត្តភ័ក្តិ អ្នកតាមដាន ឬទំនាក់ទំនង។**

- ហេតុអ្វីបានជាអ្នកធ្វើការសម្រេចចិត្តបែបនេះ?

**នៅលើអនឡាញ ខ្ញុំមានឪពុកម្តាយ អាណាព្យាបាល ឬគ្រូបង្រៀន ជាមិត្តភ័ក្តិនៅក្នុងបណ្តាញសង្គម។**

- សកម្មភាពដែលអ្នកបង្ហោះនេះមានការផ្លាស់ប្តូររបៀបដែរឬទេ?
- តើមានមនុស្សចាស់ធ្លាប់បញ្ចេញមតិលើអ្វីដែលអ្នកបង្ហោះតាមអនឡាញដែរឬទេ?
- តើមានអត្ថប្រយោជន៍ ឬបញ្ហាប្រឈមអ្វីខ្លះ ពេល អ្នកភ្ជាប់ទំនាក់ទំនងជាមិត្តភ័ក្តិជាមួយ អ្នកតាមដាន ឪពុកម្តាយ  អាណាព្យាបាល ឬគ្រូបង្រៀនរបស់អ្នក?

**ព័ត៌មាននៅលើគណនីរបស់ខ្ញុំអាចមើលឃើញដោយមិត្តរបស់មិត្តភ័ក្តិ ឬមនុស្សដែលខ្ញុំមិនបានភ្ជាប់ទំនាក់ទំនងដោយផ្ទាល់នៅលើបណ្តាញសង្គម។**

- តើព័ត៌មានអ្វីខ្លះ?

**ខ្ញុំបានមើល ឬផ្លាស់ប្តូរការកំណត់ឯកជនភាពរបស់ខ្ញុំ។**

- ហេតុអ្វី?
- តើការកំណត់ឯកជនភាពទាំងនេះងាយស្រួល ឬពិបាក? តើអ្វីធ្វើឱ្យការកំណត់ទាំងនេះងាយស្រួលមើល ឬផ្លាស់ប្តូរ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## តើបណ្តាញទំនាក់ទំនងរបស់អ្នកមានវិសាលភាពកម្រិតណា?

### ផ្នែកទី ១

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ សូមនិយាយពីវិសាលភាពរបស់អ្នកប្រើប្រាស់អនឡាញនៅលើបណ្តាញសង្គម។ វិធីសំខាន់ពីរក្នុងការចែករំលែកមាតិកា(ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះអត្ថបទ) ជាមួយទស្សនិកជន។ ព័ត៌មានត្រូវបានចែករំលែកដោយកំណត់ទស្សនិកជនទុកជាមុន ដែលអាចជាមិត្តភ័ក្តិ អ្នកតាមដាន អ្នកភ្ជាប់ទំនាក់ទំនងជាមួយ ឬរួមបញ្ចូលទាំងមិត្តរបស់មិត្តភ័ក្តិអ្នកផងដែរ។ លើសពីនេះ ទស្សនិកជនចម្បងរបស់អ្នកអាចចែករំលែកមាតិកាជាមួយមិត្តភ័ក្តិរបស់អ្នកតាមដាន ឬអ្នកដែលពួកគេបានភ្ជាប់ទំនាក់ទំនងជាមួយ។

អ្នកទំនងជាជ្រើសរើសទស្សនិកជនជិតស្និទ្ធ ប៉ុន្តែវាពិបាកជាងក្នុងការគ្រប់គ្រងថាអ្នកណា ដែលជាទស្សនិកជនរបស់អ្នកចែករំលែកឡើងវិញ បង្ហោះសារឡើងវិញ ឬផ្សាយឡើងវិញមាតិកាទាំងនោះ។

### សួរសិស្ស

សន្មតថាអ្នកចែករំលែកមាតិកាជាមួយមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកដែលភ្ជាប់ទំនាក់ទំនងជាមួយ ហើយមាតិកា ដូចគ្នាក៏ ត្រូវបានចែករំលែកជាមួយមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកដែលភ្ជាប់ទំនាក់ទំនងជាមួយផងដែរ។ តើអ្នកគិតថាអ្នកកំពុង ចែករំលែកជាមួយមនុស្សប៉ុន្មាននាក់?

### ផ្នែកទី២

### សកម្មភាពក្នុងថ្នាក់

សរសេរសមីការ ឬលទ្ធផលខាងក្រោមនៅលើក្តារខៀន។

### ប្រាប់សិស្សរបស់អ្នក

ឥឡូវចាប់ផ្តើមធ្វើលំហាត់គណិតវិទ្យា។ ឧទាហរណ៍៖ ប្រសិនបើអ្នកមានមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនង ២នាក់ នៅលើវេទិកាបណ្តាញសង្គម ហើយពួកគេម្នាក់ៗមានមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនងចំនួន ៣នាក់ តើអតិបរិមា មានមនុស្សប៉ុន្មាននាក់ (មិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនងមួយចំនួនអាចជាន់គ្នា) អាចមើលឃើញមាតិកាដែលអ្នកចែករំលែកនៅលើវេទិកា?

ចម្លើយ៖ ២ + ២ x ៣ = ៨

ប្រសិនបើអ្នកមានមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនងចំនួន ១០នាក់នៅលើវេទិកាបណ្តាញសង្គម ហើយពួកគេម្នាក់ៗមានមិត្តភ័ក្តិ អ្នកតាមដាន អ្នកភ្ជាប់ទំនាក់ទំនងចំនួន ១០នាក់ផ្សេងទៀត តើអតិបរមា មានមនុស្សប៉ុន្មាននាក់ (មិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនងប្រហែលជាអាចជាន់គ្នា) អាចមើលឃើញមាតិកាដែលអ្នកចែករំលែកនៅលើវេទិកា?

ចម្លើយ៖ ១០ + ១០ x ១០ = ១១០

ប្រសិនបើអ្នកមានមិត្តភ័ក្តិ អ្នកតាមដាន អ្នកភ្ជាប់ទំនាក់ទំនងចំនួន ៣០០នាក់នៅលើវេទិកាបណ្តាញសង្គម ហើយពួកគេម្នាក់ៗមានមិត្តភ័ក្តិ អ្នកតាមដាន អ្នកភ្ជាប់ទំនាក់ទំនងចំនួន ៣០០នាក់ផ្សេងទៀត

តើអតិបរមា មានមនុស្សប៉ុន្មាននាក់ (មិត្តភ័ក្តិ អ្នកតាមដាន អ្នកភ្ជាប់ទំនាក់ទំនងប្រហែលជាអាចជាន់គ្នា) អាចមើលឃើញមាតិកាដែលអ្នកចែករំលែកនៅលើវេទិកា?

ចម្លើយ៖ ៣០០ + ៣០០ x ៣០០ = ៩០ ៣០០

### ប្រាប់សិស្ស

ការគណនាទាំងនេះ គឺផ្អែកលើការសន្មតថាទស្សនិកជនជិតស្និទរបស់អ្នកចែករំលែកមាតិកាជាមួយទស្សនិកជនជិតស្និទរបស់ពួកគេ នឹងគ្មានការចែករំលែកបន្ថែមកើតឡើងបន្ទាប់ពីនោះទេ។ ទោះយ៉ាងណាក៏ដោយ ក្នុងករណីជាច្រើនមាតិកាដែលបានចែករំលែកលើសពីទស្សនិកជនជិតស្និតទាំងពីរនាក់នោះទៀត។

**ផ្នែកទី៣**

### សួរសិស្ស

- តើអ្នកមានអារម្មណ៍យ៉ាងណាចំពោះលទ្ធភាព ដែលមនុស្សជាច្រើនដែលអ្នកប្រហែលជាមិនស្គាល់ (អ្នកប្រហែល ជាស្គាល់ថាមិត្តរបស់មិត្តភ័ក្តិអ្នក) ដែលអាចដឹងបានយ៉ាងស្រួលពីអ្វីអ្នកធ្វើនៅលើអនឡាញ? តើមានទិដ្ឋភាព អវិជ្ជមាន និងវិជ្ជមានអ្វីខ្លះដែរឬទេ?
- ហេតុអ្វីបានជាមានបញ្ហានេះ?
- តើចំណុចនេះធ្វើឱ្យអ្នកផ្លាស់ប្តូរឥរិយាបថក្នុងការចែករំលែករឿងរ៉ាវលើអនឡាញឬទេ? ហេតុអ្វី?

### ការចែករំលែកតាមអនឡាញ

**ការពិភាក្សា១**

### ប្រាប់សិស្ស

អ្នកនឹងចែករំលែករឿងរ៉ាវសម្រាប់ទស្សនិកជនគោលដៅម្នាក់ ប៉ុន្តែអ្នកបង្កើតមាតិកាសម្រាប់សារធារណៈជន វាអាចផ្ទុះការចាប់អារម្មណ៍ដោយមិនបានរំពឹងទុក។ បណ្តាញផ្សព្វផ្សាយបានចែករំលែកលើអនឡាញអាចថា "ផ្ទុះការចាប់អារម្មណ៍" ចែករំលែកយ៉ាងឆាប់រហ័សនៅលើបណ្តាញសង្គមដោយត្រូវបានចែករំលែកពីមួយទៅមួយ និងអាចបង្ហោះឡើងវិញបាន។

### សួរសិស្ស

តើនរណាអាចឱ្យឧទាហរណ៍មួយអំពីបណ្តាញសង្គមដែលផ្ទុះការចាប់អារម្មណ៍? ប្រសិនបើមិនមានទេ ឱ្យពួកគេគិតពី រូបត្លុក ឬវីដេអូពេញនិយមដែលពួកគេបានឃើញ ចែករំលែកទៅកាន់មិត្តភ័ក្តិរបស់ពួកគេ។

### សកម្មភាពក្នុងថ្នាក់

បង្ហាញឧទាហរណ៍ថ្មីៗដែលស្របនឹងបរិបទតំបន់របស់អ្នក របស់សិស្សដើម្បីពង្រឹងគោលគំនិតបន្ថែមទៀត។

**ការពិភាក្សា២**

### ប្រាប់សិស្សរបស់អ្នក

ប្រព័ន្ធផ្សព្វផ្សាយដែលផ្ទុះការចាប់អារម្មណ៍អាចល្អ ប្រសិនបើអ្នកចង់ទាញចំណាប់អារម្មណ៍មកលើការងាររបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ ចំណាប់អារម្មណ៍ដែលមិនចង់បាន អាចរួមបញ្ចូលការរំលោភ

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

បំពាន និងការគំរាមកំហែងតាមអ៊ីនធឺណិត។ វីដេអូឯកជនដែលបែកធ្លាយ ឬចែករំលែកដោយគ្មានការអនុញ្ញាតពីអ្នកអាចធ្វើឱ្យខូច កេរ្តិ៍ឈ្មោះរបស់អ្នក។

**សួរសិស្ស**

- តើមានវិធីណាខ្លះដែលមាតិការបស់អ្នកនៅលើអនឡាញអាចចែករំលែកលើសពីទស្សនិកជនគោលដៅរបស់អ្នក ហើយតើវាអាចប៉ះពាល់ដល់អ្នក ឬកេរ្តិ៍ឈ្មោះរបស់អ្នកយ៉ាងដូចម្ដេច?

## ជម្រើសឯកជនភាពសម្រាប់វេទិកាបណ្ដាញសង្គម

**ផ្នែកទី ១**

និយាយ **ប្រាប់សិស្ស**

ឥឡូវនេះ យើងនិយាយពីហេតុផលខ្លះអ្នកប្រហែលមិនចង់ឱ្យអ្វីគ្រប់យ៉ាង ដែលអ្នកធ្វើនៅលើអ៊ីនធឺណិត ទៅជាសាធារណៈ សូមនិយាយពីរបៀបដែលយើងអាចគ្រប់គ្រង ឯកជនភាពរបស់យើងនៅលើអ៊ីនធឺណិត។

**ផ្នែកទី ២**

**សកម្មភាពក្នុងថ្នាក់**

ចូរពិភាក្សាសំណួរនីមួយៗ នៅក្នុងស្ថានភាពខាងក្រោម។

**សួរសិស្ស**

- តើវាសមហេតុផលទេដែលមានការកំណត់ឯកជនភាពផ្សេងៗគ្នាចំពោះប្រភេទព័ត៌មានផ្សេងៗគ្នា? អ្នកអាចពិចារណាផ្នែកផ្សេងៗរបស់ព័ត៌មានអំពីកម្រិតឯកជនភាពដែលមានលក្ខណៈខុសគ្នា។ អ្នកប្រហែលជាចង់ចែករំលែករូបថតដែលបង្ហាញមុខរបស់អ្នក ពីនយោបាយ ជំនឿ សាសនា ឬវីដេអូកំប្លែងជាមួយទស្សនិកជនផ្សេងៗគ្នា។
- តើអ្វីជាការកំណត់ឯកជនភាពផ្សេងគ្នាសម្រាប់មនុស្សផ្សេងគ្នា? ឧទាហរណ៍៖ តើឪពុកម្ដាយអាណាព្យាបាល និងមិត្តភ័ក្តិរបស់អ្នកអាចឃើញអ្វីដូចគ្នានៅលើគណនីបណ្ដាញសង្គមរបស់អ្នកដែរឬទេ? សិស្សប្រហែលជាមិនចង់ឱ្យ គ្រួសាររបស់ពួកគេបញ្ចេញមតិលើការបង្ហោះទេ ប៉ុន្តែប្រហែលជាចង់ឱ្យមិត្តភ័ក្តិរបស់គេបញ្ចេញមតិជាង។
- តើអ្នកនឹងពិនិត្យមើលឡើងវិញនូវអ្វីគ្រប់យ៉ាងដែលអ្នកត្រូវបានគេដាក់ភ្ជាប់(Tagged)ដែរឬទេ? ហេតុអ្វី? អ្នកប្រហែលជាចង់លុបមាតិកាដែលអាម៉ាស់ (ឧទាហរណ៍៖ រូបថតមិនស្អាត ការបង្ហោះអ្វីពីអ្នកដែលអ្នកមិនចង់ចែករំលែក)។ នៅលើវេទិកាបណ្ដាញសង្គមមួយចំនួនដូចជា Facebook អ្នកអាចផ្លាស់ប្ដូរការកំណត់របស់អ្នក ដូច្នេះអ្នកត្រូវតែយល់ព្រមអ្វីមួយ មុនពេលវាបង្ហាញឡើងនៅលើគណនីរបស់អ្នក។ តើអ្នកគិតថា នោះជាគំនិតល្អឬទេ? ហេតុអ្វី? ឧទាហរណ៍៖ មួយចំនួនដូចជា វាអនុញ្ញាតឱ្យអ្នកជួយការពារមាតិកាមិនល្អដែលនឹងភ្ជាប់ទៅនឹងគណនីបណ្ដាញសង្គមរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ វាមិនអាចបញ្ឈប់អ្នកបង្ហោះមាតិកា ពីការចែករំលែកវា នៅលើគណនីរបស់ពួកគេ ទៅកាន់មិត្តភ័ក្តិ អ្នកតាមដានមនុស្សដែលពួកគេភ្ជាប់ជាមួយ។

- ហេតុអ្វីបានជាបុគ្គលម្នាក់ៗចង់កំណត់ឯកជនភាព? តើអ្នកអាចផ្តល់ឧទាហរណ៍បានទេ? អ្នកប្រហែលជាមិនចង់បានមនុស្សដទៃដែលអ្នកមិនស្គាល់ច្បាស់ ធ្វើជាមិត្តភ័ក្តិ អ្នកតាមដាន ភ្ជាប់ជាមួយអ្នកនៅលើបណ្តាញសង្គម ឬការផ្ញើសារដែលអ្នកមិនចង់ឱ្យផ្ញើមក។
- តើអ្នកជាមិត្តភ័ក្តិ អ្នកតាមដាន ឬអ្នកភ្ជាប់ទំនាក់ទំនងជាមួយឪពុកម្តាយ អាណាព្យាបាល គ្រូបង្រៀនរបស់អ្នកតាមអ៊ីនធឺណិតដែរឬទេ?ជាមួយមនុស្សពេញវ័យផ្សេងទៀត? តើវាផ្លាស់ប្តូរប្រភេទនៃមាតិកាអ្នកចែករំលែក ឬបុគ្គលអ្នកចែករំលែកមាតិកាជាមួយ? តើឪពុកម្តាយ អាណាព្យាបាល ឬគ្រូបង្រៀនត្រូវធ្វើជាមិត្តភ័ក្តិ អ្នកតាម អ្នកភ្ជាប់ទំនាក់ទំនងជាមួយអ្នកដើម្បីមើលគណនីរបស់អ្នកទេ?
- សិស្សគួរពិចារណាថា តើការកំណត់ឯកជនភាពផ្ទាល់ខ្លួនរបស់ពួកគេអនុញ្ញាតឱ្យសាធារណជនទូទៅមើលឃើញគណនីបណ្តាញសង្គមរបស់ពួកគេ។ ជួយសិស្សឱ្យគិតពីវិធីផ្សេងទៀតដែលឪពុកម្តាយអាណាព្យាបាលឬគ្រូបង្រៀនអាចមើលគណនីរបស់ពួកគេ។
- តើមានការកំណត់ឯកជនភាពផ្សេងៗគ្នាទេ នៅលើវេទិកាបណ្តាញសង្គមផ្សេងគ្នា? នៅលើ Twitter (X) តើសារខ្លីរបស់អ្នកជាលក្ខណៈឯកជន ឬសាធារណៈ? តើមានមនុស្សប៉ុន្មាននាក់អាចមើលរឿងរ៉ាវ (Snap Stories) របស់អ្នក?
- តើមានមនុស្សប៉ុន្មាននាក់ដែលអាចចូលមើលព័ត៌មាន Instagram របស់អ្នក? តើអ្នកផ្សេងទៀតអាចមើលវីដេអូ របស់អ្នកនៅលើ YouTube បានដែរឬទេ? តើបុគ្គលអាចមើលឃើញរូបថតរបស់អ្នកនៅលើ Facebook ក្រៅពីរូបភាពគណនីរបស់អ្នកដែរឬទេ? ប្រសិនបើសិស្សមិនដឹងទេ ចូរប្រាប់ពួកគេថាមានការកំណត់ឯកជនភាព សម្រាប់រឿងនេះ។
- តើអ្នកប្រើឈ្មោះពិត ឬឈ្មោះក្លែងក្លាយរបស់អ្នកនៅលើ Facebook? ហេតុអ្វី?សិស្សអាចមិនចង់ឱ្យមនុស្ស ទូទៅដឹងថាតើឈ្មោះពិតរបស់ពួកគេឈ្មោះអ្វី។ ក្នុងស្ថានភាពនេះ ពួកគេប្រហែលជាចង់ប្រើ ឈ្មោះក្លែងក្លាយ។

**ផ្នែកទី ៣**

**សកម្មភាពក្នុងថ្នាក់**

រៀបចំសិស្សជាដៃគូ

**ប្រាប់សិស្ស**

យើងដឹងថាការកំណត់ឯកជនភាពអាចភាន់ច្រឡំ។ ធ្វើការជាដៃគូដោយប្រើពេល ២ ឬ៣នាទី សួរសំណួរ ឬបញ្ចេញមតិយោបល់ពីការកំណត់ឯកជនភាពនេះ។

**សកម្មភាពក្នុងថ្នាក់**

ទុកពេលឱ្យសិស្ស ៥នាទី ដើម្បីសួរសំណួរ ឬបញ្ចេញមតិយោបល់ពីការកំណត់ឯកជនភាព។ ឱ្យពួកគេចែករំលែកជាមួយក្រុមធំហើយឆ្លើយសំណួរនីមួយៗដែលបានសួរ។ សុំចម្លើយពីសិស្សមុនពេល ផ្តល់ចម្លើយរបស់អ្នក។ ប្រសិនបើមានកុំព្យូទ័រ ឬឧបករណ៍អេឡិចត្រូនិកផ្សេងៗទៀត ភ្ជាប់អ៊ីនធឺណិតបានសូមបង្ហាញពីរបៀបគ្រប់គ្រងការ កំណត់ឯកជនភាពលើអ៊ីនធឺណិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## កិច្ចការ

### ប្រាប់សិស្ស

ឥឡូវនេះ យើងនិយាយពីភាពឯកជននៅលើបណ្តាញសង្គម ចូរយើងជជែកបន្ថែមដោយបង្កើតការណែនាំដើម្បីជួយ អ្នកជទៃឱ្យរៀនអ្វីដែលអ្នកទើបបានរៀន។

ក្នុងរយៈពេល ៣០នាទី បន្ទាប់ សិស្សម្នាក់ៗបង្កើតការណែនាំខ្លីៗដើម្បីជួយអ្នកដទៃ៖

- គិតពីទស្សនិកជនចំពោះការបង្ហោះក្នុងបណ្តាញសង្គមរបស់ពួកគេ។
- ឆ្លុះបញ្ចាំងពីអ្វីដែលពួកគេចង់ចែករំលែកជាសាធារណៈ និងមូលហេតុដែលពួកគេចង់រក្សាឯកជនភាព។
- ពិចារណាពីមូលហេតុដែលពួកគេចង់ពិនិត្យ ឬកែសម្រួលការកំណត់ឯកជនភាព នៅលើបណ្តាញសង្គមរបស់ពួកគេ។
- ស្វែងយល់ពីរបៀបដែលពួកគេអាចកំណត់ឯកជនភាពផ្សេងៗគ្នា សម្រាប់ព័ត៌មានផ្សេងៗគ្នា និងមូលហេតុដែលពួកគេចង់ធ្វើដូច្នេះ។

ការណែនាំនេះអាចជាទម្រង់ណាមួយដែលអ្នកចង់បាន។ អ្នកអាចសរសេរអត្ថបទណែនាំមួយជំហានម្តងៗ ដោយរៀបរៀងជា "សៀវភៅណែនាំសម្រាប់អ្នកប្រើប្រាស់" បញ្ចូលរូបភាព ឬគំនូសតាង ឬប្រើវិធីសាស្ត្រផ្សេងទៀត ដែលអ្នកគិតថានឹងជួយអ្នកដទៃឱ្យរៀនបាន មានអារម្មណ៍ថាមានសេរីភាពក្នុងការច្នៃប្រឌិត។ នៅក្នុងការណែនាំ សូមប្រាកដថា៖

- បង្ហាញអ្នកអានពីរបៀបពិនិត្យមើល និងផ្លាស់ប្តូរការកំណត់ឯកជនភាពនៅលើវេទិកាបណ្តាញសង្គម។
- ផ្តល់ចម្លើយចំពោះសំណួរពីការកំណត់ឯកជនភាពដែលអ្នកគិតថាមានសារៈសំខាន់ ដោយផ្អែកលើការពិភាក្សាក្រុមពីមុន។

# មេរៀនទី៣៖ វត្តមានលើអនឡាញ

រយៈពេល ៖ ៦០នាទី

**សំណួរគន្លឹះ**

- តើអ្នកមានការគ្រប់គ្រងព័ត៌មានពីអ្នកនៅលើអនឡាញយ៉ាងដូចម្ដេច?

**វត្ថុបំណងមេរៀន**

- សិស្សអាចកំណត់អត្តសញ្ញាណប្រភេទព័ត៌មានផ្ទាល់ខ្លួនមួយ ដែលពួកគេអាចគ្រប់គ្រងលើអនឡាញ ទម្រង់នៃព័ត៌មាន មិនអាចគ្រប់គ្រងតាមអនឡាញ និងរឿងមួយចំនួន អាចធ្វើទៅលើព័ត៌មានផ្ទាល់ខ្លួនរបស់គេតាមអនឡាញដែលមិនត្រូវបានគ្រប់គ្រងដោយផ្ទាល់។

**ធនធាន សម្ភារៈ និងការរៀបចំ**

សិស្សត្រូវការប្រើអ៊ីនធឺណិតដើម្បីរៀនមេរៀននេះ។

**គណនី និងការនិទានរឿងតាមអនឡាញ**

**ផ្នែកទី ១**

និយាយ

**ប្រាប់សិស្សរបស់អ្នក**

ព័ត៌មានសាធារណៈពីអ្នកនៅលើអនឡាញបានពីប្រភពជាច្រើន។ អ្នកអាចគ្រប់គ្រងប្រភពមួយចំនួនដូចជា មាតិកាដែលអ្នកចែករំលែក (ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះជាអត្ថបទ) នៅលើវេទិកាបណ្ដាញសង្គមរបស់អ្នក។

**សកម្មភាពក្នុងថ្នាក់**

បង្ហាញ Facebook Page របស់លោក Barack Obama នៅលើផ្ទាំងអេក្រង់។ បន្ទាប់មកសូមអាន និងបង្ហាញនូវការបញ្ចេញមតិអវិជ្ជមានពីលោក Obama ដែលបានផ្ដល់ជូននៅលើផ្ទាំងអេក្រង់។ សូមប្រាកដថាសិស្ស យល់ពីខ្លឹមសារនៃមតិទាំងនេះ និងគណនីទាំងនោះគឺជាការប្រឌិត។ ពួកវាបង្កើតឡើងសម្រាប់តែគោលដៅនៃសកម្មភាពនេះតែប៉ុណ្ណោះ។

ឧទាហរណ៍៖ @Luciano1782586: Barack Obama ចម្អិនម្ហូបខ្លោចគ្រប់មុខ សូម្បីតែសេដ្ឋកិច្ច។ @Artemis4062456: លោក Obama មានគោលដៅមិនច្បាស់លាស់។ គាត់មិនអាចស្វែងរកផ្លូវទៅកាន់សេតវិមានដោយគ្មាន GPS។ @Sergei5639876: លោក Obama មិនដឹងពីគោលនយោបាយការបរទេសប្រសិនបើមានការវាយប្រហារដោយពាក្យសម្ដីចំពោះមុខគាត់។

**សួរសិស្សរបស់អ្នក**

- តើអ្នកមានប្រតិកម្មយ៉ាងណាចំពោះ Facebook Page របស់លោក Barack Obama?
- ចុះអ្នកមានប្រតិកម្មយ៉ាងណាចំពោះយោបល់បែបអវិជ្ជមាននៅលើ Facebook Page របស់លោក Obama?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើអ្នកគិតថាមតិយោបល់ទាំងនោះធ្វើឱ្យលោក Obama មានអារម្មណ៍យ៉ាងណា (ឧទាហរណ៍៖ អាក់អន់ចិត្ត ឬមានការសប្បាយ)?
- តើពួកគេអាចធ្វើឱ្យអ្នកដទៃមានអារម្មណ៍យ៉ាងណាក្នុងលក្ខខណ្ឌថាពួកគេចូលចិត្ត មិនចូលចិត្តលោក Obama?

**ផ្នែកទី ២**

**ប្រាប់សិស្សរបស់អ្នក**

ឥឡូវនេះ គិតអំពីគណនីវេទិកាបណ្តាញសង្គមផ្ទាល់ខ្លួនរបស់អ្នក។

**សួរសិស្សរបស់អ្នក**

- តើរឿងអ្វីខ្លះដែលមនុស្សទទួលបានបន្ទាប់ពីមើលគណនីរបស់អ្នក?
- តើនរណាជាអ្នកសរសេររឿងនោះ?
- តើអ្នកអាចគ្រប់គ្រងព័ត៌មាននោះដោយរបៀបណា?
- តើអ្នកមានឥទ្ធិពលយ៉ាងណាចំពោះមាតិកាអនឡាញរបស់អ្នក? តើអ្នកមិនអាចគ្រប់គ្រងអ្វីខ្លះ?

**ប្រាប់សិស្សរបស់អ្នក**

ក្រឡេកមើលគណនីបណ្តាញសង្គមរបស់អ្នក (Facebook, Instagram, Snapchat, Twitter, WeChat, Telegram។ល។) ឬប្រព័ន្ធផ្សព្វផ្សាយដែលជារបស់បុគ្គលល្បីល្បាញ (ឧទាហរណ៍៖ នរណាម្នាក់នៅក្នុងវិស័យសិល្បៈ ឬភាពយន្ត ឬទូរទស្សន៍ ឥស្សរជននយោបាយ អ្នកដឹកនាំអាជីវកម្ម) ជ្រើសរើសខ្លឹមសារជាច្រើន (ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះផ្អែកលើអត្ថបទ) ដែលអាចមើលឃើញនៅលើកម្រងព័ត៌មាន។

**សួរសិស្សរបស់អ្នក**

- តើនរណាជាអ្នកបង្ហោះមាតិកា? ហេតុអ្វី?
- តើមានយោបល់អ្វីខ្លះនៅលើមាតិកានោះ?
- តើមាតិកានីមួយៗដែលបង្កើតសម្រាប់នរណា?
- តើមានព័ត៌មានអ្វីខ្លះដែលគេមិនចាប់អារម្មណ៍?

**កិច្ចការ**

ឱ្យសិស្សសរសេរ ២ ឬ៣ កថាខណ្ឌដោយផ្អែកទៅលើមាតិកានៅលើអ៊ីនធឺណិត រួចឆ្លើយនឹងសំណួរខាងក្រោម៖

តើខ្លឹមសារមួយណាដែល ម្ចាស់គណនី មានការគ្រប់គ្រងដោយផ្ទាល់?

ចម្លើយរំពឹងទុក៖ ឈ្មោះអ្នកប្រើប្រាស់ បច្ចុប្បន្នភាពស្ថានភាព ការបង្ហោះ ចែករំលែក រូបថត ឬវីដេអូដែលអ្នកបង្ហោះទៅក្នុងរឿងរ៉ាវ ឬពេលវេលារបស់អ្នក មតិយោបល់របស់អ្នកដទៃលើខ្លឹមសារដែលអ្នកផ្សេងទៀតចែករំលែកនៅលើបណ្តាញសង្គម។

តើខ្លឹមសារប្រភេទណាដែលម្ចាស់គណនី មិនមានការគ្រប់គ្រងដោយផ្ទាល់?

ចម្លើយរំពឹងទុក៖ មតិអ្នកផ្សេង លើខ្លឹមសារដែលអ្នកចែករំលែកនៅលើបណ្ដាញសង្គម (ឧទាហរណ៍៖ រឿងរ៉ាវរបស់អ្នក ពេលវេលា បច្ចុប្បន្នភាពស្ថានភាព) ខ្លឹមសារដែលអ្នកដទៃចែករំលែកនៅលើបណ្ដាញសង្គម របៀបដែលមិត្តភ័ក្ដិ អ្នកតាមដាន អ្នកដែលត្រូវបានភ្ជាប់ទំនាក់ទំនងដើម្បីចែករំលែក និងបង្ហោះមាតិកាលើអនឡាញ។

តើអ្នកអាចធ្វើអ្វីបាន នៅពេលមាននរណាម្នាក់សរសេរអ្វីមួយអំពីអ្នក ហើយអ្នកមិនពេញចិត្ត (ឧទាហរណ៍៖ ព័ត៌មាននេះមិនមែនជាការគ្រប់គ្រងផ្ទាល់របស់អ្នកទេ)?

ចម្លើយរំពឹងទុក៖ ដកស្លាកខ្លួនឯង (Untag) ទាក់ទងទៅអ្នកដែលចែករំលែកខ្លឹមសារហើយសុំឱ្យពួកគេលុបវាចេញ។ រាំងខ្ទប់អ្នកប្រើប្រាស់ (Block User) ប្រសិនបើអ្នកបារម្ភពីសុវត្ថិភាពរបស់អ្នក ចូរប្រាប់មនុស្ស ដែលអាចទុកចិត្ត អាស្រ័យលើវេទិកានោះ។ អ្នកអាចរាយការណ៍អំពីខ្លឹមសារ ឬអ្នកប្រើប្រាស់ ប្រសិនបើវាជាការបៀតបៀន ឬការគំរាមកំហែង។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# មេរៀនទី៤៖ ទស្សនៈផ្សេងគ្នា

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

តើព័ត៌មានអ្វីខ្លះនៅលើអនឡាញជួយកំណត់ពីរបៀបដែលអ្នកដទៃមើលមកអ្នក?

## វត្ថុបំណងមេរៀន

សិស្សនឹងពិនិត្យមើលតួនាទីនៃការយល់ឃើញ នៅពេលវាយតម្លៃព័ត៌មាន ដែលភ្ជាប់ទៅនឹងវត្តមានអនឡាញរបស់ពួកគេ ឬវត្តមានលើអនឡាញរបស់អ្នកដទៃ។ ពួកគេនឹងទទួលបានការយល់ដឹងអំពីកត្តាបរិបទដែលពាក់ព័ន្ធ (ឧទាហរណ៍៖ ពេលវេលា វប្បធម៌ សង្គម មូលដ្ឋាន តំបន់ សកល) ដែលជះឥទ្ធិពលលើវត្តមានលើអនឡាញរបស់មនុស្សម្នាក់។ លើសពីនេះទៀតសិស្សនឹងពិចារណាពីផលប៉ះពាល់នៃព័ត៌មាន ដែលពួកគេបង្ហោះលើអនឡាញ អំពីទំនាក់ទំនងរបស់ពួកគេជាមួយក្រុមគ្រួសារ មិត្តភ័ក្តិ និងបុគ្គលល្បីល្បាញ (ឧទាហរណ៍៖ គ្រូបង្រៀន និយោជក)។

**ធនធាន សម្ភារៈ និងការរៀបចំ**

- ចែកសន្លឹកកិច្ចការឱ្យសិស្ស
- សិស្សត្រូវការចូលប្រើអ៊ីនធឺណិតសម្រាប់មេរៀននេះ
- សន្លឹកកិច្ចការ "កម្រងព័ត៌មានបណ្ដាញសង្គមរបស់ Kassra"
- បញ្ចាំងរូបភាព Rubin Vase
- ខ្មៅដៃ
- ក្រដាស

## តើទស្សនវិស័យជាអ្វី?

**ផ្នែកទី ១**

## រូបភាព សកម្មភាពសិស្សក្នុងថ្នាក់

បញ្ចាំងរូបភាព Rubin Vase នៅលើអេក្រង់។ ពេលសួរសំណួរ សូមឱ្យសិស្សឡើងមក ហើយចង្អុលបង្ហាញថារូបភាពណាដែលពួកគេឃើញ។

**សួរសិស្សរបស់អ្នក**

- តើអ្នកឃើញអ្វីខ្លះនៅពេល អ្នកមើលរូបភាពនេះ?

- តើនរណាខ្លះមើលឃើញរូបថូ?
- តើនរណាខ្លះមើលឃើញរូប មុខមនុស្ស ២នាក់?
- តើអ្នកអាចឃើញទាំងពីរក្នុងពេល តែមួយបានទេ?
- អ្វីដែលអ្នកឃើញអាចអាស្រ័យលើទស្សនៈរបស់អ្នក។
- តើអ្នកគិតថាទស្សនៈគឺជាអ្វី?

### សកម្មភាពសិស្សក្នុងថ្នាក់

សូមសរសេរនិយមន័យរបស់សិស្សនៅលើក្តារខៀន។

### ប្រាប់សិស្សរបស់អ្នក

ទស្សនៈវិស័យ គឺជាអាកប្បកិរិយាជាក់លាក់ចំពោះអ្វីមួយ ឬការមើលឃើញជ្រុងមួយ។

## <u>ផ្នែកទី ២</u>

### ប្រាប់សិស្សរបស់អ្នក

នេះជាឧទាហរណ៍មួយទៀត ឧបមាថាមិត្តរបស់យើង រដ្ឋា ទើបតែចូលក្នុងក្រុមបាល់ទាត់របស់សាលា។ ពេលគាត់ប្រាប់ម្តាយគាត់ ដោយនិយាយថា "ខ្ញុំបានចូលក្នុងក្រុមបាល់ទាត់" ម្តាយរបស់គាត់មានមោទកភាពចំពោះគាត់ណាស់។ នៅពេលដែល រដ្ឋា ប្រាប់មិត្តល្អរបស់គាត់ រ៉ាវី ថាគាត់បានចូលក្នុងក្រុមបាល់ទាត់របស់សាលារៀន រ៉ាវី និយាយថាគាត់សប្បាយចិត្តខ្លាំងណាស់ជាមួយ រដ្ឋា ។

រដ្ឋា ក៏ប្រាប់មិត្តរបស់គាត់ វីរៈ ថាគាត់បានចូលក្នុងក្រុមបាល់ទាត់។ ទោះយ៉ាងណាក៏ដោយ វីរៈ ក៏បានព្យាយាមដាក់ពាក្យចូលដែរតែ រដ្ឋា ទទួលបានកន្លែងនោះ។ ដូច្នេះ វីរៈ មិនសប្បាយចិត្តទេ រដ្ឋា ក៏ជាសមាជិកនៃក្លឹបវិទ្យាសាស្ត្រ ហើយឥឡូវនេះគាត់សម្រេចចិត្តខកខានការប្រជុំក្លឹបវិទ្យាសាស្ត្រដើម្បីអាចទៅ ហាត់បាល់ទាត់បាន។ ពេលគាត់ប្រាប់ ដានី ដែលជាប្រធានក្លឹបវិទ្យាសាស្ត្រ នាងក៏មិនសប្បាយចិត្តដែរ។ មនុស្សផ្សេងគ្នាទាំងអស់នេះនៅក្នុងជីវិតរបស់ រដ្ឋា បានលឺព័ត៌មានដូចគ្នា៖ រដ្ឋា បានចូលទៅក្នុងក្រុមបាល់ទាត់។

### សួរសិស្សរបស់អ្នក

- ហេតុអ្វីបានជាពួកគេទាំងអស់មានប្រតិកម្មខុសៗគ្នា?
- ហេតុអ្វីបានជាទស្សនៈ និងទំនាក់ទំនងផ្សេងៗរបស់ពួកគេចំពោះ រដ្ឋា មានសារៈសំខាន់?
- តើអ្នកអាចគិតអំពីឧទាហរណ៍ផ្សេងទៀតនៃរបៀបដែលមនុស្សផ្សេងគ្នាអាចមើលឃើញស្ថានភាពដូចគ្នា ឬខុសគ្នាដែរឬទេ?
- ហេតុអ្វីបានជាទស្សនៈមានសារៈសំខាន់?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ផ្នែកទី ៣

## សកម្មភាពសិស្សក្នុងថ្នាក់

ចែកសិស្សជាបី ឬបួនក្រុម។ ចែកក្រដាស និងប៊ិក ឬខ្មៅដៃឱ្យក្រុមនីមួយៗ។

និយាយ

### ប្រាប់សិស្សរបស់អ្នក

ខ្ញុំនឹងប្រគល់ឯកសារដែលមានស្រាប់ដល់ក្រុមនីមួយៗ ជាមួយនឹងវេទិកាបណ្តាញសង្គមដែលប្រឌិត ឡើងដោយ Kassra ជាមួយក្រដាសមួយសន្លឹក។ នៅលើក្រដាស ជាឈ្មោះរបស់នរណាម្នាក់នៅក្នុងជីវិតរបស់ Kassra។ ក្នុងក្រុមស្រមៃថាអ្នកកំពុងសម្លឹងមើលវេទិកាបណ្តាញសង្គមនេះជានរណាម្នាក់នៅលើ ក្រដាសដែលបានចែក។

តើអ្នកគិតថា Kassra ជានរណា? តើអ្នកអាចសន្មតអ្វីខ្លះ? តើគាត់ចូលចិត្តអ្វី? តើគាត់មិនចូលចិត្តអ្វី? តើគាត់បានបញ្ចេញយោបល់អ្វីខ្លះ? តើអ្នកមានការយល់ឃើញយ៉ាងណាចំពោះ Kassra ដោយផ្អែកលើទស្សនៈរបស់អ្នក?

អ្នកនឹងមានពេល ១០នាទី ត្រៀមខ្លួនដើម្បីធ្វើបទបង្ហាញនៅពេលបញ្ចប់
ឱ្យក្រុមនីមួយៗឡើងធ្វើបទបង្ហាញ ពីតួនាទី មនុស្សដែលមានសក្តានុពលក្នុងជីវិតរបស់ Kassra ៖

- ម្តាយរបស់ Kassra ដែលបារម្ភពីសុវត្ថិភាពកូនប្រុសគាត់
- មិត្តល្អបំផុតរបស់ Kassra ដែលបារម្ភពីគាត់
- ក្មេងស្រីរៀននៅសាលាក្បែរគ្នាដែលមិនស្គាល់ Kassra
- គ្រូរបស់ Kassra
- ចៅហ្វាយដែលអាចផ្តល់ការងារដល់ Kassra

### សួរសិស្សរបស់អ្នក

- តើមានអ្វីខ្លះដែលមានភាពខុសគ្នានៅក្នុងវិធីដែលអ្នកយល់ឃើញ និងវាយតម្លៃលើ Kassra?
- ហេតុអ្វីបានជាអ្នកគិតថាភាពខុសគ្នាទាំងនោះកើតមានឡើង?
- តើអ្នកគិតថាការវាយតម្លៃទាំងអស់នេះត្រឹមត្រូវទេ? ហេតុអ្វី?
- តើអ្នកអាចគិតអំពីពេលវេលាដែលវាបានកើតឡើងក្នុងជីវិតរបស់អ្នកដែរឬទេ នៅពេលដែលព័ត៌មានដូចគ្នាត្រូវបានគេបកស្រាយខុសគ្នាដោយមនុស្សផ្សេងគ្នា?

### សួរសិស្សរបស់អ្នក

- តើមានមនុស្សប៉ុន្មាននាក់ ដែលមិនយល់ស្របជាមួយឪពុកម្តាយ អាណាព្យាបាល ឬមិត្តភ័ក្តិរបស់អ្នក?
- ក្នុងថ្នាក់នេះ តើមានសិស្សប៉ុន្មាននាក់ដែលបានប្រើប្រាស់វេទិកាបណ្តាញសង្គម? តើអ្នកគិតថាមនុស្សផ្សេងទៀត យល់ឃើញពីគណនីលើបណ្តាញសង្គមរបស់អ្នកយ៉ាងដូចម្តេច?

- តើអ្នកធ្លាប់លុបមាតិកា ឬដកស្លាកខ្លួនឯង (Untagged Yourself) ដែលបានចែករំលែកនៅលើបណ្តាញសង្គម (ឧទាហរណ៍៖ រូបថត វីដេអូ ការបង្ហោះតាមអត្ថបទ) ដែរឬទេ? ហេតុអ្វី?

### ការឆ្លុះបញ្ចាំងលើទស្សនៈ

### ប្រាប់សិស្សរបស់អ្នក

គិតអំពីវិធីផ្សេងៗដែលមនុស្សទាំងនោះបានដឹងពីជីវិតរបស់អ្នក។

### សួរសិស្សរបស់អ្នក

- តើអ្នកធ្លាប់ធ្វើអ្វីមួយ ខុសគ្នាចំពោះមនុស្សផ្សេងគ្នាឬទេ?
- តើអ្នកនិយាយដូចគ្នានឹងឪពុកម្តាយ អាណាព្យាបាល ឬគ្រូរបស់អ្នក ដូចដែលអ្នកនិយាយចំពោះមិត្តភ័ក្តិរបស់អ្នកដែរឬទេ? ហេតុអ្វី?

### ប្រាប់សិស្សរបស់អ្នក

- យើងទាំងអស់គ្នាគឺមានភាពខុសគ្នាបន្តិចបន្តួចអាស្រ័យលើកន្លែងដែលយើងនៅ និងនរណាដែលយើងនៅជាមួយ។
- ជាផ្នែកនៃសកម្មភាពនេះ យើងនឹងពិភាក្សាអំពីរបៀបដែលអ្នកបង្ហាញខ្លួនឯងលើអ៊ីនធឺណិត ជាពិសេសនៅលើបណ្តាញសង្គម និងរបៀបដែលអ្នកដទៃអាចយល់ឃើញពីអ្នកតាមវិធីផ្សេងៗគ្នា អាស្រ័យលើទស្សនៈរបស់ពួកគេ។

### សួរសិស្សរបស់អ្នក

- តើការបង្ហាញខ្លួនឯងលើប្រព័ន្ធអនឡាញខុសពីអ្នកដទៃបង្ហាញឬទេ?
    - ឧទាហរណ៍៖ នៅលើវេទិកា Facebook អ្នកអាចប្រើឈ្មោះពិតរបស់អ្នក ប៉ុន្តែតើអ្នកប្រើឈ្មោះពិតរបស់អ្នកសម្រាប់អ្វីគ្រប់យ៉ាងដែលអ្នកធ្វើនៅលើអ៊ីនធឺណិតទេ?
- តើទម្រង់អ្វីខ្លះដែលអ្នកជានិច្ចកាលមិនប្រើឈ្មោះពិតរបស់អ្នក ឬជាទម្រង់ដែលអ្នកប្រើដោយអនាមិក? ហេតុអ្វី?
- តើអ្នកគិតថាព័ត៌មានដែលអ្នកបាន ចែករំលែកនៅលើអ៊ីនធឺណិតអំពីខ្លួនអ្នក បង្ហាញពីទិដ្ឋភាពទាំងមូលរបស់អ្នកទេ?
- តើអ្នកគិតថាទម្រង់បណ្តាញសង្គមរបស់អ្នកប្រាប់រឿងរ៉ាវទាំងមូលទេ? តើអ្នកចង់ឱ្យគេដឹងទេ?
- តើពួកគេអាចឃើញយ៉ាងដូចម្តេចប្រសិនបើពួកគេមានសិទ្ធិចូលប្រើព័ត៌មានមួយចំនួនរបស់អ្នក?
    - ឧទាហរណ៍៖ តើឪពុកម្តាយ អាណាព្យាបាលរបស់អ្នកនឹងផ្លាស់ប្តូរទេ ប្រសិនបើពួកគេបានឃើញអ្វីគ្រប់យ៉ាង ដែលអ្នកបានធ្វើនៅលើវេទិកាមួយ ប៉ុន្តែមិនមែននៅលើវេទិកាផ្សេងទៀតទេ?
- តើអ្នកធ្លាប់រក្សាការបង្ហោះរបស់អ្នកជាឯកជនទេ? ហេតុអ្វី?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### ស្នួរសិស្សរបស់អ្នក

- យើងបាននិយាយច្រើនអំពីទស្សនៈថ្ងៃនេះ។ ផ្អែកលើការសន្ទនារបស់យើង តើអ្វីដែលអ្នកបានរៀន និងយល់ឃើញនៅថ្ងៃនេះ?
- តើអ្វីទៅជាវិធីផ្សេងទៀតដែលយល់ឃើញថាប៉ះពាល់ដល់របៀបដែលយើងវាយតម្លៃព័ត៌មាន? តើអ្នកអាចដាក់ឈ្មោះព្រឹត្តិការណ៍ថ្មីៗដែលវាពាក់ព័ន្ធបានទេ?
- តើទស្សនៈវិស័យក្នុងមេរៀននេះ មានសារៈសំខាន់យ៉ាងណាក្នុងជីវិតផ្ទាល់ខ្លួនរបស់យើង និងនៅលើសារព័ត៌មានផងដែរ?

<u>កិច្ចការ</u>

### ស្នួរសិស្សរបស់អ្នក

ថតអេក្រង់ពីការបង្ហោះលើបណ្តាញសង្គមណាមួយ (ឧទាហរណ៍៖ រូបភាព វីដេអូ ឬការបង្ហោះដែលជាអត្ថបទ) វាមិនចាំបាច់ជារបស់ពួកគេផ្ទាល់ទេ។ កំណត់តួនាទី៣ ទាក់ទងការបង្ហោះលើបណ្តាញសង្គមរបស់នរណាម្នាក់ (ឧទាហរណ៍៖ មិត្តភ័ក្តិ សមាជិកគ្រួសារ គ្រូបង្រៀន) ចំពោះតួនាទីនីមួយៗ នៅក្នុងអត្ថបទខ្លីមួយពណ៌នាថាតើបុគ្គលអាចគិតដូចម្តេចពីការបង្ហោះនេះ។

រយៈពេល ១០នាទី ចុងក្រោយ សិស្សធ្វើការជាដៃគូ ឱ្យពួកគេចែករំលែកជាមួយគ្នាយ៉ាងតិចវិធីចំនួន២ ដែលពួកគេជឿថាទស្សនៈមានសារៈសំខាន់នៅក្នុងបរិបទនៃការបង្ហោះដែលពួកគេជ្រើសរើស។





រូបភាព Rubin Vase

# មេរៀនទី៥៖ តើអ្នកចង់ក្លាយជាអ្វី?

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើបច្ចេកវិទ្យាឌីជីថលមានឥទ្ធិពលលើចំណាប់អារម្មណ៍ និងគោលដៅរបស់អ្នកយ៉ាងដូចម្តេច?
- តើអ្នកបង្ហាញចំណាប់អារម្មណ៍ និងគោលដៅទាំងនេះទៅកាន់អ្នកដទៃតាមអនឡាញយ៉ាងដូចម្តេច?

**វត្ថុបំណងមេរៀន**

- សិស្សអាចពិនិត្យមើល ពីរបៀបកំណត់អត្តសញ្ញាណរបស់ពួកគេ និងខ្លឹមសារដែលពួកគេបង្កើតលើអនឡាញ និងចែករំលែកតាមគោលដៅរបស់ពួកគេ (ឧទាហរណ៍៖ ទាក់ទងនឹងអាជីពការសិក្សាចំណាប់អារម្មណ៍ដែលពួកគេចង់បន្ត)។
- សិស្សនឹងស្វែងយល់ពីរបៀបគ្រប់គ្រងពត៌មានផ្ទាល់ខ្លួនលើអនឡាញ ដែលពិចារណាលើប្រធានបទ វេទិកាឈ្មោះ ការបង្ហាញរូបភាព និងការកំណត់ឯកជនភាព។

**សម្ភារៈ ធនធាន ការរៀបចំ**

- សន្លឹកកិច្ចការ "អត្តសញ្ញាណអនឡាញរបស់ខ្ញុំ"។
- ចែកសន្លឹកកិច្ចការដល់សិស្ស

## អត្តសញ្ញាណអនឡាញរបស់ខ្ញុំ

### ការពិភាក្សា

និយាយ

**ប្រាប់សិស្សរបស់អ្នក**

សូមចំណាយពេល ១នាទី គិតពីរបៀបដែលយើងប្រាស្រ័យទាក់ទងជាមួយមនុស្សផ្សេងទៀតអាស្រ័យលើពួកគេជានរណា។ អ្នកអាចបញ្ចេញសកម្មភាពខុសគ្នាខណៈពេល អ្នកនៅជិតមិត្តភ័ក្តិ សមាជិកគ្រួសារ ឬគ្រូរបស់អ្នកនៅសាលា។ អ្នកក៏អាចបញ្ចេញសកម្មភាពខុសគ្នាអាស្រ័យលើការកំណត់ ឬក្នុងឱកាសណាមួយជាមួយមិត្តភ័ក្តិនៅសាលា និងវិធីផ្សេងៗជាមួយមិត្តភ័ក្តិដូចគ្នា នៅពេល អ្នកចំណាយពេល ជាមួយគ្នាខាងក្រៅសាលា។

យើងទាំងអស់គ្នាប្រហែលជា បញ្ចេញសកម្មភាពខុសគ្នាបន្តិចបន្តួច អាស្រ័យលើកន្លែងដែលយើងរស់នៅ និងអ្នកណាដែលយើងនៅជាមួយ។ អ្នកមានសមត្ថភាពស្រដៀងគ្នាក្នុងការគ្រប់គ្រងរបៀបដែលអ្នក និងមាតិការបស់អ្នកនឹងបង្ហាញ ជាសាធារណៈនៅលើអនឡាញ ហើយវាអាចមានប្រយោជន៍ក្នុងការចាប់ផ្តើមគិតពីរបៀបដែលអ្នក ចង់ឱ្យអ្នកដទៃមើលមកអ្នកនៅលើអនឡាញ។

បុគ្គលល្បីល្បាញ (ឧទាហរណ៍៖ អ្នកសិល្បៈ ឥស្សរជននយោបាយ ម្ចាស់ជំនួញ) ធ្វើរឿងនេះគ្រប់ពេល ទាំងអស់។ តាមការកសាងឡើងដោយយកចិត្តទុកដាក់លើគ្រប់ផ្នែកនៃម៉ាកយីហោ និងវត្តមាន

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ជាសាធារណៈរបស់ពួកគេ ចាប់តាំងពីមាតិកានៅលើបណ្ដាញសង្គម (ឧទាហរណ៍៖ រូបភាព វីដេអូ សារជាអត្ថបទ) រហូតដល់ការសម្ភាសន៍ ដែលពួកគេព្យាយាមទាក់ទាញអ្នកគាំទ្រ ឬអតិថិជនឱ្យបានច្រើនតាមដែលអាចធ្វើទៅបាន។ អ្នកមិនចាំបាច់ក្លាយជាបុគ្គលល្បីដែលមានយុទ្ធសាស្ត្រទីផ្សាររាប់ពាន់លានដុល្លារនោះទេ។ ប៉ុន្តែ វាមានសារៈសំខាន់ក្នុងការគិតពីនរណាដែលអាចមើលវត្តមានអនឡាញរបស់អ្នក និងរៀបចំផែនការពីរបៀបដែលអ្នកបង្ហាញខ្លួននៅលើអនឡាញនាពេល អនាគត។

## អន្តរទំនាក់ទំនង

### សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សធ្វើការជាដៃគូ

### សួរសិស្សរបស់អ្នក

- តើមាតិកាអ្វីដែលអ្នកបង្កើតបច្ចុប្បន្ន ឬចែករំលែកនៅលើអនឡាញ (ឧទាហរណ៍៖ វីដេអូ តន្ត្រី បទចម្រៀង បែបបចម្រុះ ប្លុក ការរចនា រូបភាពមានចលនា)?
- តើអ្វីជំរុញទឹកចិត្តអ្នកឱ្យបង្កើត ឬចែករំលែកមាតិកានេះ?
- ហេតុអ្វីបានជាអ្នកធ្វើវា? តើមាតិកាអ្វីដែលអ្នកភ្ជាប់ឈ្មោះ និងរូបភាពពិតរបស់អ្នក?
- តើមានមាតិកាអ្វី ដែលអ្នកមិនចង់បង្ហាញជាសាធារណៈ? ហេតុអ្វី?

### សកម្មភាពក្នុងថ្នាក់

ទុកពេលឱ្យសិស្ស ៧នាទី ដើម្បីពិភាក្សា ឱ្យពួកគេចែករំលែក។

### សួរសិស្សរបស់អ្នក

មុនពេល យើងអាចនិយាយពីវត្តមាននៅលើអនឡាញនាពេល អនាគតរបស់អ្នក សូមនិយាយពីគោលដៅនាពេលអនាគតរបស់អ្នកសិន ។ ពិភាក្សាជាមួយដៃគូរបស់អ្នក៖

- តើអ្នកចង់ទៅកន្លែងណា និងធ្វើអ្វីក្នុងរយៈពេល ពីរ-បីឆ្នាំនេះ ហើយតើអ្នកបានគំនិតនោះមកពីណា? វាមិនអីទេប្រសិនបើអ្នកមានគំនិតច្រើនជាងមួយ ឬការងារមួយដែលអ្នកចាប់អារម្មណ៍នាពេលបច្ចុប្បន្ន។
- តើអ្នកមានគោលដៅផ្ទាល់ខ្លួនអ្វីផ្សេងទៀតដែលមិនទាក់ទងនឹងអាជីពរំពឹងទុករបស់អ្នក?
- តើអ្នកគួរធ្វើអ្វីតាមអនឡាញដើម្បីជួយអ្នកសម្រេចបាននូវអាជីពរំពឹងទុក ឬគោលដៅផ្ទាល់ខ្លួនរបស់អ្នកនាពេលអនាគត?

### សកម្មភាពក្នុងថ្នាក់

ចែកសន្លឹកកិច្ចការ "អត្តសញ្ញាណលើអនឡាញរបស់ខ្ញុំ" ដល់សិស្ស។

### ប្រាប់សិស្សរបស់អ្នក

អ្វីដែលអ្នកធ្វើនៅលើអនឡាញអាចជួយអ្នកស្វែងរកចំណាប់អារម្មណ៍បច្ចុប្បន្នរបស់អ្នក និងអាចជួយអ្នក ឱ្យរកឃើញចំណង់ចំណូលចិត្តនាពេលអនាគតផងដែរ។ ចំណាយពេល២ ឬ៣នាទី ដើម្បីបំពេញសន្លឹកកិច្ចការនេះ ហើយឆ្លុះបញ្ចាំងពីសេចក្ដីប្រាថ្នារបស់អ្នកក្នុងបរិបទនៃរបៀបដែលអ្នកបង្ហាញខ្លួននៅលើអនឡាញ។

សូមចងចាំថាអត្តសញ្ញាណអនឡាញរបស់អ្នកគ្រប់គ្នាអាចមានភាពខុសប្លែកគ្នា ហើយអត្តសញ្ញាណរបស់អ្នកទំនងជាវិវត្តន៍តាមគោលដៅ និងចំណាប់អារម្មណ៍របស់អ្នកផ្លាស់ប្តូរយ៉ាងណានាពេលអនាគត។

## <u>កិច្ចការ</u>

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ យើងបានឆ្លុះបញ្ចាំងពីរបៀបដែលអ្នកយល់ឃើញ និងចំណាប់អារម្មណ៍របស់អ្នកសូមគិតពីរបៀបដែលអ្នកចង់បញ្ជាក់ទិដ្ឋភាពនៃអត្តសញ្ញាណរបស់អ្នកទៅកាន់អ្នកដទៃ។

ស្រមៃថា អ្នកកំពុងបង្កើតវត្តមានលើបណ្តាញសង្គមថ្មីមួយ ដែលផ្តោតលើទិដ្ឋភាពជាក់លាក់នៃអត្តសញ្ញាណរបស់អ្នក។ អ្នកនឹងចាប់ផ្តើមពីដំបូង ហើយអ្នកនឹងមានសេរីភាពទាំងស្រុងក្នុងការកែតម្រូវការកំណត់ឯកជនភាពទាំងអស់ និងរៀបចំខ្លឹមសារតាមវិធីដែលអ្នកចង់បាន។ នៅក្នុងអត្ថបទខ្លីសូមពិភាក្សាពីរបៀបដែលអ្នកអាចរៀបចំរចនាសម្ព័ន្ធវត្តមានលើបណ្តាញសង្គមថ្មីនេះ ដើម្បីបង្ហាញរូបភាពដែលអ្នកបានជ្រើសរើសទៅកាន់មិត្តភ័ក្តិ និងអ្នកតាមដានរបស់អ្នក។ ជាពិសេស ពិចារណាពីគោលគំនិតខាងក្រោម៖

- ប្រភេទនៃគណនី និងវេទិកា ( ឧទាហរណ៍៖ បណ្តាញសង្គម ឬវេបសាយ )
- ប្រភេទនៃមាតិកា ( ឧទាហរណ៍៖ រូបភាព វីដេអូ ការបង្ហោះជាសារអត្ថបទ )
- តើអ្នកនឹងសរសេរអ្វីនៅក្នុងផ្នែក "អំពីខ្ញុំ" ?
- តើអ្នកនឹងប្រើរូបភាពបែបណា ?
- តើអ្នកនឹងកំណត់ឯកជនភាពរបស់អ្នកទៅជាយ៉ាងដូចម្តេច ? តើការកំណត់ទាំងអស់នេះផ្អែកលើប្រភេទមាតិកាដែលអ្នកចងចែករំលែកដែរឬទេ ?

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# មេរៀនទី៦៖ ពេលវេលាផ្ទាល់ខ្លួនសម្រាប់មនុស្សវ័យជំទង់

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើការលើកទឹកចិត្តខ្លួនឯងគឺជាអ្វី ?
- ហេតុអ្វីបានជាខ្ញុំគួរអនុវត្តការលើកទឹកចិត្តខ្លួនឯង ?

## វត្ថុបំណងមេរៀន

- សិស្សធ្វើការប្រៀបធៀប និងរកភាពផ្ទុយពីវិធីដែលពួកគេឆ្លើយតបទៅកាន់មិត្តជិតស្និទ្ធ ដែលមានវិបត្តិ (នឹងខ្លួនពួកគេ) ហើយពិចារណាពីរបៀប ដែលអាចកែតម្រូវនូវអ្វីដែលពួកគេនិយាយទៅកាន់ខ្លួនឯងនៅពេល ជួបការលំបាក។

**សម្ភារៈ ធនធាន និងការរៀបចំ**

- កន្លែងស្ងប់ស្ងាត់ដើម្បីអនុវត្ត
- ការឆ្លុះបញ្ចាំងមុនពេលអនុវត្ត
- សូមចំណាយពេលបន្តិចដើម្បីសាកល្បងការអនុវត្តនេះ សម្រាប់ខ្លួនអ្នកដោយប្រើប្រាស់ បញ្ហាប្រឈមផ្ទាល់ខ្លួន ឬវិជ្ជាជីវៈដែលអ្នកកំពុងជួបប្រទះនៅពេលបច្ចុប្បន្ន។ ជ្រើសរើសអ្វីដែលជាបញ្ហាប្រឈមកម្រិតស្រាល ឬកម្រិតមធ្យមជាជាងកម្រិតខ្លាំង។ តើការអនុវត្តនេះបានកែប្រែអារម្មណ៍របស់អ្នកចំពោះបញ្ហាប្រឈម ឬក៏ខ្លួនអ្នកដែរឬទេ ?
- តើអ្នកគិតថា ការលើកទឹកចិត្តខ្លួនឯងពាក់ព័ន្ធនឹងការរស់នៅប្រចាំថ្ងៃសិស្សរបស់អ្នក ទាំងក្នុង និងក្រៅសាលារៀនដោយរបៀបណា ? តើពួកគេយល់ព្រមទេ ?
- តើការអនុវត្តនេះផ្តល់តម្លៃឱ្យអ្នកលើសតម្លៃរបស់ពួកគេតាមមធ្យោបាយណាមួយទេ ? ឧទាហរណ៍៖ តើអ្នកជឿថាការធ្វើល្អចំពោះខ្លួនឯង ជាការលើកទឹកចិត្តប្រសើរជាងការធ្វើឱ្យខ្លួនឯងលំបាក ចំណែកឯសិស្ស និងឪពុកម្តាយមិនគិតអញ្ចឹងទេ ?
- ប្រសិនបើជំនឿរបស់អ្នកខុសគ្នា តើវាអាចទៅរួចទេក្នុងការគោរពចំពោះជំនឿផ្សេងៗគ្នានេះ ក្នុងរបៀបដែលគ្មាននរណាម្នាក់គិតពីចំណុចខ្វះខាតរបស់អ្នកដែរទេ ?

## សកម្មភាពក្នុងថ្នាក់

មុនពេលចាប់ផ្តើមសកម្មភាពនេះ សូមដកដង្ហើមវែងៗបន្តិច។ រំលឹកសិស្ស ថាពួកគេត្រូវបានលើកទឹកចិត្តប៉ុន្តែមិនតម្រូវឱ្យចូលរួមទេ។ (ពួកគេអាចអង្គុយដោយស្ងៀមស្ងាត់ ប្រសិនបើពួកគេជ្រើសរើសមិនចូលរួម។)

និយាយ

**ប្រាប់សិស្សរបស់អ្នក**

យើងនឹងបង្កើតភាពតានតឹង ទាំងក្នុងផ្លូវកាយ និងផ្លូវចិត្តរបស់យើង ដោយគិតពីស្ថានភាពប្រឈម ដូច្នេះយើងអាចរៀនពីរបៀបប្រើការលើកទឹកចិត្តខ្លួនឯង។

**អានអត្ថបទខាងក្រោមឱ្យពួកគេស្តាប់។**

គិតអំពីស្ថានភាពក្នុងជីវិតរបស់អ្នកដែលពិបាក ឬធ្វើឱ្យអ្នកតានតឹង។ សូមជ្រើសរើសស្ថានភាពដែលមិនអាក្រក់ ឬពិបាកបំផុតក្នុងជីវិតរបស់អ្នក ប៉ុន្តែជ្រើសរើសអ្វីដែលធ្វើឱ្យអ្នកមានអារម្មណ៍មិនល្អ។ នៅពេលអ្នកគិតពីស្ថានភាពនេះ អ្នកអាចនឹកឃើញពីស្ថានភាពនោះ ប្រហែលជាមានអារម្មណ៍មិនល្អដូចជាតឹងទ្រូង ឬផើតពោះ? ឥឡូវនេះប្រាប់ខ្លួនអ្នកថា៖ «ក្នុងពេល នេះ ផ្នែកមួយនៃដងខ្លួនរបស់ខ្ញុំកំពុងមានបញ្ហា»។ នេះជាការផ្តោតអារម្មណ៍ អ្នកអាចជ្រើសរើសនិយាយថា "មានអារម្មណ៍មិនល្អសោះ" ឬ "ភាពតានតឹង"។

ឥឡូវនេះប្រាប់ខ្លួនឯងថា "បញ្ហាបែបនេះគឺជាផ្នែកមួយនៃជីវិត"។ នេះគឺរឿងធម្មតារបស់មនុស្ស។ មនុស្សជាច្រើនជួបបញ្ហាដូចនេះដែរ។

អ្នកអាចនិយាយថា "ក្មេងផ្សេងទៀតក៏មានអារម្មណ៍បែបនេះដែរ" ឬ "មិនមែនមានតែខ្ញុំនោះទេ ដែលមានអារម្មណ៍បែបនេះ" និង"នេះគឺជាផ្នែកមួយនៃភាពជាក្មេងជំទង់ ហើយក្មេងៗជាច្រើនផ្សេងទៀតជួបបញ្ហាដូចខ្ញុំដែរ"។ "ក្មេងជំទង់ទាំងអស់មានអារម្មណ៍បែបនេះនៅពេលណាមួយ!"

ឥឡូវនេះ សូមយកដៃប៉ះខ្លួនឯងដោយភាពស្រទន់ ស្រស់ស្រាយ និងកក់ក្តៅ ដាក់ដៃនៅលើដើមទ្រូងរបស់អ្នក ឬកាយវិការផ្សេងទៀតដែលស័ក្តិសមនឹងអ្នក។ មានអារម្មណ៍ថាដៃរបស់អ្នកមានភាពកក់ក្តៅដែលចូលមកក្នុងខ្លួនរបស់អ្នក។ ឥឡូវនេះ ចូរនិយាយទៅកាន់ខ្លួនអ្នកថា៖ «សូមឱ្យខ្ញុំមានសន្តានចិត្តល្អចំពោះខ្លួនខ្ញុំផង» សូមចងចាំថាពេលជាយុវវ័យ អ្នកកំពុងឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនដូចជា ខួរក្បាល និងរាងកាយ អ្នកអាចនឹងចូលរៀននៅសាលាថ្មី ឬគិតពីមហាវិទ្យាល័យ ដែលអាចមានសម្ពាធ និងមានការផ្លាស់ប្តូរជាច្រើន។ ដូច្នេះត្រូវចេះលួងលោមខ្លួនឯង។

សម្រាប់ភាសាផ្ទាល់ខ្លួនបន្ថែមសូមសួរថា "តើខ្ញុំត្រូវស្តាប់អ្វីឥឡូវនេះ?" ឬប្រសិនបើអ្នកមានបញ្ហាក្នុងការស្វែងរកពាក្យអ្វីដែលត្រូវនិយាយ សូមសួរខ្លួនអ្នកថា "តើខ្ញុំនឹងនិយាយអ្វីទៅកាន់មិត្តល្អដែលកំពុងជួបរឿងនេះ? តើខ្ញុំអាចនិយាយពាក្យទាំងនោះដាក់ខ្លួនខ្ញុំបានទេ?»

- សូមឱ្យខ្លួនខ្ញុំទទួលនូវសេចក្តីមេត្តាដែលខ្ញុំត្រូវការ។
- សូមឱ្យខ្ញុំទទួលយកការពិតសម្រាប់ខ្លួនឯង។
- សូមឱ្យខ្ញុំរៀនទទួលការពិតសម្រាប់ខ្លួនឯង។
- សូមឱ្យខ្ញុំអត់ទោសឱ្យខ្លួនឯង។
- សូមឱ្យខ្ញុំរឹងមាំ។
- សូមឱ្យខ្ញុំមានសុវត្ថិភាព។
- សូមឱ្យខ្ញុំសុខសាន្ត។
- សូមឱ្យខ្ញុំដឹងថាខ្ញុំសមនឹងទទួលបានសេចក្តីស្រឡាញ់។
- ប្រសិនបើពាក្យថា "សូមឱ្យខ្ញុំ" ធ្វើឱ្យអ្នកមានអារម្មណ៍ចម្លែក ឬដូចជាកំពុងសុំការអនុញ្ញាត អ្នកអាចផ្លាស់ប្តូរគ្រាន់តែនិយាយថា "ខ្ញុំចង់ទទួលយកការពិតសម្រាប់ខ្លួនឯង" ឬ "ភាពរឹងមាំ" ឬ "ទទួលយកខ្លួនឯង"។ គ្រាន់តែកត់សម្គាល់អ្វីដែលអ្នកកំពុងគិត។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## សួរសិស្សរបស់អ្នក

សួរសិស្សម្នាក់ ឬច្រើននាក់ពីសំណួរខាងក្រោម៖

- តើវាមានអារម្មណ៍យ៉ាងដូចម្ដេចពេលអ្នកលួងលោមខ្លួនឯងបែបនេះ? តើវាទៅជាយ៉ាងណា បើអ្នកអាចកត់សម្គាល់នៅពេលដែលអ្នកមានបញ្ហា ហើយចាប់ផ្ដើមនិយាយពាក្យល្អៗដល់ខ្លួនឯង?
- តើមានអ្វីផ្លាស់ប្ដូរ នៅពេលអ្នកដាក់ដៃលើដើមទ្រូងរបស់អ្នក?
- តើវាទៅជាយ៉ាងណាពេលដែលដឹងថា អ្នកមើលថែខ្លួនឯងដោយចិត្តល្អជាងនេះ?
- តើអ្នកអាចគិតពីស្ថានភាពណាមួយ ដែលវានឹងមានផលប្រយោជន៍សម្រាប់អ្នក?
- ពិចារណាសមាសធាតុទាំង៣ នៃការលើកទឹកចិត្តខ្លួនឯង តើមួយណាមានអត្ថន័យបំផុតសម្រាប់អ្នក និងសំខាន់ ក្នុងការសិក្សា?
    - សតិសម្បជញ្ញៈ ("នេះជាគ្រាដែលមានទុក្ខ")។
    - មនុស្សជាតិទូទៅ ("មិនមែនមានតែខ្ញុំម្នាក់ឯងទេដែលរងទុក្ខ")។
    - ការធ្វើល្អចំពោះខ្លួនឯង (ការប៉ះពាល់ផ្លូវកាយ ឬសំឡេងបន្ទរអារម្មណ៍ "សូមឱ្យខ្ញុំពេញចិត្តចំពោះខ្លួនឯង")។

## កិច្ចការ

**ការឆ្លុះបញ្ចាំងបន្ទាប់ពីការអនុវត្ត៖**

- តើអ្វីបានដំណើរការ ឬមិនបានផលសម្រាប់អ្នកក្នុងការដឹកនាំការអនុវត្តនេះ? តើសិស្សឆ្លើយតបទៅនឹងការអនុវត្តយ៉ាងដូចម្ដេច? តើអ្នកនឹងផ្លាស់ប្ដូរអ្វីសម្រាប់លើកក្រោយ?
- តើអ្នកកត់សម្គាល់ទេ ថាតើសិស្សត្រូវឆ្លើយតបទៅនឹងកំហុស បរាជ័យ ឬបញ្ហាប្រឈមផ្សេងទៀតក្នុងជីវិតជាមួយនឹងឥរិយាបថខុសគ្នាបន្ទាប់ពីចូលរួមក្នុងការអនុវត្តនេះ?
- តើការកែតម្រូវអ្វីខ្លះដែលត្រូវបានធ្វើឡើងចំពោះ ការអនុវត្តផ្អែកលើសិស្ស និងគ្រួសារ? តើវាទៅជាយ៉ាងណា?
- តើសិស្សពិភាក្សា ពីរបៀបអនុវត្តនេះដែលអាចទាក់ទងនឹងរឿង មាន ឬគ្មានប្រយោជន៍ក្នុងជីវិតរបស់ពួកគេ?

# មេរៀនទី៧៖ ពេលវេលាដែលខ្ញុំមានអារម្មណ៍ដឹងគុណ

**រយៈពេល** ៖ ៦០នាទី

**សំណួរគន្លឹះ**

- តើការដឹងគុណមានន័យយ៉ាងណា?
- តើយើងអាចបង្ហាញការដឹងគុណយ៉ាងដូចម្តេច?

**វត្ថុបំណងមេរៀន**

- សិស្សអាចកំណត់ការដឹងគុណ ហើយផ្តល់ឧទាហរណ៍ពីពេលវេលាដែលពួកគេមានអារម្មណ៍ដឹងគុណ។
- សិស្សយល់ថាមានរឿងជាច្រើនប្រភេទដែលយើងអាចមានអារម្មណ៍ដឹងគុណ។

**សម្ភារៈ ធនធាន ការរៀបចំ**

- ក្រដាសបិទចំណាំ
- ខ្មៅដៃ
- ស្លាកសញ្ញា៤ ដែលដាក់នៅជ្រុងណាមួយនៃបន្ទប់ដែលសរសេរថា "អ្វីដែលយើងមាន" "សកម្មភាពល្អ" "ធម្មជាតិ" និង "រឿងសំខាន់ផ្សេងៗទៀត"
- សម្ភារៈផ្សេងៗ៖ ក្រដាស ឬសម្ភារៈគូរូប

**សួរសិស្សរបស់អ្នក**

គិតអំពីនរណាម្នាក់ដែលអ្នកបាននិយាយថា "សូមអរគុណអ្នក" ថ្មីៗនេះ។ សូមចំណាយពេល ២ ឬ៣នាទី គិតអំពីរឿងនេះដោយស្ងៀមស្ងាត់។ ឥឡូវនេះ ពិភាក្សាជាមួយដៃគូរអំពីនរណាដែលអ្នកគិតដល់ ហេតុអ្វី?

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សធ្វើការជាដៃគូ

**សួរសិស្សរបស់អ្នក**

ពេលបញ្ចប់ការពិភាក្សា សួរសិស្សថា៖

- តើអ្នកណាអាចចែករំលែកឧទាហរណ៍នៃពេលវេលាដែលអ្នកនិយាយថា "អរគុណ" ទៅកាន់នរណាម្នាក់? ហេតុអ្វី?
- តើមានអ្នកណាដឹងថាពាក្យ «ដឹងគុណ» មានន័យដូចម្តេច?

**ប្រាប់សិស្សរបស់អ្នក**

ពន្យល់ថា «ការដឹងគុណ» សំដៅទៅលើអារម្មណ៍ដែលយើងមាននៅពេល ដែលយើងដឹងគុណអ្នកដទៃចំពោះការមានចិត្តល្អ ឬសម្រាប់ការយកចិត្តទុកដាក់។ សូមលើកឧទាហរណ៍មួយពីជីវិតអ្នកដូចជា៖ «ខ្ញុំមានអារម្មណ៍ដឹងគុណពេល មាននរណាម្នាក់បើកទ្វារឱ្យខ្ញុំនៅព្រឹកមិញនេះ ពេលខ្ញុំកំពុងលើករបស់ធ្ងន់»។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ពិភាក្សាថាតើយើងអាចមានអារម្មណ៍ដឹងគុណដូចម្ដេច នៅពេលដែលយើងឱ្យតម្លៃលើវត្ថុអ្វីមួយដែលយើងមានវត្ថុដែលនរណាម្នាក់ឱ្យមកយើង ឬរបស់ដែលជាផ្នែកមួយនៃជីវិតប្រចាំថ្ងៃរបស់យើង ដែលយើងប្រហែលជាមិនបានគិតដល់វា។ សូមលើកឧទាហរណ៍មួយពីជីវិតផ្ទាល់ខ្លួនរបស់អ្នកដូចជា៖ «ខ្ញុំមានអារម្មណ៍ដឹងគុណសម្រាប់អាហារពេលល្ងាចរបស់ខ្ញុំកាលពីយប់មិញ ពីព្រោះខ្ញុំឃ្លានខ្លាំងហើយវាឆ្ងាញ់»។ បង្ហាញថាតើមានមនុស្សប៉ុន្មាននាក់ ដែលមានអារម្មណ៍ដឹងគុណចំពោះអ្វីៗដែលមានក្នុងពិភពធម្មជាតិ។ ឧទាហរណ៍ដូចជា៖ «ខ្ញុំមានអារម្មណ៍ដឹងគុណចំពោះភ្លៀងដែលផ្ដល់ទឹកឱ្យយើងផឹក និងជួយឱ្យរុក្ខជាតិលូតលាស់»។

ពិភាក្សាអំពីពេលខ្លះ ដែលយើងមានអារម្មណ៍ដឹងគុណ ចំពោះអ្វីដែលយើងមិនអាចមើលឃើញ ឬប៉ះបាន ប៉ុន្តែអ្វីទាំងនោះសំខាន់ដូចជា៖ សុខភាព បេតិកភណ្ឌ ឬប្រពៃណីរបស់យើង យុត្តិធម៌ គំនិតដែលជម្រុញទឹកចិត្តយើង ឬគ្រាន់តែនៅមានជីវិត។ សូមលើកឧទាហរណ៍មួយទៀតពីជីវិតរបស់អ្នក៖ «ខ្ញុំមានអារម្មណ៍ ដឹងគុណពេលខ្ញុំបានរៀនអ្វីដែលថ្មី ព្រោះការរៀនធ្វើឱ្យគំនិតរបស់ខ្ញុំរីកចម្រើន»។

ពន្យល់ថា យើងច្រើនតែបង្ហាញការដឹងគុណដោយនិយាយពាក្យថា "អរគុណ" ទៅកាន់នរណាម្នាក់។ (**ចំណាំ៖** សិស្សមួយចំនួនអាចមកពីតំបន់ ឬមានវប្បធម៌ ដែលពាក្យសម្ដីបង្ហាញពីការដឹងគុណប្លែក ទៅតាមតំបន់។ លើកទឹកចិត្តសិស្ស ឱ្យចែករំលែកពីវិធីដែលគ្រួសារ ឬសហគមន៍របស់ពួកគេបង្ហាញពី ការដឹងគុណ។) នៅពេលយើងមានអារម្មណ៍ដឹងគុណ យើងនិយាយថាយើងអរគុណ ឬមានអារម្មណ៍ ដឹងគុណ។

ធ្វើ

## សកម្មភាពក្នុងថ្នាក់

ឱ្យក្រដាសកត់ត្រាមួយដល់សិស្សគ្រប់គ្នា សុំឱ្យពួកគេកត់ត្រាខ្លីមួយពីពេលវេលា ដែលពួកគេមានអារម្មណ៍ដឹងគុណ និងអ្វីដែលពួកគេដឹងគុណ ឬនរណាដែលពួកគេដឹងគុណ (នេះប្រហែលជាគំនិតដូចគ្នាដែលពួកគេចែករំលែក ឬជាគំនិតថ្មីមួយទៀត)។ ដាក់បង្ហាញប្រភេទនៃការដឹងគុណទាំងបួនខាងក្រោមនៅជ្រុងទាំងបួននៃបន្ទប់។

និយាយ

## ប្រាប់សិស្សរបស់អ្នក

សូមក្រឡេកមើលក្រដាសកំណត់ត្រារបស់អ្នក ហើយគិតអំពីប្រភេទណាមួយក្នុងចំណោមប្រភេទនៃការដឹងគុណទាំង៤ **"អ្វីដែលខ្លួនយើងមាន" "សកម្មភាពល្អ" "ធម្មជាតិ" និង"រឿងសំខាន់ផ្សេងៗទៀត"** មួយណាដូចនឹងក្រដាសដែលអ្នកសរសេរ។ សូមទៅឈរនៅជ្រុងដែលប្រភេទនៃការដឹងគុណទាំងបួន ដែលពិពណ៌នាអំពីគំនិតរបស់អ្នក។ ប្រសិនបើគំនិតរបស់អ្នកមិនត្រូវគ្នានឹងប្រភេទណាមួយទេ ចូរឈរនៅកណ្ដាលបន្ទប់។ សិស្សណាដែលឈរនៅកណ្ដាលថ្នាក់រៀនអាចនឹងមានប្រភេទថ្មីនៃការដឹងគុណ។ ចែករំលែកអ្វីដែលអ្នកបានសរសេរនៅក្នុងក្រុមរបស់អ្នក។

ធ្វើ

## សកម្មភាពក្នុងថ្នាក់

ប្រសិនបើមានតែសិស្សម្នាក់ឈរនៅកណ្ដាលបន្ទប់ សុំឱ្យគាត់ចែករំលែកអ្វីដែលពួកគេបានសរសេរ និងប្រភេទនៃការដឹងគុណថ្មី។ ពិភាក្សាពីប្រភេទការដឹងគុណថ្មីនោះក្នុងថ្នាក់។ សុំឱ្យអ្នកស្ម័គ្រចិត្តម្នាក់ ឬពីនាក់ពីក្រុមនីមួយៗដើម្បីផ្ដល់ ឧទាហរណ៍អំពីប្រភេទនៃការដឹងគុណ ដែលបង្ហាញការដឹងគុណប្រភេទថ្មី របស់ពួកគេ។ នៅពេលដែលឧទាហរណ៍ពីក្រុមនីមួយៗបានចែករំលែក សូមប្រាប់ក្រុមឱ្យផ្លាស់ទីជាមួយគ្នាតាមទ្រនិចនាឡិកា ដើម្បីឈរក្បែរប្រភេទនៃការដឹងគុណថ្មី។ ឱ្យសិស្សពិភាក្សាម្ដងទៀតអំពីអ្វីដែលពួកគេមាន

អារម្មណ៍ដឹងគុណ ចំពោះអ្វីដែលនឹងត្រូវបានពិពណ៌នានូវប្រភេទនៃការដឹងគុណថ្មី (ពួកគេមិនចាំបាច់សរសេរទេ)។ ឱ្យពួករកឧទាហរណ៍មួយ ឬពីរពីក្រុមនីមួយៗ។

ប្រសិនបើមានពេលសូមបន្តឱ្យសិស្សឡើងឆ្លើយរហូតដល់គ្រប់គ្នា ដោយផ្លាស់ទីតាមប្រភេទទាំងបួន ឬប្រាំ។

### ស្ទួរសិស្សរបស់អ្នក

- តើឧទាហរណ៍ណាដែលងាយស្រួលគិត? ហេតុអ្វី?
- តើឧទាហរណ៍ណាខ្លះពិបាកគិត? ហេតុអ្វី?
- តើគំរូនៃការដឹងគុណអ្វីខ្លះដែលអ្នកបានឮហើយធ្វើឱ្យអ្នកភ្ញាក់ផ្អើល?
- តើអ្នកបានរៀនអ្វីខ្លះអំពីការដឹងគុណពីសកម្មភាពនេះ?

### កិច្ចការ

ឱ្យសិស្សឆ្លុះបញ្ចាំងពីអារម្មណ៍ដែលគិតពីវត្ថុ ឬមនុស្សដែលពួកគេដឹងគុណ។ តើពួកគេអាចលើកទឹកចិត្តអ្នកដទៃឱ្យអនុវត្តការដឹងគុណយ៉ាងដូចម្តេច?

### ផ្នែកបន្ថែម

សូមឱ្យសិស្សសរសេរអត្ថបទខ្លី ឬគូររូបភាពស្រមើលស្រមៃជាឧទាហរណ៍ អំពីអ្វីដែលពួកគេមានអារម្មណ៍ដឹងគុណបង្ហាញអ្វីដែលសិស្សបានធ្វើទាំងនេះនៅលើក្តារខៀន។ លើកទឹកចិត្តសិស្សមើល "វត្ថុ" ជាក់ស្តែងណាមួយ ដែលបានពិភាក្សា។ តើនរណាជាអ្នកឱ្យវត្ថុទាំងនោះមកអ្នក? គិតអំពីមនុស្សដែលជួយអ្នកបង្កើតវត្ថុទាំងនោះ។ រួមបញ្ចូលពួកគេទាំងនោះនៅក្នុងការដឹងគុណរបស់អ្នក!

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# ម៉ូឌុលទី ៤៖

# ការផ្សារភ្ជាប់ទៅនឹងពិភពឌីជីថល

[កម្មវិធីសិក្សាដែលមានភាពបត់បែន សិស្សដែលមានអាយុ ១៣-១៨ឆ្នាំ]

**គន្លឹះ៖**

| | |
|---|---|
| | ទទួលបានមាតិកាឌីជីថល |
| | ឱកាសក្នុងការផ្លាស់ប្តូរតាមអ្នកប្រើប្រាស់ឌីជីថល |
| | ឱកាសធ្វើមូលដ្ឋានីយកម្ម ( Localization ) |

# មាតិកា


មេរៀនទី១៖ ការគោរព និងដែនកំណត់ ........ 101

មេរៀនទី២៖ សុវត្ថិភាពទំនាក់ទំនងតាមអនឡាញ ........ 103

មេរៀនទី៣៖ តើការផ្សៀងផ្ទាត់គឺជាអ្វី? ........ 111

មេរៀនទី៤៖ ជំហានផ្សៀងផ្ទាត់ ........ 115

មេរៀនទី៥៖ កំណែនៃអត្ថបទប្រព័ន្ធផ្សព្វផ្សាយ ........ 119

មេរៀនទី៦៖ ភាពអាចធ្វើបានល្អបំផុតសម្រាប់ខ្លួនឯង ........ 124



t.me/moeysnews
sala.moeys.gov.kh
youtube.com/moeyscambodia

# មេរៀនទី១៖ ការគោរព និងដែនកំណត់

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

តើមានអ្វីកើតឡើងនៅពេល នរណាម្នាក់បានបំពានព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកតាមអនឡាញ ?

**វត្ថុបំណងមេរៀន**

សិស្សយល់កាន់តែច្បាស់អំពីទស្សនៈ និងអារម្មណ៍របស់អ្នកដទៃ នៅក្នុងបរិបទដែលបុគ្គលណាម្នាក់ចែករំលែកព័ត៌មានផ្ទាល់ខ្លួនតាមអនឡាញ។

**សម្ភារៈ ធនធាន ការរៀបចំ**

- សន្លឹកកិច្ចការ "ការស្វែងយល់ និងចែករំលែកអារម្មណ៍អ្នកដទៃ"
- ឯកសារគ្រូ "ការស្វែងយល់ និងការចែករំលែកអារម្មណ៍របស់អ្នកដទៃ"
- ចែកសន្លឹកកិច្ចការឱ្យសិស្ស។

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សធ្វើការជាដៃគូ ហើយចែកសន្លឹកកិច្ចការ "ការយល់ដឹង និងចែករំលែកអារម្មណ៍របស់អ្នកដទៃ" ឱ្យសិស្សគ្រប់គ្នា។ ទុកពេល ឱ្យសិស្ស ១៥នាទី ធ្វើការអាន និងពិភាក្សាពីសេណារីយ៉ូ បន្ទាប់មកជួយសម្របសម្រួលពួកគេ។

**សួរសិស្សរបស់អ្នក**

- តើមានសេណារីយ៉ូអ្វីខ្លះដែលដូចគ្នា ?
- តើសេណារីយ៉ូមួយណាពិបាកដោះស្រាយជាងគេ ? ងាយស្រួលដោះស្រាយជាងគេ ? ហេតុអ្វី ?
- តើអ្នកនឹងដោះស្រាយជាមួយសេណារីយ៉ូនីមួយៗដែលវាកើតឡើងចំពោះអ្នកដោយរបៀបណា ?
- តើអ្នកអាចការពារខ្លួនអ្នកពីការបំពានឯកជនភាពដោយរបៀបណា ?

**សកម្មភាពក្នុងថ្នាក់**

សូមណែនាំសិស្សថា ការចង់ដឹងជីវិតឯកជនរបស់មិត្តភក្តិក្នុងថ្នាក់ ដោយមិនមានការអនុញ្ញាត គឺជារឿងខុសច្បាប់ ហើយគ្មានសីលធម៌។ ប្រភេទទំនាក់ទំនងផ្សេងៗគ្នា ការចែករំលែកព័ត៌មានផ្ទាល់ខ្លួនក៏ផ្សេងៗគ្នាដែរ។ ភាពខុសគ្នានេះវាជារឿងធម្មតា និងសមហេតុផល។

**ប្រាប់សិស្សរបស់អ្នក**

ឥឡូវនេះយើងនឹងបន្ថែមសេណារីយ៉ូដែលយើងទើបតែបាននិយាយ។ នៅលើសន្លឹកកិច្ចការរបស់អ្នក សូមគូររូបកំប្លែងពីរដាច់ដោយឡែកពីគ្នា (ប្រសិនបើសិស្សមិនចាប់អារម្មណ៍ពីគំនិតនៃរឿងកំប្លែងទេ សូមស្នើឱ្យពួកគេសរសេររឿងខ្លីជំនួសវិញ) ដោយបញ្ជាក់៖

- សេណារីយ៉ូមួយដែលអ្នកមានអារម្មណ៍ថា ដែនកំណត់ឯកជនភាពរបស់អ្នក ឬរបស់នរណាម្នាក់មិនត្រូវបាន គេគោរព តើអ្នកចង់ឱ្យអ្នកដទៃមានប្រតិកម្មយ៉ាងដូចម្ដេច?
- សេណារីយ៉ូផ្សេងគ្នាដែលអ្នកមានអារម្មណ៍ថាដែនកំណត់ឯកជនភាពរបស់អ្នក ឬរបស់នរណាម្នាក់ត្រូវបាន គេគោរព តើអ្នកដទៃបានបង្ហាញការគោរព និងសន្ដានចិត្តយ៉ាងដូចម្ដេច?

**កិច្ចការ**

ទុកពេល ឱ្យសិស្ស ៣០នាទី ដើម្បីបញ្ចប់ការគូររូប ឬសរសេររឿងកំប្លែងរបស់ពួកគេ។

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

# មេរៀនទី២៖ សុវត្ថិភាពទំនាក់ទំនងតាមអនឡាញ

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

នៅក្នុងពិភពឌីជីថល តើអ្នកដឹងដោយរបៀបណាថាទំនាក់ទំនងនោះល្អ ឬមិនល្អ?

**វត្ថុបំណងមេរៀន**

- សិស្សស្វែងយល់ពីវិធីបង្កើតទំនាក់ទំនងល្អ មានសុវត្ថិភាព និងរបៀបដែលអាកប្បកិរិយាតាមអនឡាញ (Online Behaviors) ដើរតួនាទីទាំងទំនាក់ទំនងមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។
- សិស្សពិនិត្យមើលឱកាស និងបញ្ហាប្រឈមជុំវិញចំណុចរួមគ្នារវាងបណ្តាញសង្គម និងទំនាក់ទំនងជាមួយមិត្តភ័ក្តិរបស់ពួកគេ ហើយរៀនពីរបៀបលើកកម្ពស់ "ការចេះជួយគ្នា" ក្នុងចំណោមមិត្តភ័ក្តិ។

**សម្ភារៈធនធាន ការរៀបចំ**

- ក្រដាសផ្ទាំងធំ
- ផ្ទាំងផ្សព្វផ្សាយ (Poster) សម្រាប់សំណួរ
- ក្រដាសបិទចំណាំ
- ប៊ិក
- សរសេរសកម្មភាពហើយបិទនៅលើក្តារខៀន
- រៀបចំសំណួរដែលអាចកើតមានដាក់ផ្ទាំងផ្សព្វផ្សាយ (Poster)

**<u>ផ្នែកទី ១</u>**

**សកម្មភាពក្នុងថ្នាក់**

ឱ្យសិស្សឈរ ឬអង្គុយជារង្វង់។

**ប្រាប់សិស្សរបស់អ្នក**

ថ្ងៃនេះ ខ្ញុំចង់និយាយអំពីរបៀបដែលយើងមានសកម្មភាព នៅលើប្រព័ន្ធអនឡាញមានឥទ្ធិពលលើសុខុមាលភាពនៃទំនាក់ទំនងរបស់យើង។ ពួកយើងនឹងនិយាយផងដែរពីអ្វីដែលយើងអាចធ្វើបានដើម្បីក្លាយជា "អ្នកចេះជួយគ្នា" ចំពោះអ្នកដទៃ និងទទួលស្គាល់នៅពេលដែលមិត្តភ័ក្តិរបស់យើងត្រូវការជំនួយដើម្បីដោះស្រាយបញ្ហាទំនាក់ទំនងមួយចំនួនរបស់ពួកគេ។

**សួរសិស្សរបស់អ្នក**

អ្នកណាខ្លះធ្លាប់លឺពាក្យ "អ្នកមិនចេះជួយគ្នា" "Bystander" ឬ "អ្នកចេះជួយគ្នា" "Upstander"? តើពាក្យទាំងនេះមានន័យយ៉ាងណាចំពោះអ្នក?

### សកម្មភាពក្នុងថ្នាក់

ស្ដាប់ចម្លើយរបស់សិស្ស

និយាយ

### ប្រាប់សិស្សរបស់អ្នក

Bystander គឺជាអ្នកដែលសង្កេតមើលសកម្មភាពមួយចំនួនកើតឡើង។ សម្រាប់លំហាត់ថ្ងៃនេះ យើងកំពុងនិយាយអំពីទង្វើដែលទាក់ទងនឹងទំនាក់ទំនងមិនល្អ ឬគ្មានសុវត្ថិភាព។ Upstander គឺជាអ្នកដែលធ្វើអ្វីមួយជាវិជ្ជមានក្នុងការឆ្លើយតប ប្រហែលជាការជួយជនរងគ្រោះ ជួយបញ្ឈប់ទង្វើ ឬតាមវិធីផ្សេងទៀត អាស្រ័យលើស្ថានភាព។

## ផ្នែកទី ២

និយាយ

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ សូមនិយាយពីទំនាក់ទំនងជាដំបូងយើងគួរតែទទួលស្គាល់ថា "ទំនាក់ទំនង" គឺជាពាក្យទូលំទូលាយណាស់ សម្រាប់គោលបំណងរបស់យើង។ យើងនឹងឱ្យនិយមន័យពាក្យ "ទំនាក់ទំនង" គឺការតភ្ជាប់ណាមួយរវាងមិត្តភ័ក្តិ។ ឧទាហរណ៍៖ អ្នកអាចភ្ជាប់ជាមួយដៃគូរបស់អ្នក ជាមិត្តភ័ក្តិ មិត្តរួមសាលា ឬជាសមាជិកនៃសកម្មភាពក្រៅសាលាដូចគ្នា (ឧទាហរណ៍៖ ក្លឹបភាពយន្ត)។ នៅពេលណាដែលយើងនិយាយអំពីទំនាក់ទំនងដែលមានសុវត្ថិភាព សំណួរដ៏លំបាកតែងតែកើតឡើងថា "តើទំនាក់ទំនងដែលមានសុវត្ថិភាពតាមអនឡាញជាអ្វី?" មនុស្សគ្រប់រូបមានគំនិតខុសៗគ្នាអំពីប្រធានបទនេះហើយមានចម្លើយល្អៗជាច្រើន។

ដើម្បីប្រាកដថាយើងទាំងអស់គ្នាយល់ដូចគ្នា ចូរយើងគិតពិចារណាពីពាក្យដែលអាចពិពណ៌នាពីទំនាក់ទំនងដែលមានសុវត្ថិភាព ឧទាហរណ៍៖ មិត្តភាព មិត្តរួមថ្នាក់ ទំនាក់ទំនងផ្សេងៗ។ យើងដឹងថាពេលខ្លះអ្វីៗមិនត្រូវគ្រប់រឿងសម្រាប់ទំនាក់ទំនងគ្រប់ប្រភេទទេ ដូច្នេះសូមនិយាយតែពីអាកប្បកិរិយាដែលមានសុវត្ថិភាពសម្រាប់ប្រភេទទំនាក់ទំនងផ្សេងៗ។

ធ្វើ

### តស់លេងហ្គេមតូចមួយ

នៅពេល យើងដើរជុំវិញរង្វង់មួយ (តាមស្ថានភាពជាក់ស្ដែងរបស់ថ្នាក់) អ្នកខុសលក្ខខណ្ឌ (គ្រូជាអ្នកកំណត់) ត្រូវនិយាយពាក្យមួយឃ្លាដែលពិពណ៌នាអំពីទំនាក់ទំនងដែលមានសុវត្ថិភាព។ ខ្ញុំនឹងចាប់ផ្ដើម ខ្ញុំគិតថាទំនាក់ទំនងអាចជា (ការគាំទ្រការយកចិត្តទុកដាក់ អំពើល្អ។ល។)។

### សកម្មភាពក្នុងថ្នាក់

សរសេរចម្លើយរបស់សិស្សនៅលើក្ដារខៀន។

និយាយ

### ប្រាប់សិស្សរបស់អ្នក

អស្ចារ្យ! អរគុណសម្រាប់ការចូលរួម តោះមើលពាក្យទាំងនេះ។

### សួរសិស្សរបស់អ្នក

- តើយើងឯកភាពជាមួយពួកគេឬទេ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- តើអ្នកមានអ្វីចង់បន្ថែមឬទេ ?
- ដោយផ្អែកលើពាក្យទាំងនេះ តើនរណាម្នាក់អាចឱ្យនិយមន័យពាក្យទំនាក់ទំនងដែលមានសុវត្ថិភាពបាន ដែរឬទេ ?

**ណែនាំក្រុមឱ្យនិយមន័យរួមគ្នានៃទំនាក់ទំនងដែលមានសុវត្ថិភាព។**

**សកម្មភាព** Gallery Walk សិស្សត្រូវបានបែងចែកទៅជាក្រុមតូចៗ ដោយផ្លាស់ទីតាមស្ថានីយផ្សេងៗគ្នា និងបំពេញភារកិច្ចរបស់ស្ថានីយ៍នីមួយៗ។ ចាប់ផ្តើមពីការឆ្លើយសំណួរដែលបានចាត់តាំង ចែករំលែកចម្លើយគ្នាទៅវិញទៅមក ពិភាក្សា ផ្តល់យោបល់ ជជែកវែកញែកនៃការឆ្លើយតប ថាតើការឆ្លើយតបរបស់អ្នកណាល្អជាង និងបោះឆ្នោតសម្រាប់ចម្លើយដែលល្អបំផុត។

## សកម្មភាពក្នុងថ្នាក់

ឱ្យសិស្សធ្វើការជាដៃគូ

## ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ យើងមានបញ្ជីនិយមន័យច្រើនគួរសម នៅពេលដែលយើងនិយាយពី "ទំនាក់ទំនងដែលមានសុវត្ថិភាព" វាដល់ពេលដែលត្រូវប្តូរការផ្តោតអារម្មណ៍របស់យើងបន្តិច ហើយពិនិត្យមើលបទពិសោធផ្ទាល់ខ្លួនរបស់យើងជាមួយទំនាក់ទំនងនៅលើអ៊ីនធឺណិត។

## សកម្មភាពក្នុងថ្នាក់

សរសេរសំណួរពីបញ្ជីដែលមានខាងក្រោមនៅលើផ្ទាំងរូបភាព និងបិទផ្ទាំងរូបភាពជុំវិញបន្ទប់។

## សំណួរទៅលើផ្ទាំងរូបភាព៖

- តើអ្នកប្រាស្រ័យទាក់ទងជាមួយនរណាតាមរយៈបច្ចេកវិទ្យា ?
- តើវេទិកា សេវាកម្ម ឬវេបសាយណាខ្លះដែលអ្នកប្រើដើម្បីធ្វើទំនាក់ទំនងជាមួយគ្នា ?
- តើបច្ចេកវិទ្យាអ៊ីនធឺណិត និងទូរសព្ទចល័ត (ដូចជាកុំព្យូទ័របន្ទះ ឬទូរសព្ទចល័ត) បានផ្តល់ឱកាសឱ្យអ្នកបង្កើត ឬរក្សាទំនាក់ទំនងប្រកបដោយសុវត្ថិភាពយ៉ាងដូចម្តេច ?
- តើអ្នកអាចរក្សាទំនាក់ទំនងជាមួយមនុស្សដោយរបៀបណា ដោយសារឧបករណ៍ចល័ត និងកុំព្យូទ័រ ?
- តើបច្ចេកវិទ្យាអ៊ីនធឺណិត និងទូរសព្ទចល័តមានបញ្ហាប្រឈមអ្វីខ្លះក្នុងការបង្កើត ឬរក្សាទំនាក់ទំនងឱ្យមានសុវត្ថិភាព ?
- តើការបរិយាយទាក់ទងរឿងមិត្តភាពបែបណាដែលអ្នកបានជួប ឬឃើញគេបង្ហោះតាមអនឡាញ ?

## ប្រាប់សិស្សរបស់អ្នក

ខ្ញុំនឹងផ្តល់ក្រដាសកត់ត្រាមួយចំនួនដល់ក្រុមនីមួយៗ។ នៅលើផ្ទាំងរូបភាពជុំវិញបន្ទប់មានសំណួរផ្សេងៗគ្នា។ ពេលខ្ញុំផ្តល់ក្រដាសកត់ត្រាដល់អ្នក អ្នកអាចមើលផ្ទាំងរូបភាពទាំងអស់ រួចសរសេរចម្លើយនៅលើក្រដាសកត់ត្រា ហើយបិទវានៅលើផ្ទាំងរូបភាព។ ប្រសិនបើអ្នកមានចម្លើយលើសពីមួយសម្រាប់សំណួរមួយ

សូមសរសេរចម្លើយនីមួយៗនៅលើក្រដាសកត់ត្រាផ្សេងៗគ្នា ហើយបិទវានៅលើផ្ទាំងរូបភាព យើងមានពេល ៨នាទី។

### សកម្មភាពក្នុងថ្នាក់

ប្រមូលផ្ទាំងរូបភាពនៅចុងបញ្ចប់នៃសកម្មភាព ហើយឱ្យសិស្សទាំងអស់ចូលតាមក្រុមធំវិញ។

### សួរសិស្សរបស់អ្នក

- តើមានចម្លើយរួមអ្វីខ្លះសម្រាប់សំណួរនីមួយៗ?
- តើមានអ្វីដែលអ្នកគិតថានៅមានចំនុចខ្វះខាតទេ?
- តើបច្ចេកវិទ្យាបានផ្លាស់ប្តូរទំនាក់ទំនងជាមួយមិត្តរបស់អ្នកយ៉ាងដូចម្តេច?
- តើបច្ចេកវិទ្យាបានធ្វើឱ្យអ្វីៗកាន់តែងាយស្រួល ឬពិបាកជាងមុន? ហេតុអ្វី?

### ការពិភាក្សាពីសេណារីយ៉ូ

### ប្រាប់សិស្សរបស់អ្នក

ឥឡូវនេះ យើងនឹងពិភាក្សាអំពីសេណារីយ៉ូដែលភ្ជាប់ទៅនឹងបច្ចេកវិទ្យា និងទំនាក់ទំនងដែលគេហៅថា "ការផ្ញើសារដ៏លើសលប់" (Over-texting)។ មាននរណាដឹងថាតើការផ្ញើសារដ៏លើសលប់ជាអ្វី?

### សកម្មភាពក្នុងថ្នាក់

ស្តាប់ចម្លើយពីរ ឬបី

### ប្រាប់សិស្សរបស់អ្នក។

"ការផ្ញើ សារដ៏លើសលប់" នៅពេលដែលនរណាម្នាក់ផ្ញើសារជាច្រើនទៅកាន់មនុស្សម្នាក់ទៀត ដែលធ្វើឱ្យ អ្នកដទៃទទួលបានសារលើសលប់។

### សួរសិស្សរបស់អ្នក។

- តើមាននរណាម្នាក់ធ្លាប់ជួបប្រទះការផ្ញើសារលើសលប់ទេ?
- ប្រសិនបើអ្នកជាអ្នកទទួលសារលើសលប់នេះ តើអ្នកនឹងធ្វើអ្វី? ហេតុអ្វី?
- ប្រសិនបើមិត្តភ័ក្តិរបស់អ្នកនៅជិតអ្នក និយាយថាគាត់កំពុងប្រឈមមុខនឹងស្ថានភាពនេះ តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះ? តើអ្នកនឹងចាត់វិធានការដូចម្តេច? តើអ្នកអាចធ្វើសកម្មភាពផ្សេងៗអ្វីខ្លះ?

**ការតាមដាន៖** ការធ្វើសកម្មភាពទាំងនេះដើម្បីជួយមិត្តរបស់អ្នក ក៏ត្រូវបានគេហៅថា "អ្នកចេះជួយគ្នា" ផងដែរ។

### សួរសិស្សរបស់អ្នក

- តើអ្វីអាចរារាំងនរណាម្នាក់មិនឱ្យជួយមិត្តភ័ក្តិរបស់គេ?
- ចូរសម្តែងថា មិត្តម្នាក់របស់អ្នកសុំឱ្យមិត្តម្នាក់ទៀតឈប់ផ្ញើសារច្រើនពេក។ តើមានអ្វីកើតឡើង ប្រសិនបើមិត្តម្នាក់នោះ មកដល់ផ្ទះមិត្តភ័ក្តិរបស់អ្នកគ្រប់ពេលវេលាឥតឈប់ឈរសួររកគាត់?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

- បញ្ហាហាក់ដូចជាកាន់តែអាក្រក់ទៅៗ ដែលអាចត្រូវបានគេហៅថា "បញ្ហាទំនាក់ទំនងធ្ងន់ធ្ងរ" (Escalation)។ តើអ្នកនឹងផ្តល់ដំបូន្មានអ្វីខ្លះដល់មិត្តរបស់អ្នក ប្រសិនបើបញ្ហាកាន់តែធ្ងន់ធ្ងរ?
- ប្រសិនបើបញ្ហាកាន់តែកើនឡើង តើអ្នកនៅតែអាចឆ្លើយតបដូចមុនបានដែរឬទេ? តើឥឡូវនេះអ្នកអាចធ្វើសកម្មភាពអ្វីខ្លះដើម្បីធ្វើជាអ្នកចេះជួយគ្នា?

### ប្រាប់សិស្សរបស់អ្នក

"ការផ្ញើសារលើសលប់" គឺជាឧទាហរណ៍មួយនៃស្ថានភាពបច្ចេកវិទ្យា ដែលយើងអាចជួបនៅក្នុងវិធីទំនាក់ទំនង ដែលមានសុវត្ថិភាព។

### សួរសិស្សរបស់អ្នក

- តើមានឧទាហរណ៍អ្វីផ្សេងឬទេ?
- តើមានដំណោះស្រាយអ្វីខ្លះចំពោះបញ្ហាទាំងនេះ?
- តើការពិភាក្សារបស់យើងកន្លងមកបានប្រាប់យើងអ្វីខ្លះអំពីតួនាទីនៃបច្ចេកវិទ្យាក្នុងការទំនាក់ទំនង?

### សកម្មភាពក្នុងថ្នាក់

ពិភាក្សាអំពីផលជះវិជ្ជមាន និងអវិជ្ជមាននៃបច្ចេកវិទ្យាក្នុងការទំនាក់ទំនង។

## សកម្មភាពផ្សេងៗ

### ប្រាប់សិស្សរបស់អ្នក

សូមក្រឡេកមើលអាកប្បកិរិយាជាក់លាក់នៅក្នុងទំនាក់ទំនងដែលមានសុវត្ថិភាព និងគ្មានសុវត្ថិភាព។ ខ្ញុំនឹងចែកក្រដាសកត់ត្រាមួយដល់អ្នកទាំងអស់គ្នា។ នៅលើក្រដាសកត់ត្រា ជាសកម្មភាពដែលកើតឡើងនៅក្នុងទំនាក់ទំនងដូចជា "ផ្ញើសារទៅដៃគូរបស់អ្នក ២៤ម៉ោង/៧ថ្ងៃ" ឬ "ការផ្លាស់ប្តូរពាក្យសម្ងាត់ប្រព័ន្ធផ្សព្វផ្សាយសង្គម"។ ពេលដែលខ្ញុំផ្តល់ក្រដាសកត់ត្រា ខ្ញុំចង់ឱ្យអ្នកក្រោកឈរហើយឡើងទៅខាងមុខក្តារខៀន។ ឈរនៅផ្នែកម្ខាងនៃបន្ទប់ ជាអាកប្បកិរិយាទំនាក់ទំនងដែលមានសុវត្ថិភាព ហើយម្ខាងទៀតគឺជាអាកប្បកិរិយាទំនាក់ទំនងដែលគ្មានសុវត្ថិភាព។

នៅពេលអ្នកឡើងមក សូមគិតថានៅលើក្រដាសកត់ត្រាតើជាអាកប្បកិរិយាមានសុវត្ថិភាព ឬគ្មានសុវត្ថិភាព សូមឈរជាជួរ។ ឧទាហរណ៍៖ ប្រសិនបើអ្នកជឿថា "ការផ្ញើសារទៅកាន់ដៃគូរបស់អ្នក ២៤ម៉ោង/៧ថ្ងៃ" គឺសុវត្ថិភាពតិចតួចប្រៀបនឹង "ការចូលចិត្ត ឬចែករំលែកឡើងវិញនូវអ្វីគ្រប់យ៉ាងដែលមិត្តរបស់អ្នកបានបង្ហោះ" សូមមកឈរជិតនៅជ្រុងដែលបញ្ជាក់ថាគ្មានសុវត្ថិភាព។

### សកម្មភាពក្នុងថ្នាក់

ក្រដាសប្រធានបទដែលបានណែនាំ៖

- ផ្ញើសារទៅដៃគូរបស់អ្នក ២៤ម៉ោង/៧ថ្ងៃ
- ការផ្លាស់ប្តូរពាក្យសម្ងាត់របស់បណ្តាញសង្គមគ្នា។
- ការអានសាររបស់មិត្តភ័ក្តិដោយគ្មានការអនុញ្ញាតពីពួកគេ។
- និយាយជាមួយមនុស្សចម្លែក ឬមនុស្សដែលអ្នកមិនស្គាល់ច្បាស់តាមអនឡាញ។

- ការបញ្ចេញមតិមិនសមរម្យលើការបង្ហោះរបស់នរណាម្នាក់តាមបណ្ដាញសង្គម។
- ការផ្ញើសារ "រាត្រីសួស្ដី" ឬ "អរុណសួស្ដី" ទៅកាន់នរណាម្នាក់ដែលអ្នកយកចិត្តទុកដាក់។
- និយាយអំពីការឈ្លោះប្រកែកគ្នាជាមួយមិត្តភ័ក្ដិជាសាធារណៈតាមបណ្ដាញសង្គម។
- ការឱ្យមេដៃ និងចែករំលែកឡើងវិញនូវអ្វីគ្រប់យ៉ាងដែលមិត្តរបស់អ្នកបានបង្ហោះ។
- ការបង្ហោះមាតិកានៅលើបណ្ដាញសង្គមដោយប្រើគណនីមិត្តភ័ក្ដិរបស់អ្នក (ក្នុងឈ្មោះរបស់ពួកគេ)។
- បញ្ចាប់ស្លាក (Tag) មិត្តភ័ក្ដិរបស់អ្នកនៅក្នុងរូបថត ពិធីជប់លៀងមួយ។
- ការនិយាយដើមមិត្តភ័ក្ដិរួមសាលារបស់អ្នកនៅលើផ្សព្វផ្សាយសង្គម។

នៅពេលសិស្សបានជ្រើសរើស និងឡើងមកឈរតាមជួរ សួរពួកគេអំពីមូលហេតុដែលពួកគេឈរនៅកន្លែងនោះ លើកទឹកចិត្តសិស្សឱ្យផ្លាស់ទីជុំវិញ ប្រសិនបើពួកគេចង់ផ្លាស់ប្ដូរ។ នៅពេលដែលសិស្សបានធ្វើសកម្មភាពរួចហើយ ឱ្យពួកគេបិទក្រដាសកំណត់ត្រានៅលើ ជញ្ជាំង នៅខាងមុខបន្ទប់ ហើយថយក្រោយមួយជំហាន។

### សកម្មភាពក្នុងថ្នាក់

ប្រសិនបើពួកគេជ្រើសរើសធ្វើដូច្នេះ សិស្សអាចឆ្លើយសំណួរចំនួន២ដំបូង ខាងក្រោមតាមរយៈការពិភាក្សា ឬ សរសេរ នៅលើក្រដាសកត់ត្រា ហើយបិទ នៅលើជញ្ជាំងខាងមុខថ្នាក់រៀន។

### សួរសិស្សរបស់អ្នក

- តើមានអាកប្បកិរិយា មាន និងគ្មានសុវត្ថិភាព ណាផ្សេងទៀតដែលអ្នកអាចគិតឃើញ?
- តើមានលំដាប់ត្រឹមត្រូវតែមួយសម្រាប់សកម្មភាពនេះទេ? ហេតុអ្វី? តើអ្នកទាំងអស់គ្នាយល់ស្របទេ?

### សួរសិស្សរបស់អ្នក

- យើងដាក់អាកប្បកិរិយាដាក់លាក់ទាំងនេះនៅលើសកម្មភាពផ្សេងៗពីមានទៅគ្មានសុវត្ថិភាព។ ប៉ុន្តែវាអាចមានក្នុងស្ថានភាពនៅពេល ដែលអាកប្បកិរិយាដែលមានសុវត្ថិភាពប្រែទៅជាគ្មានដែរឬទេ? ផ្ទុយមកវិញ? តើវាអាចកើតឡើងនៅពេលណា?
- ប្រសិនបើ X គឺជាអាកប្បកិរិយាដែលគ្មានសុវត្ថិភាព (ជ្រើសរើសអាកប្បកិរិយាដាក់លាក់មួយដែលសិស្សដាក់នៅជិតផ្នែក "គ្មានសុវត្ថិភាព" នៃសកម្មភាព) តើអ្នកនឹងដោះស្រាយដូចម្ដេច?
- តើអ្នកនឹងនិយាយជាមួយនរណាម្នាក់ដោយរបៀបណា ប្រសិនបើអ្នកមិនពេញចិត្តនឹងអ្វីដែលគេកំពុងធ្វើ?

## កិច្ចការ

### ផ្នែកទី ១

### ប្រាប់សិស្សរបស់អ្នក

ថ្ងៃនេះ យើងបាននិយាយច្រើនអំពីបច្ចេកវិទ្យា និងទំនាក់ទំនង។ ឥឡូវ សូមគិតថា តើអ្នកអាចចែករំលែកអ្វីដែលអ្នកបានរៀនជាមួយអ្នកដទៃដោយរបៀបណា? តើសកម្មភាពអ្វីខ្លះដែលអ្នកអាចបង្កើតដើម្បីលើកទឹកចិត្តមិត្តភ័ក្ដិរបស់អ្នកឱ្យក្លាយជា «អ្នកចេះជួយគ្នា» ប្រសិនបើពួកគេឃើញអាកប្បកិរិយាគ្មានសុវត្ថិភាពណាមួយ នៅក្នុងទំនាក់ទំនង?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

**កិច្ចការ**

ចែកសិស្សជា បី ឬបួនក្រុម។

**ប្រាប់សិស្សរបស់អ្នក**

យើងមានយោបល់ចំនួនពីរនៅពេលនេះ ប៉ុន្តែប្រសិនបើអ្នកមានគំនិតផ្សេងសូមបន្ថែម។ ទុកពេលឱ្យសិស្ស ៣០នាទី។

**ការណែនាំទី១៖** បង្កើតចំណុចសំខាន់ៗសម្រាប់ព្រឹត្តិការណ៍មួយ ដែលអាចកើតមានចំពោះសមាជិកសាលារៀន ឬសហគមន៍របស់អ្នក ជុំវិញតួនាទីនៃបច្ចេកវិទ្យានៅក្នុងទំនាក់ទំនង។ ព្រឹត្តិការណ៍នេះអាចជាការចាក់បញ្ចាំងឯកសារ ឬការពិភាក្សាពីយុទ្ធនាការដូចជា "សប្តាហ៍នៃក្តីស្រឡាញ់" ឬបទបង្ហាញ។ ផ្តល់ឧទាហរណ៍អំពីរបៀបដែលអ្នកប្រើបណ្តាញសង្គមដូចជា Facebook ឬ Twitter(X) ដើម្បីផ្សព្វផ្សាយព្រឹត្តិការណ៍នោះ។ អ្នកអាចបង្កើតរូបភាពដោយសេរីរួមជាមួយចំណុចសំខាន់ៗរបស់អ្នក (ឧទាហរណ៍៖ គំនូរ, រូបត្លុក)។

**ការណែនាំទី២៖** បង្កើតរឿងខ្លីអំពីទំនាក់ទំនង ឧទាហរណ៍៖ ទំនាក់ទំនងរវាងបងប្អូន ឬទំនាក់ទំនងរវាងមិត្តភ័ក្តិនៅសាលា និងរបៀបដែលវាអាចរងផលប៉ះពាល់ដោយបណ្តាញសង្គម។ អ្នកអាចធ្វើការសម្តែងខ្លីៗ បង្កើតរូបភាព (ឧទាហរណ៍៖ ឈុតកំប្លែង) ឬសរសេរសម្មតិកម្ម Facebook News Feed ឬការសន្ទនា Twitter (X)។ សូមធ្វើវាឱ្យមានភាពច្នៃប្រឌិត!

<u>**ផ្នែកទី ២**</u>

**កិច្ចការ**

បន្ទាប់ពី ៣០នាទី ហើយ ឱ្យពួកគេចែករំលែកអ្វីដែលបានបង្កើត ហើយឆ្លើយសំណួរខាងក្រោម។

**សួរសិស្សរបស់អ្នក**

- តើអ្នកកំពុងនិយាយអំពីប្រធានបទអ្វី?
- តើអ្នកចង់ឱ្យអ្នកដទៃរៀនអ្វីខ្លះពីគំនិតរបស់អ្នក? តើគំនិតនេះនឹងផ្តល់ប្រយោជន៍ដូចម្តេចចំពោះសាលា សហគមន៍ ឬមិត្តភ័ក្តិរបស់អ្នក?
- តើនរណាជាទស្សនិកជនគោលដៅរបស់អ្នក?
- តើអ្នកនឹងផ្សព្វផ្សាយគំនិតនេះទៅឱ្យទស្សនិកជនគោលដៅរបស់អ្នកដោយរបៀបណា?
- តើអ្នកគិតថាទស្សនិកជនរបស់អ្នកនឹងមានប្រតិកម្មយ៉ាងណាដែរ?

**ការឆ្លុះបញ្ចាំង**

**ប្រាប់សិស្សរបស់អ្នក**

យើងសង្ឃឹមថា អ្នកទាំងអស់គ្នាបានគិតពីទំនាក់ទំនងដែលមានសុវត្ថិភាព ឱ្យស៊ីជម្រៅ ជាពិសេសទាក់ទងនឹងរបៀបដែលបច្ចេកវិទ្យា បានផ្លាស់ប្តូរអ្វីៗទាំងអស់។ យើងក៏ចង់ឱ្យអ្នកគិតអំពីវិធីដើម្បីលើកទឹកចិត្តមិត្តរបស់អ្នកឱ្យ "ចេះជួយគ្នា" ឬក្រោកឈរឡើងសម្រាប់ខ្លួនគេ ឬអ្នកដទៃ នៅពេលពួកគេឃើញអ្វីមួយមិនពេញចិត្ត ឬអ្វីមួយដែលធ្វើឱ្យអ្នកដទៃឈឺចាប់។

## សួរសិស្សរបស់អ្នក

- តើអ្នកបានរៀនអ្វីខ្លះ ?
- តើសកម្មភាពមួយណា ដែលអ្នកចូលចិត្តជាងគេ ? ហេតុអ្វី ?
- តើសកម្មភាពមួយណា ដែលអ្នកមិនសូវចូលចិត្តជាងគេ ? ហេតុអ្វី ?
- តើអ្នកអាចយកអ្វីដែលអ្នករៀន ឬធ្វើការមកអនុវត្តក្នុងជីវិតប្រចាំថ្ងៃរបស់អ្នកដោយរបៀបណា ? តើអ្នកនឹងពណ៌នាអំពីអ្វីដែលអ្នកបានធ្វើទៅលើមិត្តភ័ក្តិរបស់អ្នកដោយរបៀបណា ?
- តើមានអ្វីខ្លះដែលថ្មី ឬធ្វើឱ្យអ្នកមានការភ្ញាក់ផ្អើល ?
- តើអ្នកមានសំណួរផ្សេងទៀតទេ អំពីទំនាក់ទំនងដែលមាន និងគ្មានសុវត្ថិភាព ?

t.me/moeysnews sala.moeys.gov.kh youtube.com/moeyscambodia

## មេរៀនទី៣៖ តើការផ្ទៀងផ្ទាត់គឺជាអ្វី?

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើអ្នកមានអារម្មណ៍ថា តើប្រព័ន្ធអេកូព័ត៌មានរបស់អ្នកតាមប្រព័ន្ធអ៊ីនធឺណិតគឺជាការពិតឬទេ?
- ហេតុអ្វីបានជាពិត ឬហេតុអ្វីបានជាមិនពិត?

**គោលបំណងមេរៀន**

សិស្សដឹងថា តើការផ្ទៀងផ្ទាត់ព័ត៌មានគឺជាអ្វី? ហើយហេតុអ្វីបានជាវាសំខាន់សម្រាប់អ្នកប្រើប្រាស់ព័ត៌មានដើម្បីផ្ទៀងផ្ទាត់អ្វីដែលពួកគេអាន ឬមើល។ ពួកគេពិចារណាអំពីការទទួលខុសត្រូវរបស់អង្គភាពព័ត៌មានសមាជិកអ្នកចូលរួម និងក្រុមហ៊ុនបណ្តាញសង្គម ដែលបានផ្សព្វផ្សាយព័ត៌មានពិតដែលអាចជឿទុកចិត្ត។

**សម្ភារៈ ធនធាន ការរៀបចំ**

- រូបភាពត្រីក្បាលជ្រូក (បញ្ចាំងស្លាយ ឬបោះពុម្ពមកក្រៅ)
- កុំព្យូទ័រយួរដៃ
- ធនធានបន្ថែមសម្រាប់គ្រូ
- សិស្សត្រូវការចូលប្រើប្រព័ន្ធអ៊ីនធឺណិតសម្រាប់មេរៀននេះ។

និយាយ

**ប្រាប់សិស្សរបស់អ្នក**

ក្នុងឆ្នាំ ២០១៦ វេបសាយឈ្មោះ World News Daily Report បានចុះផ្សាយអត្ថបទមួយពីអ្នកថតរូបឱ្យកម្មវិធី National Geographic ដែលត្រូវបានត្រីសមុទ្រ (SunFish) យ៉ាងធំមួយក្បាលស៊ីទាំងរស់ក្នុងប្រទេសប៉េរូ។ យោងតាមអត្ថបទនេះ Joaquín Álvarez Santos អាយុ ២៩ឆ្នាំ បានកំពុងថតនៅក្រោមទឹកជាមួយអ្នកមុជទឹក ៤នាក់ ផ្សេងទៀត នៅពេលនោះគាត់ត្រូវបានត្រីលេបទាំងមូល ដែលត្រីនោះមានទម្ងន់ជាង ២០០០គីឡូក្រាម (៤៤០០ផោន)។ អ្នកមុជទឹកម្នាក់ ក្នុងចំណោមអ្នកមុជទឹកដែលកំពុងថតរូបនោះគឺ James C.Wyatt បាននិយាយថាគេបានថតរូបនេះនៅមុនពេលកើតហេតុ។

**សួរសិស្សរបស់អ្នក**

ចំណាយពេល ២នាទី ដើម្បីស្វែងរកតាមកម្មវិធី Google នៃព្រឹត្តិការណ៍ព័ត៌មាននេះ។ តើអ្នកបានរកឃើញអ្វីខ្លះ?

និយាយ

**ប្រាប់សិស្សរបស់អ្នក**

អ្នកប្រហែលជាបានរកឃើញនៅក្នុងការស្វែងរករបស់អ្នកថា អត្ថបទនេះគឺជារឿងប្រឌិត។ រាល់ខ្លឹមសារព័ត៌មានមានប្រភពដើម ដែលអាចកំណត់បានថាជាបុគ្គលម្នាក់នោះ ការបោះពុម្ពផ្សាយ ឬភ្នាក់ងារដែលចាប់យករូបភាព ឬមានព័ត៌មានអំពីព្រឹត្តិការណ៍សារព័ត៌មានដើម។ ប្រភពនៃរឿងរ៉ាវនេះមាននៅវេបសាយ World News Daily Report ដែលចេញមុខបដិសេធដោយបញ្ជាក់ថា "ការទទួលខុសត្រូវទាំងអស់ចំពោះការរិះគន់នៃអត្ថបទ" ហើយថា "តួអង្គទាំងអស់ដែលលេចឡើងនៅក្នុងអត្ថបទនៅក្នុងវេបសាយនេះ សូម្បីតែរឿងទាំងនោះមានតួអង្គពិតក៏ដោយ ក៏ជាការប្រឌិតទាំងស្រុងដែរ។ យ៉ាងណាមិញ អ្នកប្រហែលជាបានរកឃើញថារូបថតនោះពិត។ វាត្រូវបានថតដោយអ្នកថតរូប Miguel Pereira ដែលបានជួបប្រទះត្រីម្យ៉ាងដែលមានរូបរាងដូចព្រះអាទិត្យ (SunFish) នៅឆ្នេរសមុទ្រនៃប្រទេសព័រទុយហ្គាល់ (ហើយនៅរស់បានប្រាប់រឿងនិទាននេះ) ក្នុងឆ្នាំ២០១៣។

## សួរសិស្សរបស់អ្នក

- ហេតុអ្វីបានជាអ្នកគិតថាវេបសាយចុះផ្សាយអត្ថបទនេះ?
- តើអ្នកគិតថាគួរតែមានវេបសាយដែលចុះផ្សាយតែមាតិកាប្រឌិតដែរឬទេ?
- តើអ្នកគិតថាអ្នកអានទាំងអស់នឹងដឹងថាវេបសាយ World News Daily Report ចុះផ្សាយរឿងប្រឌិតដែរឬទេ? ហេតុអ្វី?

## ប្រាប់សិស្សរបស់អ្នក

ក្នុងចំណោមអ្នកទាំងអស់គ្នាតើមាននរណាខ្លះដែលធ្លាប់បានចែករំលែកព័ត៌មាននៅលើបណ្តាញសង្គមពីមុនមក? មនុស្សជុំវិញពិភពលោកសព្វថ្ងៃនេះកំពុងរាយការណ៍អំពីព្រឹត្តិការណ៍នៅលើ Facebook, Twitter, YouTube និងកម្មវិធីផ្ញើសារដូចជា Telegram, Snapchat និង WhatsApp ជាដើម។ មនុស្សរាប់លាននាក់បានប្រើប្រាស់ បណ្តាញសង្គមជាឧបករណ៍សំខាន់ដើម្បីរៀបចំការតវ៉ា និងការចូលរួមជាមួយសារព័ត៌មាន (ដោយការបង្ហោះ រូបថត វីដេអូ បច្ចុប្បន្នភាពស្ថានភាព ការចែករំលែក និង ការបញ្ចេញមតិ)។ ការដឹងពីរបៀបប្រោះ និងធ្វើឱ្យយល់នូវព័ត៌មានទាំងអស់នេះ គឺជាជំនាញដ៏សំខាន់សម្រាប់អ្នកណាម្នាក់ដែលចង់ប្រើប្រាស់ព័ត៌មាននាពេលបច្ចុប្បន្ននេះ។ ជំនាញនេះមានសារៈសំខាន់ណាស់ជាពិសេស ដោយសារមនុស្សអាចបង្កើតអាន ឬចែករំលែកព័ត៌មានខុស និងព័ត៌មានក្លែងក្លាយដោយមិនដឹងខ្លួន។

## សួរសិស្សរបស់អ្នក

- "តើអ្នកអាចគិត អំពីព្រឹត្តិការណ៍ព័ត៌មានដែលអ្នកត្រូវបានបោកបញ្ឆោតដោយពាក្យចាមអារ៉ាម រូបភាព ឬវីដេអូមិនពិត?"
- តើវាជាព្រឹត្តិការណ៍អ្វី?
- តើអ្នកអាចដឹងថាព័ត៌មាននោះជាព័ត៌មានក្លែងក្លាយដោយរបៀបណា?

## ប្រាប់សិស្សរបស់អ្នក

ខណៈដែលមនុស្សមួយចំនួន ព្យាយាមបោកបញ្ឆោតតាមរយៈ បណ្តាញផ្សព្វផ្សាយព័ត៌មានដោយចេតនា ជាឧទាហរណ៍៖ ការបង្ហោះសារខ្លីថាផ្សារភាគហ៊ុនញូវយ៉ក បានធ្លាក់ចុះយ៉ាងខ្លាំងក្នុងអំឡុងពេលព្យុះខ្យាច់។ មនុស្សផ្សេងទៀតអាចចែករំលែកព័ត៌មានដូចគ្នា នៅលើបណ្តាញសង្គមដើម្បីជួយ ឬផ្តល់បច្ចុប្បន្នភាព

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

ដល់អ្នកដទៃ។ "ជាញឹកញាប់មានពាក្យចចាមអារ៉ាមមិនពិតជាច្រើនកើតឡើង ក្នុងអំឡុងពេល ព្រឹត្តិការណ៍ព័ត៌មាន ទាន់ហេតុការណ៍ ដែលបន្ទប់ប្រមូលព័ត៌មានបានចាប់ផ្តើម ប្រមូលបញ្ចីព័ត៌មានរបស់ពួកគេ" (FirstDraft News)។ អ្នកកាសែតត្រូវបានបណ្តុះបណ្តាលឱ្យចេះសង្ស័យចំពោះអ្វីគ្រប់យ៉ាងដែលពួកគេឮ និងឃើញ (ថាតើវាជាព័ត៌មានទាន់ហេតុការណ៍ ឬខ្លឹមសារដែលរាលដាលលឿន) រហូតដល់ពួកគេអាចផ្ទៀងផ្ទាត់ ឬកំណត់ប្រភពបាន។

នៅក្នុងបណ្តុំនៃបទពិសោធសិក្សានេះ អ្នកនឹងរៀនពីរបៀបផ្ទៀងផ្ទាត់ព័ត៌មានដូចជា វីដេអូ រូបភាព និងព័ត៌មាន ផ្សេងៗដើម្បីឱ្យអ្នកអាចបែងចែកការពិត ឬប្រឌិតនៅក្នុងទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ន។ ការផ្ទៀងផ្ទាត់ គឺជាដំណើរការមួយដែលអង្គភាពព័ត៌មាន ឬបុគ្គលណាម្នាក់ប្រមូល និងវាយតម្លៃភស្តុតាងដើម្បីស៊ើបអង្កេត ថាតើព័ត៌មានត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ ទោះបីជាដំណើរការផ្ទៀងផ្ទាត់ធ្លាប់ត្រូវបានអនុវត្តជាចម្បងដោយអ្នកសារព័ត៌មាន និងស្ថាប័នព័ត៌មានក៏ដោយ វាមានភាពចាំបាច់សម្រាប់អ្នកដែលចង់ទទួលបានព័ត៌មានត្រឹមត្រូវអំពីព្រឹត្តិការណ៍បច្ចុប្បន្ន។ នៅក្នុងបរិយាកាសដែលនរណាម្នាក់អាចបង្កើត និងចែករំលែកព័ត៌មានតាមអនឡាញជាពិសេសនៅលើបណ្តាញសង្គម ការដែលអាចផ្ទៀងផ្ទាត់ខ្លឹមសារដែលយើងប្រើប្រាស់ និងចែករំលែកមានសារៈសំខាន់សម្រាប់ការកសាងសហគមន៍អនឡាញដែលមានសុខុមាលភាពល្អ និងកសាងកេរ្តិ៍ឈ្មោះដែលមានទំនុកចិត្តលើបណ្តាញសង្គម។

### សួរសិស្សរបស់អ្នក

- តើមាននរណាធ្លាប់លឺពីការត្រួតពិនិត្យការពិត ឬក្រុមអ្នកត្រួតពិនិត្យការពិតដែរឬទេ?
- តើអ្នកគិតថាក្រុមអ្នកត្រួតពិនិត្យការពិត គេធ្វើអ្វី?

### ប្រាប់សិស្សរបស់អ្នក

ក្រុមអ្នកត្រួតពិនិត្យការពិត (Fact-Checkers) គឺជាអ្នកដែលកំណត់អត្តសញ្ញាណហើយបន្ទាប់មកផ្ទៀងផ្ទាត់ ឬបដិសេធរាល់ការពិតទាំងអស់នៅក្នុងអត្ថបទមួយ។ ក្រុមអ្នកត្រួតពិនិត្យការពិត ជារឿយៗធ្វើការឱ្យក្រុមហ៊ុនកាសែត ទស្សនាវដ្តី អ្នកនិពន្ធ ឬអ្នកបោះពុម្ពសៀវភៅ ហើយក្នុងប៉ុន្មានទសវត្សរ៍ថ្មីៗនេះ ពួកគេបានកំពុងផ្ទៀងផ្ទាត់ខ្លឹមសារនយោបាយកាន់តែខ្លាំងឡើងៗ។ ដូចដែលអ្នកឃើញនៅក្នុងអត្ថបទនេះ អ្នកជំនាញជឿថា ចំនួនក្រុមអ្នកត្រួតពិនិត្យការពិតនៅទូទាំងពិភពលោកនឹងកើនឡើងនាពេលអនាគត ដោយសារតែការកើនឡើងនៃបណ្តាញសង្គម និងមាតិកាព័ត៌មានដែលបង្កើតឡើងដោយអ្នកប្រើប្រាស់។

ការផ្ទៀងផ្ទាត់ គឺជាការត្រួតពិនិត្យមើលប្រភពក្រៅផ្លូវការនៅលើគេហទំព័រដែលជួនកាលគេស្គាល់ថាជា "ខ្លឹមសារដែលបង្កើតដោយអ្នកប្រើប្រាស់" ដូចជានៅពេលដែលនរណាម្នាក់នៅក្នុងព្រឹត្តិការណ៍មួយ ហើយបន្ទាប់មកបង្ហោះវីដេអូ។ ក្រុមអ្នកត្រួតពិនិត្យការពិតធ្វើការផ្ទៀងផ្ទាត់ប្រភពផ្លូវការ៖ គោលនយោបាយ ឯកសាររដ្ឋាភិបាល សុន្ទរកថា ដែលធ្វើឡើងដោយអ្នកនយោបាយ។ល។ ក្រុមអ្នកត្រួតពិនិត្យការពិតទាំងអស់ប្រើភាពខុសគ្នាមួយចំនួននៃដំណើរការផ្ទៀងផ្ទាត់។ ទោះជាយ៉ាងណាក៏ដោយដូចដែលបានរៀបរាប់ពីមុនមក អ្នកណាក៏អាចប្រើដំណើរការផ្ទៀងផ្ទាត់នៅពេលប្រើប្រាស់ព័ត៌មាន។ អ្នកអាចប្រើវេបសាយដ៏ពេញនិយម ដូចជា https://www.snopes.com/ https://www.factcheck.org/ និងការពិនិត្យការពិតនយោបាយរបស់ NPR (National Public Radio) ដើម្បីជួយអ្នកក្នុងការផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃមាតិកាព័ត៌មានដែលអ្នកបានឆ្លងកាត់តាមអនឡាញ។

## កិច្ចការ

### សកម្មភាពក្នុងថ្នាក់

បញ្ចាំងរូបភាពខាងក្រោមនៅលើអេក្រង់។ នៅពេលសួរសំណួរ សូមសួរសិស្សថាតើការកំណត់អត្តសញ្ញាណ រូបភាពនេះថាជាការបោកបញ្ឆោតមានអត្ថប្រយោជន៍សម្រាប់ការបោះពុម្ពផ្សាយ និងអ្នកប្រើប្រាស់ព័ត៌មាន យ៉ាងដូចម្តេច។

## កិច្ចការ

### ប្រាប់សិស្សរបស់អ្នក

រូបភាពនេះត្រូវបានចែករំលែកនៅលើបណ្តាញសង្គមដូចជា Facebook និង YouTube ជាមួយនឹងអត្ថបទកំណត់អត្តសញ្ញាណសត្វនេះថាជា "ត្រីមានមុខជ្រូក" ឬ "ត្រីជ្រូកព្រៃ"។ ចូរមើលវេបសាយ Snopes ហើយពិនិត្យមើលពីរបៀបដែលក្រុមអ្នកត្រួតពិនិត្យការពិតបានបដិសេធរូបភាពនេះថាជាការបោកបញ្ឆោត។

សរសេរកថាខណ្ឌខ្លីមួយដោយពន្យល់ពីរបៀបដែលការកំណត់អត្តសញ្ញាណរូបភាពនេះ ថាជាការបោកបញ្ឆោតមានប្រយោជន៍សម្រាប់ការបោះពុម្ពផ្សាយ និងអ្នកប្រើប្រាស់ព័ត៌មាន។ តើមានផលវិបាកអ្វីខ្លះ សម្រាប់ការផ្សព្វផ្សាយព័ត៌មាន ដែលមិនបានផ្ទៀងផ្ទាត់? តើអ្នកគិតថា មានក្រមសីលធម៌សម្រាប់មនុស្សក្នុងការផ្សព្វផ្សាយព័ត៌មានដែលមិនបានផ្ទៀងផ្ទាត់ឬទេ?

## ធនធាន

វីដេអូដោយ PBS NewsHour ៖ តើព័ត៌មានក្លែងក្លាយមានឥទ្ធិពលលើលទ្ធផលនៃការបោះឆ្នោតឆ្នាំ២០១៦ ដែរឬទេ? https://www.pbs.org/newshour/classroom/daily-videos/2016/11/why-is-it-important-for-news-sources-to-be-trustworthy

វីដេអូដោយ First Draft ៖ ព័ត៌មានក្លែងក្លាយដែលមានភាពស្មុគស្មាញ
https://firstdraftnews.org/articles/fake-news-complicated/

វីដេអូដោយ BBC Newsnight៖ ការកើនឡើងនៃ 'ព័ត៌មានក្លែងក្លាយ' ឧបាយកល និង 'ការបន្លំការពិត'
https://www.youtube.com/watch?v=1aTApGWVGoI

អត្ថបទដោយ The Reporters' Lab: ចំនួនក្រុមអ្នកត្រួតពិនិត្យការពិតជុំវិញពិភពលោក
https://reporterslab.org/the-number-of-fact-checkers-around-the-world-156-and-growing/

គេហទំព័រពិនិត្យការពិត

https://www.snopes.com/

https://www.factcheck.org/

https://www.npr.org/sections/politics-fact-check

សទ្ទានុក្រមដោយយុវជន និងប្រព័ន្ធផ្សព្វផ្សាយ/សេចក្តីព្រាងដំបូង៖ បញ្ជីផ្ទៀងផ្ទាត់ព័ត៌មាន
https://docs.google.com/document/d/1VPGGLrf2a7YMAGr-OwF0DQnA9XxAXvKB4IranXCSNHc/edit

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៤៖ ជំហានផ្ទៀងផ្ទាត់

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើអ្នកអាចពិនិត្យមើលដឹងថា តើមាតិកាអនឡាញពិត ឬមិនពិត?
- តើការផ្ដោតអារម្មណ៍របស់បុគ្គលម្នាក់ (ដែលបង្កើតខ្លឹមសារ ឬចែករំលែកវាឡើងវិញ) អាចដើរតួនាទីយ៉ាងដូចម្ដេចក្នុងការផ្ទៀងផ្ទាត់ខ្លឹមសារអនឡាញ?

**វត្ថុបំណងមេរៀន**

- សិស្សរៀនអំពីបញ្ជីត្រួតពិនិត្យប្រាំជំហានដែលពួកគេអាចប្រើដើម្បីផ្ទៀងផ្ទាត់ភស្តុតាង ប្រភព កាលបរិច្ឆេទ ទីតាំង និងការផ្ដោតអារម្មណ៍លើរូបភាព ឬវីដេអូក្នុងព័ត៌មាន។ ពួកគេនឹងទទួលស្គាល់ដែនកំណត់ដែលមាននៅក្នុងដំណើរការផ្ទៀងផ្ទាត់ ហើយចាប់ផ្ដើមពិចារណាលើឧបករណ៍អនឡាញ និងអហ្វឡាញផ្សេងៗ ដែលពួកគេអាចប្រើដើម្បីស៊ើបអង្កេតភាពត្រឹមត្រូវនៃព័ត៌មាននៅលើអនឡាញ។
- សិស្សឆ្លុះបញ្ចាំងពីរបៀបដែលការផ្ដោតអារម្មណ៍ទៅលើប្រភពតែមួយ អាចប៉ះពាល់ដល់ការបង្ហាញនៃព្រឹត្តិការណ៍ព័ត៌មាន។

**សម្ភារៈ ធនធាន និងការរៀបចំ**

- សន្លឹកកិច្ចការ "បញ្ជីផ្ទៀងផ្ទាត់"
- "បញ្ជីត្រួតពិនិត្យការផ្ទៀងផ្ទាត់" ឯកសារគ្រូ
- ម៉ាស៊ីនបញ្ចាំងស្លាយ
- រូបភាព Selfie
- រូបភាព "Selfie Kid"
- ការចូលប្រើអ៊ីនធឺណិត
- ធនធានគ្រូបង្រៀនបន្ថែមទៀតដែលមានក្នុងបញ្ជី
- សិស្សត្រូវការប្រើអ៊ីនធឺណិតសម្រាប់មេរៀននេះ។

**ជំហានផ្ទៀងផ្ទាត់**

និយាយ

**ប្រាប់សិស្សរបស់អ្នក**

ការផ្ទៀងផ្ទាត់ គឺជាដំណើរការមួយដែលត្រូវបានបង្កើតឡើងយ៉ាងល្អនៅក្នុងឧស្សាហកម្មសារព័ត៌មាន។ ជាការពិតអង្គភាពដូចជា First Draft បង្កើតធនធានដែលជួយអ្នកសារព័ត៌មានពិនិត្យការពិត និងប្រយុទ្ធប្រឆាំងនឹងព័ត៌មានខុសកាន់តែមានប្រសិទ្ធភាព។ បទពិសោធន៍សិក្សានៅក្នុងមេរៀនផ្ទៀងផ្ទាត់គឺផ្អែកលើខ្លឹមសារដែលមានប្រភពដើមពី First Draft ។

ថ្ងៃនេះអ្នកនឹងរៀនពីរបៀបផ្ទៀងផ្ទាត់ព័ត៌មានតាមអ៊ីនធឺណិត តាមរយៈដំណើរការមួយជំហានម្តងៗ ដែលអ្នក សារព័ត៌មានអាជីពប្រើប្រាស់ក្នុងការងាររបស់ពួកគេ។ នៅពេលផ្ទៀងផ្ទាត់រូបភាព ឬវីដេអូតាមអនឡាញជាដំបូងត្រូវចាប់ផ្តើមដោយប្រាកដថា ព្រឹត្តិការណ៍ព័ត៌មាននោះពិតជាបានកើតឡើងមែន។ ប្រសិនបើអ្នកអាចបញ្ជាក់ថាព្រឹត្តិការណ៍ព័ត៌មានពិតជាបានកើតឡើងមែននោះ អ្នកអាចធ្វើតាមបញ្ជីផ្ទៀងផ្ទាត់ ដើម្បីផ្ទៀងផ្ទាត់រូបភាព ឬវីដេអូជាក់លាក់របស់អ្នក។

និយាយ

## ប្រាប់សិស្សរបស់អ្នក

បញ្ជីផ្ទៀងផ្ទាត់

- ភស្តុតាង៖ តើអ្នកកំពុងមើលខ្លឹមសារដើមឬទេ ?
- ប្រភព៖ តើនរណាជាអ្នកបង្កើតខ្លឹមសារ ?
- កាលបរិច្ឆេទ៖ តើខ្លឹមសារត្រូវបានដកស្រង់នៅពេលណា ?
- ទីតាំង៖ តើបំណែកនៃខ្លឹមសារត្រូវបានដកស្រង់នៅឯណា ?
- ការផ្តោតអារម្មណ៍៖ ហេតុអ្វីបានជាខ្លឹមសារត្រូវបានដកស្រង់ ?

និយាយ

## ប្រាប់សិស្សរបស់អ្នក

1. ភស្តុតាង៖ ដំណើរការការត្រួតពិនិត្យនេះជាមុនសិន ដើម្បីកំណត់ថាតើអ្នកកំពុងមើលខ្លឹមសារដើមជាជាងការផ្សាយឡើងវិញ។ ដូចដែលអ្នកនឹងរៀននៅពេល ក្រោយ នៅក្នុងមេរៀននេះ រូបភាពដើម ឬវីដេអូដើមមានព័ត៌មានសំខាន់ៗ ដែលទាក់ទងនឹងដំណើរការផ្ទៀងផ្ទាត់ដែលគ្មានក្នុងច្បាប់ចម្លង ឬរូបភាពបន្ត។
2. ប្រភព៖ ដូចដែលអ្នកបានរៀននៅក្នុងមេរៀនមុន រាល់ខ្លឹមសារព័ត៌មាន មានប្រភពដែលអាចកំណត់បានថាជាបុគ្គល ជាការបោះពុម្ពផ្សាយ ឬភ្នាក់ងារផ្សព្វផ្សាយដែលបានដកស្រង់រូបភាព ឬព័ត៌មានអំពីព្រឹត្តិការណ៍ព័ត៌មានដើម។ នៅពេល កំណត់ប្រភព ត្រូវប្រាកដថា ត្រូវបែងចែករវាងអ្នកដែលបានផ្សព្វផ្សាយខ្លឹមសារដើម និងអ្នកដែលបង្ហោះព័ត៌មានបន្ត។ សព្វថ្ងៃនេះមនុស្សជាច្រើនមានដានជើងឌីជីថលដ៏ធំ និងអ្នកសារព័ត៌មានតែងតែព្យាយាម ភ្ជាប់ទៅកាន់គណនីបណ្តាញសង្គមផ្សេងៗរបស់នរណាម្នាក់ ដើម្បីស្វែងរកព័ត៌មានដូចជា ទំនាក់ទំនង ឬទីតាំងរបស់បុគ្គលនោះអំឡុងពេលព្រឹត្តិការណ៍ព័ត៌មាន។
3. កាលបរិច្ឆេទ៖ ទោះបីជាវាអាចពិបាកក្នុងការកំណត់កាលបរិច្ឆេទដែលរូបភាព ឬវីដេអូត្រូវបានថត និងពេលដែលវាត្រូវបានបង្ហោះ ស្ថាប័នព័ត៌មានមួយចំនួនធ្លាប់ទទួលបាន ការរិះគន់កន្លងមកចំពោះការយល់ច្រឡំកាលបរិច្ឆេទទាំងពីរនេះ។ ជាមួយនឹងការកើនឡើងនៃទូរសព្ទឆ្លាតវៃ មនុស្សអាចបង្ហោះរូបភាពភ្លាមៗបន្ទាប់ពីថត ប៉ុន្តែវាមិនទាំងអស់នោះទេ។
4. ទីតាំង៖ វេទិកាបណ្តាញសង្គមអនុញ្ញាតឱ្យអ្នកបញ្ជាក់ ឬដាក់ទីតាំងជាក់លាក់មួយក្នុងការបង្ហោះ ប៉ុន្តែព័ត៌មាននេះអាចមានការយល់ច្រឡំ។ មធ្យោបាយដ៏ល្អបំផុតដើម្បីផ្ទៀងផ្ទាត់ទីតាំងរបស់សារបង្ហោះ គឺស្វែងរកទីតាំងនៅលើផែនទី ឬផ្កាយរណបដោយខ្លួនឯង។
5. ការផ្តោតអារម្មណ៍៖ ពេលដែលអ្នករៀននៅក្នុងថ្នាក់ប្រវត្តិវិទ្យា អ្នកធ្វើការស្វែងយល់ពីទស្សនៈ និងការផ្តោតអារម្មណ៍លើប្រភព។ តើប្រភពជារូបភាព ឬវីដេអូអាចយកធ្វើជាភស្តុតាង ឬសាក្សីបានដែរឬទេ ? ពីមន្ត្រីធ្វើការឱ្យអង្គការសហប្រជាជាតិ ? ពីសកម្មជន ?
   ចម្លើយរបស់អ្នក អាចជះឥទ្ធិពលដល់របៀបដែលអ្នកយល់អំពីព័ត៌មានច្រើនជាងនេះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### សួរសិស្សរបស់អ្នក

- ហេតុអ្វីបានជាវាសំខាន់ក្នុងការកំណត់សក្តានុពលការផ្តោតអារម្មណ៍លើប្រភពព័ត៌មាន?
- តើរឿងសំខាន់ៗអ្វីខ្លះដែលអ្នកអាចនឹងចោទសួរអំពីការផ្តោតអារម្មណ៍លើប្រភពព័ត៌មាន?

សម្រាប់សិស្សក្មេងៗសូមពិចារណាផ្តល់ឧទាហរណ៍មួយក្នុងចំណោម ឧទាហរណ៍ខាងក្រោម មុនពេលសុំឱ្យពួកគេគិតពីឧទាហរណ៍បន្ថែមទៀត។ អ្នកទទួលព័ត៌មានអាចនឹងចោទសួរអំពី ការផ្តោតអារម្មណ៍របស់អ្នកកាសែតដែលសរសើរនរណាម្នាក់កំពុងឈរឈ្មោះក្នុងតំណែង ហើយក៏ពាក់ព័ន្ធនឹងបុគ្គលនោះដែរ។ ពួកគេក៏អាចអានអត្ថបទអំពីបេក្ខជននយោបាយ ដែលត្រូវបានសរសេរដោយនរណាម្នាក់ដែលបានបរិច្ចាគ ដល់យុទ្ធនាការរបស់បេក្ខជន នាពេលកន្លងមក ហើយបានសម្ភាសន៍តែមនុស្សដែលគាំទ្របេក្ខជនដូចគ្នា។

### ប្រាប់សិស្សរបស់អ្នក

បន្ទាប់ពីអ្នកបានបញ្ចប់ការប្រើប្រាស់បញ្ជីផ្ទៀងផ្ទាត់  អ្នកនឹងយល់កាន់តែច្បាស់ថាតើអ្នកមានទំនុកចិត្តកម្រិតណាក្នុងការបង្ហោះ ឬចែករំលែកខ្លឹមសារនៅលើអនឡាញ។ វាអាចជាករណីដែលអ្នកប្រាកដចិត្ត១០០% នៃ ទីតាំងវីដេអូ ប៉ុន្តែអ្នកមិនប្រាកដ ១០០% ថាអ្នកមានវីដេអូច្បាប់ដើម។ អ្នកប្រហែលជាមានការ ព្រួយបារម្ភថាអ្នកដែលបានបង្ហោះរូបភាព មិនមែនជាអ្នកដែលបានថតវានោះទេ។ ដំណើរការផ្ទៀងផ្ទាត់មិនប្រាកដថានាំអ្នកទៅរកភាពពិតប្រាកដនោះទេ។ ផ្ទុយទៅវិញ វាគឺជាដំណើរការមួយដែលស្វែងរកតម្រុយ និងការតភ្ជាប់នៅពេលដែលអ្នកប្រើឧបករណ៍ជាច្រើន ដើម្បីមានទំនុកចិត្តលើមាតិកានោះ។

### កិច្ចការ

### សកម្មភាពក្នុងថ្នាក់

បញ្ចាំងរូបភាពខាងក្រោមនៅលើអេក្រង់។ ចែកសិស្សជាក្រុម ហើយចែកសន្លឹកកិច្ចការ "បញ្ជីផ្ទៀងផ្ទាត់"។

### កិច្ចការ

ប្រើ "បញ្ជីផ្ទៀងផ្ទាត់" សម្រាប់ជាឯកសារយោង។ ជាមួយក្រុមរបស់អ្នក សូមបំពេញ "បញ្ជីផ្ទៀងផ្ទាត់" ហើយសួរខ្លួនអ្នកពីរបៀបដែលអ្នកអាចរកចម្លើយចំពោះសំណួរនីមួយៗ។ តើឧបករណ៍អនឡាញ ឬអហ្វឡាញអ្វីដែលអាចប្រើដើម្បីជួយអ្នក? តើអ្នកនឹងនិយាយជាមួយនរណា? តើមានតម្រុយអ្វីខ្លះនៅក្នុងរូបថតដែលអាចជួយអ្នកបាន?

### ប្រាប់សិស្សរបស់អ្នក

សូមចែករំលែកការរកឃើញក្រុមរបស់អ្នក។ លើកដៃឡើងប្រសិនបើក្រុមរបស់អ្នកបានរកឃើញច្បាប់ដើមនៃរូបភាព។

### សួរសិស្សរបស់អ្នក

- តើវេបសាយមួយណាដែលអ្នកគិតថាមានច្បាប់ដើម?
- តើអ្នកកំណត់យ៉ាងណាថាតើរូបភាពនេះជាខ្លឹមសារដើម ឬអត់?

## ប្រាប់សិស្សរបស់អ្នក

រូបភាពរបស់ Selfie Kid ខាងក្រោមក៏ត្រូវបានចែករំលែកយ៉ាងទូលំទូលាយនៅលើបណ្ដាញសង្គម និងបណ្ដាញព័ត៌មានផ្សេងៗផងដែរ។

## សកម្មភាពក្នុងថ្នាក់

នៅពេលដែលព្រឹត្តិការណ៍ព័ត៌មានកើតឡើង រូបភាព និងវីដេអូអាចកើនឡើងយ៉ាងងាយស្រួលដោយមនុស្សដូចគ្នាត្រូវបានថតដោយមនុស្សជាច្រើនពីជ្រុងផ្សេងៗគ្នា។ មនុស្សម្នាក់ៗដែលចាប់យក និងចែករំលែកខ្លឹមសារមួយផ្នែកអាចត្រូវបានផ្ដោតអារម្មណ៍ក្នុងការធ្វើដូច្នេះដោយហេតុផលផ្សេងៗ។ ឧទាហរណ៍៖ រូបថតនៃព្រឹត្តិការណ៍ដូចគ្នាអាចត្រូវបានថត ដោយអ្នកកាសែត សកម្មជន អ្នកដែលធ្វើការ នៅក្នុងតំបន់នោះ ឬអ្នកដែលកំពុងធ្វើដំណើរឆ្លងកាត់តំបន់នោះនៅថ្ងៃសម្រាក។ លទ្ធផលនៃរូបភាពនីមួយៗ អាចឆ្លុះបញ្ចាំងពីចំណាប់អារម្មណ៍ និងទស្សនៈផ្សេងៗគ្នា សូម្បីតែភាពលំអៀងក៏អាចកើតមានពីប្រភពរបស់វា។

## សួរសិស្សរបស់អ្នក

- តើអ្នកអាចកំណត់អត្តសញ្ញាណ និងផ្ទៀងផ្ទាត់ប្រភពនៃរូបភាពទីពីរនេះដោយរបៀបណា?
- ប្រៀបធៀបការផ្ដោតអារម្មណ៍លើប្រភពដែលបានថតរូបភាពពីរផ្សេងគ្នានៃ Selfie Kid និង Justin Timberlake។ តើការផ្ដោតអារម្មណ៍ទៅលើប្រភពអាចប៉ះពាល់ដល់របៀបដែលរូបភាព ឬវីដេអូត្រូវបានថត ឬបង្ហាញដែរឬទេ?

**ធនធាន៖**

វីដេអូដោយ https://www.factcheck.org/

https://www.youtube.com/watch?v=AkwWcHekMdo

អត្ថបទដោយ Ashley Hoffman៖ Selfie Kid' Who Stole Justin Timberlake's Halftime Show Was the Super Bowl MVP https://time.com/5133184/selfie-kid-justin-timberlake-super-bowl-halftime-show/

បញ្ជីត្រួតពិនិត្យដោយយុវជន និងប្រព័ន្ធផ្សព្វផ្សាយ/បញ្ជីផ្ទៀងផ្ទាត់
https://docs.google.com/document/d/1xp4-0cpVM_00ufanK2mSPGW-vyFo1ahslZ0QdnMBjY4/edit#heading=h.jtzqtwi9q5at

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

# មេរៀនទី៥៖ គំណៃនៃអត្ថបទប្រព័ន្ធផ្សព្វផ្សាយ

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- ហេតុអ្វី បានជាវាមានសារៈសំខាន់ក្នុងការកំណត់រូបភាពដើមនៅលើអនឡាញ និងរូបភាពថតចម្លង? កំណត់ដោយរបៀបណា?
- ក្រឡេកទៅមើលរូបភាពដើម និងច្បាប់ចម្លងដែលមានជាបន្តបន្ទាប់ តើរឿងអ្វីដែលអាចនឹងកើតឡើងក្នុងរូបភាពទាំងពីរនេះ?

**វត្ថុបំណងមេរៀន**

- សិស្សអាចកំណត់ថាតើអ្វីជាការចម្លង (ច្បាប់ចម្លងពីច្បាប់ដើម)? និងពន្យល់ពីមូលហេតុដែលការរីកសាយនៃអត្ថបទប្រព័ន្ធផ្សព្វផ្សាយប្រភេទនេះអាចធ្វើឱ្យដំណើរការផ្ទៀងផ្ទាត់កាន់តែពិបាកក្នុងអំឡុងពេលព្រឹត្តិការណ៍ព័ត៌មានទាន់ហេតុការណ៍។
- ពួកគេនឹងបង្កើត និងចែករំលែកព័ត៌មានចម្លងផ្ទាល់ខ្លួនរបស់ពួកគេលើអនឡាញ នៅពេលដែលពួកគេឆ្លុះបញ្ចាំងថាពេលណាដែលវាមានសារៈសំខាន់ក្នុងការកំណត់ ប្រភពនៃការចម្លង ឬបរិបទដើមនៃព្រឹត្តិការណ៍ព័ត៌មានមួយ។

**សម្ភារៈ ធនធាន និងការរៀបចំ**

- បោះពុម្ព ឬបញ្ចាំងរូបភាព "Selfie Kid"
- ការចូលប្រើអ៊ីនធឺណិត
- ធនធានគ្រូបន្ថែមដែលបានរាយបញ្ជី
- សិស្សត្រូវការប្រើអ៊ីនធឺណិតសម្រាប់មេរៀននេះ។

**ប្រាប់សិស្សរបស់អ្នក**

ពីមុនអ្នកបានរៀនអំពីបញ្ជីផ្ទៀងផ្ទាត់ប្រាំជំហាន ដែលអ្នកសារព័ត៌មានអាជីពប្រើនៅពេលពួកគេចង់ផ្ទៀងផ្ទាត់រូបភាព ឬវីដេអូ។ (រំលឹកឡើងវិញជាមួយសិស្សនូវធាតុទាំងប្រាំនៅលើបញ្ជីផ្ទៀងផ្ទាត់។)

- ភស្តុតាង៖ តើអ្នកកំពុងមើលខ្លឹមសារដើមទេ?
- ប្រភព៖ តើនរណាជាអ្នកបង្កើតខ្លឹមសារ?
- កាលបរិច្ឆេទ៖ តើខ្លឹមសារត្រូវបានដកស្រង់នៅពេលណា?
- ទីតាំង៖ តើបំណែកនៃខ្លឹមសារត្រូវបានដកស្រង់នៅឯណា?
- ការផ្តោតអារម្មណ៍៖ ហេតុអ្វីបានជាខ្លឹមសារត្រូវបានដកស្រង់?

ថ្ងៃនេះយើងនឹងនិយាយអំពីជាតុពីរ ដំបូងនៅក្នុងបញ្ជីផ្ទៀងផ្ទាត់ ភស្តុតាង និងប្រភព។ នៅក្នុងទិដ្ឋភាពប្រព័ន្ធផ្សព្វផ្សាយបច្ចុប្បន្ន មនុស្សកំពុងបង្កើតចែករំលែក និងសម្របខ្លួនតាមមាតិកាផ្សព្វផ្សាយឥតឈប់ឈរ ជាពិសេសនៅលើវេទិកាបណ្ដាញសង្គម។ អ្នកសារព័ត៌មាន និងអ្នកប្រើប្រាស់ព័ត៌មានអាចប្រើប្រាស់ឧបករណ៍ជាច្រើន ដើម្បីផ្ទៀងផ្ទាត់រូបភាព ឬវីដេអូ និងកំណត់ថាតើវាត្រូវបានគេប្រើក្នុងបរិបទត្រឹមត្រូវ ឬមិនត្រឹមត្រូវ។ នោះហើយជាមូលហេតុដែលយើង ចាត់ទុកការផ្ទៀងផ្ទាត់ជាដំណើរការមួយ ពីព្រោះការផ្ទៀងផ្ទាត់ខ្លឹមសារពាក់ព័ន្ធនឹងជំហានជាច្រើន ហើយពេលខ្លះវាអាចចំណាយពេលយូរដើម្បីបញ្ចប់។ បញ្ហាប្រឈមមួយដែលមនុស្សប្រឈមនឹងការផ្ទៀងផ្ទាត់ខ្លឹមសារគឺ រូបថត និងវីដេអូ ចរាចរពីវេទិកាមួយទៅវេទិកាមួយ ហើយអាចត្រូវបានកែប្រែ ចម្លង និងដកស្រង់ចេញក្រៅយ៉ាងងាយស្រួល។

## សួរសិស្សរបស់អ្នក

- តើប្អូនធ្លាប់ចម្លងរូបភាព ឬវីដេអូពីវេទិកាណាមួយ ហើយចែករំលែកវានៅលើវេទិកាមួយផ្សេងទៀតទេ?
- តើប្អូនធ្លាប់យកអ្វីដែលមិត្តភ័ក្ដិបានចែករំលែកជាមួយ ហើយយកទៅបង្ហោះនៅលើវេទិកាផ្សេងដែរឬទេ?
- តើប្អូនធ្លាប់លុបអ្វីមួយ ហើយបង្ហោះវាឡើងវិញនៅពេលក្រោយទេ?

## ប្រាប់សិស្សរបស់អ្នក

ច្បាប់ចម្លង គឺជាបំណែកនៃមាតិកាដែលត្រូវបានចម្លងពីប្រភពដើមមួយ ហើយជួនកាលផ្លាស់ទីពីវេទិកាមួយ ទៅវេទិកាមួយទៀត។ ការចម្លង សំដៅទៅលើផ្នែកមួយនៃមាតិកាដែលត្រូវបានចម្លង ដោយអ្នកប្រើប្រាស់ដើម្បីបង្កើតកំណែថ្មីនៃមាតិកា។ (ការចម្លងត្រូវបានគេហៅថា ច្បាប់ចម្លង ឬកំណែនៃអត្ថបទប្រព័ន្ធផ្សព្វផ្សាយផងដែរ។ ប្រសិនបើអ្នក ឬសិស្សរបស់អ្នកចង់ស្វែងរកធនធានបន្ថែមអំពីការចម្លងតាមអនឡាញ អ្នកក៏អាចប្រើពាក្យផ្សេងទៀតទាំងនេះដែរ។ "Version" ដើម្បីឆ្លុះបញ្ចាំងពីចំនួនដង និងលក្ខខណ្ឌផ្សេងៗទៀត។)

ស្រមៃថាអ្នកកំពុងចែករំលែករូបថតដែលអ្នកបានថតនៅលើវេទិកាផ្ញើសារឯកជនដូចជា Telegram ឬ Messenger ហើយបន្ទាប់មកមិត្តម្នាក់របស់អ្នកថតអេក្រង់ហើយបង្ហោះវានៅលើវេទិកា "សាធារណៈ" បន្ថែមទៀតដូចជា Facebook។ ឧបមាថាអ្នកកាសែតម្នាក់បានរកឃើញរូបភាពនោះ ហើយចង់ដឹងថានរណាជាអ្នកថតរូបនោះ?

ជម្រើស៖ ឱ្យសិស្ស ពិភាក្សាសំណួរទាំងនេះជាដៃគូ។

## សួរសិស្សរបស់អ្នក

- តើអ្នកកាសែតអាចដឹងថាអ្នកជាអ្នកបង្កើតមាតិកាដើមដោយរបៀបណា?
- ចុះបើការបង្ហោះរបស់មិត្តភ័ក្ដិរបស់អ្នកក្លាយជាការពេញនិយម ហើយមនុស្ស ៥០នាក់ ផ្សេងទៀតបានចែករំលែកវា? តើអ្នកកាសែតអាចដឹងថានរណាជាម្ចាស់ដើម? (អ្នកកាសែតអាចទាក់ទងមិត្តភ័ក្ដិរបស់អ្នក ហើយសួរថាតើគាត់ថតរូបឬអត់។ ប្រសិនបើអ្នកកាសែតបានរកឃើញបំណែកជាច្រើន (Version) នៃរូបភាព គាត់អាចមើលកាលបរិច្ឆេទដែលការថតចម្លងនីមួយៗត្រូវបានបង្ហោះ ហើយព្យាយាមទាក់ទង អ្នកដែល បានដាក់ប្រកាសមុនគេ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## ប្រាប់សិស្សរបស់អ្នក

ការចម្លង (Version) អាចក្លាយជាបញ្ហាក្នុងអំឡុងពេល ព្រឹត្តិការណ៍ព័ត៌មានទាន់ហេតុការណ៍ ពីព្រោះព័ត៌មានអាចរីករាលដាលយ៉ាងឆាប់រហ័ស ហើយវាអាចពិបាកក្នុងការស្វែងយល់ថានរណាជាអ្នកបង្កើតខ្លឹមសារដំបូង និងកាលបរិច្ឆេទដែលវាត្រូវបានបង្កើត។ នៅលើវេសាយដូចជា YouTube មនុស្សមួយចំនួននឹងទាញយកវីដេអូដើមនៃព្រឹត្តិការណ៍ព័ត៌មានមួយ ហើយបង្ហោះវាឡើងវិញយ៉ាងឆាប់រហ័សដោយប្រើឈ្មោះអ្នកប្រើប្រាស់ផ្សេង ដោយសង្ឃឹមថាអាចរកលុយបាន (First Draft)។ "ពេលខ្លះអ្នកអាចឃើញ វីដេអូដូចគ្នារាប់រយ (Version) ក្នុងរយៈពេលប៉ុន្មានម៉ោងបន្ទាប់ពីព្រឹត្តិការណ៍ព័ត៌មានទាន់ហេតុការណ៍" (First Draft)។

## ប្រាប់សិស្សរបស់អ្នក

នៅពេល អ្នករកឃើញមាតិកាដំបូង អ្នកមិនអាចសន្មតថាអ្នកកំពុងមើលមាតិកាដើមនោះទេ។ រកមើលតម្រុយដូចខាងក្រោម ដែលអាចប្រាប់អ្នកថាតើរូបភាព ឬវីដេអូគឺជាមាតិកាដើម៖

- ការចម្លង (Version) ជាទូទៅមានគុណភាពរូបភាព ឬវីដេអូទាបជាងបើប្រៀបធៀបទៅនឹងមាតិកាដើម។ ពួកវាក៏អាចមានទំហំឯកសារតូចជាង ឬទំហំមិនស្តង់ដា (ដែលបង្ហាញថាខ្លឹមសារអាចត្រូវបានរៀបចំ ឬផ្លាស់ប្តូរពីរបស់ដើម)។
- មើលគណនីរបស់អ្នកដែលកំពុងចែករំលែករូបភាព ឬវីដេអូ។ តើពួកគេចែករំលែកការចម្លងរបស់ព័ត៌មានទាន់ហេតុការណ៍ផ្សេងទៀត (Version) ដែរឬទេ? នោះប្រហែលជាមានន័យថាពួកគេមិនមែនជាអ្នកបង្កើតខ្លឹមសារដើមនោះទេ។
- តើរូបភាព ឬវីដេអូបានមកពីវេបសាយរបស់ស្ថាប័នទេ? អង្គការ "ពេលខ្លះអាចចែករំលែកខ្លឹមសារឡើងវិញពីសាក្សីដែលបានឃើញផ្ទាល់" (First Draft)។
- ជាចុងក្រោយ ពិនិត្យទៅលើអារម្មណ៍ជឿជាក់របស់អ្នក។ តើមនុស្សម្នាក់នេះនៅក្នុងព្រឹត្តិការណ៍នេះ ហើយកំពុងចែករំលែកវីដេអូដើម?

## ប្រាប់សិស្សរបស់អ្នក

ចូលទៅកាន់អ៊ីនធឺណិត ហើយស្វែងរករូបភាពពីព្រឹត្តិការណ៍ព័ត៌មានថ្មីៗ ដែលអ្នកចាប់អារម្មណ៍។ កំណត់ប្រភព នៃរូបភាព។ ធ្វើការបង្កើតរូបភាពក្លែងក្លាយ ហើយចែករំលែកវានៅលើគណនីបណ្តាញសង្គមរបស់អ្នក។ នៅពេលបង្ហោះរូបភាព អ្នកអាចជ្រើសរើសកែរូបភាពតាមមធ្យោបាយណាមួយ (ឧទាហរណ៍៖ កែសម្រួល ច្រឹប បន្ថែមអត្ថបទ) មុនពេលអ្នកចែករំលែកវា។ នៅពេលបង្ហោះរូបភាព ត្រូវប្រាកដថាអ្នកស្គាល់ច្បាស់ពីប្រភពដើមរបស់វា។

## កិច្ចការ

បន្ទាប់មកសរសេរកថាខណ្ឌខ្លីមួយឆ្លើយនឹងសំណួរខាងក្រោម៖

- តើរូបភាពមួយណាដែលអ្នកសម្រេចចិត្តយកមកចែករំលែក? ហេតុអ្វី?
- តើអ្នកបានចែករំលែករូបភាពនៅទីណា និងជាមួយនរណា?
- តើអ្នកបានកែសម្រួលរូបភាព (ឧទាហរណ៍៖ កែសម្រួល ច្រឹប បន្ថែមអត្ថបទ) តាមមធ្យោបាយណាមួយមុនពេល ចែករំលែកវាទេ? តើអ្វី ដែលជម្រុញទឹកចិត្តរបស់អ្នកនៅពីក្រោយការកែ ឬមិនកែរូបភាព?

- តើអ្នកគិតថា ប្រសិនបើអ្នកមិនបានកំណត់ប្រភពដើម តើការបង្ហោះរបស់អ្នកនឹងមានប្រតិកម្មអ្វីដែរឬទេ? ហេតុអ្វី?

### ប្រាប់សិស្សរបស់អ្នក

ក្រឡេកទៅរកមនុស្សដែលនៅក្បែរអ្នក។ ចែករំលែករូបភាពដែលអ្នកបានបង្ហោះហើយពន្យល់យ៉ាងខ្លីអំពីមូលហេតុដែលអ្នកជ្រើសរើសរូបភាពនេះ។

### សួរសិស្សរបស់អ្នក

- តើមានហេតុផលអ្វីខ្លះដែលមនុស្សអាចចែករំលែកខ្លឹមសារនៅលើអ៊ីនធឺណិតឡើងវិញ?
- គិតពីព័ត៌មានចម្លងដ៏ល្បីផ្សេងទៀត ដែលអ្នកបានឃើញមនុស្សចែករំលែកលើអនឡាញ។ តើមានករណីណាខ្លះដែលការកំណត់ពីប្រភពដើម មានប្រសិទ្ធភាពជាង?

## ការពិភាក្សា

### សកម្មភាពក្នុងថ្នាក់

នៅក្នុងបរិយាកាសព័ត៌មាននាពេលបច្ចុប្បន្ននេះ រូបភាព ឬវីដេអូណាមួយអាចត្រូវបានផ្សព្វផ្សាយផ្លាស់ប្តូរ ឬចែករំលែកដោយនរណាម្នាក់ដែលមានសិទ្ធិចូលប្រើអ៊ីនធឺណិត និងកុំព្យូទ័រ ឬឧបករណ៍ចល័ត។ ក្នុងករណីខ្លះ ខ្លឹមសារដែលចោទសួរអាចត្រូវបានគេមើលឃើញដោយមនុស្សរាប់មិនអស់ ហើយបានផ្លាស់ប្តូរម្តងហើយម្តង ទៀតតាមរបៀបដែលរូបភាពដើមស្ទើរតែមិនអាចសម្គាល់បាន។ ឧទាហរណ៍ពិសេសមួយនៃបាតុភូតនេះអាចត្រូវបានគេមើលឃើញនៅពេល ដែល ច្បាប់ចម្លង (Version) ក្លាយជា Memes ពេញនិយម។

### សកម្មភាពក្នុងថ្នាក់

ពិចារណារូបភាព "Selfie Kid" Ryan McKenna ។

### ប្រាប់សិស្សរបស់អ្នក

រូបភាពនៃ Selfie Kid បានត្រូវបានផ្ទុះបន្ទាប់ពីគាត់បានថតរូបនេះជាមួយ Justin Timberlake ក្នុងអំឡុងពេលកម្មវិធី Super Bowl's Halftime Showឆ្នាំ ២០១៨។ ការចម្លងនៃរូបថតដើមរបស់ Selfie Kid ជាមួយ Justin Timberlake រូបថត Selfie Kid ថតដោយអ្នកដទៃ និងរូបថតអេក្រង់នៃរូបភាពនេះត្រូវបានចែកចាយបន្តតាមអនឡាញយ៉ាងឆាប់រហ័ស ពេលខ្លះមិនអាចកំណត់ ថាតើនរណាជា Selfie Kid ឬនៅពេលណា កន្លែងដែលរូបភាពត្រូវបានថត?

### ប្រាប់សិស្សរបស់អ្នក

ការចម្លងទាំងនេះ (Version) ត្រូវបានប្រែក្លាយទៅជា រូបភាពត្លុក ដ៏ពេញនិយម ដែលត្រូវបានបង្ហាញនៅក្នុងការបោះពុម្ពផ្សាយធំៗ។ ទោះជាយ៉ាងណាក៏ដោយ រូបភាពត្លុក ទាំងនេះច្រើនតែទាមទារចំណេះដឹងខ្លះៗអំពីបរិបទដើមរបស់ Selfie Kid។ ជាលទ្ធផល អ្នកដែលឃើញរូប Selfie Kid រូបភាពត្លុក ក្នុងភាពដាច់ដោយឡែក ប្រហែលជាមិនយល់ច្បាស់ទេ ប្រសិនបើពួកគេមិនដឹងថានរណាជា Selfie Kid គាត់នៅទីណា និងអ្នកណាកំពុងសម្តែងនៅក្នុងកម្មវិធីនោះ។

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

### សួរសិស្សរបស់អ្នក

- ចូរគិតពីការចម្លងល្បីៗមួយចំនួនដែលបានក្លាយជា រូបភាពត្លុក។ តើអ្នកចូលចិត្តទេ?
- តើអ្នកស្គាល់ប្រភព និងបរិបទដើមនៃ រូបភាពត្លុក នេះទេ?

### ប្រាប់សិស្សរបស់អ្នក

ព័ត៌មានដែលមើលឃើញ សូម្បីតែអត្ថបទវែងត្រូវបានរចនាឡើងដើម្បីទាក់ទាញចំណាប់អារម្មណ៍របស់មនុស្សនៅលើបណ្តាញសង្គម។ ក្នុងនាមជាអ្នកប្រើប្រាស់ព័ត៌មានដែលមានទំនួលខុសត្រូវអ្នកអាច សម្រេចចិត្ត តើអ្នកចង់ចូលរួមជាមួយចែករំលែក ឬកែសម្រួលខ្លឹមសារដែលអ្នកឃើញមិត្តភ័ក្តិ ក្រុមគ្រួសារ និងមនុស្សផ្សេងទៀតរបស់អ្នកបង្ហោះលើអនឡាញកម្រិតណា?

### សួរសិស្សរបស់អ្នក

ដោយផ្អែកលើអ្វីដែលអ្នកបានរៀនអំពី ការចម្លង (Version) តើអ្នកនឹងឆ្លើយតបយ៉ាងណាចំពោះ ការចម្លង និងរូបភាពត្លុក ដែលអ្នកឃើញនាពេលអនាគត?

### ធនធាន


វីដេអូដោយ (First Draft)៖ បញ្ហាប្រឈមនៃការដោះស្រាយជាមួយការចម្លង
https://www.youtube.com/watch?v=KoDCwBk90Hc

អត្ថបទដោយ Ashley Hoffman៖ The ‘Selfie Kid’ Who Stole Justin Timberlake’s Halftime Show Was the Super Bowl MVP https://time.com/5133184/selfie-kid-justin-timberlake-super-bowl-halftime-show/

អត្ថបទដោយ Alastair Reid (First Draft)៖ Several news outlets duped into publishing old flight turbulence footage https://firstdraftnews.org/articles/several-news-outlets-duped-into-publishing-old-flight-turbulence-footage/

អត្ថបទដោយ Alastair Reid (First Draft)៖ Why eyewitness media is central to the future of the news industry http://firstdraftnews.org/articles/why-eyewitness-media-is-central-to-the-future-of-the-news-industry/

អត្ថបទដោយ Malachy Browne (First Draft)៖ A pocket guide for verifying details of a video https://firstdraftnews.org/a-pocket-guide-on-%20verifying-details-of-a-video

# មេរៀនទី៦៖ ភាពអាចធ្វើបានល្អបំផុតសម្រាប់ខ្លួនឯង

**រយៈពេល ៖** ៦០នាទី

**សំណួរគន្លឹះ**

- តើមានវិធីអ្វីខ្លះដែលអ្នកអាចធ្វើបានល្អបំផុតសម្រាប់ខ្លួនឯង ?
- ហេតុអ្វីបានជា សំខាន់ក្នុងការគិតអំពីរឿងនេះ ?

**វត្ថុបំណងមេរៀន**

សិស្សនឹងស្រមៃ និងសរសេរអំពីជីវិតរបស់ពួកគេនៅអាយុ ៤០ឆ្នាំ។

**សម្ភារៈ ធនធាន និងការរៀបចំ**

- សន្លឹកកិច្ចការ "ភាពល្អបំផុតដែលអាចធ្វើបានដោយខ្លួនឯង"
- ប៊ិក ខ្មៅដៃ ឬហ្វឺត ក្រដាស។

**ការឆ្លុះបញ្ចាំងមុនពេល អនុវត្ត៖**

សូមចំណាយពេល បន្តិចដើម្បីកំណត់តម្លៃសំខាន់ៗចំនួនបី សម្រាប់អ្នកដែលបានវាយបញ្ចីនៅលើសន្លឹកកិច្ចការ។ ហេតុអ្វីបានជាតម្លៃទាំងនេះសំខាន់សម្រាប់អ្នក ? តើពួកគេមានឥទ្ធិពលលើជីវិតប្រចាំថ្ងៃរបស់អ្នក និងផែនការរយៈពេលវែងរបស់អ្នកយ៉ាងដូចម្តេច ?

**ប្រាប់សិស្សរបស់អ្នក**

អ្នកនឹងធ្វើលំហាត់មួយដែលអាចឱ្យអ្នកមានគំនិតច្នៃប្រឌិតដូចដែលអ្នកចង់ក្លាយទៅជាអ្វី៖ អ្នកស្រមៃថាតើជីវិតរបស់អ្នកអាចនឹងទៅជាយ៉ាងណានៅអាយុ ៤០ឆ្នាំ ?

**សកម្មភាពក្នុងថ្នាក់**

ចាប់ផ្តើមដោយហៅសិស្សមកឱ្យពួកគេបិទភ្នែក ឬមើលទៅលើឥដ្ឋនៅពីមុខពួកគេហើយដកដង្ហើមចូលវែងៗ។

**សួរសិស្សរបស់អ្នក**

ចំណាយពេលមួយភ្លែតដើម្បីស្រមៃមើលជីវិតរបស់អ្នកនៅអាយុ៤០ឆ្នាំ។ អ្វីៗអាចនឹងកើតឡើងដូចដែលអ្នកមានក្តីសង្ឃឹម។ ស្រមៃចម្លើយរបស់អ្នកដោយស្ងៀមស្ងាត់សម្រាប់សំណួរបន្ទាប់។

- តើអ្នកនឹងធ្វើអ្វី ?
- តើអ្នកនឹងក្លាយទៅអ្វី ?
- តើអ្វីដែលសំខាន់បំផុតសម្រាប់អ្នក ?

youtube.com/moeyscambodia sala.moeys.gov.kh t.me/moeysnews

## សកម្មភាពក្នុងថ្នាក់

ផ្តល់ឱ្យសិស្សនូវសន្លឹកកិច្ចការ "Best Possible Self" ហើយឱ្យពួកគេបំពេញវាដោយខ្លួនឯង។ នៅពេលសិស្សបានបញ្ចប់ សូមផ្តល់ឱកាសឱ្យសិស្សចែករំលែកទាំងការសរសេរ និងគំនិតរបស់ពួកគេអំពីដំណើរការនេះជាមួយ គ្នាទៅវិញទៅមក ឬជាមួយថ្នាក់ទាំងមូល ប្រសិនបើពួកគេគិតថាធ្វើបានល្អ។

### សួរសិស្សរបស់អ្នក

សូមឱ្យសិស្សសញ្ជឹងគិតថាតើលំហាត់នេះបានបញ្ជាក់ពីគោលបំណងរបស់ពួកគេ ឬប្រសិនបើពួកគេមិនប្រាកដ ពីគោលបំណង តើវាបានផ្តល់តម្រុយ ឬការយល់ដឹងអំពីគោលបំណងរបស់ពួកគេឬទេ?

**កិច្ចការ** ៖ (ក្នុងថ្នាក់ ឬកិច្ចការផ្ទះ) ការឆ្លុះបញ្ចាំងបន្ទាប់ពីការអនុវត្ត

តើសិស្សឆ្លើយតបនឹងការអនុវត្តនេះដោយរបៀបណា?

តើពួកគេយល់ឃើញថាវាមានប្រយោជន៍ក្នុងការសម្រេចចិត្តថា តើគោលបំណងរបស់ពួកគេជាអ្វី?

## សន្លឹកកិច្ចការ

ឯកសារភ្ជាប់មកជាមួយមេរៀននេះគឺជាធនធាន សម្រាប់សិស្ស និងគ្រូហើយមានកន្លែងសម្រាប់សរសេរចម្លើយ។ ក្នុងករណីខ្លះ ការឆ្លើយតបរបស់គ្រូត្រូវបានផ្តល់ជូន នៅពេលដែលវាមិនមែនជាសកម្មភាពរបស់ប្រធានបទ។ មេរៀនត្រូវបានបែងចែកជាផ្នែកដោយផ្អែកលើសកម្មភាពក្រុម ឬការពិភាក្សា។

## ប្រភពឯកសារ៖

The Purpose Challenge Toolkit was created by Dr. Kendall Cotton-Bronk in partnership with the Greater Good Science Center and Prosocial.

www.kendallcottonbronk.com

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់

www.purposechallenge.org

https://ggie.berkeley.edu/practice/best-possible-self/